ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ កម្មវិធីអប់រំជាសាធារណៈនិងនៅតាមមូលដ្ឋាន

◆ ភាពតក់ស្លុត និង ការប៉ះទង្គិចផ្លូវចិត្តនៅក្នុងអំពើប្រល័យពូជសាសន៍នៅកម្ពុជា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៩០ ខែមិថុនា ឆ្នាំ២០០៧

ស្វែងរកការពិត
លេខ៩០ ខែមិថុនា ឆ្នាំ២០០៧

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ សំបុត្រ ៖ កម្មវិធីអប់រំជាសាធារណៈនិងនៅតាមមូលដ្ឋាន ....................១

### ផ្នែកឯកសារ

◆ អ្នកទោសម្នាក់រួចផុតពីការសម្លាប់នៅវត្តចំពុះក្អែក ..............................៤

### ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ

◆ គុកខ្មែរក្រហម......................................................................១១
◆ យុទ្ធជនភូមិភាគឧត្តរ ...............................................................១៦
◆ ភាពភ័យរន្ធត់បន្សល់ទុកពីរបបខ្មែរក្រហម .......................................១៨
◆ ជីវិតបដិវត្តន៍របស់គ្រួសារព្នង....................................................១៩
◆ ការជួយជនរងគ្រោះស្វែងយល់ពីដំណើរយុត្តិធម៌ .............................២២
◆ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ...............២៦
◆ តើប្រជាជនចូលរួមដំណើរទស្សនកិច្ចមានចំណាប់អារម្មណ៍ដូចម្តេច .........៣២

### ផ្នែកច្បាប់

◆ ការផ្តល់យុត្តិធម៌ចំពោះឧក្រិដ្ឋកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ......៤០

### វេទិកាពិភាក្សាសាធារណៈ

◆ សេចក្តីថ្លែងការណ៍របស់លោក រ៉ូភើត ស៊្តីលបេក.............................៤៨
◆ សេចក្តីថ្លែងការណ៍រួមដោយចៅក្រមជាតិ និងអន្តរជាតិ ......................៥០
◆ ភាពតក់ស្លុត និងការប៉ះទង្គិចផ្លូវចិត្ត.............................................៥១

### ទំព័រស្រាវជ្រាវរកគ្រួសារ

◆ អ៊ីៗដែលខ្ញុំនៅចងចាំពីរបបខ្មែរក្រហម ..........................................៥៧



រូបសំណាកអ្នកតាដំបងដែក នៅក្នុងបរិវេណ
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា




ហាគិម-ទួន ទស្សនាអគារអង្គជំនុំជម្រះវិសាមញ្ញ

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ ៖** ផេង ពង្សរ៉ាស៊ី, គង់ សុកគឿន, លី សុខឃាង និង កែវ ដាស៊ីល, ឌី ខាំបូលី, ហេឡែន អ៊ុយណាក និង ស៊ីវ លាង, អេឡិចសេនជី ហ៊ីនតុន និង នូ ប៊ុនធី **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត លក្ខិណា និង សោម ប៊ុនថន **អ្នកបកប្រែ ៖** ប៉ាន់ ស៊ីម៉ាឡា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** លី សុផល **ក្រាហ្វិកកុំព្យូទ័រ ៖** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ ៖** រ័ត្ន តារាពិដោរ **Email: dccam@online.com.kh, Homepage: www.dccam.org**

*សំបុត្រ :*

# កម្មវិធីអប់រំជាសាធារណៈនិងនៅតាមមូលដ្ឋាន

*ដែនទីនៅក្នុងអត្ថបទបង្ហាញពីភូមិស្រុកដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះធ្វើការផ្សព្វផ្សាយអប់រំរៀបចំជិតរួចរាល់ ។ នៅក្នុងដែនទីបង្ហាញពីឈ្មោះភូមិចំនួន១៣៩នៅក្នុងខេត្តកំពង់ស្ពឺ ដែលមជ្ឈមណ្ឌលបានធ្វើការចុះផ្សព្វផ្សាយ ។ បច្ចុប្បន្នសកម្មភាពផ្សព្វផ្សាយអប់រំសម្រេចបានជាង៥ពាន់ភូមិនៃបណ្ដាខេត្តនានាចំនួន២០ និងក្រុង២ទៀតគឺក្រុងភ្នំពេញនិងកំពង់សោមនៃព្រះរាជាណាចក្រកម្ពុជា ។*

### ១) ការផ្សព្វផ្សាយអប់រំមុនពេលមានសវនាការ

### កម្មវិធីឯកសាររស់ៈ

### វគ្គបំពាក់បំប៉នសម្រាប់ការចូលរួមក្នុងកិច្ចការសាលាក្ដី

នៅដំណាក់កាលទីពីរនៃគម្រោងផ្សព្វផ្សាយនេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងអញ្ជើញតំណាងមកពីតាមបណ្ដាស្រុកនានាទូទាំងប្រទេសមកឃ្លាំមើលសវនាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមដែលមានរយៈពេល១សប្ដាហ៍ ។ ពេលដែលអ្នកតំណាងទាំងនេះត្រឡប់ទៅស្រុកភូមិវិញ គាត់អាចនឹងមានការពិភាក្សាថ្នាក់ស្រុកឬភូមិមួយស្ដីពីទិដ្ឋភាពដែលគាត់បានឃើញនិងបានស្ដាប់ឮនៅសវនាការនិងអំពីដំណើរការយុត្តិធម៌ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងថតទុកជាឯកសារនូវសកម្មភាពប្រជុំពិភាក្សានេះព្រមទាំងពន្យល់ពីពាក្យពេចន៍ច្បាប់មួយចំនួនផង ។ បន្ទាប់មកវីដេអូភាពយន្តឯកសារនេះនឹងត្រូវបញ្ចាំងជូននៅតាមភូមិស្រុកផ្សេងទៀតដែលមិនបានបញ្ជូនតំណាងរបស់ខ្លួនមកចូលរួមសវនាការ ។

ប្រជាជនមួយចំនួនធំដែលមកចូលរួមសវនាការនឹងជ្រើសរើសចេញពីសមាសភាពអ្នកមកចូលរួមចំនួន៥ ៦០០នាក់ នៅក្នុងដំណាក់កាលទី១នៃគម្រោងនេះ (ដំណើរទស្សនកិច្ចទៅកាន់សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បូជនីយដ្ឋានវាលពិឃាតជើងឯក និងអគារអង្គជំនុំជម្រះវិសាមញ្ញ) ។ ប្រជាជនដែលមកចូលរួមស្ទើរតែទាំងអស់សុទ្ធសឹងជាជនរងគ្រោះពីរបបកម្ពុជាប្រជាធិបតេយ្យ (ក្នុងនោះក៏មានអតីតខ្មែរក្រហមដែរ) ។ អ្នកចូលរួមមួយចំនួននឹងត្រូវបានជ្រើសរើសឲ្យមកស្ដាប់សវនាការអាស្រ័យលើចំណាប់អារម្មណ៍របស់គាត់ចំពោះសាលាក្ដី កម្រិតនៃការយល់ដឹងនិងកេរ្ដិ៍ឈ្មោះដែលប្រជាជនឯទៀតក្នុងសហគមន៍គោរពគាត់ ។

ភាពស្មុគស្មាញនៃតុលាការដែលកើតចេញពីបន្សំនៃច្បាប់ស៊ីវិលកម្ពុជា (ច្បាប់បារាំង) និងច្បាប់អន្តរជាតិ (ច្បាប់ដែលមិនមានចែងនៅក្នុងស្រុក) ជាបញ្ហាប្រឈមចំពោះមុខមួយសម្រាប់ជនដែលមិនមានមូលដ្ឋានអប់រំផ្នែកច្បាប់ ។ នៅខែកុម្ភៈ ឆ្នាំ២០០៧ មជ្ឈមណ្ឌលឯកសារកម្ពុជាចាប់ផ្ដើមរៀបចំដំណាក់កាលទី២នៃគម្រោងឯកសាររស់ដោយបន្សាំអនាគតអ្នកមកចូលរួមស្ដាប់សវនាការជាមួយនឹងបរិដ្ឋានការងាររបស់សាលាក្ដីនេះ ។ តាមរយៈវគ្គបំពាក់បំប៉នពេញមួយថ្ងៃ ប្រជាជនបានស្វែងយល់ពីទ្រង់ទ្រាយផ្លូវច្បាប់ផ្សេងៗនៃសវនាការច្បាប់កាត់ទោសអតីត



*មេដឹកនាំខ្មែរក្រហម តួនាទីនៃសហព្រះរាជអាជ្ញា តួនាទីចៅក្រម និងចៅក្រមស៊ើបអង្កេត និងសេចក្តីសម្រេចចិត្តដែលនឹងធ្វើឡើងក្នុងកម្រិតខុសៗគ្នានៃអង្គជំនុំជម្រះវិសាមញ្ញ ។*

*នៅថ្ងៃទី១ នៃកម្មវិធីបំពាក់បំប៉នចំនួនពីរថ្ងៃ ប្រជាជនបានទៅទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនិងវាលពិឃាតជើងឯក ។ នៅថ្ងៃបន្ទាប់ ប្រជាជនបានទស្សនាខ្សែភាពយន្តរយៈពេល៣០នាទីដែលមានចំណងជើងថា «នៅគៀនជញ្ជាំងមន្ទីរ ស-២១» ដែលជាការបង្ហាញដ៏ល្អមួយទាក់ទិននឹងបញ្ហាដែលនឹងយកទៅដោះស្រាយនៅក្នុងសវនាការ ដូចជាការរៀបរាប់របស់ជនរងគ្រោះនិងរឿងរ៉ាវនិយាយចេញពីមាត់របស់ជនដៃដល់ ។*

## ព្រឹត្តិការណ៍សំខាន់ៗ ប្រចាំខែមេសា

*ឯកឧត្តម ម៉ោញ សាផាន សមាជិកសភាជាតិដែលបានចូលរួមក្នុងការផ្តល់សច្ចាប័នច្បាប់កាត់ទោសអតីតមេដឹកនាំខ្មែរក្រហម បានជំរុញឲ្យប្រជាជនចូលរួមដំណើរការតុលាការតាមរយៈការផ្តល់ព័ត៌មាននិងការធ្វើជាសាក្សី ។ ឯកឧត្តមបានពិភាក្សានូវការវិវត្តន៍នៃសាលាក្តីនេះ និងស្រាយបំភ្លឺសំណួរជាច្រើនពីសំណាក់ប្រជាជន ។ បន្ទាប់មក លោកស្រី ដាមេឡា រ៉ែស៍ នៃការិយាល័យសហព្រះរាជអាជ្ញាបានធ្វើការណែនាំបង្ហាញពីអង្គភាពចំនួនបីនៃអង្គជំនុំជម្រះវិសាមញ្ញគឺសហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត និងអង្គភាពមេធាវីការពារចុងចោទ ។ ប្រជាជនម្នាក់បានសុំឲ្យលោកស្រីបំភ្លឺថា តើហេតុអ្វីបានជាលោកស្រីមានមុខងារក្នុងសាលាក្តីនេះ ។ លោកស្រីឆ្លើយតបវិញដោយធ្វើការរៀបរាប់ពីប្រវត្តិសាស្ត្រប្រទេសអាល្លឺម៉ង់ ដែលជាប្រទេសកំណើតរបស់លោកស្រី និងអំពីតួនាទីរបស់ប្រទេសនេះចំពោះការសម្លាប់រង្គាល ។ លោកស្រីបានសង្កត់ធ្ងន់ថា យើងត្រូវយល់ដឹងពីប្រទេសកំណើតយើង ហើយស្វែងយល់ពីអំពើប្រល័យពូជសាសន៍នៅប្រទេសឯទៀតក្នុងគោលបំណងការពារសោនាដកម្មដ៏ឃោរឃៅនេះកុំឲ្យកើតមានម្តងទៀត ។ ប្រជាជនដែលសួរសំណួរនេះឆ្លើយតបទៅលោកស្រីវិញថា ៖ «ខ្ញុំធ្លាប់បានអានឯកសារ ហ៊ីត្លែរ ដែរ ហើយខ្ញុំទុកចិត្តលោកស្រី ព្រមទាំងជឿជាក់លើសាលាក្តីនេះ ។» បន្ទាប់មកលោក វ៉ាន់ថាន់ ពៅដារ៉ា នាយករងមជ្ឈមណ្ឌលបានបើកការពិភាក្សាជាមួយប្រជាជនអំពីសិទ្ធិរបស់ជនរងគ្រោះ ។*

## ព្រឹត្តិការណ៍សំខាន់ៗ ប្រចាំខែឧសភា

*ឯកឧត្តម ម៉ោញ សាផាន បានចូលរួមមានប្រសាសន៍នៅក្នុងកម្មវិធីនេះដែរ ។ បន្ទាប់ពីណែនាំព័ត៌មានស្តីអំពីច្បាប់កាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ឯកឧត្តមសង្កត់ធ្ងន់លើចំណុចបីគឺ៖ ទី១ មានតែ «មេដឹកនាំជាន់ខ្ពស់និងជនទទួលខុសត្រូវខ្ពស់បំផុត» នឹងត្រូវកាត់ទោសពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ទី២) អង្គជំនុំជម្រះវិសាមញ្ញចែកចេញជាពីរថ្នាក់គឺសាលាដំបូងនិងសាលាកំពូល និង ៣) រូបមន្ត «មតិភាគច្រើនដាច់ខាត» ចាំបាច់ត្រូវអនុវត្តក្នុងការសម្រេចចិត្តនៅអង្គជំនុំជម្រះវិសាមញ្ញ ។ បន្ទាប់មកទៀត សហព្រះរាជអាជ្ញាពីររូបគឺ លោក យូ ប៊ុនឡេង និងលោក ម៉ាកសែល ឡឺម៉ុងដ៍ ពន្យល់ពីដំណើរការសាលាក្តីដល់ប្រជាជន ។ មានសំណួរជាច្រើនត្រូវបានចោទសួរឡើងដូចជាហេតុអ្វីបានជាចាំបាច់តម្រូវឲ្យមានចៅក្រមបរទេសធ្វើការជាមួយចៅក្រមខ្មែរ? ហេតុអ្វីបានជាមានការអូសបន្លាយពេលយ៉ាងយូរមុននឹងមានសាលាក្តី? ហេតុអ្វីបានជាឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហមកំណត់រយៈកាលត្រឹមពីឆ្នាំ១៩៧៥ដល់១៩៧៩និងតើសំណងប្រភេទណាដែលជនរងគ្រោះអាចទទួលបានបន្ទាប់ពីចប់សវនាការ ។ សហចៅក្រមស៊ើបអង្កេតក៏បានឆ្លើយនូវសំណួរអំពីបញ្ហាការប្រែក្លាយរណ្តៅសាកសពជាកន្លែងតាំងទៅជាវាលស្រែ ចំនួនបុគ្គលដែលជាប់ចោទ និងបញ្ហាលើកលែងទោសផងដែរ ។*

*ប្រជាជនជាច្រើនមានចំណាប់អារម្មណ៍បន្ទាប់ពីវគ្គសំណួរចម្លើយ ។ លោក ឆាយ លើកឡើងដោយក្តីគោរពថា៖ «ខ្ញុំមិនអាចរកពាក្យអ្វីមកពិពណ៌នាអំពើដ៏ឃោរឃៅក្នុងរបបខ្មែរក្រហមឡើយ ។ ច្រើនឆ្នាំមកហើយ ខ្ញុំតែងតែឆ្ងល់ថាតើពេលណាទើបមានសវនាការកាត់ទោសបទឧក្រិដ្ឋនេះ ។ មនុស្សរាប់លាននាក់បានបាត់បង់ជីវិត ចុះហេតុអ្វីបានជាមានការអូសបន្លាយក្នុងការបង្កើតតុលាការកាត់ទោសបទឧក្រិដ្ឋនេះ ?» លោក ឆាយ លើកឡើងថា ទោះបីជាអង្គជំនុំជម្រះវិសាមញ្ញផ្តល់យុត្តិធម៌ក្នុងកម្រិតមួយមិនស័ក្តិសមនឹងអាយុជីវិតប្រពន្ធកូនគាត់ដែលបានបាត់បង់ក្នុងរបបខ្មែរក្រហមក៏ដោយ ក៏គាត់នៅតែគិតថា ការឲ្យមានសវនាការកាត់ទោសជាប្រការល្អ ។ គាត់ថែមទាំងបានបង្ហាញ*

ចំណាប់អារម្មណ៍ចង់ចូលរួមស្តាប់សវនាការផងដែរ ។

បញ្ហាមួយទៀតត្រូវបានលើកឡើងក្នុងវគ្គសំណួរចម្លើយនេះគឺចម្ងល់ថាតើត្រូវគ្រប់គ្រងកំហឹងទុក្ខសោក និងការឈឺចាប់ពីរបបខ្មែរក្រហមដោយរបៀបណា ។ លោក ត្រាង លើកឡើងថា ការតបស្នងដោយការចងពៀរ ជាប្រការមិនត្រឹមត្រូវតាមពុទ្ធសាសនាទេ ។ ការសងសឹកបានត្រឹមតែបន្សល់ទុកនូវការសងសឹកកាន់តែច្រើន ។ ពេលសួរទាក់ទិននឹងវិធីសាស្ត្រដែលជួយសម្រាលការឈឺចាប់ផ្លូវចិត្តនេះ លោក ឌិម យល់ឃើញថា រដ្ឋាភិបាលគួរតែសាងសង់បូជនីយដ្ឋាន ព្រោះទីនោះនឹងជាទីស្នាក់អាស្រ័យនៃវិញ្ញាណក្ខន្ធរបស់ជនរងគ្រោះវិលមកជួបជុំគ្នា និងជាទីកន្លែងសម្រាប់អ្នករស់រានមានជីវិតចងចាំមនុស្សជាទីស្រឡាញ់របស់ខ្លួនដែលបានស្លាប់ទៅ ។ យោងតាមលោក ឌិម ការស្ថាបនាបូជនីយដ្ឋានជាទង្វើមួយបង្ហាញពីការគិតគូររបស់រដ្ឋាភិបាលចំពោះប្រជាពលរដ្ឋដែលបាត់បង់ជីវិត ។

នៅចុងបញ្ចប់នៃកម្មវិធីសំណួរចម្លើយ ប្រជាជនមកចូលរួមទទួលការលើកទឹកចិត្តឲ្យជួយផ្សព្វផ្សាយអំពីអ្វីដែលគាត់បានរៀនសូត្រក្នុងថ្ងៃនេះ និងចែករំលែកព័ត៌មានជាមួយអ្នកភូមិក្នុងសហគមន៍គាត់ ក៏ដូចជាបើកការពិភាក្សាអំពីបញ្ហាទាំងឡាយដូចដែលមានក្នុងសេចក្តីណែនាំអប់រំកន្លងមក ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# សេចក្តីប្រកាសព័ត៌មាន

***ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៧***

## ***ការបើកបញ្ជីមេធាវីរបស់អង្គភាពគាំពារការពារក្តី***

នៅថ្ងៃនេះអង្គភាពគាំពារការពារក្តី (DSS) នៃអង្គជំនុំជម្រះវិសាមញ្ញចាប់ផ្តើមបើកបញ្ជីមេធាវីកម្ពុជានិងមេធាវីបរទេសដែលអាចជ្រើសរើសដោយកូនក្តីដើម្បីការពារក្តីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ។ ជនជាប់ចោទនៅអង្គជំនុំជម្រះវិសាមញ្ញអាចការពារដោយសហមេធាវីមួយរូបនិងសហមេធាវីបរទេសមួយរូប ។ ទាំងសហមេធាវីកម្ពុជានិងសហមេធាវីបរទេសមានបទពិសោធន៍ការងារយ៉ាងតិចដប់(១០)ឆ្នាំ ។ ការបញ្ចូលឈ្មោះទៅក្នុងបញ្ជីមេធាវី ត្រូវប្រតិបត្តិតាមនីតិវិធីដែលបញ្ញត្តិនៅក្នុងវិធានផ្ទៃក្នុងអនុម័តដោយមន្ត្រីតុលាការនាថ្ងៃទី១២ ខែមិថុនា ២០០៧ និងបទបញ្ញារដ្ឋបាលរបស់អង្គភាពគាំពារការពារក្តីអនុម័តនៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៧ ។ កាលពីដើមឆ្នាំនេះ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាសម្រេចឲ្យមេធាវីបរទេសបង់ថ្លៃចុះបញ្ជីចំនួន៥០០ដុល្លារដើម្បីបញ្ចូលឈ្មោះទៅក្នុងបញ្ជីមេធាវី ។ បេក្ខជនអាចដាក់ពាក្យសុំដើម្បីបញ្ចូលឈ្មោះទៅក្នុងបញ្ជីមេធាវីតាមរយៈគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញ www.eccc.gov.kh. លោករ៉ូភឺត ស្កីលបេក ប្រធានអង្គភាពគាំពារការពារក្តីមានប្រសាសន៍ថា «យើងរំពឹងទុកថា នឹងមានមេធាវីនៅជុំវិញពិភពលោកដាក់ពាក្យសុំដើម្បីបញ្ចូលឈ្មោះទៅក្នុងបញ្ជីមេធាវី ។ យើងបានទទួលដំណឹងស្តីពីការចាប់អារម្មណ៍របស់មេធាវីនៅអូស្ត្រាលី កាណាដា បារាំង ហុងកុង ជប៉ុន ម៉ាឡេស៊ី សាំងហ្គាពួ និងនៅចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ។ ខ្ញុំជឿជាក់ថាយើងអាចបង្កើតក្រុមការពារដ៏ខ្លាំងមួយ ដើម្បីធានានូវការកាត់សេចក្តីដ៏យុត្តិធម៌ដល់មនុស្សគ្រប់រូបនៅអង្គជំនុំជម្រះវិសាមញ្ញ» ។

សហមេធាវីទាំងពីរនឹងគាំទ្រដោយក្រុមការពារដែលមានសមាសភាពជាទីប្រឹក្សាពិគ្រោះយោបល់ផ្នែកច្បាប់និងអ្នកគ្រប់គ្រងសំណុំរឿង ។ ស្របពេលជាមួយគ្នានេះអង្គភាពគាំពារការពារក្តីសូមប្រកាសបើកនីតិវិធីជ្រើសរើសតំណែងទាំងនេះ ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងលោក រាជ សម្បត្តិ មន្ត្រីព័ត៌មានផ្នែកទំនាក់ទំនងកិច្ចការសាធារណៈនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តាមរយៈទូរស័ព្ទលេខ ០១២ ៤៨៨ ១៥៦ ។

# អ្នកទោសម្នាក់រួចផុតពីការសម្លាប់នៅខត្តចំពុះក្អែក

របបកម្ពុជាប្រជាធិបតេយ្យបានផុតរលត់ទៅអស់រយៈពេលជិត៣០ឆ្នាំហើយ ក៏ប៉ុន្តែស្លាកស្នាមនិងការឈឺចាប់មិនទាន់រលុបបាត់ពីអារម្មណ៍របស់ជនរងគ្រោះនៅឡើយ ។ ស្លាកស្នាមដែលនៅជិតជាប់នឹង ក របស់ សាបាន គឺជាការចងចាំនិងជាឧទាហរណ៍ជាក់ស្តែងមួយសម្រាប់បង្ហាញឲ្យក្មេងជំនាន់ក្រោយក៏ដូចជាក្មេងនៅក្នុងភូមិរបស់គាត់ជឿជាក់ថានៅក្នុងរបបខ្មែរក្រហមពិតជាមានការធ្វើបាបនិងសម្លាប់រង្គាលជនស្លូតត្រង់ពិតមែន ។ តើស្លាកស្នាមនោះមានអ៊ីពាក់ព័ន្ធនឹងជីវិតរបស់ សាបាន?

សាបាន ជាកូនទី៣ក្នុងចំណោមបងប្អូន៦នាក់ និងជាកូនប្រុសច្បងនៅក្នុងគ្រួសារមួយបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ។ ក្នុងវ័យ៥០ឆ្នាំថ្វាយ សាបាន កំពុងបោះជំហានមួយៗចុះពីលើកាំជណ្តើរជាមួយនឹងទឹកមុខស្រពាប់ស្រពោនបង្ហាញឲ្យឃើញថា គាត់ជាមនុស្សមានកាយសម្បទាមិនមាំមួន ។ ជាការពិត សាបាន ជាអ្នកទោសម្នាក់ដែលបានរួចផុតពីសេចក្តីស្លាប់នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ គឺជាថ្ងៃដែលរបបកម្ពុជាប្រជាធិបតេយ្យឈានទៅរកភាពរលំរលាយ ។


សាបាន អាយុ ៥០ឆ្នាំ

សាបាន កើតនិងធំដឹងក្តីនៅស្រុកកំពង់រោទិ៍ក្នុងខេត្តស្វាយ-រៀង ។ នៅឆ្នាំ១៩៧០ សាបាន ចម្រើនវ័យ១៥ឆ្នាំ ជាវ័យដែលកំពុងស្ថិតនៅក្នុងការសិក្សា ។ កាលណោះ សាបាន ឈប់រៀនត្រឹមថ្នាក់ទី១០ ដោយហេតុថា ភូមិរបស់គាត់ឋិតនៅក្រោមការគ្រប់គ្រងរបស់កងទ័ពរំដោះ (ជាក្រុមអ្នកតស៊ូគាំទ្រសម្តេចសីហនុហើយប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរ) ។

### ស្រុកកំពង់រោទិ៍ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០

បន្ទាប់ពីថ្ងៃរដ្ឋប្រហារ១៨មីនា ឆ្នាំ១៩៧០ ប្រទេសកម្ពុជាឋិតនៅក្រោមការដឹកនាំរបស់សេនាប្រមុខ លន់ នល់ ។ ក៏ប៉ុន្តែខេត្តនិងតំបន់ដាច់ស្រយាលមួយចំនួនត្រូវកាន់កាប់ដោយកងទ័ពរំដោះ ។ នៅក្នុងអំឡុងពេលនោះស្ថានភាពស្រុកទេសចាប់ផ្តើមកើតមានចលាចល ។ នៅក្នុងស្រុកកំពង់រោទិ៍មានភូមិឃុំជាច្រើនដែលនៅជាប់ផ្លូវជាតិត្រូវកាន់កាប់ដោយទាហានលន់នល់ ហើយភូមិមួយចំនួនដែលនៅឆ្ងាយពីផ្លូវជាតិត្រូវបានកាន់កាប់ដោយកងទ័ពរំដោះ ។ ដោយសារមានការប៉ះទង្គិចគ្នាជាញឹកញាប់រវាងទាហានលន់នល់និងកងទ័ពរំដោះដែលច្រើនតែកើតឡើងនៅរដូវប្រាំងបណ្តាលឲ្យប្រជាជនត្រូវរស់នៅក្នុងក្តីភិតភ័យជានិច្ច ។ ប្រជាជនមួយចំនួនបានបង្ខំចិត្តចាកចោលលំនៅដ្ឋានដើម្បីស្វែងរកកន្លែងមានសុវត្ថិភាពដូចជាទៅរស់នៅទីប្រជុំជននិងនៅទីក្រុងជាដើម ។ ពេលមានការប្រយុទ្ធគ្នាប្តូរផ្លោងគ្រាប់ម្តងៗ ប្រជាជនទាំងអស់បាននាំគ្នាភៀសខ្លួនចេញពីភូមិទៅព្រែកខាងកើតចម្ងាយប្រហែល១,៥គីឡូម៉ែត្រដើម្បីគេចចេញពីគ្រោះថ្នាក់នេះ ។ ទោះយ៉ាងណាក៏ពុំសូវមានអ្នកភូមិស្លាប់ច្រើនដែរ ដោយសារថាមុនពេលប្រយុទ្ធគ្នាម្តងៗទាហានលន់នល់បានបាញ់ផ្តក់មួយគ្រាប់ឬពីរគ្រាប់ដើម្បីជាសញ្ញាឲ្យប្រជាជនត្រៀមលក្ខណៈចេញពីភូមិ ប៉ុន្តែផ្ទះសម្បែង ទីវត្តអារាម និងសាលារៀនត្រូវឆេះអស់គ្មានសល់ ។ ទ្រព្យសម្បត្តិនិងផ្ទះសម្បែងរបស់ឪពុកម្តាយ សាបាន ត្រូវបានបំផ្លិចបំផ្លាញទាំងស្រុងនៅពេលនោះដែរ ។ សាបាន បានក្លាយជាកូនកំព្រាម្តាយនៅឆ្នាំ១៩៧០ ។ គាត់និងបងប្អូនរស់នៅជាមួយឪពុកនិងជីដូនជីតា ។ នៅឆ្នាំ១៩៧២ ឪពុក របស់ សាបាន ឈ្មោះ សេក យុន ត្រូវអង្គការតែងតាំងជាប្រធានភូមិ ហើយនៅក្នុងឆ្នាំ១៩៧៣ សាបាន ត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានយុវជនភូមិក្តាប់យុវជនចំនួន២០នាក់ដែលមានឈ្មោះ សោម ធឿន ជាប្រធាន ។ ការងាររបស់យុវជននិងយុវនារីគឺចូលរួមបង្កបង្កើនផលជាក្រុមប្រវាស់ដៃប្រមូលផលទាំងអស់ទៅផ្គត់ផ្គង់កងទ័ពនៅសមភូមិមុខនិងដឹកប្រឡាយនៅភូមិព្រៃស្មៀង ឃុំស្វាយតាយាន ក្នុងស្រុកកំពង់រោទិ៍ ។ បន្ទាប់មកក្រុមការងាររបស់គាត់ត្រូវបានបញ្ជូនឲ្យទៅច្រូតកាត់នៅតាមព្រំដែនវៀតណាមរយៈពេលកន្លះខែ ។ សាបាន ត្រូវបាន

អនុញ្ញាតឲ្យត្រឡប់មកភូមិវិញក្រោយពីប្ដូតកាត់ និងប្រមូលផល មកដាក់ភូមិរួចរាល់ ។

## មិនបានទទួលតំណែងព្រោះមានជាប់ពាក់ព័ន្ធ

ក្រោយពីខ្មែរក្រហម (ដែលមានប្រភពចេញមកពីកងទ័ពរំដោះ) ក្ដាប់អំណាចត្រួតត្រាប្រទេសទាំងស្រុងនៅឆ្នាំ១៩៧៥ ខ្មែរក្រហមចាប់ផ្ដើមបង្វែរទិសដៅពីក្រុមប្រវាស់ដៃមកបង្កើតជាសហករណ៍វិញ ហើយរចនាសម្ព័ន្ធគ្រប់គ្រងនៅក្នុងភូមិក៏ត្រូវបានរៀបចំឡើងវិញដែរ ។ ក្រុមយុវជនរបស់ សាបាន ត្រូវបានរៀបចំជាយុវជនកងចល័តស្រុកកំពង់រោទិ៍ដោយបែងចែកជាពីរ“គ” ក្នុងមួយ“គ”មានបី“ខ” ហើយក្នុងមួយ“ខ”មាន៣២នាក់ ។ ចំពោះយុវជនណាដែលមានប្រវត្តិរូបស្អាតស្អំ ប្រធានសហករណ៍បានចាត់តាំងឲ្យកាន់តំណែងដូចជាប្រធានក្រុម ប្រធានកងជាដើម ដែលអ្នកទាំងនោះមានសិទ្ធិជាងយុវជនដទៃ ក៏ប៉ុន្តែចំពោះអ្នកដែលមានជាប់និន្នាការមិនបានទទួលតំណែងនេះទេ ។ វ៉ែក ប៉ាន់ ប្រធានសហករណ៍ដែលមានសិទ្ធិក្នុងការចម្រាញ់នេះបាននិយាយប្រាប់គាត់ថា “អ្នកជាប់និន្នាការនៅផ្សេង អ្នកមិនជាប់និន្នាការនៅផ្សេង” ។ ក្រោយមក សាបាន ត្រូវអង្គការដកតួនាទីជាប្រធានយុវជនភូមិមកនៅជាសមាជិកកងចល័តវិញ ដោយសារគាត់ត្រូវបានស្រាវជ្រាវរកឃើញថា មានជាប់និន្នាការជាមួយឪពុក ។ ដោយយោងតាមការចាប់ខ្លួនរបស់ឪពុកគាត់ជាច្រើនលើក : លើកទី១) ប្រហែលក្នុងឆ្នាំ១៩៧០ឪពុករបស់គាត់ត្រូវចាប់ខ្លួន ដោយសារមានការក័ន្តប្រឡំថា “លាក់កាំភ្លើងនៅក្នុងផ្ទះ” ។ ទី២) នៅឆ្នាំ១៩៧២ ត្រូវបានចោទប្រកាន់ថាជាខ្មែរ ស (មានទំនាក់ទំនងជាមួយវៀតណាម) ហើយគាត់ត្រូវបានចាប់ខ្លួនបញ្ជូនទៅដាក់នៅសន្តិសុខស្វាយតាយាន ប៉ុន្តែត្រូវបានដោះលែងមកវិញ ដោយសារគាត់មានកូនស្រីជាយុទ្ធនារីនិងជាគ្រូបង្រៀននារីៗនៅក្នុងភូមិ ។ ក្រោយមកខ្មែរក្រហមបានចោទប្រកាន់គាត់ថាជាមនុស្សរបស់ លន់ នល់ ពេលនោះឪពុកគាត់ដឹងខ្លួនមុន ក៏គៀសខ្លួនចេញពីភូមិទៅរស់ជាមួយប្រពន្ធចុងនៅឯទីរួមខេត្តស្វាយរៀង ហើយរហូតដល់ថ្ងៃរំដោះ១៧ មេសា ១៩៧៥ ឪពុករបស់គាត់បានសម្រេចចិត្តវិលមកត្រឡប់ទៅរកកូនវិញទោះបីជាមានការហាមឃាត់ពីប្រពន្ធចុងក៏ដោយ ។ “មកដល់មួយម៉ោងស្លាប់ក៏ដោយឲ្យតែជួបកូន” ។ មកដល់ភូមិសម្រាកនៅផ្ទះបានមួយយប់ ព្រឹកឡើងម៉ោងប្រហែល៨ ប្រធានសហករណ៍បានហៅគាត់ឲ្យទៅកាន់ទីស្នាក់ការវត្ត ហើយឈ្លបក៏បានបណ្ដើរគាត់ចេញពីទីនោះទៅ ។ សាបាន ដឹងច្បាស់ថា ឪពុកគាត់ប្រហែលជាមិនអាចមានជីវិតរស់បានទេ ដោយសារអ្នកដែលបញ្ជាឲ្យចាប់ខ្លួនឪពុកគាត់កាលពីលើកមុនក៏នៅទីនោះដែរ ។ សាបាន បានជួបមុខឪពុកជាលើកចុងក្រោយនៅផ្ទះម្ដាយមីងនៅឃុំស្វាយតាយាន ។ បងស្រីរបស់ សាបាន ខកចិត្តយ៉ាងខ្លាំងក្រោយពីទទួលដំណឹងថាឪពុករបស់គាត់ត្រូវចាប់ខ្លួន ព្រោះថាគាត់ខំធ្វើការតស៊ូដើម្បីបម្រើបដិវត្តន៍និងសង្គមជាតិ ប៉ុន្តែបែរជាត្រូវអង្គការចាប់ឪពុកគាត់ទៅវិញ ។

គោលនយោបាយរបស់ខ្មែរក្រហមគឺលុបបំបាត់របបវណ្ណៈសក្តិភូមិនាយទុន កសាងសង្គមមួយដែលស្អាតស្អំដើម្បីឲ្យប្រជាជនរស់នៅដោយស្មើភាពគ្នា ប៉ុន្តែទោះជាយ៉ាងណាក៏យើងនៅតែមើលឃើញថា របបនេះមិនទាន់មានសមភាពដដែល ដោយសារមានបែងចែកដាច់ស្រឡះរវាងប្រជាជនមូលដ្ឋានគឺ “ប្រជាជនចាស់” និងប្រជាជនជម្លៀសគឺ “ប្រជាជនថ្មី” ។ ប្រជាជនជម្លៀសទទួលការងារច្រើនជាងប្រជាជនមូលដ្ឋាន សូម្បីតែរបបហូបចុកក៏ខុសពីគ្នាដែរ ។ ប្អូនតូចៗបីនាក់របស់ សាបាន ត្រូវបានអនុញ្ញាតឲ្យរស់នៅជាមួយជីដូននៅឯភូមិ ចំណែក សាបាន និងបងស្រីបងប្រុសទៅរស់តាមកងចល័ត ហើយការហូបចុករបស់គាត់នៅពេលនោះមិនអត្តខាត់ខ្លាំងពេកទេ ។ អង្គភាពកងចល័តរបស់ សាបាន ត្រូវផ្លាស់ទៅធ្វើការគ្រប់ទឹកន្លែងដូចជាលើកទំនប់ជីកប្រឡាយជីកអាងទឹកនៅខាងលិចប្រសូត ស្រុករំដួល និង ស្រុកកំពង់រោទិ៍ជាដើមក្នុងរយៈពេលកន្លះខែ ឬមួយខែទើបទទួលការអនុញ្ញាតមកលេងភូមិម្ដង ។

## ស្រុកកំពង់រោទិ៍ក្នុងឆ្នាំ១៩៧៧

នៅចុងឆ្នាំ១៩៧៧ប្រជាជននៅក្នុងស្រុកកំពង់រោទិ៍ទាំងអស់ត្រូវបានជម្លៀសឲ្យទៅរស់នៅស្រុកស្វាយជ្រុំនិងស្រុកស្វាយរៀង ។ ប្អូនៗបីនាក់របស់គាត់ត្រូវជម្លៀសជាមួយជីដូនខាងឪពុកទៅរស់នៅខាងស្រុកស្វាយរៀង ចំណែកបងប្រុសបងស្រីរបស់គាត់ធ្វើការនៅក្នុងកងចល័តដដែល ។ សាបាន ត្រូវអង្គការចាត់តាំងឲ្យទៅធ្វើការជាអ្នកសែងកងទ័ពរបួសនៅសមរភូមិមុខរយៈពេល៥

ខែ ។ បន្ទាប់មក កងទ័ពវៀតណាមបានវាយប្រហារកងទ័ពខ្មែរក្រហមខ្ចាត់ខ្ចាយ សាបាន បានរត់គៀសខ្លួនតាមផ្លូវជាតិត្រឡប់មកកងចល័តរបស់ខ្លួនវិញ ។ ពេលនោះកងចល័តរបស់គាត់ត្រូវកងទ័ពវៀតណាមដេញប៉ះដាប់ចាប់ពតភីងទៅកាន់ភាគខាងលិច ។ មិនបានប៉ុន្មានថ្ងៃផង កងចល័តរបស់គាត់ក៏ត្រូវបានរំសាយ ហើយគាត់ក៏វិលត្រឡប់មកជួបជុំជីដូនខាងម្តាយវិញ ។

## ការជម្លៀសនិងការចាប់ខ្លួន

នៅក្នុងឆ្នាំ១៩៧៨ ប្រជាជននៅក្នុងខេត្តស្វាយរៀងត្រូវបានជម្លៀសមកកាន់តំបន់ភាគខាងលិច ដូចជា ខេត្តកណ្តាល កំពង់ឆ្នាំង ពោធិ៍សាត់ និងបាត់ដំបងជាដើម ។ ក្រុមគ្រួសាររបស់សាបាន ត្រូវបានជម្លៀសមកដល់ខេត្តកណ្តាលនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៧៨ ។ ស្នាក់នៅទីនោះបានរយៈពេលមួយសប្តាហ៍ សាបាន ត្រូវបានចាប់ខ្លួននៅវេលាម៉ោង១១យប់ថ្ងៃទី២៥ ខែសីហា ដោយគ្មានមូលហេតុច្បាស់លាស់ ។ សាបាន ប្រាប់ឲ្យដឹងថា ក្នុងខណៈពេលដែលគាត់កំពុងតែដីកស្រះប្រធានកងឈ្មោះ ត្រុន បានហៅឲ្យគាត់ឡើងលើ ហើយគាត់នឹកក្នុងចិត្តថា គ្មានរឿងអ្វីក្រៅតែពីរឿងខ្ចីនាឡិកាដៃមួយគ្រឿងនោះទេ ។ ត្រុន បានខ្ចីនាឡិកាដៃរបស់គាត់ដែលផ្ញើទុកនឹងបងថ្លៃប្រើប្រាស់ពីរ-បីថ្ងៃ ដោយសន្យាថាបីថ្ងៃក្រោយនឹងប្រគល់ជូនវិញ ប៉ុន្តែថ្ងៃដែលត្រូវសងនាឡិកា គឺជាថ្ងៃចាប់ខ្លួនគាត់ទៅវិញ ។ ដំបូង ត្រុន បាននាំគាត់ចូលទីស្នាក់ការឃុំជីឥដ្ឋ ស្រុកកៀនស្វាយ ពេលចូលដល់ទីនោះភ្លាម ឈ្លបក៏ចាប់ដៃគាត់ទាំងពីរចងហើយភ្ជង់កាំភ្លើងដាប់ ។ ឈ្លបនោះបានសួរគាត់ថា មានគ្នាប៉ុន្មាននាក់? គាត់ភ្ញាក់ខ្លួនព្រើតពេលឮសំណួរនេះពីព្រោះថាគាត់មិនដែលបានធ្វើអ្វីខុសទាល់តែសោះ ។ ក្រោយមកឈ្លបពីរនាក់បានបណ្តើរគាត់និងបុរសចំណាស់ម្នាក់ឈ្មោះ តៃ សាត ដែលរស់នៅឃុំស្វាយតាយានដែរ ទៅកាន់វត្តចំពុះក្អែកទាំងកណ្តាលអធ្រាត្រ ហើយប្រហែលម៉ោងបួនទៀបភ្លឺទើបពួកគាត់ដើរដល់វត្តនោះ ។ តៃ សាត ក៏ត្រូវទទួលរងការចោទប្រកាន់ដូចគ្នា ។

## ទារុណកម្មនិងការសួរចម្លើយនៅវត្តចំពុះក្អែក

ព្រឹកឡើងសន្តិសុខមន្ទីរវត្តចំពុះក្អែកបានចាប់គាត់ដាក់ច្រវាក់ជើងទាំងពីរយ៉ាងតឹងនិងចងដៃក្រពាត់ទៅក្រោយ រួចបណ្តើរយកទៅបន្ទប់សួរចម្លើយដែលមានចម្ងាយប្រហែល៥០ម៉ែត្រពីមន្ទីរឃុំឃាំង ។ កន្លែងសួរចម្លើយរបស់សន្តិសុខខ្មែរក្រហមគឺនៅក្នុងចេតិយមួយដែលមានតុមួយ ខ្សែភ្លើង កៅអីបាក់បែក និងកាំភ្លើងខ្លីនៅលើតុ ។ សាបាន ពិពណ៌នាថា មុនពេលសួរចម្លើយឈ្លបបានចាប់ជើងទាំងពីររបស់គាត់ ចងភ្ជាប់ទៅនឹងខ្សែច្រវាក់ធ្វើឲ្យគាត់មិនអាចស្ទុះចេញទៅណារួច ។ បន្ទាប់មក អ្នកសួរចម្លើយពីរនាក់បានចាប់ផ្តើមសួរគាត់ថា «មានខ្សែចាត់តាំងប៉ុន្មាននាក់ហើយ ក្នុងការគ្រប់គ្រងភ្នាក់ងារតើអ្នកឯងហ្នឹងមានឋានៈអី» ហើយគាត់បានឆ្លើយបដិសេធថាគ្មានបណ្តាញភ្នាក់ងារសេ.អ៊ី.អាទេ ហើយក៏គ្មានឋានៈអ្វីដែរ គាត់ជាយុវជនកងចល័តប៉ុណ្ណោះ ។ ដោយសារគាត់ឆ្លើយខុសគោលដៅដែលអ្នកសួរចម្លើយចង់បាន គាត់ក៏ត្រូវអ្នកសួរចម្លើយវាយធ្វើបាបយ៉ាងដំណំ ។ ក្នុងរយៈពេលពេញមួយខែដំបូង គាត់ត្រូវបានវាយសួរសម្លើយស្ទើរមិនលស់ថ្ងៃឡើយ ។ ពេលសួរចម្លើយម្តងៗមានរយៈពេលពីកន្លះម៉ោងដល់មួយម៉ោង ហើយគាត់តែងតែទទួលរងទារុណកម្ម ដូចជាវាយនឹងរំពាត់ខ្សែតី និងយកថង់ផ្លាស្ទិកប្រកក្បាលឲ្យថប់ដង្ហើមនិងទាត់ធាក់ជានិច្ច ។ ដោយមិនអាចស៊ូទ្រាំនឹងការឈឺចាប់នេះបាន គាត់ត្រូវតែបង្ខំចិត្តឆ្លើយកុហកដើម្បីធ្វើយ៉ាងណាឲ្យរួចផុតពីការធ្វើទារុណកម្មនេះ ។ សាបាន មិនសង្ឃឹមថា ចម្លើយរបស់គាត់អាចធ្វើឲ្យសន្តិសុខទុកជីវិតឲ្យគាត់ឡើយ ប៉ុន្តែទោះយ៉ាងណាក៏គាត់ត្រូវតែធ្វើការសម្រេចចិត្តមួយ ព្រោះថា «បើមិនឆ្លើយក៏ស្លាប់ ឆ្លើយក៏ស្លាប់ដូចគ្នា» ដែលយ៉ាងហោចណាស់ក៏ចម្លើយគាត់អាចកាត់បន្ថយការធ្វើទារុណកម្មរយៈពេលយូរដែរ ។ «បើប្រុងថាងាប់ហើយឆ្លើយឲ្យងាប់តែម្តងទៅវារេទនាខ្លាំងពេក ។ មួយថ្ងៃ៧ដងបន់ឲ្យតែស្លាប់ ។ យកគ្នាទៅវាយដូចល្បែងលេង ។ ទាំងរូបខ្ញុំនិងអ្នកទោសផ្សេងទៀតលែងគិតខ្វាយខ្វល់ ហើយមួយថ្ងៃៗបន់ឲ្យតែស្លាប់កុំឲ្យគេធ្វើទារុណកម្មយូរពេក» ។ ក្រោយមក សាបាន បានរកឃើញចម្លើយមួយសមរម្យគឺ ត្រូវឆ្លើយស្របនឹងសំណួររបស់អ្នកសួរម្លើយ «ខ្ញុំបានចាត់តាំងតាមខ្សែបណ្តាញខ្ញុំមែន ។ ខ្សែបណ្តាញចាត់តាំងរបស់ខ្ញុំមានតាមឃុំ សហករណ៍» ។ អ្នកសួរចម្លើយបានសួរគាត់បន្តទៀតថា «តើខ្សែបណ្តាញនៅឯណា?» ហើយគាត់បន្តឆ្លើយកុហកទៀតថា «អ្នកទាំងអស់នោះត្រូវអង្គការហៅទៅរៀនសូត្រ

*អស់ហើយ»* នេះក៏ព្រោះគាត់មិនចង់ឲ្យអ្នកផ្សេងទៀតមករងទុក្ខទោសដូចគាត់ ។

ចាប់តាំងពីពេលនោះមក ការសួរចម្លើយនិងការធ្វើទារុណកម្មមកលើរូបគាត់មានលក្ខណៈធូរស្រាលជាងមុន ។ គាត់ត្រូវឆ្លើយនឹងសំណួរដដែលៗរាល់ពេលដែលគាត់ស្ទើរតែទន្ទេញចាំរត់មាត់ទៅហើយ ។ *«តើអ្នកឯងជាភ្នាក់ងារសេ.អ៊ី.អា របស់ខ្មាំងយួនមែនទេ? អ្នកឯងចាត់ឲ្យបណ្ដាញបានប៉ុន្មាន ហើយពីណាទៅណា?»* ។ ក្រោយមក សាបាន បានរកឃើញថា មូលហេតុដែលសន្តិសុខសួរគាត់បែបនេះ ដោយសារកម្មាភិបាលភូមិភាគនិរតីចោទប្រកាន់ថា ប្រជាជនរស់នៅខាងភូមិបូព៌ាជាខ្មាំងយួន (ដោយសារអ្នកទាំងនោះរស់នៅជាប់ព្រំដែនវៀតណាម) ។ ពីមួយថ្ងៃទៅមួយថ្ងៃ ការសួរចម្លើយមានសភាពកាន់តែរយាលទៅៗ មួយខែក្រោយមកគាត់មិនត្រូវបានសួរចម្លើយទៀតឡើយ ប៉ុន្តែគាត់នៅតែជាអ្នកទោសកម្រិតធ្ងន់ដដែល ។ នៅក្នុងអំឡុងពេលនោះ សាបាន បានឃើញកងសន្តិសុខចាប់អ្នកទោសថ្មីមកឃុំឃាំងជាបន្តបន្ទាប់ ។ អ្នកទោសដែលជាប់នៅក្នុងបន្ទប់ជាមួយគាត់មិនត្រូវបានអនុញ្ញាតឲ្យចេញពីបន្ទប់ឃុំឃាំងឡើយ ។

## ៨ខែ១០ថ្ងៃរស់នៅក្នុងគុក

អ្នកទោសដែលជាប់នៅទីនោះមានបីប្រភេទ ៖ អ្នកទោសកម្រិតស្រាលអាចដើរទៅធ្វើការបាន ហើយពេលល្ងាចត្រូវវិលត្រឡប់មកកន្លែងវិញ ។ សាបាន ស្ថិតនៅក្នុងចំណោមអ្នកទោសកម្រិតធ្ងន់ចំនួន៤៣នាក់ ។ អ្នកទោសប្រភេទនេះមិនអនុញ្ញាតឲ្យធ្វើការងារអ្វីទាំងអស់ហើយត្រូវជាប់ខ្នោះនៅក្នុងបន្ទប់ឃុំឃាំងទាំងយប់ទាំងថ្ងៃ សូម្បីតែទឹកក៏មិនដែលបានងូតដែរ ។ កន្លែងសម្រាកការហូបចុកនិងបន្ទោរបង់គឺនៅកន្លែងតែមួយ ហើយអ្នកទោសអាចត្រឹមតែងើបឈរពត់ខ្លួនប្រាណបន្តិចប៉ុណ្ណោះ ។ សាបាន រៀបរាប់ថា រយៈពេលកន្លះខែដំបូងគាត់អាចទ្រាំទ្រ និងសម្រាកបានខ្លះ បន្ទាប់ពីនោះមកគាត់ដេកមិនបានឡើយពីព្រោះខ្លួនប្រាណរបស់គាត់កើតសុទ្ធតែចៃ ។ ក្នុងមួយថ្ងៃគាត់ទទួលបានបបរគ្រាប់ពោតឬបបរត្រកួនពីរពេល ហើយរបបដែលទទួលបាននោះតិចតួចបំផុតដោយសារថា គាត់ស្ថិតនៅក្នុងលំដាប់ទី៩នៃជួរទីបួន ដូច្នេះរបបអាហាររបស់គាត់ត្រូវអ្នកទោសនៅមុខដែលចាំហុចទឹក ឬបាយបន្តនោះបានដកយកបន្តិចម្នាក់ៗ ស្ទើរតែអស់ទម្រាំដល់ដៃគាត់ ។ ចំពោះទឹកផឹកនិងទឹកសម្រាប់ផ្ងូត គាត់ទទួលបានតែមួយចានទៀបប៉ុណ្ណោះក្នុងមួយថ្ងៃ ។ រៀងរាល់ពីរ-បីថ្ងៃម្ដង តែងតែមានអ្នកទោសស្លាប់ម្នាក់ឬពីរនាក់នៅក្នុងបន្ទប់ឃុំឃាំង ជាពិសេសអ្នកទោសដែលជាប់យូរខែថ្ងៃ ហើយមានរូបកាយស្គមស្គាំងដោយសារកង្វះជីវជាតិ ។ ស្ថិតក្នុងស្ថានភាពបែបនេះ សាបាន នឹកឃើញតែសេចក្ដីស្លាប់នៅនឹងមុខប៉ុណ្ណោះ ។

## សម្លាប់បំបាត់ភ័ស្តុតាង

ថ្ងៃទី៦ មករា ឆ្នាំ១៩៧៩មុនការដួលរលំនៃរបបនេះបន្តិច កងឈ្លបនិងប្រធានសន្តិសុខដែលដឹងសភាពការណ៍មុន បានបញ្ចេញអ្នកទោសធ្ងន់កម្រិតធ្ងន់ទាំងអស់ពីមន្ទីរឃុំឃាំងយកទៅសម្លាប់នៅគុម្ពោតព្រៃមួយ ដែលមានទីតាំងនៅក្នុងបរិវេណវត្តនេះដែរ ចម្ងាយប្រមាណជា១០ម៉ែត្រពីព្រះវិហារ ។ ម៉ោងប្រហែល១១ថ្ងៃត្រង់ កងឈ្លបបណ្ដើរពួកគាត់បីនាក់ចេញទៅ សាបាន ដឹងច្បាស់ថា គាត់នឹងត្រូវសម្លាប់នៅពេលនេះហើយ ពីព្រោះមិត្តភក្តិដែលជាប់គុកជាមួយគ្នា ធ្លាប់និយាយប្រាប់ថា ប្រសិនបើគេ [សន្តិសុខ] បណ្ដើរទៅតាមផ្លូវនោះច្បាស់ជាស្លាប់ហើយមិនរស់ទេ ។ សន្តិសុខ៥នាក់ដើរអមសងខាងផ្លូវក្លួងគាត់ទៅកាន់ទីតាំងសម្លាប់ដែលមានសណ្ឋានជាថ្លុកមួយទំហំ២ម៉ែត្របួនជ្រុង ។ សាបាន និងអ្នកទោសពីរនាក់ជាមនុស្សដែលត្រូវបាននាំយកទៅសម្លាប់មុនគេ ។ កងឈ្លបបានបញ្ជាឲ្យគាត់ទាំងបីអង្គុយទន្ទឹមគ្នាបែរមុខទៅទីតាំងសម្លាប់ ។ សាបាន ពិពណ៌នាថា សន្តិសុខបញ្ជាឲ្យគាត់អង្គុយសណ្ដូកជើងទៅមុខហើយដាក់ដៃទៅក្រោយ នៅពេលដែលគាត់កំពុងក្រឡេកមើលជនដៃដល់ម្នាក់ទៀត ស្រាប់តែជននោះបានយកបំពង់ទីបវាយកញ្ចឹងកតែម្ដង ហើយខ្លួនប្រាណគាត់ដួលស្រុបទៅដី ។ *«ភ្នែករបស់ខ្ញុំចាប់ផ្ដើមបើកមិនរួច ហាមាត់និយាយក៏មិនបាន ប៉ុន្តែត្រចៀករបស់ខ្ញុំអាចស្ដាប់ឮសន្តិសុខជជែកគ្នាថា [ចាក់ឬបាញ់] គ្នារបស់វាម្នាក់ឆ្លើយថា កុំបាញ់បែកការណ៍»* ។ ឈ្លបម្នាក់ទៀតបានយកកាំបិតស្រួចចាក់បំពង់កគាត់សម្លាប់បន្ថែមទៀត ។ សាបាន ដឹងថាឈ្លបចាក់បំពង់ករបស់គាត់ដែរ «ពេលចាក់ហើយវាគាស់ផ្ដាច់សរសៃតែម្ដង» ប៉ុន្តែពេលនោះគាត់ហាក់ដូចជាលែងឈឺទៅហើយ ។ ក្រោយពីចាក់សម្លាប់ ឈ្លបបានលើកសាកសពរបស់គាត់

គ្រវែងចូលថ្មុកនោះ ។ ពេលឃើញទិដ្ឋភាពបែបនេះអ្នកដែលមិនទាន់ត្រូវសម្លាប់ បាននាំគ្នាស្រែកយំហៅម៉ែឪឲ្យជួយ ហើយក៏ត្រូវឈ្លបវាយសម្លាប់ទាំងពីរនៅពេលនោះទៅ ។ សាបាន មិនស្គាល់ឈ្មោះជនដៃដល់ទាំងនោះទេ គាត់គ្រាន់តែដឹងថាអ្នកទាំងនោះជាកូនចៅ របស់ ថ្វាង (អនុប្រធានសន្តិសុខ) និង ស៊ុន (ពិការជើង ប្រធានសន្តិសុខ) ដែលជាអ្នកបញ្ជាឲ្យសម្លាប់អ្នកទោស ។ បន្ទាប់ពីនោះ សាបាន ក៏សន្លប់បាត់ស្មារតី ។ ម៉ោងប្រហែលបីរសៀល ពេលគាត់ដឹងខ្លួនឡើងវិញ គាត់ឃើញសាកសពដេកស្លាប់ក្បែរគាត់ពាសពេញទីធ្លានោះ ហើយមានសាកសពពីរនាក់សង្កត់ពីលើគាត់ទៀតផង ។ សាបាន អះអាងថា សាកសពទាំងនោះជាអ្នកទោសទាំង៤៣នាក់ដែលជាប់ឃុំជាមួយគាត់ «ខ្មោចហ្នឹង៤៣នាក់ហ្នឹងគឺទាំងអស់តែម្តង» ។ គាត់ខំរើបម្រះចេញពីសាកសពដែលសង្កត់ពីលើ ហើយព្យាយាមស្រាយចំណងចេញពីដៃបានបន្តិច ដោយទុកខ្សែចំណងឲ្យនៅជាប់ដៃដើម្បីបំភ័ន្តភ្នែកឃាតករ ។ ឈាមកកទាំងដុំៗដែលបិទមុខរបួសបានចាប់ផ្តើមហូរចេញតាមបំពង់កដែលដាច់នៅពេលដែលគាត់ក្អកម្តងៗ ។ មិនយូរប៉ុន្មាន សាបាន ត្រូវសន្លប់ម្តងទៀត រហូតដល់ពាក់កណ្តាលអធ្រាត្រត្រូវទឹកសន្សើម គាត់ក៏បានដឹងខ្លួនវិញ ។ «ពេលខ្ញុំក្អកក៏យកដៃទ្រឈាមកកចេញមកទាំងដុំៗ ។ នៅយប់នោះខ្ញុំមិនទាន់ចេញពីទីនោះភ្លាមទេ ព្រោះគ្មានកម្លាំងដើរ» ។ ដោយហេវហត់ខ្លាំងពេក សាបាន សម្ងំសម្រាកយកកម្លាំងនៅក្នុងគំនរសាកសពនោះរហូតដល់មេឃភ្លឺ ។ សម្ងំនៅជាមួយសាកសពមួយថ្ងៃមួយយប់ សាបាន បានឃើញខ្មែរក្រហមរុះរើផ្ទះនិងប្រមូលស្បៀងយ៉ាងប្រញាប់ប្រញាល់ដើម្បីភៀសខ្លួនចេញពីទីនោះ ។ ព្រឹកឡើងមុនពេលចេញដំណើរ សន្តិសុខខ្មែរក្រហមក៏បានដើរមកមើលគំនរសាកសពម្តងទៀត ដើម្បីរកមើលក្រែងមានអ្នកទោសណាមិនទាន់ស្លាប់? មិនអស់ចិត្តសន្តិសុខខ្មែរក្រហមក៏ស្រែកឃោសនាថា «បងប្អូនណានៅរស់ សូមលើកដៃ ពួកសង្គ្រោះមកដល់ហើយ» ។ នៅពេលនោះមានអ្នកទោសម្នាក់ឈ្មោះ រី ដែលមិនទាន់ស្លាប់ បានលើកដៃឡើងលើ ដើម្បីសុំការជួយសង្គ្រោះ ។ សន្តិសុខក៏បានជួយវែកយក រី ចេញពីគំនរសាកសព ហើយយកទៅទម្លាក់ក្នុងស្រះទឹកមួយដែលនៅខាងលិចវត្ត ។ ឃើញហេតុការណ៍ដូចនេះ សាបាន ធ្វើពុតជាស្លាប់បន្តទៀត ។

## ផ្សងព្រេងនៅក្នុងព្រៃបីយប់បីថ្ងៃ

ក្រោយពីសន្តិសុខទៅបាត់អស់ ប្រហែលជាថ្ងៃត្រង់ទើប សាបាន ចាកចេញពីទីនោះរត់សំដៅចូលព្រៃទាំងមិនដឹងទិសតំបន់ ។ ពេលទៅដល់វាលមួយ សាបាន បានជួបប្រទះក្មេងឃ្វាលគោពីរនាក់ ហើយគាត់បានសុំបាយក្មេងទាំងពីរនោះហូប ក្មេងទាំងពីរនាក់នោះប្រាប់ឲ្យគាត់ចាំមួយភ្លែត ។ ដោយការមិនទុកចិត្តចំពោះក្មេងទាំងពីរ សាបាន បានលាក់ខ្លួននៅក្នុងគុម្ពោតព្រៃមួយដោយយកសំរាមគ្របពីលើខ្លួនរង់ចាំមើលសកម្មភាពរបស់ក្មេងនោះ ។ មួយស្របក់ក្រោយមកគាត់ឃើញសន្តិសុខមកជាមួយក្មេងនេះមកតាមរកគាត់ទៀត ។ ដោយឃើញបែបនេះ សាបាន បានគេចខ្លួនចេញពីទីនោះចូលទៅក្នុងព្រៃវិញភ្លាម ហើយអាហារដែលគាត់អាចរកបាននៅពេលនោះគឺមានតែអំពៅនិងដំឡូងប៉ុណ្ណោះដែលគាត់លួចកាច់ និងដកពីចម្ការអ្នកភូមិ ។ នៅយប់ទីបី សាបាន បានដើរចេញពីព្រៃ មកសម្រាកនៅរោងដាំបន្លែមួយរបស់អ្នកស្រុក ។


ពីឆ្វេង: សាបាន បងស្រី និងម្តាយមីង

ជូនពេលនោះ សន្តិសុខខ្មែរក្រហមពីរនាក់ក៏បានមករុះរើខ្ទមនោះទៀត ពេលឃើញគាត់ដេកបែរខ្នងឈ្លបនោះក៏សួរគាត់ថា *«ម៉េចបានជាមកដេកនៅហ្នឹង»?* សាបាន បានឆ្លើយតបទៅឈ្លបនោះវិញថា គាត់ដើរហត់ពេក សន្តិសុខក៏សួរគាត់ទៀតថា *«ហើយចុះទៅណាមកណា?»* គាត់និយាយទាំងបែរខ្នងប្រាប់សន្តិសុខថា មិនទាន់ដឹងទៅខាងណាទេចាំមេឃភ្លឺសិន។ ឈ្លប នោះនៅតែសួរដេញដោលគាត់ថា *«ចុះកូនចៅទៅណាអស់ហើយ?»* ហើយគាត់ចេះឆ្លើយវិញថា «មិនដឹងទៅណាអស់ទេ»។ ពេលនោះឈ្លបម្នាក់ទៀតបាននិយាយប្រាប់គ្នាវាថា *«បើអីចឹងទុកគាត់ទៅ គ្មានរស់បានប៉ុន្មានថ្ងៃទេដឹងតែស្លាប់ហ្នឹង»*។ ពេលឈ្លបទាំងពីរចេញផុត សាបាន បានគេចខ្លួនចូលទៅក្នុងព្រៃម្តងទៀត។ ដោយឃើញប្រជាជនធ្វើដំណើរតាមផ្លូវយ៉ាងច្រើនកុះករ សាបាន ក៏សម្រេចធ្វើដំណើរជាមួយអ្នកទាំងនោះមកដល់ព្រែកប្រា។ តាមផ្លូវអ្នកដំណើរបានសួរគាត់ថា ហេតុអ្វីបានជារបួស ដោយភ័យខ្លាចអ្នកទាំងនោះជាខ្មែរក្រហម សាបាន កុហកថា គាត់ត្រូវរបួសពេលឡើងសមរភូមិប្រយុទ្ធនៅអ្នកលឿង ហើយអម្បែងគ្រាប់ខ្មាំងត្រូវពេលឡើងផុតពីលេណដ្ឋាន។ ប៉ុន្តែអ្នកទាំងនោះមិនជឿសម្តីរបស់គាត់ទេ ហើយថែមទាំងឆ្ងោយពាក្យថា «មុខរបួសដូចមុខកាំបិត»។ សាបាន មិនបានចាប់អារម្មណ៍ថា ប្រជាជនយល់បែបណានោះទេ គាត់ចេះតែដើរបន្តទៅមុខទៀត ដោយរកបានក្រមាមួយគ្របមុខរបួសនោះកុំឲ្យគេឃើញទៀត។



## ជួបអ្នកជួយសង្គ្រោះ

ថ្ងៃទី១២ ខែមករា ឆ្នាំ១៩៧៩ សាបាន បានជួបកងទ័ពវៀតណាម ប៉ុន្តែមុននោះបន្តិចគាត់បានជួបបងស្រីម្នាក់ដែលរស់នៅក្នុងស្រុកជាមួយគ្នាដែលគាត់អាចសម្គាល់បានតាមរយៈក្រមាដែលអង្គការចែកឲ្យអ្នកស្រុកស្វាយរៀងប្រើមុនពេលជម្លៀសទៅកាន់ខេត្តផ្សេងៗដើម្បីជាសញ្ញាបញ្ជាក់ថាប្រជាជនមកពីស្វាយរៀង។ សាបាន បានសុំឲ្យស្ត្រីម្នាក់នោះ ជួយប្រាប់ដំណឹងពីការស្លាប់រស់របស់គាត់ទៅសាច់ញាតិគាត់ផង ព្រោះថាឥឡូវនេះ គាត់កំពុងមានរបួសធ្ងន់មិនទាន់មានពេទ្យព្យាបាលទេ។ ក្រោយពីផ្តែផ្តាំរួច សាបាន បានដើរទៅក្នុងព្រៃវិញ។ តាមផ្លូវគាត់ត្រូវបុរសចំណាស់ចិត្តធម៌ម្នាក់បានប្រាប់គាត់ឲ្យទៅព្យាបាលនៅមន្ទីរពេទ្យថ្នល់កែង។ ទោះជាយ៉ាងណា សាបាន មិនហ៊ានទៅជួបពេទ្យឡើយ គាត់ចេះតែដើរគេចពីហ្វូងមនុស្សព្រោះខ្លាចជួបអ្នកសម្លាប់គាត់។ ក្រោយមក ពេលបានឃើញប្រជាជនរត់ឈូរចុះឈូរឡើង ពេលនោះទើបគាត់ហ៊ានដើរតាមថ្នល់ជាតិ។ មុខរបួសរបស់ សាបាន លែងមានឈាមហូរទៀតហើយ ប៉ុន្តែការហូបចុកពិតជាមានការលំបាក។ ពេលហូបម្តងៗគាត់ត្រូវយកដៃរបស់គាត់ម្ខាងទប់បំពង់កដែលដាច់នោះដើម្បីឲ្យអាហារចូលបានខ្លះ *«កាលណានិយាយ ឬហូបអីហៀរតាមមុខរបួសនោះមកវិញ។ ពេលហូបអាហារម្តងៗខ្ញុំយកដៃជួយទប់ដើម្បីឲ្យអាហារចូលពោះបានខ្លះ»*។

កងទ័ពរណសិរ្សសង្គ្រោះជាតិកម្ពុជាបានប្រកាសថា អ្នករស់នៅស្រុកណាអាចត្រឡប់ទៅស្រុកនោះវិញ។ ប្រជាជនខ្លះនាំគ្នាដឹកអង្ករនិងអំបិលតាមរទេះតាមលទ្ធភាពរបស់ខ្លួនត្រឡប់ទៅភូមិកំណើតរៀងៗខ្លួន។ សាបាន បានជួបកងទ័ពរណសិរ្សម្នាក់ ហើយកងទ័ពនោះបាននាំគាត់ទៅជួបកងទ័ពវៀតណាមដើម្បី

វាយវាប់ប្រាប់ការពិតឲ្យទាហានទាំងអស់នោះស្តាប់ ប៉ុន្តែអ្នកទាំងនោះមិនជឿគាត់ឡើយ ហើយថែមទាំងឲ្យគាត់នាំទៅកាន់ទីតាំងសម្លាប់ទៀតផង ។ នៅទីតាំងសម្លាប់នោះ កងទ័ពវៀតណាមបានរកឃើញអ្នកទោសមិនទាន់ស្លាប់ពីរនាក់ទៀតគឺស្ត្រីម្នាក់និងបុរសម្នាក់ឈ្មោះ លី (រស់នៅស្រុកបន្ទាយដែក) អ្នកទាំងពីរនៅមានដង្ហើមនៅឡើយ ប៉ុន្តែដៃជើងត្រូវហើមរលួយអស់ដោយសារកម្តៅនៃសាកសពដែលសង្កត់ពីលើ ។ បន្ទាប់មកគាត់ទាំងបីត្រូវបានបញ្ជូនទៅសម្រាកនៅមន្ទីរពេទ្យសាលាក្រៅរយៈពេលបីយប់ទើបបញ្ជូនបន្តទៅព្យាបាលនៅមន្ទីរពេទ្យព្រៃនគរប្រទេសវៀតណាម ។ ជាអកុសលជនរងគ្រោះពីរនាក់ដែលត្រូវបានជួយសង្គ្រោះបានស្លាប់នៅមន្ទីរពេទ្យក្នុងប្រទេសវៀតណាម ។

សាបាន បានទទួលការព្យាបាលនៅមន្ទីរពេទ្យព្រៃនគរប្រទេសវៀតណាមរយៈពេល៦ខែ ទើបបានជាសះស្បើយ ។ ក្នុងរយៈពេលព្យាបាលគ្មានសាច់ញាតិណាម្នាក់បានដឹងថាគាត់កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យនេះទេ ហើយចំពោះគាត់វិញក៏មិនបានដឹងថា បងប្អូនរបស់គាត់ស្លាប់រស់ប៉ុន្មាននាក់ដែរ ។ ក្រោយមកគាត់បានជួប ខៅ សាត (បច្ចុប្បន្នអភិបាលរងស្រុកកំពង់រោទិ៍) ហើយបានពឹងពាក់គាត់ឲ្យជួយនាំព័ត៌មានមកប្រាប់សាច់ញាតិរបស់គាត់នៅឯស្រុកផង ។ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៧៩ សាបាន ត្រូវកងទ័ពវៀតណាមបញ្ជូនមកមន្ទីរពេទ្យខេត្តស្វាយរៀងវិញ ព្រោះថាជំងឺរបស់គាត់បានធូរស្រាលហើយ ។ នៅមន្ទីរពេទ្យស្វាយរៀង ជាពេលវេលាមួយដែលសាបាន មានឱកាសបានសើបសួរដំណឹងអំពីបងប្អូនរបស់គាត់ដែលព្រាត់គ្នាអស់រយៈពេលជាងមួយឆ្នាំ ។ សព្វថ្ងៃ សាបាន នៅសល់បងប្អូនប្រាំនាក់ កំពុងរស់នៅក្នុងភូមិជាមួយគ្នា ហើយបងប្រុសម្នាក់បានស្លាប់នៅក្នុងរបបខ្មែរក្រហម ។ ដោយសារនៅមន្ទីរខ្វះខាតសម្ភារនិងថ្នាំសង្កូវព្យាបាល និងខ្វះការយកចិត្តទុកដាក់ពីគ្រូពេទ្យ សាបាន បានសម្រេចចិត្តវិលត្រឡប់មកផ្ទះវិញដើម្បីបន្តព្យាបាលជំងឺដោយថ្នាំខ្មែរបុរាណ ។

**ផលប៉ះពាល់**

បន្ទាប់ពីមុខរបួសបានជាសះស្បើយរយៈពេលជិតមួយឆ្នាំ សាបាន បានរៀបការប្រពន្ធដែលជាអ្នករស់នៅក្នុងភូមិជាមួយគាត់ហើយបានកូន៦នាក់ ប្រុសបីនិងស្រីបី ប្រកបមុខរបរធ្វើស្រែ ។ ទោះបីជាមុខរបួសជាសះស្បើយក៏ដោយ ក៏ស្នាមរបួសនេះបានធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ដល់សុខភាពនិងជីវភាពរស់នៅប្រចាំថ្ងៃរបស់គាត់ ។ សាបាន មិនអាចធ្វើការងារពេញលេញដូចពីមុនបានទេ ក្រៅពីការងារធ្វើស្រែជាមួយប្រពន្ធដែលស៊ើរតែមិនគ្រប់ហូបសម្រាប់មួយឆ្នាំៗនោះ សាបាន បានត្រឹមតែនៅមើលការខុសត្រូវកូនចៅនិងផ្ទះសម្បែងប៉ុណ្ណោះ ។ ចំណែកប្រពន្ធរបស់គាត់លក់ដូរបន្តិចបន្តួចនៅសាលារៀន ។ សាបាន នៅតែមានអាការៈតឹងទ្រូង ឆាប់ហត់ និងមិនអាចធ្វើការងារធ្ងន់ៗបាន ។ ជួនពេលខ្លះគាត់សុបិនឃើញសន្តិសុខធ្វើបាបគាត់ ហើយម្តងម្កាល គាត់សុបិនឃើញខ្លួនគាត់វិលត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៅវត្តនោះវិញ ។ សាបាន បង្ហាញពីអារម្មណ៍សោកស្តាយថា នៅក្នុងភូមិគាត់បុរសៗទៅធ្វើសំណង់អស់ ពីព្រោះថានៅតំបន់ដែលគាត់រស់នៅប្រជាជនអាចធ្វើស្រែបានតែម្តងទេក្នុងមួយឆ្នាំ គឺស្រែវស្សា ហើយនៅរដូវប្រាំង បុរសៗចេញទៅធ្វើការជាកម្មករសំណង់នៅបារិតបុភ្នំពេញដើម្បីរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារបន្ថែម ។

ថ្វីដ្បិតតែ សាបាន មិនបានបង្ហាញកំហឹងតាមរយៈកាយវិការនិងពាក្យសម្តីក៏ដោយ ក៏ប្រយោគមួយឃ្លារបស់គាត់អាចបញ្ជាក់ច្បាស់ថា គាត់មានអារម្មណ៍បែបណាចំពោះខ្មែរក្រហម “គេ [ខ្មែរក្រហម] ធ្វើបាបគ្រួសារខ្ញុំច្រើនលើកច្រើនគ្រា តាំងពីឪពុករហូតដល់កូនទៀត” ។ ខ្មែរក្រហមធ្វើបាបគាត់មិនសមហេតុផលទាល់តែសោះ ពីព្រោះគាត់មិនដែលបានប្រព្រឹត្តកំហុសណាមួយឡើយ ហើយខ្មែរក្រហមបែរជាច្នៃប្រឌិតឲ្យមានរឿងទៅវិញ ។ សាបាន មានសំណូមពរតែមួយគត់ដល់រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិសូមជួយកាត់ខ្មែរក្រហមឲ្យបានត្រឹមត្រូវតាមគតិយុត្តិ ហើយប្រសិនបើខាងតុលាការត្រូវការគាត់ធ្វើជាសាក្សី គាត់នឹងបំពេញបំណងរបស់តុលាការដោយគ្មានភ័យខ្លាចជនដៃដល់តាមសងសឹកគាត់ឡើយ ។ ឆ្លៀតពេលនេះ សាបាន សូមដាក់ពាក្យប្តឹងតាមរយៈទស្សនាវដ្តីស្វែងរកការពិតទៅតុលាការឲ្យជួយរកយុត្តិធម៌ឲ្យគាត់និងក្រុមគ្រួសារគាត់ផង ។

**លី សុផល**

# គុកខ្មែរក្រហម

## ខេត្តព្រៃវែង

## ស្រុកកំចាយមារ

### ១) មន្ទីរសន្តិសុខតាសំ

មន្ទីរសន្តិសុខតាសំ មានទីតាំងនៅក្នុងភូមិតាសំ ឃុំក្រញូង ស្រុកកំចាយមារ ខេត្តព្រៃវែង ។ មន្ទីរនេះជាស្នាដៃរបស់ខ្មែរក្រហមសាងសង់ពីដើមឫស្សីនិងយកស្លឹកត្នោតក្រៀបធ្វើជាជញ្ជាំង ។ យ៉ែម ជាប្រធាន និង សាម៉ៃ ជាអនុប្រធានមន្ទីរសន្តិសុខនេះតាំងពីដំបូង ។

ជនរងគ្រោះប្រហែល១៥០នាក់ ដែលក្នុងនោះភាគច្រើន


ចិន គាត់ បង្ហាញទីតាំងមន្ទីរសន្តិសុខតាសំ

ជាបុរសត្រូវកងឈ្លបចាប់ខ្លួន និងបញ្ជូនមកកាន់មន្ទីរសន្តិសុខតាសំ ដើម្បីឃុំឃាំងនិងសួរចម្លើយ ។ ចិន គាត់ អាយុ៦២ឆ្នាំ ជាបុគ្គលិកធ្វើការនៅមន្ទីរធម្មការ ខេត្តព្រៃវែងបាននិយាយថា ខ្មែរក្រហមបានសាងសង់បន្ទប់តូចៗជាច្រើន សម្រាប់ដាក់អ្នកទោសដាច់ដោយឡែកពីគ្នា ។ ជារៀងរាល់ថ្ងៃ អ្នកទោសខ្លះត្រូវកងសន្តិសុខនាំយកទៅសួរចម្លើយ ខ្លះទៀតត្រូវបណ្តើរចេញទៅធ្វើការនៅឆ្ងាយៗពីមន្ទីរឃុំឃាំង និងខ្លះទៀតត្រូវបានសម្លាប់បន្ទាប់ពីកងសន្តិសុខស៊ើបដឹងថាមានជាប់និន្នាការនយោបាយពីសង្គមចាស់ ។ បុគ្គលិកក្រឡាបញ្ជីម្នាក់ទៀតឈ្មោះ ស្រ៊ុន ប៊ូ ត្រូវបានសម្លាប់យ៉ាងព្រៃផ្សៃនៅក្នុងមន្ទីរសន្តិសុខតាសំ ។ ធាងត្នោត ដំបង និង ព្រនង់ ជាឧបករណ៍ចាំបាច់សម្រាប់ធ្វើទារុណកម្មនិងសម្លាប់អ្នកទោស ។

ចិន គាត់ ជាអតីតអ្នកទោសនៅមន្ទីរសន្តិសុខតាសំ ។ គាត់ត្រូវខ្មែរក្រហមចាប់ខ្លួនដោយសារគាត់ជាប្រជាជនជម្លៀស ។ ពីព្រលឹមទល់ព្រលប់ គាត់ បានចេញទៅធ្វើការជាមួយអ្នកទោស ហើយនៅពេលយប់គាត់និងអ្នកទោស៦ទៀតត្រូវកងសន្តិសុខដាក់ខ្នោះជាប់ៗគ្នា និងសម្ងំដេកយ៉ាងស្ងៀមស្ងាត់ ។ កងសន្តិសុខប្រចាំមន្ទីរមាននាទីឃ្លាំមើលនិងការពារមិនឲ្យអ្នកទោសណាម្នាក់លួចរត់ចេញពីមន្ទីរឃុំឃាំងឡើយ ។ គាត់ បន្តថា មានអ្នកទោសជាច្រើននាក់បានស្លាប់ដោយសារជំងឺ ធ្វើការហួសកម្លាំង និង បរិភោគអាហារមិនគ្រប់គ្រាន់ ។

បន្ទាប់ពីថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩ អ្នកទោសខ្លះបានរួចជីវិតនិងវិលត្រឡប់ទៅកាន់ស្រុកកំណើតវិញ ដូចករណី ចិន គាត់ ជាដើម ។

### ២) មន្ទីរសន្តិសុខព្រៃបឹងព្រោះ

ព្រៃបឹងព្រោះមានទីតាំងស្ថិតនៅភូមិសាមគ្គី ឃុំក្រញូង ស្រុកកំចាយមារ ខេត្តព្រៃវែង ។ ទីតាំងនេះត្រូវខ្មែរក្រហមកំណត់យកធ្វើជាមន្ទីរសន្តិសុខដើម្បីឃុំឃាំងអ្នកទោសជាប្រជាជនដែលជម្លៀសចេញពីទីក្រុងភ្នំពេញនិងប្រជាជនមូលដ្ឋានដែល


មន្ទីរសន្តិសុខព្រៃបឹងព្រោះ

ប្រព្រឹត្តខុសនឹងបទបញ្ជារបស់អង្គការ ។ មន្ទីរសន្តិសុខនេះសាងសង់ពីដើមឬស្សី ប្រក់ស្លឹកត្នោត ដែលមានរាងទ្រវែង ហើយមានខណ្ឌជាបន្ទប់តូចៗជាច្រើន ។ នៅចម្ងាយប្រហែលពីរគីឡូម៉ែត្រពីមន្ទីរសន្តិសុខ គឺជាទីតាំងសម្លាប់ ។ មនុស្សប្រមាណ ៥.០០០នាក់ ត្រូវបានសម្លាប់នៅទីនេះក្នុងនោះមានទាំងអ្នកទោសដែលខ្មែរក្រហមឃុំឃាំងនៅមន្ទីរសន្តិសុខព្រៃបឹងព្រោះផង ។

បច្ចុប្បន្នមន្ទីរសន្តិសុខនេះត្រូវបំផ្លិចបំផ្លាញទាំងស្រុង និងគ្មានបន្សល់ទុកនូវស្លាកស្នាមអ្វីជាភ័ស្តុតាងឡើយ ។

## ស្រុកកំពង់ត្របែក

### ៣) មន្ទីរសន្តិសុខទួលម្រេញ

មន្ទីរសន្តិសុខទួលម្រេញ ស្ថិតនៅភូមិកន្ទ្រោមអក ឃុំកន្ទ្រោមអក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។ មន្ទីរសន្តិសុខប្រចាំតំបន់២៤ ហៅថា ទួលម្រេញ បានលេចរូបរាងឡើងនៅឆ្នាំ ១៩៧៣ ដែលកាលណោះមន្ទីរសន្តិសុខនេះឃុំឃាំងតែប្រជាជនមូលដ្ឋានដែលធ្លាប់ធ្វើទាហាន ប៉ូលិស និងអ្នកមានបណ្តាស័ក្តិក្នុងរបបសាធារណរដ្ឋខ្មែរប៉ុណ្ណោះ ។ មុំ សី និង យឹម ហាត់ សព្វថ្ងៃរស់នៅភូមិកន្ទ្រោមអក ឃុំកន្ទ្រោមអក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង បានជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខនេះ ដោយសារតែគាត់ជាបក្ខពួកសន្តិសម្ព័ន្ធ ។ នៅឆ្នាំ១៩៧៤ អ្នកទាំងពីរបានរួចខ្លួនមកវិញ ប៉ុន្តែអ្នកទោសផ្សេងទៀតត្រូវកងឈ្លបសម្លាប់ទាំងអស់នៅត្រពាំងត្នោតនិងត្រពាំងឈូក ដោយសារអ្នកទាំងនោះជាទាហានរបស់ លន់ នល់ ។

បន្ទាប់ពីខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុងនៅឆ្នាំ ១៩៧៥ មន្ទីរសន្តិសុខនេះបានឃុំឃាំងអ្នកទោសដែលជាប្រភេទប្រជាជនជម្លៀសថែមទៀត ។ យឹម ហាត់ និយាយថា គាត់បានឃើញប្រជាជនជម្លៀសមកពីខេត្តស្វាយរៀងនិងតំបន់២៣ជាច្រើននាក់ ត្រូវកងឈ្លបបណ្តើរមកកាន់មន្ទីរសន្តិសុខទួលម្រេញ ។ អ្នកទោសត្រូវ កងសន្តិសុខសួរចម្លើយ ធ្វើទណ្ឌកម្ម និងឲ្យបំពេញការងារផ្សេងៗដូចជាធ្វើស្រែ លើកទំនប់ ជីកខស កាស់គល់ឈើ និងដាំស្ពៃជាដើម ។ ចំពោះអ្នកទោសណាដែលធ្វើការងារមិនកើតនឹងត្រូវកងឈ្លបនាំយកទៅសម្លាប់ចោលនៅទីតាំងសម្លាប់ត្រពាំងត្នោតនិងត្រពាំងឈូក ។

នៅឆ្នាំ១៩៧៨ អ្នកទោសដែលត្រូវសម្លាប់ដោយស្នាដៃកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតី បានកើតឡើងទៀតនៅទីតាំងពិឃាតផ្សេងទៀត ដូចជានៅទួលច្រេះ ទួលរកា ត្រពាំងរុន ឬស្សីជួរ និងឬស្សីចិន ។

សឹម, និន, កែវ សាម៉ាន់ និង ណាវ ជាកម្មាភិបាលគ្រប់គ្រងនៅមន្ទីរសន្តិសុខទួលម្រេញ ។ រហូតមកដល់បច្ចុប្បន្នពុំមាននរណាម្នាក់បានដឹងដំណឹងពីអ្នកទាំងនោះឡើយ ។

នៅក្រោយឆ្នាំ១៩៧៩ មន្ទីរសន្តិសុខទួលម្រេញត្រូវរដ្ឋអំណាចរំលាយចោល ។ រណ្តៅសាកសពនៅទីតាំងទាំងប៉ុន្មានខាងលើត្រូវក្រុមចោរលួចគាស់កាលពីឆ្នាំ១៩៨០ ដើម្បីរុករកវត្ថុមានតម្លៃដែលនៅជាប់នឹងខ្លួនសាកសព ។

## ស្រុកកញ្ជ្រៀច

### ៤) មន្ទីរសន្តិសុខសាលាស្វាយរមៀត



មន្ទីរសន្តិសុខស្វាយរមៀត

សាលាស្វាយរមៀតស្ថិតនៅក្នុងភូមិល្វើន ឃុំគ្រើងរាយ ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ។ សាលានេះកសាងឡើងនៅសម័យសង្គមរាស្ត្រនិយម ដែលបច្ចុប្បន្នត្រូវប្រជាជនជួសជុលឡើងវិញ និងក្លាយទៅជាអនុវិទ្យាល័យស្វាយរមៀត ។

ស្រុកកញ្ជ្រៀចបានធ្លាក់នៅក្រោមការគ្រប់គ្រងរបស់ខ្មែររំដោះចាប់តាំងពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ហើយសាលាស្វាយរមៀតបានក្លាយជាមន្ទីរសន្តិសុខមួយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្មាភិបាលខ្មែរក្រហមខាងភូមិភាគបូព៌ា និងភូមិភាគនិរតី ។ នៅក្នុងឆ្នាំ១៩៧៨ ការសម្លាប់បានកើនឡើងខ្ពស់ជាងឆ្នាំមុន ។ អ្នកទោសដែលកងសន្តិសុខនាំយកទៅសម្លាប់

គឺជាប្រជាជនមូលដ្ឋានដែលបានប្រព្រឹត្តល្មើសនឹងគោលនយោបាយរបស់បក្សនិងប្រជាជនដម្លៀសមកពីស្រុកមេសាង ស្រុកកញ្ច្រៀច និងស្រុកព្រៃវែង ខេត្តព្រៃវែង និងខេត្តស្វាយរៀង ។ នៅក្នុងឆ្នាំដដែល កម្មាភិបាលខ្មែរក្រហមភូមិភាគបូព៌ាដែលមានឋានៈចាប់ពីគណៈឃុំ គណៈស្រុក ពេទ្យ ទាហាន កងតូច កងធំ និងកម្មាភិបាល ថ្នាក់សហករណ៍ ត្រូវកម្មាភិបាលខ្មែរក្រហមភូមិភាគនិរតីចាប់ខ្លួនយកទៅដាក់ ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខសាលាស្វាយរមៀត ។ អ៊ុន ឈាង ភេទប្រុស អាយុ៥៦ឆ្នាំ បច្ចុប្បន្នជាជំទប់ទី១ ឃុំក្បឿងរាយ ស្រុកកញ្ច្រៀច បានរៀបរាប់ថា អ្នកទោសត្រូវកងឈ្លបនាំយកទៅសម្លាប់ ដើម្បីជាការព្រមានដល់ប្រជាជនឯទៀតៗកុំឲ្យយកគំរូតាម ។

ឈួន ឈន់ អាយុ៥៨ឆ្នាំ បច្ចុប្បន្នរស់នៅភូមិសាឡុង ឃុំក្បឿងរាយ ស្រុកកញ្ច្រៀច ខេត្តព្រៃវែង បាននិយាយពីការសម្លាប់អ្នកទោសនៅក្នុងមន្ទីរសន្តិសុខសាលាស្វាយរមៀតថា ការសម្លាប់បានប្រព្រឹត្តទៅជាដំណាក់ៗ មុនដំបូងខ្មែរក្រហមបានសម្លាប់អ្នកទោសជាទាហានប៉ូលិសនៃរបបសាធារណរដ្ឋខ្មែរ ។ ក្រោយមកទៀត ទើបសម្លាប់មន្ត្រីរដ្ឋការស៊ីវិលទូទៅអ្នកជាប់ខ្សែត្រកូលអភិជន ព្រមទាំងកូនកាត់យួន-ខ្មែរផង ដោយយកទៅសម្លាប់នៅទីតាំងមួយជុំវិញបរិវេណសាលាស្វាយរមៀត ។ តាមរបាយការណ៍របស់សាក្សីបានឲ្យដឹងថា មានសាកសពចំនួនប្រហែល១៧០០នាក់ ។

ប្រធានគ្រប់គ្រងមន្ទីរសន្តិសុខនៅសាលាស្វាយរមៀតនេះគឺឈ្មោះ សាន ដែលជាកម្មាភិបាលមកពីភូមិភាគនិរតី ។ ចំណែកក្រុមកងសន្តិសុខមួយចំនួនទៀតមាន ឆុន, សេង, ឆន និង អ៊ុក ។

### ៥) មន្ទីរសន្តិសុខព្រៃទួលចាក់ប្រាស

ទួលចាក់ប្រាស មានលក្ខណៈជាដីស្រែរាប់ហិកតាដែលហ៊ុមព័ទ្ធជុំវិញដោយដើមត្នោត និងគុម្ពឫស្សីដុះស្អេកស្កះ ស្ថិតនៅក្នុងភូមិស្វាយ ឃុំព្រាល ស្រុកកញ្ច្រៀច ខេត្តព្រៃវែង ។ នៅឆ្នាំ១៩៧៤ មន្ទីរសន្តិសុខមួយដែលមានវិន័យតឹងរ៉ឹងបំផុត ត្រូវបានបង្កើតឡើងនៅលើទួលចាក់ប្រាសនេះដើម្បីឃុំឃាំងនិងអប់រំប្រជាជនមូលដ្ឋានដែលមានកំហុសពីរឿងសីលធម៌ ជាប់និន្នាការនយោបាយ ខ្សែរយៈខ្មាំងបង្កប់ និងអ្នកដែលធ្លាប់ធ្វើទាហានកាលពីសម័យសាធារណរដ្ឋខ្មែរ ។ អ្នកទោសទាំងអស់ត្រូវខ្មែរក្រហមធ្វើការអប់រំណែនាំ បំពាក់បំប៉នគោលជំហរសតិអារម្មណ៍យ៉ាងច្រើន ហើយអ្នកទោសមួយចំនួនត្រូវអង្គការដោះលែងមកវិញ ។

សាត សឹង អាយុ៤៩ឆ្នាំ រស់នៅភូមិស្វាយ ឃុំព្រាល ស្រុកកញ្ច្រៀច ខេត្តព្រៃវែង បាននិយាយថា តាំងពីឆ្នាំ១៩៧៤ ដល់ឆ្នាំ១៩៧៥ ការឃុំឃាំងនិងការសម្លាប់មនុស្សមិនទាន់មានច្រើនប៉ុន្មានទេ ប៉ុន្តែចាប់ពីឆ្នាំ១៩៧៥មក ការឃុំឃាំងនិងការសម្លាប់កើនឡើងយ៉ាងច្រើន ។

នៅឆ្នាំ១៩៧៥ មន្ទីរសន្តិសុខព្រៃទួលចាក់ប្រាសមានឃុំឃាំងជនរងគ្រោះដែលភាគច្រើនជាបុរស ដែលត្រូវបានរកឃើញថាជាសក្តិភូមិ នាយទុន ទាហាន មន្ត្រីរដ្ឋការ និងប្រជាជនជម្លៀសចេញពីទីក្រុងភ្នំពេញ និងមកពីបណ្តាខេត្តនានាបន្ថែមទៀត ។ កងសន្តិសុខ បានបែងចែកអ្នកទោសផ្សេងពីគ្នារវាងអ្នកទោសកម្រិតស្រាលនិងអ្នកទោសកម្រិតធ្ងន់ ។ ហែម សយ អាយុ៤៦ឆ្នាំ ដែលជាអតីតកងសន្តិសុខប្រចាំនៅស្រុកកញ្ច្រៀច និងជាអង្គរក្សផ្ទាល់របស់ចៅហ្វាយស្រុកឈ្មោះ សុង និងបច្ចុប្បន្នជាលេខាយុត្តិធម៌ស្រុកកញ្ច្រៀចបាននិយាយថា ការធ្វើទារុណកម្មអ្នកទោសធ្វើឡើងជារៀងរាល់ថ្ងៃ ។ ប្រសិនបើចម្លើយសារភាពមិនទាន់អាចយកជាការបានទេ ទារុណកម្មនៅតែធ្វើរហូតលុះត្រាតែសម្រេចតាមបំណងកងឈ្លបដែលចង់បាន ។ អ្នកទោសខ្លះធ្វើទារុណកម្មរហូតសន្លប់បាត់ស្មារតី ហើយពេលដឹងខ្លួនវិញកងឈ្លបក៏ចាប់ផ្តើមសួរចម្លើយជាបន្ត ។ ចំណែកអ្នកទោសកម្រិតស្រាលត្រូវកងសន្តិសុខបញ្ជាឲ្យជីករណ្តៅសម្រាប់កប់សាកសពអ្នកទោសកម្រិតធ្ងន់ដែលត្រូវបានសម្លាប់មុន ឬក្រោយពេលសួរចម្លើយ ។

នៅចុងឆ្នាំ១៩៧៨ អ្នកទោសថ្មីជាច្រើននាក់ត្រូវខ្មែរក្រហមចាប់មកឃុំឃាំងបន្តបន្ទាប់ បន្ទាប់ពីអ្នកទោសចាស់ត្រូវបានសម្លាប់ ។ ប្រជាជនដែលរស់នៅក្នុងភូមិក្បែរៗមន្ទីរសន្តិសុខ ត្រូវអង្គការជម្លៀសទៅកាន់ខេត្តកំពង់ធំទាំងអស់ ។ បូ គឺជាកម្មាភិបាលគ្រប់គ្រងមន្ទីរសន្តិសុខ រួមនឹងបក្ខពួកមួយចំនួនទៀតដែលមិនចាំឈ្មោះ ។

## ស្រុកមេសាង

### ៦) មន្ទីរសន្តិសុខទួលជើងចាប



យឹម ស៊ីម មន្ទីរសន្តិសុខទួលដើងចាប

ទួលដើងចាបស្ថិតនៅភូមិសំព័រ ឃុំព្រៃទទឹង ស្រុកមេសាង ខេត្តព្រៃវែង ។ បន្ទាប់ពីថ្ងៃជ័យជម្នះខែមេសាឆ្នាំ១៩៧៥ ប្រជាជនដែលរស់នៅភូមិសំព័រ ឃុំព្រៃទទឹង ស្រុកមេសាង ខេត្តព្រៃវែង ត្រូវខ្មែរក្រហមជម្លៀសចេញទាំងអស់ ហើយផ្ទះជាច្រើនខ្នងត្រូវអង្គការរឹបអូសយកធ្វើជាមន្ទីរសន្តិសុខ ។ ដោយធ្វើការបែងចែកជាមន្ទីរសួរចម្លើយ មន្ទីរឃុំឃាំងអ្នកទោស មន្ទីរស្នាក់នៅរបស់កម្មាភិបាល និងរោងបាយ ។ លើសពីនេះទៀត ខ្មែរក្រហមបានសង់រោងវែងៗបន្ថែមចំនួនបីដែលរោងនីមួយៗធ្វើពីដើមឫស្សី និងប្រក់ស្លឹកត្នោត ដោយខណ្ឌជាបន្ទប់តូចៗដែលអាចឃុំឃាំងអ្នកទោសតែម្នាក់ប៉ុណ្ណោះ ។ អ្នកទោសដែលជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខទួលដើងចាបនេះជាប្រជាជនជម្លៀសពីទីក្រុង និងខេត្តមួយចំនួន បន្ទាប់ពីអង្គការតាមដាននិងស៊ើបដឹងថា ជាមនុស្សធ្លាប់ពាក់ពន្ធ័នឹងរឿងនយោបាយពីសង្គមមុន ។ ក្រៅពីនេះ ប្រជាជនមូលដ្ឋានក៏មានជាប់នៅទីនោះដែរ អង្គការចោទប្រកាន់ពីរឿងសន្តិសម្ពន្ធ័ជាមួយនឹងមន្ត្រីរដ្ឋការ ទាហាន ឬ កា.ហ្សេ.បេ ។ អ្នកទោសទាំងអស់ដេកលើកម្រាលស្លឹកត្នោត ។

ចំណែកកន្លែងសួរចម្លើយជាផ្ទះតៀមមួយ នៅក្បែរដើមពោធិ៍ខាងត្បូងមន្ទីរឃុំឃាំងប្រហែល៥០ម៉ែត្រ ដែលមានជញ្ជាំងធ្វើពីដីឥដ្ឋលាយអាចម៍គោនិងចំបើង ។ នៅឆ្នាំ១៩៧៦ អ្នកទោសភាគច្រើនត្រូវបានសម្លាប់ដោយកងសន្តិសុខប្រចាំមន្ទីរ ។

អ្នកទោសត្រូវកងសន្តិសុខបណ្តើរចេញពីបន្ទប់ឃុំឃាំងទាំងដើងជាប់ច្រវាក់ឲ្យទៅធ្វើការនៅក្រៅ ។ នៅពេលយប់ អ្នកទោសត្រូវកងឈ្លបនាំត្រឡប់មកមន្ទីរឃុំឃាំងវិញ ។ អ្នកទោសទាំងអស់ត្រូវនាំយកទៅសម្លាប់ដាក់ក្នុងរណ្តៅជាច្រើនដែលមាននៅជុំវិញមន្ទីរសន្តិសុខ ។ ប្រធានមន្ទីរសន្តិសុខទួលដើងចាបឈ្មោះ ឆាំ និងអនុប្រធានឈ្មោះ អ៊ិន ព្រមទាំងកម្មាភិបាលជាច្រើននាក់ទៀត ។

ក្រោយខែមករា ឆ្នាំ១៩៧៩ មន្ទីរសន្តិសុខទួលដើងចាបត្រូវរដ្ឋអំណាចថ្មីរំលាយចោល ។ នៅក្នុងនោះ មានបន្សល់ទុកប្រមាត់មនុស្សជាច្រើនដែលព្យួរពាសពេញមន្ទីរឃុំឃាំង និងកន្លែងសួរចម្លើយ ។ ម្តាយរបស់ ស៊ីម បានឲ្យដឹងថា គាត់បានចូលមកនៅផ្ទះរបស់គាត់វិញមុនគេ ហើយបានប្រទះឃើញប្រមាត់មនុស្សយ៉ាងច្រើន មានទាំងស្រស់ និងក្រៀម ហើយប្រមាត់ខ្លះត្រាំស្រាដាក់ក្នុងឪទិនទៀតផង ។ រហូតមកដល់សព្វថ្ងៃ ពុំមានភ័ស្តុតាងណាមួយបន្សល់ទុកនៅក្នុងមន្ទីរសន្តិសុខឡើយ ។

## ស្រុកពាមជរ

### ៧) មន្ទីរសន្តិសុខទួលពោធិ៍បូរី

មន្ទីរសន្តិសុខទួលពោធិ៍បូរី ដែលជាមន្ទីរសន្តិសុខធំជាងក្នុង



អតីតមន្ទីរសន្តិសុខទួលពោធិ៍បូរី

ចំណោមមន្ទីរសន្តិសុខនានាក្នុងស្រុកពាមជរ ។ ខ្មែរក្រហមបង្កើតមន្ទីរនេះឡើងដើម្បីឃុំឃាំងអ្នកទោសរាប់រយនាក់ជាទាហានរបបសាធារណរដ្ឋខ្មែរនិងប្រជាជនជម្លៀសចេញពីទីក្រុងភ្នំពេញ ដូចជាអាណិកជនវៀតណាម ចិន ប្រជាជនដែលត្រូវអង្គការចោទប្រកាន់ថាខ្មែរ-ស សេ.អ៊ី.អា កា.ហ្សេ.បេ និងប្រជាជនមូលដ្ឋាន ។

អ្នកទោសម្នាក់ៗត្រូវកងឈ្លបប្រើឲ្យធ្វើការងារជាធ្ងន់ៗ និងពុំមានផ្គត់ផ្គង់របបអាហារឲ្យគ្រប់គ្រាន់ឡើយ ។ អ្នកទោសខ្លះត្រូវស្លាប់ដោយការអត់ឃ្លាន និងខ្លះទៀតត្រូវកងឈ្លបសម្លាប់នៅទីតាំងពិឃាតមួយក្បែរមន្ទីរសន្តិសុខតែម្តង ។ សួន ផន អាយុ

៦២ឆ្នាំ បាននិយាយប្រាប់ថា នៅក្នុងអំឡុងឆ្នាំ១៩៧៨ កងសន្តិសុខបាននាំអ្នកទោសជាច្រើននាក់ទៅសម្លាប់ដោយពុំមានការសួរចម្លើយឡើយ ។ ផន បន្តថា នៅរដូវទឹកឡើង សាកសពជាច្រើនដែលកងសន្តិសុខកប់ក្នុងរណ្តៅរាក់ៗ បានអណ្តែតទឹកឡើង ហើយហូរចុះទៅក្រោម ។

មន្ទីរសន្តិសុខទួលពោធិ៍បូរី មានប្រធានគ្រប់គ្រងបីនាក់ ឈ្មោះ លង្ហិន លង្វែក និង ចក់ ព្រមទាំងសមាជិកប្រហែល ១០ នាក់ទៀត ។ លង្ហិន បានកាន់កាប់តំណែងជំនួស លង្វែក នៅពេលដែល លង្វែក ត្រូវអង្គការចាប់ខ្លួន ហើយ ចក់ បានមកជំនួសតំណែងរបស់ លង្ហិន ម្តង ។ សព្វថ្ងៃអតីតមន្ទីរសន្តិសុខទួលពោធិ៍បូរី បានក្លាយទៅជាដីព្រៃធំល្វឹងល្វើយនិងស្ងាត់ជ្រងំ ។

## ស្រុកពារាំង

### ៨) មន្ទីរសន្តិសុខទួលស្វាង

មន្ទីរសន្តិសុខទួលស្វាង ស្ថិតនៅភូមិស្វា ឃុំកំពង់ប្ញស្សី ស្រុកពារាំង ខេត្តព្រៃវែង ស្ថិតនៅខាងជើង សាលាស្រុកពារាំង ប្រហែល១៥គីឡូម៉ែត្រ ។ ទួលស្វាង មិនត្រឹមតែជាមន្ទីរសន្តិសុខបណ្តោះអាសន្នរបស់ខ្មែរក្រហមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាកន្លែងសម្លាប់មនុស្សធំបំផុតប្រចាំតំបន់២២ ។ អ្នកទោសដែលជាប់នៅក្នុងមន្ទីរសន្តិសុខនេះមួយចំនួនត្រូវកងសន្តិសុខបណ្តើរយកមក និងខ្លះទៀតដឹកតាមរទេះគោ ។ អ្នកទោសសម្រាកបានតែជាពីរ-បីម៉ោងប៉ុណ្ណោះ ត្រូវកងសន្តិសុខនាំយកទៅសម្លាប់ចោល ។ ប្រធានឃុំព្រៃស្រឡិត ឈ្មោះ ថោង ជ័យ បានបង្ហាញអណ្តូងធំៗ៣កន្លែង ព្រមទាំងរាយការណ៍ឲ្យដឹងថាកងឈ្លបបានឲ្យជនរងគ្រោះទាំងអស់សម្រាកសិនដើម្បីរង់ចាំវេនត្រូវនាំយកទៅសម្លាប់ដោយវាយចំកញ្ចឹង-ក និងដួនកាលវាយនឹងដែកភ្លៅរទេះ ។

ជុន សិត អាយុ៥៣ឆ្នាំ ជាប្រជាជនរស់នៅភូមិក្រាំង និងជាអ្នកទោសនៅមន្ទីរសន្តិសុខទួលស្វាំងក្នុងឆ្នាំ១៩៧៧បាននិយាយថា គាត់រាប់ឃើញចំនួនអ្នកទោសទាំងប្រុស ទាំងស្រី និងក្មេងតូចៗ ដែលជាប់ជាមួយគាត់ មានប្រហែលពី៣០ទៅ៤០នាក់ ។ បន្តិចក្រោយមក សិត ក៏ត្រូវកងឈ្លបដោះលែងមកវិញ ដោយមូលហេតុថាចាប់ច្រឡំមនុស្ស ។ ពេលចាកចេញពីមន្ទីរ សិត បានសន្យាថានឹងជួយលាក់ការសម្ងាត់ទាំងអស់ មិនឲ្យអ្នកណាដឹងឡើយ ។ រណ្តៅក្រហេងក្រហូងដែលជីកកប់សាកសពកាលពីជំនាន់ខ្មែរក្រហម នៅមានសល់ខ្លះៗរហូតមកដល់បច្ចុប្បន្ននេះ ។

### ៩) មន្ទីរសន្តិសុខវត្តក្រាំងពិសី

វត្តក្រាំងពិសីស្ថិតនៅភូមិពាមអម្ពិល ឃុំរាប ស្រុកពារាំង ខេត្តព្រៃវែង ។



មន្ទីរសន្តិសុខវត្តក្រាំងពិសី

ឆ្អឹងសាកសពមួយគំនរធំត្រូវបានធ្វើពិធីបូជាក្នុងថ្ងៃតែមួយ នៅថ្ងៃបុណ្យឆ្លងព្រះវិហារដែលទើបសាងសង់ថ្មីក្នុងវត្តក្រាំងពិសី កាលពីអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ ។ នៅឆ្នាំ១៩៧៧ វត្តក្រាំងពិសី ត្រូវខ្មែរក្រហមបង្កើតជាមន្ទីរសន្តិសុខទី២សម្រាប់ដាក់អ្នកទោសកម្រិតស្រាលរាប់ម៉ឺននាក់បន្ទាប់ពីមន្ទីរសន្តិសុខនៅវិទ្យាល័យ ញឹម វណ្ណដា ពារាំងសព្វថ្ងៃ ។ ចាប់ពីចុងឆ្នាំ១៩៧៧ អ្នកទោសកម្រិតស្រាលទាំងនេះត្រូវកងសន្តិសុខនាំយកទៅសម្លាប់ចោលនៅទីវាលមួយចម្ងាយប្រហែល៥០ម៉ែត្រពីបរិវេណវត្តក្រាំងពិសីប៉ែកខាងត្បូង ។ កងសន្តិសុខបានធ្វើទារុណកម្មអ្នកទោសនៅក្នុងរូងក្រោមដីមួយដែលមានឧបករណ៍សម្រាប់សួរចម្លើយជាច្រើនដូចជាពាងដាក់ទឹកសាប៊ូ គុ និងឧបករណ៍ សម្រាប់ធ្វើទារុណកម្មជាដើម ។ អ្នកទោសដែលឆ្លងកាត់ការសួរចម្លើយរួចហើយ ត្រូវកងឈ្លបនាំយកទៅសម្លាប់ចោលដោយមិនអាចចៀសផុតឡើយ ។ តាំងពីចុងឆ្នាំ១៩៧៧ ការធ្វើចរាចរពីកន្លែងមួយទៅកន្លែងមួយរបស់ប្រជាជនត្រូវបានហាមឃាត់ ដោយសារនៅពេលនោះខ្មែរក្រហមដែលមកពីភូមិភាគនិរតីបានចូលមកកាន់កាប់ជំនួសវិញ ។ ជិន សាមឿន អាយុ៥៦ឆ្នាំ ជាគ្រូបង្រៀននៅសាលាបឋមសិក្សាវត្តក្រាំងពិសីបានរៀបរាប់ថា «ការធ្វើទារុណកម្មអ្នកទោសមាន

*ភាពសាហាវយង់ឃ្នងណាស់»។*

ខ្មែរក្រហមបានបង្កើតគុកងងឹតមួយនៅជាន់ក្រោមសាលាឆាន់វត្តក្រាំងពិសី ដើម្បីធ្វើទារុណកម្មអ្នកទោស និងមន្ទីរឃុំឃាំងមួយកន្លែងទៀតដែលគ្មានជញ្ជាំងបិទបាំង ស្ថិតនៅខាងក្រោបរិវេណវត្តតែប្រមាណ៣០ម៉ែត្រប៉ុណ្ណោះ។ អ្នកទោសដែលជាប់នៅក្នុងមន្ទីរឃុំឃាំងនេះ សុទ្ធតែត្រូវដាក់ខ្នោះជើងជាប់ទាំងសងខាងដោយភ្ជាប់ពីម្នាក់ទៅម្នាក់ទៀត។

ហែម រៀម អាយុ៧១ឆ្នាំ រស់នៅភូមិពាមអម្ពិល ឃុំរាប ស្រុកពារាំងបានប្រាប់ថា មានអ្នកទោសច្រើននាក់បានរត់គេចខ្លួនពេលដែលស្ថានភាពស្រុកទេសកំពុងវឹកវរនាចុងឆ្នាំ១៩៧៨។ ឆ្មាំងបបររបស់អ្នកទោសត្រូវសន្តិសុខនៅក្នុងមន្ទីរនោះលើកជះលើកម្រាលឥដ្ឋដើម្បីឲ្យអ្នកទោសដែលជាប់ខ្នោះលិទ្ធស៊ី មុននឹងរត់ភៀសខ្លួនចេញពីមន្ទីរឃុំឃាំងទៅរកកន្លែងសុវត្ថិភាព។ ឆ្អឹងនិងលលាដ៍ក្បាលសាកសពត្រូវប្រជាជនគាស់ប្រមូលគរទុកជាច្រើនគំនរនៅក្បែរមាត់រណ្ដៅ។

សោ ឈាង អាយុ៥០ឆ្នាំ ជាអ្នកបានឃើញហេតុការណ៍នេះច្រើនជាងគេ បានប៉ាន់ប្រមាណចំនួនសាកសពដែលខ្មែរក្រហមសម្លាប់នៅក្នុងបរិវេណវត្តក្រាំងពិសីថាមានប្រមាណពី៣-៤ម៉ឺននាក់។ កន្លែងក្រហេងក្រហូងដែលមាននៅសល់រហូតមកដល់សព្វថ្ងៃនេះ ត្រូវរលុបបាត់អស់ស្ទើរទាំងស្រុងដោយសារទឹកទន្លេឡើងនាំដីល្បាប់មកចាក់បំពេញ។

**(នៅមានត)**

**ផេង ពងរ៉ាស៊ី**

# យុទ្ធជនភូមិភាគឧត្តរ

ដោយសារស្រុកកើតសង្គ្រាម ពាង ត្រូវបានមេភូមិឈ្មោះ នោ បង្ខំឲ្យចូលបម្រើក្នុងជួរកងទ័ពខ្មែរក្រហមក្នុងឆ្នាំ១៩៧២ នៅពេលមានអាយុ១៧ឆ្នាំ ពាង ត្រូវបានបញ្ជូនឲ្យទៅហាត់រៀនដោះមីននិងយុទ្ធសាស្ត្រកងទ័ពនៅភូមិរការកំបុត ឃុំសូទ្រនិគម ស្រុកសូទ្រនិគមរយៈពេលបីខែ។ គ្រូបង្វឹករបស់ ពាង ពណ៌នាថា ជាវិធានការត្រៀមដើម្បីវាយប្រយុទ្ធជាមួយទាហានលន់នល់កាន់កាប់ ទីក្រុងភ្នំពេញ។ ពាង និយាយថាការគ្រប់គ្រងនៅកន្លែងនោះមានសភាពតឹងតែងយ៉ាងខ្លាំង។ កូនទាហានមិនត្រូវបានអនុញ្ញាតទៅលេងផ្ទះដើម្បីសួរសុខទុក្ខឪពុកម្តាយឡើយ។ អ្នកដែលប្រឆាំងនឹងបទបញ្ជានេះអាចត្រូវបានយកទៅសម្លាប់ចោលទៀតផង។



ង៉ែ ហៅ ពាង អាយុ៥១ឆ្នាំ

នៅក្នុងឆ្នាំ១៩៧៣ ពាង និងយុទ្ធជន៥០០នាក់ផ្សេងទៀតត្រូវបានបញ្ជូនទៅខេត្តកំពង់ធំ ដោយបោះទីតាំងនៅវត្តអូរតាសេក។ កងទ័ពទាំងអស់ត្រូវធ្វើដំណើរដោយថ្មើរជើងអស់រយៈពេល៣យប់៣ថ្ងៃ។ ពាង បានចូលរួមប្រយុទ្ធក្នុងសមរភូមិជាមួយនឹងទាហានលន់នល់ពីរដង។ នៅក្នុងការពើបប្រយុទ្ធនេះ កងទ័ពខ្មែរក្រហមទទួលបរាជ័យ ហើយរងការខូចខាតយ៉ាងច្រើន។ ក្នុងចំណោមនោះ មានប្រហែល២០នាក់ស្លាប់ ហើយ១៩នាក់ផ្សេងទៀតរងរបួស។ ពាង មិនមានរបួសក្នុងពេលប្រយុទ្ធទេ ប៉ុន្តែគាត់មានជំងឺគ្រុនចាញ់ ហើយត្រូវបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យភ្នំសន្ទុក រយៈពេល៣ថ្ងៃ។

នៅឆ្នាំ១៩៧៤ ក្រុមរបស់គាត់ត្រូវបានបញ្ជូនទៅសមរភូមិក្បែរក្រុងភ្នំពេញ *«ខ្ញុំជាសះស្បើយភ្លាមគេរៀបចំឲ្យទៅវ៉ៃនៅភ្នំពេញ»* គឺវាយបន្ទាយនៅភ្នំប្រសិទ្ធិ។ ក្រុមរបស់ ពាង ទទួលភារកិច្ចវាយនៅម្តុំព្រែកព្នៅ។ ដោយសារគាត់មានវ័យក្មេងជាងគេ គាត់ត្រូវបានអនុញ្ញាតឲ្យនៅដឹកបាយទៅចែកតាមក្រុមនិងជាអ្នកដឹកអង្ករទៅសមរភូមិមុខប៉ុណ្ណោះ។ ក្រៅពីនេះ ជាអ្នកប្រចាំការដាំបាយនៅនឹងកន្លែងនិងមើលខុសត្រូវផ្នែកសេដ្ឋកិច្ច។

ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមទទួលជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរ ហើយកាន់កាប់បានទីក្រុងភ្នំពេញនិងផ្ទៃប្រទេស

ទាំងមូល ។ ក្រោយពីជម្លៀសប្រជាជនចេញអស់ពីទីក្រុង ខ្មែរក្រហមបានបញ្ជូន ពាង និងកងទ័ពមួយចំនួនទៀតឲ្យមកបោសសម្អាតខ្មោចទាហានលន់នល់ដែលស្លាប់នៅខាងលិចមន្ទីរពេទ្យព្រះកេតុមាលា ។ ពាង បានរៀបរាប់ថា "មានខ្មោចមនុស្ស ខ្មោចទាហាន និងខ្មោចសត្វនៅពាសពេញផ្លូវ ជុំវិញស្តូប ដង្កូវចោះ" ។ សាកសពទាំងអស់នោះត្រូវយកទៅកប់ចោលនៅមុំមាត់ទន្លេ ។

នៅចុងឆ្នាំ១៩៧៥ ពាង ត្រូវបានផ្លាស់ឲ្យទៅធ្វើកម្មករលីសែងនៅកំពង់ផែកំពង់សោម ។ ពាង បានអះអាងថាមានអង្ករជាច្រើនត្រូវបានដឹកតាមកប៉ាល់មកពីស្រុកចិន ។ កប៉ាល់ទាំងនោះមកចតនៅកំពង់ផែកំពង់សោមរយៈពេលប្រហែលពីរខែ ។ អង្ករទាំងអស់នោះត្រូវដឹកយកទៅស្តុកទុកនៅឃ្លាំងរបស់អគ្គភាពនៅមុំផ្សារលើ ។ ពាង និយាយថា អង្ករដែលដឹកមកម្តងៗមានចំនួនប្រហែល២០ម៉ឺនតោន ហើយបើគិតពីទំហំឃ្លាំងវិញ គឺមានទទឹង៥០ម៉ែត្រនិងបណ្តោយ១០០ម៉ែត្រ ។

ពាង មិនបានធ្វើការនៅមួយកន្លែងទេ ។ មួយរយៈក្រោយមក ពាង ត្រូវបានដកឲ្យមកធ្វើការនៅភ្នំពេញវិញ ។ ដំបូង ពាង ធ្វើជាអ្នកបកផ្លែកូរយៈពេល២ខែនៅក្បាលថ្នល់ ។ ក្រោយមក ពាង ត្រូវបានដកឲ្យមកនៅអគ្គភាពធំ៦ វត្តទួលទំពូង ដែលជាទីតាំងសម្រាប់នាំកចេញទៅលក់នៅក្រៅប្រទេស ។ ពាង កាន់ខាង ម៉ាស៊ីន ហើយបកគបាន១០ដុំក្នុងមួយថ្ងៃ ។ ពាង និយាយថា ក្រោយពេលបកស្អាតហើយ ផលិតផលទាំងអស់នឹងត្រូវវាយផ្លាកដាក់ថា "លក់ចេញទៅក្រៅប្រទេស" ។ អគ្គភាពនេះមានគ្នាទាំងអស់៣០នាក់ ដោយធ្វើការឆ្លាស់គ្នា "១៥នាក់ចាប់ផ្តើមសម្រាក ១៥នាក់ថ្មីចូលមកជំនួស ។ ម៉ាស៊ីនដំណើរការរហូត២៤ម៉ោង ដោយគ្មានពេលទំនេរទេ ។ ខ្ញុំធ្វើការដល់ម៉ោង១០យប់ ទើបបានសម្រាក" ។

នៅក្នុងមន្ទីរនោះ តារិទ្ធ ជាប្រធានពាណិជកម្ម ហើយតាឡាញ់ ជាប្រធានកង ។ ពាង បានចូលរួមលើកបាវគដាក់លើឡាន ហើយដឹកទៅដាក់កប៉ាល់ចិននៅកំពង់ផែកំពង់សោម ។ ពាង និយាយថា ឡានទីមួយៗអាចដឹកបាវគពី៥០ទៅ៦០បាវ ហើយការដឹកជញ្ជូននោះត្រូវចំណាយពេល២ខែទើបដឹកអស់ពីឃ្លាំង ។

ធ្វើការនៅទីនោះ ពាង ធ្លាប់ឃើញ ខៀវ សំផន និងនិរសាររបស់គាត់ចូលមកត្រួតពិនិត្យការងារក្នុងមន្ទីរនេះដែរ ។ ពាង និយាយថា ពេលធ្វើការនៅកន្លែងបកគនៅមុំទួលទំពូងនេះ គាត់ខស្សាហ៍ឮសូរសំឡេងមនុស្សស្រែកនៅពេលយប់ "យ៉ូយៗ ជួយផងៗ!" ។ សម្រែកនោះឮខ្លាំងណាស់ ហាក់បីដូចជាទទួលរងការឈឺចាប់យ៉ាងខ្លាំង" ។ ពាង ធ្លាប់លួចសួរអ្នកនៅក្នុងក្រុមជាមួយគ្នាដែលប្រាប់ថា ជាសំឡេងអ្នកទោសក្នុងគុកមួយដែលមានទីតាំងនៅក្បែរនោះដែរ ។ ទោះជាយ៉ាងណាក៏ដោយ ពុំមាននរណាម្នាក់ហ៊ានទៅលួចមើលកន្លែងដែលជាប្រភពសំឡេងស្រែកនោះទេ ។

ធ្វើការនៅភ្នំពេញ ពាង ធ្លាប់បានចូលរួមប្រជុំរយៈពេល៣ថ្ងៃចំនួនពីរដង ។ ការប្រជុំលើកទីមួយធ្វើឡើងនៅស្តាតអូឡាំពិកក្នុងឆ្នាំ១៩៧៧ ។ កិច្ចប្រជុំនោះស្តីពីការកសាងប្រទេស ការពារប្រទេសឲ្យបានរីកចម្រើន មហាលោតផ្លោះ មហាអស្ចារ្យ និងបញ្ហាជម្លោះព្រំដែនជាមួយវៀតណាម ។ វគ្គដំបូង តារិទ្ធ ដែលជាប្រធានពាណិជ្ជកម្មឡើងខទ្ទេសនាម ហើយវគ្គទីពីរ នួន ជា បានឡើងថ្លែងសុន្ទរកថា ។ ការប្រជុំលើកទី២ធ្វើឡើងនៅពេជ្រនិលក្នុងឆ្នាំ១៩៧៨ ដែលមាន នួន ជា ជាអ្នកដឹកនាំការប្រជុំ ។ ការប្រជុំលើកនេះគឺផ្តោតជាសំខាន់ទៅលើរបៀបកសាងជាតិដែលមានមនុស្សចំនួន១៥០នាក់ចូលរួម ។

នៅក្នុងឆ្នាំនោះដែរ ពាង ត្រូវបានបញ្ជូនឲ្យទៅធ្វើការខាងជួសជុលផ្លូវរថភ្លើងនៅកំពង់សោម ។ ពាង ព្រួយបារម្ភជាខ្លាំងដោយសារមនុស្សភាគច្រើនដែលត្រូវបានបញ្ជូនទៅត្រូវបាត់ខ្លួនមិនដែលឃើញត្រឡប់មកវិញទេ ។ ពាង ធ្វើការនៅទីនោះរហូតដល់ថ្ងៃដែលវៀតណាមវាយចូលទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៩ ។ ពាង អះអាងថា នៅពេលនោះ ខ្មែរក្រហមបានសម្លាប់កម្មកររទេះភ្លើងអស់ជាច្រើន ដោយចោទថាជាអ្នកឃុបឃិតជាមួយវៀតណាម ។

ក្នុងរយៈកាលនៃរបបខ្មែរក្រហម ពាង បាត់បង់ប្អូនប្រុសម្នាក់ឈ្មោះ លើង ដែលទៅបម្រើកងទ័ពជាមួយគ្នា ។ ប្អូនរបស់ ពាង ត្រូវខ្មែរក្រហមយកទៅសម្លាប់ដោយសារតែលួចដកដំឡូងមកហូបព្រោះតែឃ្លានខ្លាំងពេក ។ បទពិសោធន៍ក្នុងរបបខ្មែរក្រហមធ្វើឲ្យ ពាង មានការឈឺចាប់រហូតដល់សព្វថ្ងៃ ហើយសង្ឃឹមថា តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងប្រព្រឹត្តទៅដោយយុត្តិធម៌ដើម្បីជាសំណងជំងឺចិត្តដ៏ស្ងួចស្ងើងសម្រាប់ប្រជាពលរដ្ឋខ្មែរដែលមានសមាជិកយ៉ាងតិចម្នាក់ត្រូវស្លាប់ឬបាត់ខ្លួន ។ **គាត លក្ខិណា**

# ភាពភ័យរន្ធត់បន្សល់ទុកពីរបបខ្មែរក្រហម

ក្រោមការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ គ្រប់ក្រសួង មន្ទីរ សាលារៀន វត្តអារាម និងមន្ទីរពេទ្យ ត្រូវបានបិទទ្វារទាំងស្រុង ហើយប្រែក្លាយទៅជាឃ្លាំងសម្រាប់ផ្ទុកស្រូវ អង្ករ អំបិល ចំណែកកន្លែងខ្លះទៀតត្រូវបានប្រើប្រាស់ជាកន្លែងឃុំឃាំងមនុស្ស ។ ប្រពន្ធត្រូវព្រាត់ប្តី កូនត្រូវព្រាត់ឪពុកម្តាយ ដោយសារតែគោលការណ៍របស់អង្គការបំពាក់មនោគមវិជ្ជាឲ្យស្រឡាញ់អង្គការ ស្មោះត្រង់នឹងអង្គការ ធ្វើការដើម្បីអង្គការ ដូច្នេះហើយអ្នកទាំងអស់ត្រូវតែបំបែកគ្នាទៅធ្វើការតាមកងរៀងៗខ្លួន ។

ហេន សុវណ្ណរី អាយុ៣៩ឆ្នាំ មានស្រុកកំណើតនៅក្នុងឃុំព្រែករកា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បច្ចុប្បន្នរស់នៅឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ឪពុកឈ្មោះ ហុង ហេន និង ម្តាយឈ្មោះយឹម សាអ៊ុត ។ រី មានបងប្អូន៧នាក់ នៅក្នុងជំនាន់ ប៉ុល ពត បងប្អូនរបស់ រី ៥នាក់ត្រូវស្លាប់ដោយសារអត់មានបាយហូប ។


ហេន សុវណ្ណរី

នៅមុនឆ្នាំ១៩៧៥ពេល រី មានអាយុ៩ឆ្នាំ ។ ឪពុកម្តាយរបស់ រី បាននាំគ្នាគ្រួសារមករស់នៅទំនប់បឹងទំពុនដែលមានទីតាំងស្ថិតនៅខាងលិចទីក្រុងភ្នំពេញជាប់នឹងទឹកដីខេត្តកណ្តាល ។ ពេលនោះ រី នៅចាំបានថា នៅមុនពេលស្រុកកើតចលាចល ឪពុកម្តាយរបស់គាត់ខសប្តាហ៍នាំមកលេងជីដូនជីតា នៅឯស្រុកកំណើតជារឿយៗ ។ ក្រោយមកនៅពេលដែល រី ចូលរៀនថ្នាក់ទី១១ រី បានដឹងថានៅពេលនោះគឺមានការវាយប្រហារគ្នាមិនលស់ថ្ងៃឡើយ ហើយមានការទម្លាក់គ្រាប់បែកយ៉ាងខ្លាំងនៅក្នុងតំបន់ដែលខ្លួនកំពុងរស់នៅ ។

ឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ខ្មែរក្រហមបានជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុងភ្នំពេញ ។ នៅក្នុងពេលជម្លៀសបងប្អូនប្រជាជនមួយចំនួនដែលជាមន្ត្រីរដ្ឋការត្រូវខ្មែរក្រហមជម្លៀសឲ្យទៅកាន់ខេត្តបាត់ដំបង ចំណែកឪពុករបស់ រី បានលាក់ប្រវត្តិរូបពិតរបស់គាត់ដោយប្រាប់ខ្មែរក្រហមថាជាអ្នកធាក់ស៊ីក្លូ ហេតុនេះបានជាក្រុមគ្រួសាររបស់គាត់ត្រូវបានជម្លៀសទៅកាន់ស្រុកកំណើត ។ នៅក្នុងពេលធ្វើដំណើរត្រឡប់មកស្រុកកំណើត រី បានឃើញទិដ្ឋភាពជាច្រើនដែលគួរឲ្យភ័យខ្លាច មានអ្នកខ្លះដេកស្លាប់នៅលើកៅអី គ្រែ និងនៅតាមវាលស្រែអមសងខាងផ្លូវសុទ្ធតែថ្កុកឈាមនិងសាកសពជាច្រើន ។ ពេលមកដល់ស្រុកកំណើតនៅក្នុងឃុំព្រែករកា ឪពុកម្តាយរបស់ រី ធ្វើការដកស្ទូងតាមធម្មតា ហើយ រី និងបងប្អូននៅកងកុមារខ្មែរក្រហម ។ ពេលនោះមិនទាន់មានប្រមូលផ្តុំរួមទេ ការរស់នៅមានលក្ខណៈជាក្រុមគ្រួសារតូចៗ ។ បានរយៈពេលជាងមួយឆ្នាំ អង្គការបានចេញគោលនយោបាយថ្មី គឺប្រមូលទ្រព្យសម្បត្តិទាំងអស់ដាក់រួម ការហូបចុកក៏រួម សូម្បីតែដំណាំបន្តិចបន្តួចដែលដាំនៅតាមរបងផ្ទះក៏ជារបស់សហមូហភាពដែរ ។ ក្រុមគ្រួសារទាំងអស់ត្រូវបែងបែកទៅធ្វើការតាមកងរៀងៗខ្លួន ឪពុកទៅកងផ្សេង ម្តាយទៅកងផ្សេង និងកុមារទៅកងផ្សេង រយៈពេលដប់ប្រាំថ្ងៃទើបអាចជួបមុខគ្នាម្តង ។ នៅក្នុងចំណោមបងប្អូនទាំង៧នាក់ រី ជាកុមារម្នាក់ដែលទទួលការធ្វើបាបច្រើនជាងគេពីសំណាក់កូនកម្មាភិបាលជាច្រើនដោយសារតែ រី មិនបានបត់បែនតាមកាលៈទេសៈ នៅតែទម្លាប់ហៅ "ប៉ាម៉ាក់" ដែលខ្មែរក្រហមវាយតម្លៃថាជាក្រុមបក្ខពួកមូលធននិយម ។ ជាញឹកញាប់ រី ត្រូវអង្គការបញ្ជូនទៅអប់រំនិងធ្វើបាបដោយសារលួចរត់ទៅផ្ទះ ។ ថ្ងៃមួយពេលដែល រី លួចរត់ទៅផ្ទះតែនៅពាក់កណ្តាលផ្លូវ រី ក៏ប្រទះឃើញកងឈ្លបខ្មែរក្រហមបណ្តើរមនុស្សមួយក្រុមដែលមានគ្នាប្រហែល៣០នាក់យកទៅសម្លាប់ចោលនៅព្រៃម្តុំគុកសង់ទន្លេបាទី ។ ដោយភ័យខ្លាំងពេក រី ក៏សម្រេចចិត្តរត់ទៅពួននៅក្នុងគុម្ពោតព្រៃក្បែរផ្លូវ ហើយបានឃើញអ្នកទោសដែលឈ្លបបណ្តើរមកនោះមានប្រុសស្រី មាន

រូបរាងស្គមស្គាំង ហើយនៅលើដៃរបស់អ្នកទោសមិនមានចង ចំណងអ្វីមាំទាំនោះទេ គឺមានតែខ្សែអំបោះមួយសរសៃរុំដៃប៉ុណ្ណោះ ហើយឲ្យដើរជាជួរ បើសិនជាអ្នកទោសធ្វើឲ្យដាច់អំបោះ ត្រូវទទួលទារុណកម្មយ៉ាងខ្លាំងមុននឹងទៅដល់កន្លែងសម្លាប់ ។ មួយសន្ទុះក្រោយមក នៅពេលដែលក្រុមអ្នកទោសដើរហួសពីកន្លែងដែល រី លាក់ខ្លួនប្រហែលពីរទៅបីរយម៉ែត្រ មានសំឡេងវាយលាន់ឮផូសៗ និងសំឡេងអ្នកទោសយំ ខ្លះស្រែករកម៉ែឲ្យជួយ ខ្លះអង្វរឲ្យទុកជីវិត ។ សំឡេងទាំងអស់នោះបានធ្វើ រី កាន់តែភ័យខ្លាំងឡើងៗ ញ័រខ្លួនដូចកូនសត្វ ធ្វើឲ្យ រី មិនអាចបន្តដំណើរទៅមុខទៀតបាន ។

នៅក្នុងកងកុមារ រី ត្រូវថ្នាក់លើលត់ដំយ៉ាងខ្លាំងដោយឲ្យលើកប្រព័ន្ធភ្លឺប្រឡាយ រែកដី រើសអាចម៍គោនិងកាប់ដើមទន្រ្ទានខែត្រ និងទទួលបានបបររាវមួយចានដើម្បីទ្រទ្រង់ជីវិតបានរស់ពីមួយថ្ងៃទៅមួយថ្ងៃ ហើយប្រសិនបើ រី ធ្វើការមិនបានគ្រប់ផែនការដែលអង្គការដាក់ឲ្យទេ សូម្បីតែបបររាវមួយវែកនោះក៏មិនបានដែរ ។ យូរៗម្តង រី និងសមមិត្តទាំងអស់ដែលនៅក្នុងកងកុមារជាមួយគ្នាមានការសប្បាយរីករាយនិងត្រេកអរយ៉ាងខ្លាំងដែលអង្គការឲ្យគាត់ហូបបាយលាយដំឡូង ជួនកាលលាយពោតនិងសម្លត្រកួនខ្មៅៗកាត់តែឬសចោលប៉ុណ្ណោះ ។

រឿងសំខាន់មួយទៀតដែល រី នៅចងចាំមិនភ្លេចនោះ គឺចុងឆ្នាំ១៩៧៦ដើមឆ្នាំ១៩៧៧ ពេលដែលកងរបស់ រី ទទួលបញ្ជាពីអង្គការឲ្យទៅកាប់ដើមទន្រ្ទានខែត្រដើម្បីយកមកធ្វើជី ។ ពេលនោះ រី ត្រូវមេកងដែលជាកូនរបស់ពួកកម្មាភិបាលយកកណ្តៀវមកឆូតមុខឲ្យចេញឈាម ហើយប្រាប់ទៅកុមារផ្សេងទៀតដែលនៅក្នុងកងជាមួយគ្នាថានេះគឺជាទណ្ឌកម្មសម្រាប់អ្នកណាដែលធ្វើការមិនបានគ្រប់ចំនួនតាមផែនការដែលអង្គការថ្នាក់លើដាក់ឲ្យ ។ ក្នុងខណៈពេលដែលឈាមកំពុងតែហូរចេញពីថ្ពាល់ដោយការឈឺចាប់នោះ ពួកមេកងទាំងនោះបែរជាឈរសើចយ៉ាងសប្បាយរីករាយទៅវិញ ។

ស្លាកស្នាមដែលបន្សល់ទុកនៅលើផ្ទៃមុខ ព្រមទាំងហេតុការណ៍និងព្រឹត្តិការណ៍ភ័យរន្ធត់តក់ស្លុតជាច្រើននៅក្នុងរបប ប៉ុល ពត ដែល សុវណ្ណរី ធ្លាប់បានជួបប្រទះនិងឆ្លងកាត់ ធ្វើឲ្យជីវិតបច្ចុប្បន្នរបស់រី ក្លាយទៅជាមនុស្សឆាប់ខឹងមួម៉ៅ បាត់បង់ទំនុកចិត្តលើខ្លួនឯង ព្រួយបារម្ភ និងគិតច្រើន ។ **គង់ សុភគឿន**

# ជីវិតបដិវត្តន៍របស់គ្រួសារព្នង

ប្រជាជននៅក្នុងខេត្តមណ្ឌលគិរីបានទទួលរងនូវការឈឺចាប់រយៈពេលយូរជាងតំបន់ផ្សេងៗនៃប្រទេសកម្ពុជា ដោយសារតំបន់នេះឋិតនៅក្រោមការគ្រប់គ្រងរបស់កងទ័ពខ្មែរក្រហមតាំងពីឆ្នាំ១៩៦៨ម៉្លេះ ។ យុវជនយុវនារីគ្រប់ជនជាតិតំបន់ភ្នំដែលពេញវ័យត្រូវអង្គការជ្រើសរើសឲ្យទៅបម្រើបដិវត្តន៍តាមផ្នែកផ្សេងៗដូចជាធ្វើយោធា ឈ្លប និរសារ និងពេទ្យជាដើម ក្រោមការឃោសនាថា "បម្រើជាតិបម្រើវណ្ណៈកសិករក្រ" រំដោះប្រទេសចេញពីការជិះជាន់ ។ យុវជនមួយចំនួនបានស្លាប់និងបាត់ខ្លួននៅក្នុងសមរភូមិ ហើយមួយចំនួនទៀតបានវិលត្រឡប់មកស្រុកកំណើតវិញ ។ ជាក់ស្តែងដូចជា ហើញ ព្លិល និង ក្រញ ជាគូស្វាមីដែលរៀបការដោយអង្គការ បាននាំគ្នាវិញត្រឡប់មកភូមិឋានវិញបន្ទាប់ពីរួមសុខរួមទុក្ខជាមួយបដិវត្តន៍អស់ពេលជាច្រើនឆ្នាំ ហើយនៅទីបំផុតត្រូវទទួលបរាជ័យទៀត ។

តើជីវិតបដិវត្តន៍របស់អ្នកទាំងពីរបានជួបប្រទះអ្វីខ្លះ? មូលហេតុអ្វីបានជាអ្នកទាំងពីរបានជួបគ្នា?

ហើញ ព្លិល ជាជនជាតិព្នងបានលាចាកពីជីវិតបដិវត្តន៍ និងវិលត្រឡប់ទៅស្រុកកោះញែកវិញនៅឆ្នាំ១៩៨១ បច្ចុប្បន្នរស់នៅក្នុងស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ។ ព្លិល ជាកូនទី៥ក្នុងចំណោមបងប្អូនប្រុស៧នាក់និងបងស្រីម្នាក់ ។ ព្លិល រៀនបានត្រឹមតែថ្នាក់ទី១២(ថ្នាក់ទី១បច្ចុប្បន្ន)ប៉ុណ្ណោះ ។ នៅក្នុងរបបខ្មែរក្រហម ព្លិល ត្រូវបានប្រធានពេទ្យស្រុកពេជ្រាដាឈ្មោះ ចិន សាហោឲ្យទៅធ្វើពេទ្យបដិវត្តន៍ទោះបីជាដឹងថា ព្លិល រៀនសូត្របាន

តិចតួចក៏ដោយ ។ ពិល នៅចាំថា ចិន សា បានមកនិយាយជាមួយឪពុកម្តាយរបស់គាត់ថា *"ឥឡូវខ្វះពេទ្យ ប្អូនៗ ក្មួយៗ ពុកម៉ែដែលមានកូនអាយុពី១៧-១៨ ឲ្យវាចូលធ្វើពេទ្យខ្លះទៅសម្រាប់បម្រើឪម៉ែ មិនមែនបម្រើគេទេ គឺបម្រើជាតិ"* ពិល រស់នៅជាមួយឪពុកម្តាយបងប្អូនតាំងពីនៅតូចៗ មិនដែលឃ្លាតឆ្ងាយពីផ្ទះឡើយ នៅពេលឮថាខ្លួនត្រូវបញ្ជូនឲ្យទៅធ្វើពេទ្យ ពិល ប្រកែកមិនព្រមទៅហើយរត់ទៅឈរយំក្បែរខ្លួនម្តាយ នៅពេលនោះម្តាយរបស់ ពិល ក៏បដិសេធយ៉ាងដាច់អហង្ការដែរ ព្រោះគាត់មានកូនស្រីតែពីរនាក់ ។ ក៏ប៉ុន្តែឪពុករបស់ ពិល មិនបានជំទាស់នឹងរឿងនេះទេ ព្រោះចង់ឲ្យកូនចូលធ្វើការប្រឡូកក្នុងសង្គមគ្រាន់


ពិល


ពិល និងស្វាមីឈ្មោះ ក្រញ

បានចេះដឹងនឹងគេខ្លះ ។ ពិល នៅចាំពាក្យរបស់ ចិន សា ដែលបានលួងលោមគាត់ថា *"ក្មួយកុំធ្វើអីចឹង មិនចង់បម្រើជាតិ បម្រើវណ្ណៈទេអី? មិនចេះអក្សរក៏រៀនបានដែរ"* ។

ពិល ចូលបម្រើការនៅមន្ទីរពេទ្យអស់រយៈពេលជិតបីឆ្នាំ គឺចាប់តាំងពីឆ្នាំ១៩៧៦រហូតដល់ចុងឆ្នាំ១៩៧៨ ។ ក្នុងនាមជានារីពេទ្យមូលដ្ឋាន ពិល មើលថែទាំអ្នកជំងឺយ៉ាងយកចិត្តទុកដាក់ ។ ដោយឃើញ ពិល បំពេញការងារបានល្អ ប្រធានពេទ្យបានបញ្ជូនទៅបំពាក់បំប៉នវិជ្ជាពេទ្យបន្ថែមនៅឯទីក្រុងភ្នំពេញចំនួនពីរលើកជាមួយយុវជនម្នាក់ទៀតឈ្មោះ ប៊ុន ធី ជាជនជាតិព្នងនិងរស់នៅភូមិជាមួយគ្នា ។ លើកទី១ ពិល បានទទួលការបំពាក់បំប៉នផ្នែកទ្រឹស្តីនិងការអនុវត្តជាក់ស្តែងរយៈពេលបីខែ ហើយក៏វិលត្រឡប់មកបម្រើការនៅពេទ្យមូលដ្ឋានវិញ ។ ពិល រំឭកថា គាត់មានការលំបាកនៅពេលរៀនសូត្រ ពីព្រោះថាគាត់រៀនបានតិចតួចពេកពេលរៀនវគ្គទ្រឹស្តីម្តងៗគាត់ត្រូវពឹងលើស្មារតីទន្ទេញមេរៀនឲ្យចាំមាត់ ហើយជួនពេលខ្លះគាត់ត្រូវពឹងអ្នកអង្គុយក្បែរខ្លួនឲ្យជួយសរសេរ ។ ប៉ុន្តែភាគច្រើនដែលគាត់អាចចេះចាំប្រភេទថ្នាំបានល្អដោយសារគាត់បានចុះអនុវត្តជាក់ស្តែងច្រើន ។ ពេលត្រឡប់មកដល់មូលដ្ឋានវិញ អង្គការបានផ្សំផ្គុំគាត់ជាមួយយុទ្ធជនម្នាក់ជាស្វាមី ។ ក្រៅពីធ្វើពេទ្យ ពិល ត្រូវបានចាត់តាំងឲ្យទៅលើកទំនប់ដែរ ។ រស់នៅជាមួយគ្នាបានរយៈពេលតែជាងមួយខែ ពិល ត្រូវបានបញ្ជូនទៅបំប៉នមុខវិជ្ជានេះម្តងទៀតនៅក្នុងឆ្នាំ ១៩៧៨ ហើយក៏បែកទីក្រុងភ្នំពេញតែម្តង ។ ពិល ត្រូវរត់ភៀសខ្លួនទៅជាមួយកម្មាភិបាលខ្មែរក្រហមពីកន្លែងមួយទៅកន្លែងមួយដើម្បីគេចពីការតាមសម្លាប់របស់កងទ័ពវៀតណាម ។ រហូតមកដល់ចុងឆ្នាំ១៩៨០ ពិល បានរត់ភៀសខ្លួនមកដល់ស្រែជេស រស់នៅជាមួយកងទ័ពខ្មែរក្រហមរយៈពេលជិតមួយឆ្នាំ ធ្វើការតស៊ូរួមជាមួយកងទ័ពរណសិរ្សរំដោះជាតិកម្ពុជា ។ អង្គការដែលមានតាបាន និង តាលើ បានផ្សំផ្គុំ ពិល ជាមួយបុរសពោះម៉ាយម្នាក់ដែលមានឈ្មោះ ក្រញ ជាកងទ័ពយាមល្បាតតាមអូរ ។ ពិល រំឭកថា មុនពេលរៀបការ ក្រញ បានមកសាកសួរចិត្តគាត់ដែរ

ហើយ តាលើ ដែលជាប្រធានវរសេនាតូច ជាអ្នកជួយសម្របសម្រួល ។ ថ្ងៃដែលគាត់រៀបការមានទាំងអស់បីគូ ហើយអង្គការបានកាប់ក្របីមួយក្បាលដើម្បីជប់លៀងនៅក្នុងពិធីមង្គលការនេះ ។

រស់នៅជាមួយស្វាមីបានរយៈពេលជិតមួយឆ្នាំ ព្លិល សម្រាលបានកូនស្រីមួយ ប៉ុន្តែសំណាងអាក្រក់ទារកបានស្លាប់ដោយជំងឺរលាកទងសួតបន្ទាប់ពីប្រសូត្របានមួយខែ ។ មិនយូរប៉ុន្មានកងទ័ពព្រៃខ្មែរក្រហមបានផ្លាស់ទីតាំងបន្តដំណើរឆ្ពោះទៅស្រុកសំឡូតដែលជាទីតាំងប្រមូលផ្តុំធំរបស់ខ្មែរក្រហម ។ ព្លិល និងស្វាមីបានសម្រេចចិត្តគេចខ្លួនធ្វើដំណើរត្រឡប់ទៅស្រុកកំណើតវិញនៅឆ្នាំ១៩៨២ ។

ក្រញ ជាកូនកាត់ ចារាយ-ទំពួន-លាវ មានស្រុកកំណើតនៅភូមិស្រែហ៊ុយ ឃុំស្រែហ៊ុយ ស្រុកកោះញែក ខេត្តមណ្ឌលគិរី ក្រុមគ្រួសាររបស់គាត់គឺជាប្រជាជនមូលដ្ឋាន ។ ដោយសារតែមានការបង្ខិតបង្ខំខ្លះពីអង្គការ ក្រញ ក៏បានចូលរួមជាមួយកងទ័ពខ្មែរក្រហមដែរ កាលណោះគាត់មានវ័យ៣០ឆ្នាំ ត្រូវបានជ្រើសរើសជាយោធាស្រុកការពារព្រំដែន ។ ក្រញ រំឭកថា ប្រសិនបើគ្រួសារណាមិនព្រមលះបង់កូនឲ្យចូលបម្រើក្នុងជួរបដិវត្តន៍ទេ អ្នកទាំងនោះនឹងត្រូវទទួលរងនូវការគំរាមថា *“ឥឡូវបើអ្នកណារឹងរូសមិនចូលធ្វើខ្មែរក្រហមទេ គេវាស់ដី៥០ម៉ែត្រឲ្យមានន័យថាវាស់ដីដើម្បីកប់ខ្លួនឯង”* ។ ដោយហេតុនេះ ក្រញ ក៏សម្រេចចិត្តធ្វើជាទាហានល្បាតនៅស្រែហ៊ុយ គាត់ដើរល្បាតតាមព្រៃគ្រប់ទីកន្លែងនៅក្នុងស្រុកកោះញែក ចំណែកឪពុកម្តាយបងប្អូនរបស់គាត់រស់នៅឯភូមិធ្វើស្រែ លើកទំនប់ជីកប្រឡាយជាមួយប្រជាជនមូលដ្ឋាននិងប្រជាជនថ្មី ។ មួយរយៈក្រោយមក ក្រញ ត្រូវបានចាត់តាំងឲ្យធ្វើជានិរសាររបស់ តាឡាន់ ប្រធានវរសេនាធំលេខ១ប្រចាំការនៅក្នុងស្រុកកោះញែក ។ នៅក្នុងជំរំរបស់ក្រញ មានយុវជនយុវនារីមកពីខេត្តផ្សេងៗ អ្នកទាំងនោះធ្វើការមិនបានយូរប៉ុន្មានផង ត្រូវអង្គការដឹកទៅកន្លែងផ្សេងៗ ។ ក្រញ សន្និដ្ឋានថា យុវជនយុវនារីទាំងអស់នេះត្រូវបានដឹកយកទៅសម្លាប់ចោល ។ ជាញឹកញាប់ ក្រញ តែងតែឃើញអង្គការដឹកមនុស្សចេញទៅទាំងឡានៗ ។ នៅចុងឆ្នាំ១៩៧៨ ក្រញ បានឡើងសមរភូមិប្រយុទ្ធប្រឆាំងនឹងកងទ័ពវៀតណាម កងទ័ពខ្មែរក្រហមជាច្រើនបានស្លាប់ ហើយនៅសេសល់ប៉ុន្មានដកខ្លួនថយ ។ ដោយដឹងថាមិនអាចយកជ័យជម្នះពីកងទ័ពវៀតណាមបាន កងទ័ពខ្មែរក្រហមរួមទាំង ក្រញ ផងបានវាយដកថយហើយភៀសខ្លួនទៅរស់នៅក្នុងព្រៃជ្រៅក្នុងស្រុកកោះញែក ។ ក្រញ មាននាទីដើរល្បាតតាមអូរការពារពីការវាយប្រហាររបស់កងទ័ពវៀតណាមរហូតមកដល់ឆ្នាំ១៩៨១ ដែលនៅទីនោះជាកន្លែងដែល ក្រញ បានជួបប្រពន្ធរបស់គាត់ ។ ក្រញ រំឭកថា ដោយឃើញចរិតស្លូតបូតរបស់ ព្លិល គាត់ក៏បានស្នើសុំទៅថ្នាក់លើ ហើយអង្គការបានព្រមព្រៀងរៀបការគាត់ទាំងពីរជាប្តីប្រពន្ធ ។ ក្រញ នៅចាំបានយ៉ាងច្បាស់ថា ថ្ងៃដែលគាត់រៀបការគឺនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៨០ ។ នៅថ្ងៃនោះអង្គការបានឲ្យគូស្វាមីភរិយាក្តាប់គ្រាប់កាំភ្លើងម្នាក់មួយគ្រាប់រួចឡើងប្តេជ្ញាចិត្ត ប្រសិនបើប្តីឬប្រពន្ធណាផិតក្បត់ ប្តីឬប្រពន្ធនោះអាចយកគ្រាប់កាំភ្លើងមួយគ្រាប់នេះបាញ់សម្លាប់ដើម្បីបញ្ចប់ជីវិត ព្រោះតែការផិតក្បត់នេះ ។ ក្រញ បានឲ្យដឹងថា គាត់រក្សាគ្រាប់កាំភ្លើងមួយគ្រាប់នេះបានរហូតដល់សព្វថ្ងៃ ។

ទោះបីយ៉ាងណា អាពាហ៍ពិពាហ៍របស់អ្នកទាំងពីរមិនបានសមប្រកបឡើយ កូនទី១ ទី២ និងទី៣ បានស្លាប់ជាបន្តបន្ទាប់ដោយសារពេលបង្កើតមិនធ្វើទៅតាមក្បួនវេជ្ជសាស្ត្រ និងគ្មានថ្នាំពេទ្យព្យាបាល ចំណែកកូនទី៤ដែលមានវ័យជាង២០ឆ្នាំបានលង់ទឹកស្លាប់ពេលទៅបង់សំណាញ់នៅទន្លេស្រែពកនៅក្នុងឆ្នាំ២០០៤ ។ នៅពេលនឹកដល់កូនម្តងៗ ព្លិល រលីងរលោងទឹកភ្នែកហើយនិយាយទាំងអួលដើមកថា គាត់អស់អារម្មណ៍ពីក្នុងខ្លួនធ្វើអ្វីសឹងតែមិនកើត ។ គាត់នឹកស្មានថា គាត់ស្លាប់មុនកូនៗ ប៉ុន្តែឥឡូវបែរជាកូនៗស្លាប់មុនគាត់ទៅវិញ ។ រយៈពេលកន្លងទៅជិតពីរឆ្នាំទើបគាត់ទាំងពីរកាត់ចិត្តបាន ហើយចាប់ផ្តើមជីវភាពជាកសិករ ប្រកបមុខរបរធ្វើស្រែឡើងវិញ ចិញ្ចឹមជីវិតពីរនាក់ប្តីប្រពន្ធដែលមានវ័យកាន់តែចាស់ទៅហើយ ។ អ្នកទាំងពីរសង្ឃឹមថាផលស្រូវក្នុងឆ្នាំនេះនឹងទទួលបានផលច្រើនដែលអាចឲ្យគាត់ផ្គត់ផ្គង់ជីវិតបានគ្រប់គ្រាន់និងអាចសងបំណុលគេរួច ។

**លី សុផល**

# ការជួយជនរងគ្រោះស្វែងយល់អំពីដំណើរយុត្តិធម៌

កម្មវិធីផ្តល់ព័ត៌មានផ្លូវច្បាប់ដែលបានប្រព្រឹត្តឡើងកាលពីថ្ងៃទី២៨-២៩ ខែឧសភា គឺជាកិច្ចប្រជុំលើកទី៤ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងគោលបំណងបន្សាំប្រជាជនដែលត្រូវបានជ្រើសរើសដើម្បីចូលរួមក្នុងសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅឆ្នាំក្រោយនេះ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលត្រូវបានស្គាល់ជាទូទៅថា “សាលាក្តីខ្មែរក្រហម” បានចាប់ផ្តើមដំណើរការតាំងពីឆ្នាំ២០០៦ ហើយមានអាណត្តិបីឆ្នាំ ។ អ្នកចូលរួម (ដែលសុទ្ធតែជាអ្នករស់រានជីវិតពីរបបដ៏សាហាវព្រៃផ្សៃនេះ) នឹងជួយចែករំលែកព័ត៌មានដែលពួកគាត់ទទួលបានពីការប្រជុំនេះទៅកាន់អ្នកជិតខាងរបស់ខ្លួន បន្ទាប់ពីពួកគាត់វិលត្រឡប់ទៅកាន់លំនៅដ្ឋានវិញ ។



រូបថតអ្នកទោសដាក់តាំងនៅមន្ទីរស-២១

អ្នកភូមិ និងប្រធានភូមិ ដែលមានចំនួន ៥៨នាក់ ត្រូវបានជ្រើសរើសមកពីបណ្តាខេត្តនានាដូចជា ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង កំពង់ធំ កំពង់ចាម ក្រចេះ និងខេត្តមណ្ឌលគិរី ។ អ្នកទាំងនេះបានមកដល់ការិយាល័យព័ត៌មានសាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីព្រឹកថ្ងៃទី២៨ ដែលមានបុគ្គលិកនិងអ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលកំពុងរង់ចាំដើម្បីជួយនាំពួកគាត់ទៅកាន់កន្លែងស្នាក់នៅ ។

នៅពេលរសៀល ដោយសារមានភ្លៀងធ្លាក់ដែលជាឥទ្ធិពលនៃខ្យល់មូសុង ការធ្វើដំណើរទស្សនកិច្ចរបស់ពួកគាត់ទៅកាន់មន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ត្រូវបានពន្យារពេលរហូតដល់ភ្លៀងរាំង ។ នៅវេលាម៉ោង៣រសៀល អ្នកចូលរួមបានធ្វើដំណើរទៅកាន់សារមន្ទីរទួលស្លែង ដែលនេះជាលើកដំបូងសម្រាប់ពួកគាត់ ។

សារមន្ទីរនេះធ្លាប់ជាមន្ទីរសន្តិសុខថ្នាក់មជ្ឈិមរបស់របបខ្មែរក្រហមដែលមានឈ្មោះសម្ងាត់ថា “ស-២១” ។ យ៉ាងហោចណាស់មានអ្នកទោសប្រមាណ១៤០០០នាក់ត្រូវបានឃុំឃាំងនៅមន្ទីរស-២១នេះ ហើយអ្នកទាំងអស់នេះ(ប៉ុន្តែលើកលែងតែមួយចំនួនតូច) បានស្លាប់ក្នុងពេលទទួលរងការធ្វើទារុណកម្ម និងការសម្លាប់នៅក្នុងទីតាំងមួយដែលនៅមិនឆ្ងាយពីទីនោះ ។ ទីវាលនេះបច្ចុប្បន្នមានឈ្មោះថាជា “វាលពិឃាតបឹងជើងឯក” ។ អ្នកភូមិទាំងអស់បាននាំគ្នាទៅទស្សនាទិដ្ឋភាពជាក់ស្តែងនៃទីតាំងនេះ

បន្ទាប់ពីដំណើរទស្សនកិច្ចរបស់ពួកគាត់នៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។

ដោយមិនចាំបាច់បរិយាយ ការមកដល់ទីតាំងប្រល័យពូជសាសន៍ទាំងពីរ បានធ្វើឲ្យអ្នកភូមិនិងប្រធានភូមិនឹកឃើញដល់អតីតកាលដ៏រន្ធត់មួយដែលបានសម្លាប់មនុស្សអស់ជាច្រើន ដោយសារការបង្អត់អាហារ ការភ័យខ្លាច និងការបាត់បង់ជីវិតដ៏ច្រើនមហិមា ។ តាមការសន្និដ្ឋាន មានប្រជាពលរដ្ឋប្រមាណ ២០ភាគរយ បានស្លាប់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ហើយជនរងគ្រោះដែលបានរស់រានមានជីវិតពីរបបនេះ យ៉ាងហោចណាស់ក៏មានសមាជិកម្នាក់នៅក្នុងគ្រួសារ ឬមនុស្សជាទីស្រលាញ់របស់ខ្លួនបានស្លាប់ដែរ ។

លោក ឆាយ សី អាយុ៧៥ឆ្នាំ រស់នៅភូមិលលក-ស ក្នុងខេត្តពោធិ៍សាត់ នៅតែចងចាំពីរបៀបដែលគាត់ត្រូវបានបង្ខំឲ្យជម្លៀសទៅភូមិម្ចេចនៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច ។ ពេលចាប់ផ្តើមការជម្លៀស កម្មាភិបាលខ្មែរក្រហមបានឃោសនាថា សេរីភាពនិងប្រជាធិបតេយ្យបានចាប់កំណើតនៅក្នុងប្រទេសទើបតែរំដោះថ្មីនៅថ្ងៃទី១៧មេសា ឆ្នាំ១៩៧៥ ។ ក៏ប៉ុន្តែអ្វីៗជាក់ស្តែងផ្ទុយពីការពិតទាំងស្រុង ។ ឆាយ ត្រូវបានចាត់តាំងឲ្យកាន់នង្គ័លភ្ជួរស្រែ ។ ឆាយ ធ្វើការតាំងពីព្រលឹមរហូតពាក់កណ្តាលអធ្រាត្រ ហើយរបបអាហាររបស់គាត់មានតែដំឡូងមួយដុំតូចនិងបបររាវៗប៉ុណ្ណោះ ។ ការឈឺចាប់ធំធេងរបស់ ឆាយ គឺការបាត់បង់ប្រពន្ធនិងកូនៗ ។ ប្រពន្ធនិងកូនបីនាក់របស់ ឆាយ ត្រូវបានសម្លាប់ដោយការចោទប្រកាន់ថាជាប់ខ្សែស្រឡាយជាជនជាតិវៀតណាម ។ នៅសារមន្ទីឧក្រិដ្ឋប្រល័យពូជសាសន៍ ឆាយ បានរៀបរាប់ប្រាប់ប្រធានរៀបចំកម្មវិធីថា «ខ្ញុំនៅតែគិតអំពីរបៀបដែលអ្នកទាំងនោះត្រូវបានធ្វើបាប ទទួលទារុណកម្ម និងសម្លាប់» ។

ការទស្សនាសារមន្ទីរប្រល័យពូជសាសន៍ក៏បានធ្វើឲ្យ តាំង ធៀន អាយុ៥៣ឆ្នាំ នៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំងនឹកឃើញអំពីអតីតកាលរបស់គាត់ឡើងវិញដែរ ។ មុនពេលដែលខ្មែរក្រហមកាន់អំណាច តាំង ធៀន បួសជាសង្ឃអស់រយៈពេលបីវស្សា ។ បន្ទាប់ពីថ្ងៃជ័យជម្នះ ១៧ មេសា ១៩៧៥ តាំង ធៀន ត្រូវបានជម្លៀសឲ្យទៅរស់នៅក្នុងស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ហើយគាត់ត្រូវបង្ខំឲ្យដោះស្បង់ចីពរ ដោយសារគណៈគ្រប់គ្រងថ្មីជឿថា ព្រះសង្ឃនិងសាសនា ជាអ្នកប្រឆាំងនឹងទិសដៅរបស់ខ្លួន ។ អង្គការបានចាត់ទុកព្រះសង្ឃជាជនបញ្ញើក្អែក ។ បន្ទាប់ពីសឹក តាំង ធៀន បានទៅធ្វើការនៅកងចល័តសាងសង់ទំនប់ទឹកនិងជីកប្រឡាយអស់រយៈពេលជាច្រើនខែ ។

បន្ទាប់មក ធៀន ត្រូវបានបញ្ជូនទៅកងភ្ជួររាស់ ។ តាមការរៀបរាប់របស់ ធៀន បានឲ្យដឹងថា កងនេះបានទទួលរងនូវទុក្ខវេទនានិងស្លាប់សមាជិកអស់ជាច្រើន ។ ប្រជាជនភាគច្រើនត្រូវបានបញ្ជូនឲ្យទៅមន្ទីរពេទ្យមួយដែលមានសម្ភារបរិក្ខារមិនត្រឹមត្រូវនិងមានបុគ្គលិកពេទ្យវ័យក្មេងអាយុចាប់ពី១៥ឆ្នាំឡើងទៅបម្រើការជាគ្រូពេទ្យនិងគិលានុបដ្ឋាក ។

ដំណើរមកកាន់មន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងបាននាំមកនូវទុក្ខក្រៀមក្រំដ៏ធំធេងដល់ ធៀន ដែលគាត់ជឿថាអំពើព្រៃផ្សៃបែបនេះមិនគួរឲ្យកើតមានមកលើប្រជាជនម្តងទៀតឡើយ ។

អ្នកចូលរួមម្នាក់ទៀត លោក ឌិម សឿន អាយុ៦៣ឆ្នាំ រស់នៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង មានបានប្រសាសន៍ថា ខ្មែរក្រហមប្រមាថជីវិតមនុស្សទាបជាងសត្វធាតុទៅទៀត ដោយគាត់សំអាងលើរូបថតដ៏គួរឲ្យរន្ធត់និងអ្នកទោសជាប់ខ្នោះនិងអារបំពង់ក ។ បទពិសោធន៍របស់គាត់នៅក្នុងរបបខ្មែរក្រហមមានរួមទាំងការងារនៅក្នុងកងធ្វើស្ករត្នោត កងភ្ជួររាស់ និងការងារនៅកន្លែងផ្សេងទៀត ។ នៅកងធ្វើស្ករត្នោត សឿន និយាយថាក្នុងមួយថ្ងៃ គាត់ត្រូវរម្ងាស់ស្ករឲ្យបាន១៧ខ្ទះត្នោត ដែលទទួលស្ករ សរុបចំនួន ២០០គីឡូក្រាម ។

ប្រវត្តិសាស្ត្រដ៏មហិមានិងទុក្ខវេទនាដែលកើតឡើងនៅក្នុងមន្ទីរស-២១ និងស្មោមុខកាំបិតនៃវាលពិឃាតជើងឯកបានបង្ហាញយ៉ាងច្បាស់និងមិនអាចបំភ្លេចបាន សម្រាប់អ្នករស់រានមានជីវិតពីរបបនោះ ។ អ្នកចូលរួមដែលមិនធ្លាប់បានឆ្លងកាត់សោកនាដកម្មក្រោយថ្ងៃ១៧មេសា មានការតក់ស្លុត និងស្រឡាំងកាំង ។ គ្មាននរណាម្នាក់គិតថា ប្រទេសកម្ពុជាធ្លាប់ឆ្លងកាត់អំពើប្រល័យពូជសាសន៍នេះបែបទេ ។ សម្រាប់ជនរងគ្រោះ

អារម្មណ៍ឈឺចាប់របស់ពួកគាត់មិនអាចសម្តែងចេញមកតាមពាក្យសម្តីទេ ពីព្រោះថា ប្រវត្តិសាស្ត្រនិងទុក្ខវេទនារបស់កម្ពុជាគឺរឿងឈឺចាប់និងជាប្រវត្តិផ្ទាល់ខ្លួនរបស់ពួកគាត់ម្នាក់ៗ ។ នេះជាប្រភេទនៃអតីតកាលដែលទាមទារនូវការរកយុត្តិធម៌ និងមិនអាចទុកចោលដោយសម្ងាត់ក្រោយជញ្ជាំងមន្ទីរស-២១ ឬកប់ទុកនៅក្នុងវាលពិឃាតនោះទេ ។ តុលាការខ្មែរក្រហមកំពុងដោះស្រាយអតីតកាលនេះ និងផ្តល់យុត្តិធម៌មួយដែលមិនគួរទុកឲ្យហួសពេលឡើយ ។

ផ្នែកនៃដំណើរការផ្តល់យុត្តិធម៌គឺជាការជួយជនរងគ្រោះឲ្យស្វែងយល់អំពី«យុត្តិធម៌» ប្រភេទណាដែលយើងចង់បាន និងសម្រាប់បទឧក្រិដ្ឋអ្វីខ្លះ ។ ច្បាប់កំណត់ថា នឹងកាត់ទោសតែ«មេដឹកនាំជាន់ខ្ពស់និងអ្នកទទួលខុសត្រូវខ្ពស់បំផុត»ប៉ុណ្ណោះ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងប្រើប្រាស់ច្បាប់ក្នុងស្រុក (តាមប្រព័ន្ធច្បាប់ស៊ីវិលរបស់បារាំង) និងច្បាប់អន្តរជាតិ (ដើម្បីបំពេញបន្ថែមនូវចន្លោះខ្វះខាតរបស់ច្បាប់ក្នុងស្រុក) ។ បញ្ហាស្មុគស្មាញជាច្រើនរបស់តុលាការនេះគឺជាឧបសគ្គមួយសម្រាប់ប្រជាជនកម្ពុជា ។ កិច្ចប្រជុំព័ត៌មានរំពឹងថា នឹងកាត់បន្ថយឧបសគ្គនេះ និងផ្តល់នូវចំណេះដឹងជាទូទៅមួយថាតើតុលាការនិងសវនាការនឹងដំណើរការទៅយ៉ាងដូចម្តេច?

នៅវេលាព្រឹកថ្ងៃទី២៩ អ្នកចូលរួមទាំងអស់បានទស្សនាខ្សែភាពយន្តឯកសារមួយដែលមានចំណងជើងថា «នៅក្បែរជញ្ជាំងនៃមន្ទីរស-២១» មានរយៈពេល៣០នាទី ។ ខ្សែភាពយន្តនេះបានផ្តល់នូវការណែនាំដ៏ល្អចំពោះបញ្ហាដែលនឹងត្រូវដោះស្រាយនៅក្នុងបន្ទប់សវនាការ ដូចជារឿងរ៉ាវរបស់ជនរងគ្រោះប្រឆាំងនឹងជនដៃដល់ ។ បន្ទាប់ពីការបញ្ចាំងខ្សែភាពយន្តនេះ ឯកឧត្តម ម៉ោញ សាផាន សមាជិកសភាដែលបានចូលរួមក្នុងដំណើរការអនុម័តច្បាប់សាលាក្តីខ្មែរក្រហម បានលើកឡើងនូវចំណុចព័ត៌មានចំៗស្តីអំពីច្បាប់ខ្មែរក្រហម ។ ឯកឧត្តមបានសង្កត់ធ្ងន់លើចំណុចសំខាន់ពីរ ៖ ទី១ គឺ«មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុត»ដែលនឹងត្រូវនាំយកមកកាត់ទោសចំពោះបទឧក្រិដ្ឋទាំងឡាយណាដែលបានប្រព្រឹត្តនៅក្នុងអំឡុងថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ៦មករា ឆ្នាំ១៩៧៩ ។ ទី២) ប្រព័ន្ធតុលាការនៅក្នុងសាលាក្តីនេះមានពីរថ្នាក់ គឺតុលាការដំបូងនិងតុលាការកំពូល ។ ឯកឧត្តម ក៏បានលើកឡើងនូវចំណុចសំខាន់ៗផ្សេងទៀតមកនិយាយដែររួមបញ្ចូលទាំងគោលការណ៍នៃ «មតិភាគច្រើន»ក្នុងការសម្រេចចិត្តរួមគ្នានៅក្នុងដំណើរការក្តីផងដែរ ។

នៅវេលាម៉ោង១០ព្រឹក សហចៅក្រមស៊ើបអង្កេតទាំងពីរ គឺលោក យូ ប៊ុនឡេង និងលោក មីសែល ឡឺម៉ុង បានចំណាយពេលវេលារបស់ខ្លួនដើម្បីពន្យល់ពីដំណើរការតុលាការដល់អ្នកចូលរួមទាំងអស់ ។ បន្ថែមពីនេះទៀត អ្នកទាំងពីរបានសម្តែងនូវ«សុទិដ្ឋិនិយម» អំពីវិធានផ្ទៃក្នុងដែលនឹងត្រូវអនុម័តនៅក្នុងសម័យប្រជុំពេញអង្គដែលត្រូវប្រារព្ធធ្វើពីថ្ងៃទី៣១ ខែឧសភា ដល់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៧ ។

បន្ទាប់ពីការណែនាំនេះ ប្រធានភូមិនិងអ្នកភូមិបានចោទសួរសំណួរជាច្រើន ។ សំណួរដែលសួរទៅឯកឧត្តម ម៉ោញ សាផាន រួមមាន ៖ ហេតុអ្វីចាំបាច់មានចៅក្រមបរទេសមកធ្វើការជាមួយចៅក្រមកម្ពុជា? ហេតុអ្វីតុលាការខ្មែរក្រហមពន្យារពេលយូរម្ល៉េះ? ហេតុអ្វីបទឧក្រិដ្ឋនៅក្នុងច្បាប់តុលាការខ្មែរក្រហមកំណត់យកតែអំឡុងពេលពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩? តើមានសំណងបែបណាដែលជនរងគ្រោះនឹងទទួលបានបន្ទាប់ពីការកាត់សេចក្តីនេះ? សហចៅក្រមស៊ើបអង្កេតទាំងពីរក៏បានឆ្លើយនូវសំណួរអំពីបញ្ហានៃការប្រើប្រាស់រណ្តៅសាកសពដែលបច្ចុប្បន្នប្រែក្លាយជាវាលស្រែជាភស្តុតាងនៅក្នុងតុលាការ, ចំនួនបុគ្គលដែលនឹងត្រូវចោទប្រកាន់និងបញ្ហានៃការលើកលែងទោស ។

អ្នកចូលរួមមួយចំនួនក៏បានងើបឡើងនិងផ្តល់ជាយោបល់បន្ទាប់ពីវគ្គសំណួរចម្លើយដែរ ។ ក្នុងភាពថ្ងៃថ្នូរ លោក ឆាយ បាននិយាយថា «ខ្ញុំមិនអាចរកពាក្យអ្វីដែលអាចបញ្ជាក់ពីសកម្មភាពគួរឲ្យស្អប់ខ្ពើមដែលរបបខ្មែរក្រហមបានប្រព្រឹត្តនោះទេ ។ ខ្ញុំរង់ចាំយូរមកហើយថាតើពេលណាសវនាការសាលាក្តីខ្មែរក្រហមនឹងត្រូវបង្កើតឡើង ។ តើនៅតែមានការពន្យារពេលបែបហ្នឹងទៀតឬក្នុងខណៈដែលមានមនុស្សស្លាប់ច្រើនយ៉ាងហ្នឹងហើយនោះ? លោក ឆាយ បានបន្តថា ទោះបីជាគាត់មិនពេញចិត្តចំពោះយុត្តិធម៌ដែលសាលាក្តីខ្មែរក្រហមរកឲ្យគាត់ ដោយសារគាត់បានបាត់បង់ប្រពន្ធនិងកូនៗនៅក្នុងរបបខ្មែរក្រហមក៏ដោយ ក៏គាត់

នៅតែជឿជាក់ថា ការកាត់ទោសមេដឹកនាំខ្មែរក្រហមជារឿងមួយល្អ ។ ឆាយ ក៏បានសម្តែងនូវចំណាប់អារម្មណ៍ ក្នុងការចូលរួមស្តាប់នៅក្នុងសវនាការនៅថ្ងៃដំបូងដែរ ។

ស្ត្រីម្នាក់បានងើបឈរហើយរៀបរាប់ប្រាប់សហចៅក្រមស៊ើបអង្កេតទាំងពីរអំពីរឿងរ៉ាវផ្ទាល់ខ្លួនរបស់គាត់ ។ សាច់ញាតិជាច្រើនរបស់គាត់ត្រូវខ្មែរក្រហមសម្លាប់ដោយសារពួកគាត់ត្រូវបានសម្គាល់ថាជានាយទុន ។ ស្ត្រីរូបនោះនិយាយថា ពួកគាត់គ្រាន់តែជាកូនខ្មែរកាត់ចិនប៉ុណ្ណោះ ។ ស្ត្រីម្នាក់នេះបានឲ្យដឹងផងដែរថាគាត់មកកាន់មន្ទីរខក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដើម្បីស្វែងរកឲ្យឃើញរូបថតបងប្រុសរបស់គាត់ដែលបានបាត់ខ្លួន ហើយគាត់ជឿជាក់ថាបងប្រុសរបស់គាត់ត្រូវបានសម្លាប់ ។ ក៏ប៉ុន្តែគាត់រកមិនឃើញរូបថតបងប្រុសរបស់គាត់ឡើយ ។ ជាចុងក្រោយ មីងបានសម្តែងនូវក្តីសោមនស្សរីករាយក្នុងការមានសាលាក្តីនេះ ។ រឿងសំខាន់មួយទៀតដែលកើតមាននៅក្នុងដំណើរទស្សនកិច្ចនេះ គឺការបង្ហាញនូវការគ្រប់គ្រង ការឈឺចាប់ ខ្វិងសម្បា និងភាពសោកសៅ ។

ការដោះស្រាយ ការបាត់បង់ និងទុក្ខព្រួយ ពិសេសទំហំនៃអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា គឺជាដំណើរការដ៏លំបាកមួយ និងងាយទទួលរងនូវការប្រេះស្រាំ ។ លោក ត្រាង បានស្នើថា ការសងសឹក គឺជាជម្រើសមិនត្រឹមត្រូវ ពីព្រោះយោងតាមធម៌ព្រះពុទ្ធបានសម្តែងថា «ពៀររំងាប់ដោយការមិនចងពៀរ» ការសងសឹកវិលវល់គ្មានទីបញ្ចប់ទេ ដូច្នេះ គំនុំគុំកួននឹងមិនមានពេលបញ្ចប់ដែរ ។ នៅពេលសួរអំពីថាតើវិធីអ្វីដែលអាចយកមកប្រើដើម្បីកាត់បន្ថយការឈឺចាប់នេះ លោក ឌិម បាន ឆ្លើយថារដ្ឋាភិបាលគួរតែសាងសង់បូជនីយដ្ឋានមួយ ។ បូជនីយដ្ឋានគួរតែផ្តល់តាមតំបន់ណាមួយសម្រាប់ឲ្យព្រលឹងអ្នកស្លាប់ជួបជុំគ្នា និងអាចផ្តល់ជាកន្លែងមួយសម្រាប់អ្នករស់រានមានជីវិតចងចាំមនុស្សជាទីស្រឡាញ់និងអតីតកាលរបស់ខ្លួន ។ យោងតាមសម្តីរបស់លោក ឌិម បានឲ្យដឹងទៀតថា តាមរយៈបូជនីយដ្ឋានក៏អាចបង្ហាញឲ្យឃើញការយកចិត្តទុកដាក់របស់រដ្ឋាភិបាលចំពោះជនរងគ្រោះដែលបានស្លាប់ទៅដែរ ។

ចុងបញ្ចប់នៃការប្រជុំ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានចែកទស្សនាវដ្តី«ស្វែងរកការពិត» សៀវភៅណែនាំរបស់តុលាការ និងសៀវភៅណែនាំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដល់អ្នកចូលរួមទាំងអស់ ។ បន្ទាប់ពីទទួលបានចំណេះដឹងជាមូលដ្ឋានពីតុលាការខ្មែរក្រហមដែលទាក់ទងនឹងទម្រង់ និងរបៀបដែលតុលាការនេះកំពុងបំពេញការងារ អ្នកចូលរួមទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យចូលរួមផ្សព្វផ្សាយព័ត៌មានដែលគាត់ទទួលបានទៅឲ្យអ្នកភូមិផ្សេងទៀត នៅក្នុងសហគមន៍របស់ខ្លួន និងរៀបចំឲ្យមានការពិភាក្សាគ្នាអំពីហេតុការណ៍ដែលបានលើកឡើងនៅក្នុងអំឡុងពេលសំណេះសំណាលគ្នា ។ ប្រជាជនដែលបានជ្រើសរើសលើកនេះ និងដែលអ្នកបានចូលរួមនៅកិច្ចប្រជុំកាលពីលើកមុននឹងវិលត្រឡប់មកទីក្រុងភ្នំពេញម្តងទៀត ដើម្បីចូលរួមស្តាប់សវនាការកាត់សេចក្តីដែលគេរំពឹងថានឹងធ្វើឡើងនៅចុងឆ្នាំ២០០៧នេះ ។ **លី សុខឃាង និង កែវ ជាស៊ីល**


ប្រជាជនកំពុងទស្សនាផែនទី និងរចនាសម្ព័ន្ធរបស់ខ្មែរក្រហម នៅវាលពិឃាតជើងឯក

# ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)


ឌី ខាំបូលី (អ្នកនិពន្ធ)

## ជំពូកទី១
## សេចក្តីសង្ខេប

«ខ្មែរក្រហម» គឺជាឈ្មោះដែលសម្តេចព្រះនរោត្តម សីហនុ មានព្រះរាជបន្ទូលសំដៅទៅលើក្រុមកុម្មុយនីស្តដែលប្រឆាំងនឹងព្រះអង្គនៅទសវត្សរ៍ឆ្នាំ ១៩៦០ ។ ឈ្មោះផ្លូវការរបស់ក្រុមនេះគឺបក្សកុម្មុយនីស្តកម្ពុជាដែលចូលកាន់កាប់ប្រទេសកម្ពុជានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតរដ្ឋកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៧៦ និងគ្រប់គ្រងប្រទេសរហូតដល់ខែមករា ឆ្នាំ ១៩៧៩ ។ វត្តមានរបស់បក្សត្រូវបានរក្សាជាការសម្ងាត់រហូតដល់ឆ្នាំ១៩៧៧ ហើយមិនមានអ្នកណាម្នាក់នៅក្រៅបក្សកុម្មុយនីស្តកម្ពុជាដឹងថា អ្នកណាជាអ្នកដឹកនាំបក្សនោះទេ (មេដឹកនាំបក្សទាំងនោះបានហៅខ្លួនឯងថា «អង្គការបដិវត្តន៍») ។

ពីរបីថ្ងៃបន្ទាប់ពីការឡើងកាន់កាប់អំណាចនៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានបង្ខំប្រជាជននៅទីក្រុងភ្នំពេញទាំងអស់ ប្រហែលពីរលាននាក់និងទីប្រជុំជនផ្សេងៗទៀត ឲ្យចេញទៅតំបន់ជនបទ ដើម្បីធ្វើការងារស្រែចម្ការ ។ ប្រជាជនរាប់ពាន់នាក់បានស្លាប់នៅក្នុងអំឡុងពេលជម្លៀសនេះ ។

ក្នុងពេលនោះដែរ ខ្មែរក្រហមបានចាប់ផ្តើមអនុវត្តកម្មវិធីកែទម្រង់របស់ខ្លួនតាមលទ្ធិម៉ៅនិងលទ្ធិម៉ាក្សលេនីនដ៏ជ្រុលហួសហេតុ ។ ខ្មែរក្រហមចង់ប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជាសង្គមជនបទមួយដែលមិនមានវណ្ណៈសង្គម ពោលគឺពុំមានអ្នកមាន ពុំមានអ្នកក្រ និងគ្មានការកេងប្រវ័ញ្ច ។ ដើម្បីសម្រេចឲ្យបាននូវគោលបំណងនេះ ខ្មែរក្រហមបានលុបបំបាត់រូបិយវត្ថុ ផ្សារផ្សេង ការអប់រំ ទ្រព្យសម្បត្តិឯកជន ម៉ូតសម្លៀកបំពាក់ស៊ីវិល័យពីបរទេស ការគោរពជំនឿសាសនា និងប្រពៃណីវប្បធម៌ខ្មែរ ។ សាលារៀនវត្តអារាម វិហារសាសនាអ៊ីស្លាម វិហារសាសនាគ្រិស្ត សាកលវិទ្យាល័យ ហាងលក់ទំនិញ និងអគាររដ្ឋាភិបាល ត្រូវបិទទ្វារ ឬក៏ប្រែក្លាយទៅជាគុក ក្រោលគោ ជំរំអប់រំកែប្រែ និងជង្រុកស្រូវ ។ ក្នុងសង្គមនេះគ្មានមធ្យោបាយដឹកជញ្ជូនឯកជន ឬសាធារណៈ គ្មានទ្រព្យសម្បត្តិឯកជន និងគ្មានសិល្បៈកម្សាន្តណាដែលមិនមានលក្ខណៈបដិវត្តន៍ទេ ហើយការលម្ហែកម្សាន្ត ត្រូវអង្គការហាមឃាត់យ៉ាងតឹងរ៉ឹងបំផុត ។ ប្រជាជននៅទូទាំងប្រទេស រួមទាំងថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផង ត្រូវបានតម្រូវឲ្យស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ ដែលជាសម្លៀកបំពាក់ប្រពៃណីបដិវត្តន៍


យោធាខ្មែរក្រហមកំពុងផឹកទឹកដូង

របស់ខ្លួន ។

នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ មនុស្សគ្រប់រូបត្រូវបានដកហូតអស់នូវសិទ្ធិជាមូលដ្ឋានរបស់ខ្លួន ។ ប្រជាជនទាំងអស់មិនត្រូវបានអនុញ្ញាតឲ្យដើរចេញក្រៅសហករណ៍របស់ខ្លួនទេ ។ ខ្មែរក្រហមមិនអនុញ្ញាតឲ្យប្រជាជនប្រមូលផ្តុំនិងពិភាក្សាគ្នាឡើយ ។ ប្រសិនបើមនុស្សបីនាក់ផ្តុំគ្នាហើយនិយាយគ្នាលេង អ្នកទាំងនោះអាចត្រូវបានចោទប្រកាន់ថាជាខ្មាំងហើយអាចត្រូវចាប់ខ្លួន ឬយកទៅសម្លាប់ចោល ។

ទំនាក់ទំនងក្នុងគ្រួសារក៏ត្រូវទទួលរងការរិះគន់យ៉ាងខ្លាំងក្លាដែរ ។ ប្រជាជនគ្រប់រូបត្រូវអង្គការហាមឃាត់មិនឲ្យសម្តែងចេញនូវសេចក្តីស្រលាញ់ សប្បាយរីករាយ ឬអាណិតអាសូរ សូម្បីតែបន្តិចបន្តួចក៏ដោយ ។ ខ្មែរក្រហមបានបង្គាប់បញ្ជាឲ្យប្រជាជនខ្មែរគ្រប់រូបជឿ ធ្វើតាម និងគោរពអង្គការបដិវត្តន៍តែមួយគត់ ដែលខ្មែរក្រហមអះអាងថា គឺជា«ឪពុកម្តាយ»របស់ប្រជាជនគ្រប់រូប ។

ខ្មែរក្រហមបានអះអាងថា មានតែមនុស្សស្អាតស្អំប៉ុណ្ណោះទើបមានគុណសម្បត្តិគ្រប់គ្រាន់ក្នុងការកសាងបដិវត្តន៍ ។ បន្ទាប់ពីដណ្តើមបានអំណាចភ្លាម ខ្មែរក្រហមបានធ្វើការចាប់ខ្លួន និងសម្លាប់ចោលនូវពលទាហាន នាយទាហាន និងអ្នករដ្ឋការរបស់របបសាធារណរដ្ឋខ្មែរដឹកនាំដោយលោកសេនាប្រមុខ លន់ នល់ ដែលខ្លួនចាត់ទុកថាមិនស្អាតស្អំអស់រាប់ពាន់នាក់ ។ ក្នុងរយៈកាលជាងបីឆ្នាំបន្ទាប់មកទៀត ក្រុមខ្មែរក្រហមបានធ្វើការកាប់សម្លាប់បញ្ញវន្ត អ្នករស់នៅទីក្រុង ជនជាតិភាគតិច ដូចជាជនជាតិ ចាម វៀតណាម និងចិន អស់រាប់សែននាក់ ។ ខ្មែរក្រហមក៏បានសម្លាប់យោធានិងសមាជិកបក្សរបស់ខ្លួនអស់ជាច្រើននាក់ដែរ ដោយចោទថាជនក្បត់ជាតិនិងក្បត់បដិវត្តន៍ ។

នៅក្នុងគម្រោងឆ្នាំ១៩៧៦នៃផែនការបួនឆ្នាំរបស់បក្សកុម្មុយនីស្តកម្ពុជា ប្រជាជនកម្ពុជានៅទូទាំងប្រទេសត្រូវបានដាក់កម្រិតឲ្យធ្វើការបង្កបង្កើនផលឲ្យបានបីតោនក្នុងមួយហិកតា ។ នេះមានន័យថា ប្រជាជនត្រូវធ្វើការដាំដុះ និងប្រមូលកាត់ស្រូវដប់ពីរខែក្នុងមួយឆ្នាំ ។ នៅតាមតំបន់ភាគច្រើន ខ្មែរក្រហមបានបង្ខំឲ្យប្រជាជនធ្វើការលើសពីដប់ពីរម៉ោងក្នុងមួយថ្ងៃ ដោយមិនមានពេលសម្រាកនិងម្ហូបអាហារគ្រប់គ្រាន់ ។

រហូតមកដល់ចុងឆ្នាំ១៩៧៧ ការប៉ះទង្គិចជាមួយប្រទេសវៀតណាមបានផ្ទុះឡើង ។ ប្រជាជនរាប់ម៉ឺននាក់ត្រូវអង្គការបញ្ជូនទៅសមរភូមិហើយត្រូវស្លាប់រាប់ពាន់នាក់ ។

នៅក្នុងខែធ្នូ ឆ្នាំ១៩៧៨ កងទ័ពវៀតណាមនិងកងកម្លាំងរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានធ្វើការវាយសម្រុកចូលប្រទេសកម្ពុជា ហើយដណ្តើមកាន់កាប់បាន ទីក្រុងភ្នំពេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

នៅពេលនោះ មេដឹកនាំខ្មែរក្រហមបានភៀសខ្លួនទៅភាគខាងលិចប្រទេស ហើយបានរៀបចំបង្កើតកងកម្លាំងរបស់ខ្លួនឡើងវិញនៅក្នុងទឹកដីថៃ ដោយមានជំនួយពីប្រទេសចិននិងថៃ ។ មហាសន្និបាតអង្គការសហប្រជាជាតិបានបោះឆ្នោតផ្តល់អាសនៈនៅអង្គការសហប្រជាជាតិឲ្យទៅក្រុមអ្នកតស៊ូប្រឆាំងនឹងកុម្មុយនីស្ត ដែលមានខ្មែរក្រហមនៅក្នុងនោះដែរ ។ ពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៩០ អង្គការសហប្រជាជាតិបានទទួលស្គាល់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យថាជាតំណាងស្របច្បាប់តែមួយគត់របស់កម្ពុជា ។

នៅឆ្នាំ១៩៨២ ខ្មែរក្រហមបានចងសម្ព័ន្ធភាពជាមួយសម្តេចព្រះនរោត្តម សីហនុ និងមេដឹកនាំមិនមែនកុម្មុយនីស្ត សឺន សាន ដើម្បីបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគី ។ នៅភ្នំពេញឯណេះវិញ វៀតណាមបានជួយបង្កើតរដ្ឋាភិបាលថ្មីមួយគឺ "សាធារណរដ្ឋប្រជាមានិតកម្ពុជា" ដែលដឹកនាំដោយសមមិត្ត ហេង សំរិន ។

ខ្មែរក្រហមបានបន្តនិរន្តរភាពរបស់ខ្លួនរហូតដល់ឆ្នាំ១៩៩៩ គឺនៅពេលដែលមេដឹកនាំខ្មែរក្រហមទាំងអស់ចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ឬត្រូវចាប់ខ្លួន ឬទទួលមរណភាព ។ ប៉ុន្តែរបបខ្មែរក្រហមបានបន្សល់ទុកនូវភាពប្រេះស្រាំ ក្នុងសង្គមជាតិរហូតដល់សព្វថ្ងៃនេះ ។ នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យប្រជាជនខ្មែរប្រមាណពីរលាននាក់បានស្លាប់ ដោយសារជំងឺ ដែលបណ្តាលមកពីការខ្វះខាតថ្នាំសង្កូវ និងសេវាសុខាភិបាល ការអត់អាហារ ការសម្លាប់ ឬការធ្វើពលកម្មហួសកម្លាំង ។ អ្នកដែលធ្លាប់រស់នៅឆ្លងកាត់របបនេះបានទទួលរងនូវការប៉ះទង្គិចខាងផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ដោយសារតែបទពិសោធន៍ដែលខ្លួនបានជួបប្រទះ ។

# ជំពូកទី២
# តើខ្មែរក្រហមជាអ្នកណា?
# តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា?

## ១) ចលនាកុម្មុយនីស្តដំបូងបំផុត

ចលនាកុម្មុយនីស្ត នៅកម្ពុជាកើតចេញពីចលនាតស៊ូប្រឆាំងនឹងអាណានិគមបារាំង ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៤០ ។ នៅខែមេសា ឆ្នាំ១៩៥០ គឺក្នុងអំឡុងពេលនៃសង្គ្រាមឥណ្ឌូចិនលើកទីមួយ គណៈប្រតិភូចំនួនពីររយនាក់ បានមកជួបជុំគ្នានៅខេត្តកំពត ហើយបានបង្កើតរណសិរ្សឯកភាពឥស្សរៈ (ខ្មែរឥស្សរៈ) ដែលដឹកនាំដោយក្រុមកុម្មុយនីស្ត ។ ក្រុមនេះសហការជាមួយវៀត-ណាមដើម្បីធ្វើការតស៊ូប្រឆាំងនឹងអាណានិគមបារាំង ។

រណសិរ្សនេះដឹកនាំដោយ សឺង ង៉ុកមិញ (អាចារ្យមៀន) ដែលជាអាចារ្យនៅវត្តខណ្ឌលោម ។ ចាន់ សម័យ មាននាទីជាអនុប្រធានរណសិរ្ស និង ស៊ីវ ហេង ជាលេខាធិការ ។ សមាជិករណសិរ្សស្ទើរតែទាំងអស់ គឺជាជនជាតិខ្មែរដែលចេះ និយាយភាសាវៀតណាម ។ សមាជិកមួយចំនួនរបស់រណសិរ្ស បានក្លាយជាសមាជិកបក្សកុម្មុយនីស្តឥណ្ឌូចិន បង្កើតឡើងនៅវៀតណាម ។ សមាជិកថ្មីនៃរណសិរ្សភាគច្រើនជាកសិករដែលត្រូវបានអូសទាញដើម្បីបុព្វហេតុបដិវត្តន៍ ។ សមាជិកផ្សេងៗទៀតជាក្រុមនិស្សិតអ្នកជាតិនិយមដែលបានក្លាយទៅជាជនកុម្មុយនីស្តក្នុងពេលស្នាក់អាស្រ័យរៀនសូត្រនៅបរទេស ។

និស្សិតមួយចំនួនក្នុងចំណោមនិស្សិតទាំងនេះ ក្រោយមកបានក្លាយទៅជាមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ។ អ្នកទាំងនេះរួមមាន សាឡុត ស (ប៉ុល ពត), សុន សេន, ខៀវ សំផន, និង អៀង សារី ។ ជនទាំងនេះយល់ឃើញថា កសិករនិងប្រជាជនក្រីក្រនៅទូទាំងពិភពលោកត្រូវបានប្រែក្លាយទៅជាទាសករនិងត្រូវជិះជាន់សង្កត់សង្កិនដោយពួកមូលធននិយមនិងពួកសក្តិភូមិនិយម ហើយថាបដិវត្តន៍តាមបែបម៉ាក្សលេនីន គឺជាផ្លូវតែមួយគត់ដែលកម្ពុជាអាចទទួលបាននូវឯករាជភាពនិងភាពស្មើគ្នានៅក្នុងសង្គម ។

## ២) ការបង្កើតបក្សប្រជាជនបដិវត្តន៍ខ្មែរ

នៅឆ្នាំ១៩៥១ នៅពេលការវាយប្រយុទ្ធប្រឆាំងនឹងបារាំងកាន់តែមានសភាពខ្លាំងក្លាឡើងនៅក្នុងឧបទ្វីបឥណ្ឌូចិន ជនកុម្មុយនីស្តវៀតណាមបានផ្តួចផ្តើមឲ្យមានការបង្កើតឡើងនូវបក្សប្រជាជនបដិវត្តន៍ ខ្មែរ ។ សមា-ជិករបស់គណៈ កម្មាធិការ មជ្ឈិមបក្សសម្ងាត់នេះរួម មាន ÷

- ◆ សឺង ង៉ុកមិញ កាន់តំណែងកំពូល
- ◆ ស៊ីវ ហេង ទទួលបន្ទុកកិច្ចការកងទ័ព
- ◆ ទូ សាមុត (ត្រូវបានស្គាល់ថាជាអាចារ្យ សុខ មកពីកម្ពុជាក្រោម) ទទួលបន្ទុកអប់រំមនោគមវិជ្ជា
- ◆ ចាន់ សម័យ ទទួលបន្ទុកផ្នែកសេដ្ឋកិច្ច

នៅពេលដែលសង្គ្រាមឥណ្ឌូ ចិនលើកទីមួយត្រូវបញ្ចប់នៅឆ្នាំ១៩៥៤ កងទ័ពរបស់បារាំងបានដកចេញពីឥណ្ឌូចិន ហើយកងកម្លាំងរបស់វៀតមិញក៏ដកចេញពីកម្ពុជាដែរ ។ ទោះជាយ៉ាងណាក៏ដោយ ក៏សមាជិកកងទ័ពវៀតណាមមួយចំនួនបន្តស្នាក់នៅកម្ពុជាតទៅទៀត ។ ដោយមានការបារម្ភពីសុវត្ថិភាពបដិវត្តន៍នៅពេលដែលប្រព័ន្ធនយោបាយមានការផ្លាស់ប្តូរ ស៊ីវ ហេង ចាន់ សម័យ កម្មាភិបាល និងសកម្មជនបក្សប្រជាជនបដិវត្តន៍ខ្មែរជាងមួយពាន់នាក់ទៀតបានភៀសខ្លួនទៅវៀតណាមខាងជើងដែលនៅទីនោះអ្នកទាំងនេះបានចូលរួមជាមួយ សឺង ង៉ុកមិញ និងសកម្មជនដទៃទៀតដែលភៀសខ្លួនទៅដល់ទីនោះមុនបន្តិច ។

មិនយូរប៉ុន្មាន ស៊ីវ ហេង បានវិលត្រឡប់មកកម្ពុជាវិញ អមដំណើរដោយ នួន ជា (សមាជិកបក្សកុម្មុយនីស្តឥណ្ឌូចិន ដែលបានទៅហ្វឹកហ្វឺននៅប្រទេសថៃនិងវៀតណាម) និងកម្មាភិបាលជាន់ខ្ពស់ផ្សេងទៀត ។ ដោយសារមេបក្ស សឺង ង៉ុកមិញ ស្នាក់នៅនិរទេសខ្លួនឯងទីក្រុងហាណូយ បក្សប្រជាជនបដិវត្តន៍ខ្មែរត្រូវបានដឹកនាំដោយគណៈកម្មាធិការមជ្ឈិមបណ្តោះអាសន្នមួយដែលមាន ស៊ីវ ហេង ជាលេខា និង ទូ សាមុត ជា អនុលេខា ។ នួន ជា មានឋានៈលំដាប់ទីបី ។ សោ ភឹម (ដែល ជាលេខាភូមិភាគបូព៌ាក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ) ជាសមាជិកលំដាប់ទីបួន ។ ការគ្រប់គ្រងទូទៅ នៅក្នុងបក្សស្ថិតក្នុងដៃកម្មាភិបាលវៀតណាម ដាំ វ៉ាន់បា ដែលធ្លាប់រស់នៅក្នុងប្រទេសកម្ពុជា ហើយដែលបានអះអាងថា វៀតណាមគួរបន្តគ្រប់គ្រងលើចលនាកុម្មុយនីស្តនៅកម្ពុជាតទៅទៀត ។

ទូ សាមុត ទទួលខុសត្រូវលើសកម្មភាពការងាររបស់បក្ស

នៅទីក្រុងដោយមានជំនួយពី នួន ជា និង សាឡុតស (ក្រោយមកត្រូវបានស្គាល់ថា ប៉ុល ពត) ដែលទើបតែត្រឡប់មកពីសិក្សានៅប្រទេសបារាំង ។ ក្រុមកុម្មុយនីស្តនៅភ្នំពេញបានប្រើប្រាស់ ប៉ុល ពត ជាអ្នកទាក់ទងក្នុងការបង្កើតគណបក្សស្របច្បាប់មួយហៅ "បក្សប្រជាជន" ។ គណបក្សនេះបានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជាតិឆ្នាំ១៩៥៥ស្របតាមសេចក្តីសម្រេចនៃកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ។ គណបក្សនេះដឹកនាំដោយ កែ មាស ដែលជាមនុស្សស្ថិតនៅក្រោមការបង្គាប់បញ្ជារបស់ ទូ សាមុត ។

ប៉ុល ពត បានជួយបង្កើតលក្ខន្តិកៈនិងកម្មវិធីនយោបាយរបស់បក្ស ។ ប៉ុល ពត ក៏បានធ្វើទំនាក់ទំនងជាមួយគណបក្សប្រជាធិបតេយ្យ ដែលនឹងចូលរួមប្រកួតប្រជែងជាមួយគណបក្សសង្គមរាស្ត្រនិយមទើបបង្កើតថ្មីរបស់សម្តេច ព្រះនរោត្តម សីហនុ ក្នុងការបោះឆ្នោតឆ្នាំ១៩៥៥ដែរ ។ ប៉ុល ពត ជឿជាក់ថាគណបក្សប្រជាធិបតេយ្យដែលមាននិន្នាការប្រឆាំងនឹងពួកសក្តិភូមិ និងពួកមូលធននិយមនោះនឹងឈ្នះនៅក្នុងការបោះឆ្នោតនេះ ហើយនឹងផ្តល់ឥទ្ធិពលនយោបាយខ្លះមកឲ្យក្រុមកុម្មុយនីស្តកម្ពុជា ។

ទោះជាយ៉ាងនេះក្តី ប៉ុល ពត បានធ្វើការព្យាករណ៍ខុសទាំងស្រុង ។ គណបក្សសង្គមរាស្ត្រនិយមបានឈ្នះកៅអីទាំងអស់នៅក្នុងរដ្ឋសភាជាតិ ចំណែកបក្សប្រជាជនទទួលសំឡេងឆ្នោតតែបីភាគរយប៉ុណ្ណោះ ។ ភ្លាមៗនោះ ស៊ីវ ហេង ជឿជាក់ថា បុព្វហេតុរបស់ក្រុមកុម្មុយនីស្ត នៅកម្ពុជាស្ថិតក្នុងភាពអស់សង្ឃឹម ព្រោះថាប្រជាជនស្ទើរតែទាំងអស់បានគាំទ្រកម្មវិធីនយោបាយរបស់សម្តេច ព្រះនរោត្តម សីហនុ ជាងគំនិតធ្វើបដិវត្តន៍ ។ ជាងនេះទៅទៀត ចលនារបស់ខ្មែរឥស្សរៈមួយចំនួនបានបោះបង់ចោលការតស៊ូរបស់ខ្លួន ហើយចុះចូលជាមួយរាជរដ្ឋាភិបាលរបស់សម្តេច ព្រះនរោត្តម សីហនុ ។ នៅឆ្នាំ ១៩៥៦ ស៊ីវ ហេង បានធ្វើការទាក់ទងជាសម្ងាត់ជាមួយ ឧត្តមសេនីយ៍ លន់ នល់ ដែលជាអគ្គ-បញ្ជាការកងទ័ពរបស់សម្តេច ព្រះនរោត្តម សីហនុ ហើយដែលបានផ្តល់ជូន ស៊ីវ ហេង នូវការធានាសន្តិសុខសុវត្ថិភាពផ្ទាល់ខ្លួន ។ នៅឆ្នាំ១៩៥៩ ស៊ីវ ហេង បានចុះចូលជាមួយរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយមរបស់សម្តេច ព្រះនរោត្តម សីហនុ ដែលធ្វើឲ្យអាជ្ញាធររដ្ឋាភិបាលមានលទ្ធភាពចង្អុលនិងចាប់ខ្លួនកម្មាភិបាលបក្សលួចលាក់ខុសច្បាប់ជាច្រើនរូប ។ យោងតាមសម្តីរបស់ ប៉ុល ពត ពីឆ្នាំ ១៩៥៥ដល់ឆ្នាំ១៩៥៩ សមាជិកបក្សប្រជាជនបដិវត្តន៍ខ្មែរប្រហែលកៅសិបភាគរយត្រូវបានចាប់ខ្លួន និងសម្លាប់ ។ រហូតមកដល់ដើមឆ្នាំ១៩៦០ មានតែកម្មាភិបាលបក្សប្រហែល៨០០ នាក់ និងសាខាបក្សពីរ នៅជនបទប៉ុណ្ណោះ ដែលនៅមានសកម្មភាព និងដំណើរការពេញលេញ ។ សាខាទាំងពីរនោះរួមមាន ÷

- ◆ ភូមិភាគបូព៌ាមានមូលដ្ឋាននៅខេត្តកំពង់ចាម (ដឹកនាំដោយ សោ ភឹម) និង
- ◆ ភូមិភាគនិរតីមានមូលដ្ឋាននៅខេត្តតាកែវ (ដឹកនាំដោយ ឈិត ជឿន ហៅ តាម៉ុក) ។

ទូ សាមុត, ប៉ុល ពត, និង នួន ជា បានបន្តដឹកនាំសកម្មភាពបក្សនៅទីក្រុងភ្នំពេញ ដោយមានជំនួយពី អៀង សារី និង សុន សេន ជាបញ្ញវន្តពីរនាក់ផ្សេងទៀតដែលបានទៅសិក្សានៅប្រទេសបារាំង ។

## ៣) បក្សពលករកម្ពុជា

មហាសន្និបាតរបស់បក្សប្រជាជនបដិវត្តន៍ខ្មែរបានប្រារព្ធធ្វើឡើងជាសម្ងាត់ នៅក្នុងស្ថានីយរថភ្លើងនាទីក្រុងភ្នំពេញ ពីថ្ងៃទី ២៨ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ ។ មហាសន្និបាតនេះត្រូវបានចូលរួមដោយសមាជិកប្រាំពីររូបពីសាខាបក្ស នៅទីក្រុង និងដប់បួនរូបពីសាខាបក្សនៅជនបទ ។ មហាសន្និបាតបានសម្រេចរៀបចំបក្សសាជាថ្មី បង្កើតមាគ៌ានយោបាយថ្មី និងប្តូរឈ្មោះបក្សទៅជាបក្សពលករកម្ពុជា ។ ទូ សាមុត បានទទួលតំណែងជាលេខាបក្ស ហើយ នួន ជា ជាអនុលេខា ។ នៅពេលនោះ ប៉ុល ពត មានឋានៈលំដាប់ទីបីក្នុងបក្ស ហើយទទួលតំណែងជាអនុលេខាទីពីរនៅឆ្នាំ១៩៦១ ។

បន្ទាប់ពី ទូ សាមុត បានបាត់ខ្លួននៅឆ្នាំ១៩៦២ មហាសន្និបាតបក្សជាបន្ទាន់មួយត្រូវបានប្រារព្ធធ្វើឡើងនៅខែកុម្ភៈ ឆ្នាំ ១៩៦៣ ។ មហាសន្និបាតបានជ្រើសតាំង ប៉ុល ពត ជាលេខាបក្ស ។ នួន ជា ដែលមានតំណែងខ្ពស់ ជាង ប៉ុល ពត នៅក្នុងបក្សមិនត្រូវបានជ្រើសរើសទេ ដោយហេតុថា នួន ជា មានជាប់សាច់ញាតិជាមួយជនក្បត់បក្ស ស៊ីវ ហេង ។ ម្យ៉ាងទៀត នួន ជា គឺជា

ជនកុម្មុយនីស្តស្មោះត្រង់ម្នាក់ ដែលចង់ឲ្យបក្សពលករកម្ពុជាកាន់តែរឹងមាំឡើង ដូច្នេះ នួន ជា មិនធ្វើការប្រកួតប្រជែងជាមួយ ប៉ុល ពត សម្រាប់តំណែងនេះទេ។ នួន ជា បានបន្តស្ថិតនៅជាអនុលេខាបក្ស និងជាជនដ៏មានឥទ្ធិពលម្នាក់នៅក្នុងចលនាកុម្មុយនីស្តអស់រយៈពេលជាងសាមសិបឆ្នាំ។

បន្ទាប់ពីទទួលតំណែងជាលេខាបក្សភ្លាម ប៉ុល ពត បានទៅជ្រកកោននៅឯមូលដ្ឋានទ័ពរបស់វៀតណាមនៅភាគឦសានប្រទេសហៅថា"មន្ទីរ១០០"។ នៅឆ្នាំ១៩៦៥ ប៉ុល ពត បានធ្វើដំណើរតាមផ្លូវលំហូជីមិញទៅទីក្រុងហាណូយ ដើម្បីធ្វើការពិភាក្សាជាមួយវៀតណាមខាងជើង។ ប៉ុល ពត បានទៅធ្វើទស្សនកិច្ចនៅប្រទេសចិននិងកូរ៉េខាងជើង។ ប៉ុល ពត ត្រូវបានទទួលស្វាគមន៍នៅប្រទេសចិន ប្រកបដោយភាពកក់ក្តៅជាងនៅវៀតណាម ហើយ ប៉ុល ពត មានការមិនពេញចិត្តចំពោះគំនិតដែលថាចលនាកុម្មុយនីស្តនៅកម្ពុជាត្រូវតែបន្តស្ថិតនៅក្រោមការមើលការខុសត្រូវរបស់វៀតណាមតទៅទៀត។

## ៤) បក្សកុម្មុយនីស្តកម្ពុជា

នៅខែកញ្ញា ឆ្នាំ១៩៦៦ បន្ទាប់ពីដំណើរបំពេញទស្សនកិច្ចក្រៅប្រទេស ប៉ុល ពត បានប្តូរឈ្មោះបក្សទៅជាបក្សកុម្មុយនីស្តកម្ពុជា ដោយហេតុថា ប៉ុល ពត ចង់បន្ថយឥទ្ធិពលរបស់វៀតណាមនិងរឹតចំណងមិត្តភាពជាមួយចិន។ គណៈកម្មាធិការមជ្ឈិមបក្សនៅពេលនោះរួមមាន ៖ ប៉ុល ពត, នួន ជា, អៀង សារី, វន វេត (អតីតគ្រូបង្រៀននៅវិទ្យាល័យ ចម្រើនវិជ្ជា នៅភ្នំពេញ) និង សុន សេន។

ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ សមាជិកថ្មីៗរបស់ខ្មែរក្រហមបានកើនឡើងថែមទៀត។ ភាគច្រើននៃក្រុមនេះ រស់នៅតាមបណ្តោយព្រំដែនវៀតណាម ដែលជាតំបន់ដាច់ស្រយាលឆ្ងាយពីកងកម្លាំងយោធារបស់សម្តេច ព្រះនរោត្តម សីហនុ។ មូលដ្ឋានធំរបស់បក្សពីឆ្នាំ១៩៦៦ទៅឆ្នាំ១៩៧០ ស្ថិតនៅខេត្តរតនគិរី។

នៅខែមីនា ឆ្នាំ១៩៧០ ឧត្តមសេនីយ៍ លន់ នល់ និងសហការីរបស់គាត់ដែលនិយមសហរដ្ឋអាមេរិកបានធ្វើរដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ ចេញពីព្រះប្រមុខរដ្ឋដោយជោគជ័យ។ មិនយូរប៉ុន្មានបន្ទាប់ពីនោះ កងកម្លាំងវៀតមិញនិងខ្មែរក្រហមបានកាន់កាប់តំបន់ជាច្រើននៅក្នុងប្រទេស។ ប្រជាជនរាប់ម៉ឺននាក់បានបដិសេធមិនគាំទ្ររដ្ឋាភិបាលសាធារណរដ្ឋខ្មែររបស់លោកសេនាប្រមុខ លន់ នល់ ហើយបែរជាចូលរួមជាមួយខ្មែរក្រហមដើម្បីនាំយកសម្តេច ព្រះនរោត្តម សីហនុ មកគ្រប់គ្រងអំណាចវិញ។ ក្នុងពេលនោះដែរ សម្តេច ព្រះនរោត្តម សីហនុ បាននិរទេសព្រះកាយទៅប្រទេសចិន។ ដោយមានការលើកទឹកចិត្តនិងការជួយជ្រោមជ្រែងពីសំណាក់រដ្ឋាភិបាលចិន រដ្ឋាភិបាល


ក្រុមយុវជន និងយុវនារី

វៀតណាមខាងជើង និងបក្សកុម្មុយនីស្តកម្ពុជា ព្រះអង្គបានបង្កើត "រណសិរ្សរួបរួមជាតិកម្ពុជា" និងរដ្ឋាភិបាលនិរទេសមួយដែលមានឈ្មោះថា "រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា"។ សមាជិកបក្សកុម្មុយនីស្តកម្ពុជាក៏ជាសមាជិករបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដែរ។

សភាពការណ៍វិវត្តន៍ទាំងនេះបានផ្តល់ឱកាសយ៉ាងច្រើនដល់ក្រុមខ្មែរក្រហម។ វៀតណាមខាងជើងនិងចិនគាំទ្រក្រុមខ្មែរ

ក្រហម ហើយសម្តេច ព្រះនរោត្តម សីហនុ បានអំពាវនាវឲ្យប្រជាជនចូលព្រៃម៉ាគី(ព្រៃដែលអ្នកតស៊ូធ្វើបដិវត្តន៍លាក់ខ្លួន) ជួយផ្តួលរំលំរដ្ឋាភិបាលសាធារណរដ្ឋខ្មែររបស់លោកសេនាប្រមុខ លន់ នល់ ។ ជាងនេះទៅទៀត ការទម្លាក់គ្រាប់បែកដ៏សន្ធឹកសន្ធាប់របស់របបសាធារណរដ្ឋខ្មែរ ក្រោមការជួយជ្រោមជ្រែងរបស់សហរដ្ឋអាមេរិកទៅលើផ្លូវផ្គត់ផ្គង់សម្ភារនិងមូលដ្ឋាននានារបស់ក្រុមកុម្មុយនីស្ត បានធ្វើឲ្យមានការគាំទ្រខ្មែរក្រហមពីសំណាក់ប្រជាជនកាន់តែច្រើនឡើង ហើយកម្លាំងទ័ពរបស់ខ្មែរក្រហមមាន



នៅក្នុងសន្និសីទមួយក្នុងខេត្តសៀមរាប នាថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៣

ចំនួនកាន់តែកើនឡើងជាលំដាប់ ។

កងកម្លាំងកុម្មុយនីស្តវៀតណាមបានចូលកាន់តែជ្រៅទៅក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៧០ ហើយបានធ្វើការជាមួយខ្មែរក្រហមដើម្បីរើសនិងហ្វឹកហ្វឺនទ័ពសម្រាប់កងកម្លាំងតស៊ូ ដែលបានកើនឡើងពីចំនួនប្រហែលពាពាន់នាក់ នៅឆ្នាំ១៩៧០ទៅចំនួន៤ម៉ឺននាក់ក្នុងឆ្នាំ១៩៧៣ ។ នៅលើសមរភូមិដោយមានជំនួយពីវៀតណាម ខ្មែរក្រហមបានទទួល ជ័យជម្នះលើកងទ័ពរបស់លោកសេនាប្រមុខ លន់ នល់ ជាបន្តបន្ទាប់ ។ ចុងឆ្នាំ១៩៧២ កងទ័ពវៀតណាមបានដកចេញពីកម្ពុជា ហើយបានប្រគល់បន្ទុកសំខាន់ៗនៃសង្គ្រាមនេះមកឲ្យបក្សកុម្មុយនីស្តកម្ពុជាគ្រប់គ្រងវិញ ។ ទោះជាយ៉ាងនេះក្តី ទីប្រឹក្សាវៀតណាមពីរ ឬបីពាន់នាក់បានបន្តស្នាក់នៅធ្វើជាទីប្រឹក្សាផ្នែកបច្ចេកទេស ។

ចាប់ពីខែមករាដល់ខែសីហា ឆ្នាំ១៩៧៣ របបសាធារណរដ្ឋខ្មែរដែលមានសហរដ្ឋអាមេរិកជាអ្នកផ្គត់ផ្គង់គ្រឿងសព្វាវុធ បានទម្លាក់គ្រាប់បែកប្រមាណកន្លះលានតោនលើ កម្ពុជា ហើយធ្វើឲ្យប្រជាជនខ្មែរប្រហែលបីសែននាក់ស្លាប់បាត់បង់ជីវិត ។ ការទម្លាក់គ្រាប់បែកនេះបានពន្យឺតដំណើរឆ្ពោះទៅរកជ័យជម្នះរបស់ខ្មែរក្រហម ហើយក្នុងពេលជាមួយគ្នានោះ មនុស្សជាច្រើនដែលរងសម្បានឹងការទម្លាក់គ្រាប់បែក ហើយដែលមានបាត់បង់សមាជិកគ្រួសារខ្លួននោះបានចូលរួមជាមួយបដិវត្តន៍ខ្មែរក្រហម ។

កងទ័ពខ្មែរក្រហមមានភាពស្វាហាប់ និងគោរពវិន័យជាងកងទ័ពរបស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ហើយក្រុមខ្មែរក្រហមអាចទ្រាំទ្រនឹងការខ្វះខាតម្ហូបអាហារនិងថ្នាំសង្កូវបាន ។ ជាងនេះទៅទៀត "ខ្មែរហាណូយ" មួយចំនួនបានត្រឡប់ចូលមកក្នុងប្រទេសវិញ ដើម្បីជួយចលនាបដិវត្តន៍របស់ខ្មែរក្រហម ។ អ្នកទាំងអស់នេះត្រូវបានដាក់ឲ្យកាន់តំណែងថ្នាក់ទាបនៅទូទាំងប្រទេស ប៉ុន្តែរហូតមកដល់ឆ្នាំ១៩៧៣ គឺបន្ទាប់ពីទីប្រឹក្សាវៀតណាមភាគច្រើនត្រឡប់ទៅប្រទេសខ្លួនវិញ អ្នកទាំងនោះត្រូវបានធ្វើឃាតជាសម្ងាត់ ក្រោមបញ្ជារបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែលចង់ឲ្យបក្សចេញផុតពីឥទ្ធិពលរបស់វៀតណាម ។

នៅដើមឆ្នាំ១៩៧៣ ប៉ែតសិបប្រាំភាគរយនៃប្រទេសកម្ពុជាបានធ្លាក់ក្រោមការត្រួតត្រារបស់ខ្មែរក្រហម ហើយកងទ័ពរបស់លោកសេនាប្រមុខ លន់ នល់ ស្ទើរតែគ្មានលទ្ធភាពធ្វើការប្រយុទ្ធបន្តទៅទៀតទេ ។ ទោះជាយ៉ាងនេះក្តី ដោយសារមានជំនួយពីសហរដ្ឋអាមេរិក កងទ័ពលោក សេនាប្រមុខ លន់ នល់ មានលទ្ធភាពបន្តការប្រយុទ្ធជាមួយខ្មែរក្រហមអស់រយៈពេលជាងពីរឆ្នាំបន្តមកទៀត ។ ***(នៅមានត)*** **ឌី ខាំបូលី**

# តើប្រជាជនចូលរួមដំណើរទស្សនកិច្ចមានចំណាប់អារម្មណ៍ដូចម្តេច ចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាយុត្តិធម៌និងការផ្សះផ្សា

មកទល់បច្ចុប្បន្នមានរយៈពេលជាង៣០ឆ្នាំ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមដែលបណ្តាលឲ្យប្រជាជនកម្ពុជាជិត២លាននាក់បាត់បង់ជីវិតក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ។ របបដ៏ព្រៃផ្សៃនេះ មិនត្រឹមតែបំផ្លិចបំផ្លាញមូលដ្ឋានគ្រឹះវិស័យសេដ្ឋកិច្ចនិងនយោបាយប៉ុណ្ណោះទេ ថែមទាំងបន្ថែមការឈឺចាប់ដ៏មហិមាដល់ជនរងគ្រោះជាច្រើនដែលបាត់បង់សមាជិកគ្រួសារក្រោមរូបភាពជាការសម្លាប់និងបាត់ខ្លួនក្នុងអំឡុងពេលកាន់កាប់នៃរបបនោះ ។

រយៈកាលជាច្រើនទសវត្សរ៍កន្លងមកនេះប្រទេសកម្ពុជានៅមិនទាន់មានយន្តការជាក់ស្តែងណាមួយដើម្បីជួយជនរងគ្រោះឲ្យទទួលបាននូវដំណោះស្រាយផ្សះផ្សាមួយដើម្បីបិទទំព័រអតីតកាលដ៏គួរឲ្យខ្លោចផ្សានេះទេ ។ បច្ចុប្បន្ន យន្តការមួយក្រោមរូបភាពជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានផ្តល់ពន្លឺនៃក្តីសង្ឃឹមក្នុងការស្វែងរកយុត្តិធម៌ ។ យ៉ាងណាមិញ ប្រជាជនមួយចំនួនធំនៅតែមានអារម្មណ៍ថា មិនអាចឈោងចាប់យុត្តិធម៌បានដោយសារគាត់គ្មានលទ្ធភាពទទួលបានព័ត៌មានអំពីដំណើរការតុលាការ ដែលកំពុងកើតមាន ។ ជាងនេះទៅទៀត ទោះបីជាជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យបានឆ្លងកាត់បទពិសោធន៍ពីរបបនេះផ្ទាល់ក៏ដោយក៏ប្រជាជនមួយចំនួនធំគ្មានឱកាសមើលឃើញថាតើក្នុងទំព័រប្រវត្តិសាស្ត្រសម័យនោះមានការប្រព្រឹត្តយ៉ាងដូចម្តេចខ្លះនៅតាមអតីតគុកខ្មែរក្រហមនិងរណ្តៅសាកសពរួមដែរ ។


ទិដ្ឋភាពក្នុងអគារសវនាការ

ដើម្បីជម្នះឲ្យបាននូវឧបសគ្គទាំងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តួចផ្តើមកម្មវិធីផ្សព្វផ្សាយព័ត៌មានមុនពេលសវនាការដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃគម្រោងឯកសាររស់ ។ ក្នុងចន្លោះពេលខែកុម្ភៈ ឆ្នាំ២០០៦ និងខែឧសភា ឆ្នាំ២០០៧ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំដំណើរទស្សនកិច្ចសិក្សាអប់រំ នាំប្រជាជនទៅកាន់ទីតាំងប្រវត្តិសាស្ត្រដូចជាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងជាកន្លែងអ្នកទោសប្រមាណ១៤០០០នាក់បាត់បង់ជីវិត វាលពិឃាតជើងឯកជាទីតាំងដែលអ្នកទោសគុកទួលស្លែងត្រូវយកទៅសម្លាប់និងរុញចូលរណ្តៅសាកសពរួមនិងអគារអង្គជំនុំជម្រះវិសាមញ្ញ ។

ជារៀងរាល់ខែ មជ្ឈមណ្ឌលឯកសារកម្ពុជាតែងតែអញ្ជើញប្រជាជនតាមស្រុកភូមិចំនួន៥០០នាក់ ក្នុងនោះមានសមាសភាពមេដឹកនាំសហគមន៍និងសាសនា សិស្សានុសិស្សមកពីសាលារៀនតាមបណ្តាខេត្តនានា ដើម្បីមកទស្សនាទីតាំងប្រវត្តិសាស្ត្រក្នុងគោលបំណងជំរុញឲ្យអ្នកទាំងអស់គ្នាបានចូលរួមដំណើរការស្វែងរកយុត្តិធម៌ ។ ប្រជាជនចំនួន៦ពាន់នាក់ (ជាង៩០ភាគរយនៃចំនួនប្រជាជនដែលទទួលបានលិខិតអញ្ជើញ) បានចូលរួមដំណើរទស្សនកិច្ចរយៈពេលបីថ្ងៃ ដោយសុខចិត្តចំណាយពេលវេលាពីការងារប្រចាំថ្ងៃរបស់ខ្លួន ។ អ្នកចូលរួមទាំងអស់ទទួលបានសោហ៊ុយធ្វើដំណើរបន្តិចបន្តួច រួមទាំងថ្លៃអាហារនិងការស្នាក់នៅដើម្បីជាការតបស្នងការខំប្រឹងប្រែងរបស់គាត់ ។ ពេល

គាត់ទាំងអស់គ្នាត្រឡប់ទៅស្រុកវិញ គាត់នឹងចែករំលែកចំណេះដឹងពីដំណើរទស្សនកិច្ចនេះតាមរយៈការជជែកលេងជាមួយគ្រួសារ សាច់ញាតិ បងប្អូន និងអ្នកភូមិជិតខាង ។

ដើម្បីស្វែងយល់ពីអារម្មណ៍របស់ប្រជាជនចំពោះដំណើរទស្សនកិច្ច ការផ្សះផ្សា និងការយល់ដឹងពីដំណើរការច្បាប់ក្នុងអង្គជំនុំជម្រះវិសាមញ្ញ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការស្ទង់មតិនៅក្នុងខណៈពេលទស្សនកិច្ចនិងថ្ងៃបញ្ចប់ដំណើរទស្សនកិច្ច ។ សំណួរស្ទង់មតិចំនួន៦៦៧ច្បាប់ត្រូវបានចែកចាយឲ្យប្រជាជនសមាជិកក្រុមប្រឹក្សាឃុំ ស្រុក ឬមេឃុំ ។

### សំណួរស្ទង់មតិ

ជាទូទៅ តើលោក-អ្នកគិតយល់ដូចម្តេចដែរចំពោះដំណើរទស្សនកិច្ចទៅកាន់អង្គជំនុំជម្រះវិសាមញ្ញដែលលោក-អ្នកបានចូលរួមកន្លងមក?

តើលោក-អ្នកបានយល់ដឹងអំពីព័ត៌មានថ្មីៗអ្វីខ្លះ តាមរយៈការចូលរួមដំណើរទស្សនកិច្ច តាមរយៈឯកសារដែលបានចែកជូន ឬតាមរយៈការជួបសំណេះសំណាលជាមួយមន្ត្រីសំខាន់ៗ?

តើលោក-អ្នកមានសំណួរ ឬមានបញ្ហាអ្វីខ្លះដែលពីមុនមកមិនទាន់យល់ ហើយតាមរយៈដំណើរទស្សនកិច្ចនេះបានឆ្លើយបំភ្លឺឲ្យលោក-អ្នកបានយល់ច្បាស់?

តើដំណើរទស្សនកិច្ចនេះបានធ្វើឲ្យលោក-អ្នកយល់ដឹងបន្ថែមអ្វីខ្លះ បើធៀបទៅនឹងពេលដែលលោក-អ្នកមិនទាន់បានមកទស្សនា?

តើលោក-អ្នកបានចែករំលែកការយល់ដឹងអ្វីខ្លះទៅដល់អ្នកស្រុកភូមិអំពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម? ប្រសិនបើបានចែករំលែក សូមមេត្តាឆ្លើយនឹងសំណួរដូចខាងក្រោម ÷

- តើលោក-អ្នក ចែករំលែកការយល់ដឹងទៅឲ្យនរណាខ្លះ?
- តើព័ត៌មានអ្វីទៅដែលលោក-អ្នកចែករំលែក ហើយតើអ្នកដែលទទួលព័ត៌មានមានប្រតិកម្មយ៉ាងដូចម្តេចដែរ?
- តើលោក-អ្នកគិតថាមានប្រយោជន៍យ៉ាងណាខ្លះចំពោះការចែករំលែកព័ត៌មានទាំងអស់នោះទៅអ្នកដទៃ?
- តើដំណើរទស្សនកិច្ចនេះធ្វើឲ្យលោក-អ្នកនឹកឃើញអំពីអតីតកាលដែលទាក់ទងនឹងរបបខ្មែរក្រហម ឬក៏ថាមានអារម្មណ៍ផ្សេងពីនេះវិញ?
- តើដំណើរទស្សនកិច្ចនេះជួយឲ្យលោក-អ្នកឈានទៅរកការរសាយក្នុងចិត្តអំពីការចងចាំដ៏ជូរចត់ ឬក៏ថាអាចរសាយពីកំហឹងក្រេវក្រោធបានដែរឬទេ បើបានតើធ្វើដូចម្តេច?
- តើដំណើរទស្សនកិច្ចនេះបានធ្វើឲ្យលោក-អ្នកមានមតិយ៉ាងណាចំពោះគំនិតផ្សះផ្សាជាតិនិងយុត្តិធម៌? ចូរពន្យល់?
- តើលោក-អ្នក មានអ្វីចង់បន្ថែមទៀតដែរឬទេ ទាក់ទងនឹងដំណើរទស្សនកិច្ច?

បន្ថែមពីនេះ ការឲ្យពិន្ទុលើបទសម្ភាសន៍ត្រូវបានធ្វើឡើងជាមួយអ្នករស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យដោយយោងតាមរឿងរ៉ាវជីវិតរបស់គាត់ផ្ទាល់ ។ ខាងក្រោមនេះជាការរៀបរាប់សង្ខេបនូវបទពិសោធន៍ជនរងគ្រោះ ដើម្បីផ្តល់ជាមូលដ្ឋានគ្រឹះនៃប្រតិកម្មផ្លូវអារម្មណ៍របស់ប្រជាជនដែលមកចូលរួមដំណើរទស្សនកិច្ចនេះ ។ នៅក្នុងបទសង្ខេបខាងក្រោមក៏មានលើកឧទាហរណ៍ខ្លះៗដែលដកស្រង់ចេញពីបទសម្ភាសន៍ដែលក្រុមអ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅសាកសួរអ្នករស់រាន មានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ ។

អត្ថបទនេះនឹងសង្កេតលើទំហំថាតើដំណើរទស្សនកិច្ចនេះធ្វើឲ្យប្រជាជនមានអារម្មណ៍ខឹងសម្បា ឬធូរស្រាលបន្ទាប់ពីទៅទស្សនាទីតាំងប្រវត្តិសាស្ត្រទាំងបី ។ អត្ថបទក៏មានរាប់បញ្ចូលនូវការយល់ឃើញរបស់ប្រជាជនទាក់ទិននឹងតួនាទីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាស្វែងរកយុត្តិធម៌ ។ អត្ថបទនេះថែមទាំងឆ្លុះបញ្ចាំងពីអារម្មណ៍ជនរងគ្រោះថាតើដំណើរការតុលាការអាចជួយគាត់ផ្នែកស្មារតី សេដ្ឋកិច្ចនិងនយោបាយដែរឬទេ? សេចក្តីសន្និដ្ឋានចុងក្រោយនៃអត្ថបទនេះនឹងធ្វើការសង្កេតថាតើដំណើរទស្សនកិច្ចអាចប្រើប្រាស់ជាមធ្យោបាយក្នុងការជំរុញឲ្យមានការផ្សះផ្សាឬទេ?

### ១) ការឈឺចាប់ជាបុគ្គលនៅក្នុងរបបខ្មែរក្រហម

នៅក្នុងអំឡុងពេលបួនឆ្នាំពេលដែលខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជា ប្រជាជនត្រូវបានបង្ខំឲ្យធ្វើការក្នុងស្ថានភាពដ៏

សែនលំបាកដោយគ្មានអាហារហូបគ្រប់គ្រាន់ ។ ជាងនេះទៅទៀត ប្រជាជនកម្ពុជាងាយនឹងទទួលរងនូវជំងឺតម្កាត់ដោយគ្មានការថែរក្សាព្យាបាល ការចាប់ដាក់គុកនិងការសម្លាប់ និងដោយសារសមាជិកគ្រួសារស្លាប់ជាបន្តបន្ទាប់ មិត្តភក្តិជិតខាងកាន់តែមានក្តីបារម្ភជានិច្ចដោយមិនដឹងថាថ្ងៃណាខ្លួននឹងត្រូវយកទៅសម្លាប់ ។ ការនឿយហត់ផ្លូវកាយនិងអសុវត្ថិភាព ដែលកើតមានក្នុងរបបនោះ ធ្វើឲ្យប្រជាជនកើតការតានតឹងផ្លូវចិត្តយ៉ាងខ្លាំងដែលនៅតែបន្សល់ទុកស្លាកស្នាមផ្លូវចិត្តមកទល់សព្វថ្ងៃ ។

ជាការពិតណាស់ដែលថារបបខ្មែរក្រហមបានអនុវត្តគោលនយោបាយចាប់មនុស្សយកទៅសម្លាប់ដោយមើលទៅលើប្រវត្តិរូបធ្លាប់ជាទាហាន មន្ត្រីរដ្ឋការ សិស្សនិស្សិត បញ្ញវន្ត និងអ្នកធ្លាប់បម្រើការរបបសាធារណរដ្ឋខ្មែរ ។ ប្រជាជនថ្មី (អ្នកដែលរស់នៅក្រៅតំបន់ខ្មែរក្រហមកាន់កាប់) និងគ្រួសារធូរធារ (អ្នកដែលចាត់ថ្នាក់ថា ជាពួកចក្រពត្តិ សក្តិភូមិ និងមូលធននិយម) ជាមុខសញ្ញាទទួលរងនូវការធ្វើបាបដ៏ឃោរឃៅ ។ ប្រជាជនមួយចំនួនទៀតត្រូវបានចោទថាមានទំនាក់ទំនងជាមួយខ្សែសេ.អ៊ី.អា កា.ហ្សេ.បេ ឬវៀតណាម ។ សូម្បីតែអ្នកស្ម័គ្រចិត្តបម្រើបដិវត្តន៍ក៏ត្រូវជាប់ចោទថា ជាខ្សែវៀតណាមដែរ ហើយត្រូវយកទៅកម្ទេចចោលដើម្បីបោសសម្អាតសមាសភាពក្បត់នៅក្នុងប្រទេស ។

យោងតាមបទសម្ភាសន៍ដោយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា រឿងរ៉ាវខាងក្រោមនេះជាការរៀបរាប់របស់ប្រជាជនដែលត្រូវបានអញ្ជើញឲ្យចូលរួមដំណើរទស្សនកិច្ចចាប់ផ្តើមពីខែកុម្ភៈ ឆ្នាំ២០០៦ ដល់ខែឧសភា ឆ្នាំ២០០៧ ។

យិន សំអ៊ុន អាយុ៥៣ឆ្នាំ មកពីស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ។ គាត់រៀបរាប់ទាំងទឹកភ្នែកអំពីរឿងរ៉ាវក្រុមគ្រួសារគាត់ក្នុងរបបខ្មែរក្រហម ។ យិន រៀបការជាមួយ អ៊ីង ដេត ហៅ នឿន អតីតទាហានកងអនុសេនាធំនៃកងពល៣១០ ។ អ៊ីង ដេត បានស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍នៅឆ្នាំ១៩៧១ រីឯ យិន សំអ៊ុន ឆ្នាំ ១៩៧៣ ដោយសារមានការអំពាវនាវពីសម្តេច ព្រះនរោត្តម សីហនុ សុំឲ្យប្រជាជនរត់ចូលព្រៃដើម្បីកសាងកម្លាំងរំដោះប្រទេសជាតិ ។ អ្នកទាំងពីរមានចិត្តស្មោះស និងខិតខំប្រឹងប្រែងធ្វើការបម្រើបដិវត្តន៍ ។ ប៉ុន្តែជាអកុសលពេលដែល សំអ៊ុន ទើបនឹងសម្រាលកូនបានប្រាំថ្ងៃ ស្រាប់តែគាត់ទទួលដំណឹងថាប្តីគាត់ស្លាប់ក្នុងឆ្នាំ ១៩៧៥ ។ គាត់យល់ថាមកពីប្តីគាត់បង្ករឿងអ្វីមួយ ហើយបានជាត្រូវចាប់ខ្លួនដូច្នេះ ។

ឆ្លើយតបទៅនឹងសេចក្តីអំពាវនាវរបស់សម្តេច សីហនុ ឡុង វុទ្ធី ស្ម័គ្រចិត្តបម្រើបដិវត្តន៍នៅឆ្នាំ១៩៧៣ បានអះអាងថា គាត់រស់នៅដោយគ្មានការលំបាកក្នុងរបបកម្ពុជាប្រជាធិបតេយ្យនិងបញ្ជាក់ថា គាត់មិនធ្លាប់ឃើញការសម្លាប់មនុស្សឡើយ ។ វុទ្ធី លើកឡើងពីអត្ថប្រយោជន៍នៃការរស់នៅក្នុងតំបន់កាន់កាប់ដោយខ្មែរក្រហមបន្ទាប់ពីការដួលរលំនៃរបបនេះថា នៅតំបន់នោះគ្មានចោរលួច ចោរប្លន់ប្រដាប់អាវុធឡើយ ។ យ៉ាងណាមិញ គាត់សម្គាល់ឃើញថា ទាំងចាស់ទាំងក្មេងត្រូវបានបង្ខំឲ្យធ្វើការគ្មានឈប់ឈរ ។ វុទ្ធីនៅតែមានចម្ងល់ថា ហេតុអ្វីគ្រូបង្រៀន និងបញ្ញវន្តទទួលរងនូវការធ្វើបាប បើអ្នកទាំងនោះមិនប្រកាន់គោលជំហរនយោបាយប្រឆាំងនឹងខ្មែរក្រហមផង ហើយក៏មិនមែនជាមន្ត្រីរដ្ឋការឋានៈធំដុំអ្វីដែរកាលពីជំនាន់លន់នល់ ។

វិសុទ្ធកម្មលុបបំបាត់ជនជាប់ពាក់ព័ន្ធនឹងរបបចាស់ត្រូវបានអនុវត្តឥតឈប់ឈរ និងឈានដល់ចំណុចកំពូលនៅពាក់កណ្តាលឆ្នាំ១៩៧៦ ។ គួយ៉ាងដូចជាឪពុករបស់ សាន សេន អាយុ៤៣ឆ្នាំ នៅខេត្តតាកែវ ជាចៅហ្វាយស្រុកសម័យ លន់នល់ ។ ដោយសារគាត់មានប្រវត្តិរូបមិនល្អ សាន សេន ជាកូនត្រូវខ្មែរក្រហមចាប់ដាក់គុកក្រាំងតាចាន់ ។ នៅទីនោះ សេន ជាប់ខ្នោះជើងទាំងពីរដើរមិនរួចអស់រយៈពេលជាង៣ខែ មុនពេលគាត់ត្រូវដោះលែងនិងបញ្ជាឲ្យឃ្វាលគោវិញ ។ បន្ទាប់មក សេន ត្រូវបានចាត់តាំងឲ្យជីករណ្តៅកប់សាកសពដែលខ្មែរក្រហមសម្លាប់ ។ សេន និយាយថា “អ្នកទោសត្រូវខ្មែរក្រហមចងស្លាបសេកនិងយកក្រមារុំមុខបណ្តើរទៅ ។ ពេលបណ្តើរទៅដល់មាត់រណ្តៅ អ្នកទោសត្រូវខ្មែរក្រហមវាយនឹងដងចបរួចច្រានទម្លាក់ចូលរណ្តៅ” ។ ពេលនៅក្នុងគុក សាន សេន ទទួលរងនូវការវាយដំចំក្បាលធ្វើឲ្យគាត់ស្ទើរនឹងស្លាប់ ។

អ៊ុក វណ្ណនី ហៅ ញ៉ែម នី មកពីខេត្តកំពង់ធំ មិនអាចទ្រាំបិទភ្នែកមិនជួយឪពុករបស់ខ្លួនឡើយ ។ ឈ្លបខ្មែរក្រហមគំរាមថា បើគាត់មិនចូលបដិវត្តន៍ទេ ឪពុកគាត់នឹងត្រូវស្លាប់ ។ ក្រោយចូល

បដិវត្តន៍ គាត់ក៏ត្រូវចាប់ខ្លួនបន្ទាប់ពីថ្នាក់លើរបស់គាត់ត្រូវចាប់ខ្លួនដោយជាប់ចោទថាក្បត់បក្ស ។ នៅក្នុងគុក គាត់ត្រូវស្លូរចម្លើយនិងរងទារុណកម្មជារឿយៗ ។ ការឈឺចាប់នេះនៅបន្សល់ទុករហូតដល់សព្វថ្ងៃ គឺជួនកាលគាត់ទន់ខ្សោយ ឆាប់ហត់ និងឈឺទ្រោមពេញរាងកាយ ។

ចិន វន អាយុ ៥៣ឆ្នាំ បានបាត់បង់ឪពុកបង្កើតដោយសារអត់អាហារនិងស្លាប់ក្នុងឆ្នាំ១៩៧៦ ។ សព្វថ្ងៃ វន រស់នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ សមាជិកគ្រួសាររបស់ វន ស្លាប់ទាំងអស់ មានតែ វន ទេដែលនៅរស់រានមានជីវិត ។ ចុងឆ្នាំ ១៩៧៧ បងប្អូនបង្កើតរបស់ វន បីនាក់ត្រូវបណ្តើរយកទៅសម្លាប់ខណៈពេលកំពុងតែភ្ជួរស្រែនៅសហករណ៍អន្លង់រមៀត ។ វន មិនដែលដឹងអំពីមូលហេតុដែលខ្មែរក្រហមសម្លាប់បងប្អូនរបស់គាត់ឡើយ ។

ខៀវ សំភឿន អាយុ៤៥ឆ្នាំ បានរស់រានមានជីវិតពីកម្ពុជាប្រជាធិបតេយ្យ ។ សព្វថ្ងៃ គាត់រស់នៅក្នុងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។ គាត់នៅតែមិនអាចបំភ្លេចអតីតកាលដ៏សែនវេទនានៃរបបខ្មែរក្រហមបាន ។ គាត់បញ្ជាក់ថា "ខ្ញុំមើលឃើញឧក្រិដ្ឋកម្មប្រព្រឹត្តចំពោះប្រជាជនដ៏ព្រៃផ្សៃបំផុត ដែលប្រទេសកម្ពុជាមិនដែលធ្លាប់មានពីមុនមកក្នុងប្រវត្តិសាស្ត្រ ។ ខ្ញុំមិនអាចភ្លេចរឿងនេះបានឡើយ" ។

អត្រាស្លាប់មួយភាគបួននៃចំនួនប្រជាជនសរុបនិងការឈឺចាប់ហួសប្រមាណដែលជនរងគ្រោះបានឆ្លងកាត់គឺជារឿងមួយមិនអាចបដិសេធបាន ។ ការបណ្តោយឲ្យខ្មែរក្រហមរំលោភសិទ្ធិមនុស្សដោយគ្មានការដាក់ទោសជារឿងអាប់ឱនកិត្តិយសដល់វិញ្ញាណក្ខន្ធអ្នកស្លាប់ និងធ្វើឲ្យភាពមិនប្រាកដប្រជាបន្តយាយីអ្នករស់រានមានជីវិត ។ ដូច្នេះការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះនឹងធ្វើឲ្យគាត់រសាយចម្ងល់ដែលដក់ជាប់ក្នុងអារម្មណ៍កន្លងមក ។ ការឃ្លាំមើលកិច្ចការតុលាការគឺចាំបាច់ដូចគ្នា ហើយកិច្ចការនេះនឹងជួយឲ្យតុលាការដំណើរការទៅមុខដោយមិនវៀរចាកមាគ៌ាយុត្តិធម៌សម្រាប់ជនរងគ្រោះ ។

**៣) ប្រតិកម្មចំពោះទីតាំងប្រវត្តិសាស្ត្រក្នុងពេលដំណើរទស្សនកិច្ច**

ដើម្បីធានាឲ្យបានថា ប្រជាជនមកចូលរួមបានស្វែងយល់ពីប្រវត្តិសាស្ត្រទំនើបនិងឲ្យគាត់ទាំងអស់គ្នាមានទំនាក់ទំនងជាមួយសាលាក្តីខ្មែរក្រហម ដំណើរទស្សនកិច្ចបានរៀបចំឲ្យអ្នកចូលរួមទាំងអស់ ទស្សនាទីតាំងមួយចំនួនដូចជា សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង វាលពិឃាតបឹងជើងឯក និងបន្ទប់សវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

**ទីតាំងប្រវត្តិសាស្ត្រ**

សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងជាទីតាំងគុកទួលស្លែង(ស-២១) ។ ក្នុងសម័យសង្គមរាស្ត្រនិយមក្រោមព្រះរាជដឹកនាំដោយសម្តេច ព្រះនរោត្តម សីហនុ គុកទួលស្លែងជាវិទ្យាល័យពៅញាយ៉ាត លុះក្រោយមកត្រូវបានប្តូរឈ្មោះថា "វិទ្យាល័យទួលស្វាយព្រៃ" ក្នុងរបបលន់នល់វិញ ។ ទួលស្លែង ឬមន្ទីរស-២១ ជាមន្ទីរសម្ងាត់ថ្នាក់មជ្ឈិម ឬ "មន្ទីរសន្តិសុខ" នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងចំណោមអ្នកទោសប្រមាណ១ម៉ឺន៤ពាន់នាក់ មានប្រហែលតែ២០នាក់ប៉ុណ្ណោះ ដែលនៅរស់រានមានជីវិតភាគច្រើនដោយសារគាត់មានជំនាញពិសេស ដូចជាជំនាញគូររូប សូនរូប និងជំនាញគ្រឿងចក្រផ្សេងៗ ។


ការទស្សនាមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

ជើងឯកស្ថិតនៅចម្ងាយ១៨គីឡូម៉ែត្រពីទីក្រុងភ្នំពេញ ។ ទីតាំងនេះត្រូវបានមនុស្ស

ភាគច្រើនស្គាល់ថាជា «វាលពិឃាត» ។ អ្នកទោសគុកទួលស្លែងត្រូវដឹកយកទៅសម្លាប់នៅទីនេះ ។ នៅទសវត្សរ៍ឆ្នាំ១៩៨០ បន្ទាប់ពីលលាដ៍ក្បាលជនរងគ្រោះរាប់រយត្រូវបានរកឃើញ វាលពិឃាតនេះបានប្រែរូបរាងជាបូជនីយដ្ឋានវិញ ។

ប្រជាជនខ្លះដែលមកចូលរួមដំណើរទស្សនកិច្ចនេះមិនដែលឮឈ្មោះកន្លែងនេះទេពីមុនមក ហើយខ្លះទៀតបានដឹងពីទីតាំងនេះដែរ ប៉ុន្តែមិនដែលមកឃើញផ្ទាល់ភ្នែក ។ ពេលដែលគាត់ទាំងអស់គ្នាបានមកទស្សនាទីតាំងនេះធ្វើឲ្យគាត់មានប្រតិកម្មខុសៗគ្នា ។ ប្រជាជនមួយភាគធំមានការសោយសោក ខ្លះព្រួយបារម្ភ ខ្លះហៀបនឹងបាត់ស្មារតី ខ្លះមានចម្ងល់ និងមួយចំនួនតូចមានចំណាប់អារម្មណ៍ ។

សំណួរស្ទាបស្ទង់មតិធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានចែកជូនដល់អ្នកមកចូលរួមបន្ទាប់ពីទស្សនកិច្ចនៅទីតាំងទាំងនេះ ។ គាត់ទាំងអស់គ្នាបង្ហាញពីការយល់ឃើញ និងអារម្មណ៍ផ្ទាល់ខ្លួនយ៉ាងច្បាស់លាស់ ។ តួយ៉ាងសមាជិកក្រុមប្រឹក្សាឃុំម្នាក់កត់សម្គាល់ពីសារប្រយោជន៍នៃដំណើរទស្សនកិច្ចនេះ ពីព្រោះគាត់មិនដែលមានឱកាសបានមកឃើញសារមន្ទីរប្រល័យពូជសាសន៍ផ្ទាល់នឹងភ្នែកឡើយក្រោយពីរបបខ្មែរក្រហមដួលរលំ ។ ការមកឃើញកន្លែងសួរចម្លើយនិងឧបករណ៍ធ្វើទារុណកម្មទាំងនេះ ធ្វើឲ្យគាត់មានការតក់ស្លុត នឹកឃើញដល់បទពិសោធន៍ដ៏ជូរចត់សម្រាប់គាត់និងរំឭកគាត់ពីឧក្រិដ្ឋកម្មសម្លាប់មនុស្សដោយគ្មានការដាក់ទោសតាមផ្លូវច្បាប់ ។

ចម្លើយតបនឹងសំណួរស្ទាបស្ទង់មតិផ្តោតលើគោលគំនិតស្រដៀងគ្នា ។ ក្នុងនោះ មានចម្លើយមួយសង្កត់ធ្ងន់ពីអំពើព្រៃផ្សៃ ប្រព្រឹត្តនៅក្នុងគុកទួលស្លែងដែលជាកន្លែងមនុស្សរាប់ពាន់នាក់បាត់បង់ជីវិតក្នុងដៃឃាតករ ។ បន្ថែមពីនេះ គាត់បានថ្លែងអំណរគុណដល់មជ្ឈមណ្ឌលដែលបានជួយឧបត្ថម្ភសោហ៊ុយធ្វើដំណើរនិងថ្លៃចាយវាយក្នុងអំឡុងពេលប៉ុន្មានថ្ងៃនេះ ។ ដោយឡែក ចម្លើយមួយទៀតយល់ឃើញថា ដំណើរទស្សនកិច្ចនេះសំខាន់ណាស់ ហើយគាត់ថែមទាំងបានភ្ជាប់សុភាសិតខ្មែរថា «ស្តាប់ឮដប់ដងមិនស្មើនឹងឃើញផ្ទាល់ភ្នែកម្តង» ។

ខែម ផល្លា គ្រូបង្រៀននៅស្រុកព្រៃកប្បាស ខេត្តតាកែវ និយាយថា «យើងអាចចាត់ទុកដំណើរទស្សនកិច្ចនេះថាជាការស្វែងរកការពិតនិងយុត្តិធម៌សង្គមពីឧក្រិដ្ឋកម្មប្រព្រឹត្តក្នុងរបប៣ឆ្នាំ ៨ខែ និង២០ថ្ងៃ» ។ បន្ទាប់ពីបានឃើញទីតាំងប្រវត្តិសាស្ត្រទាំងនេះ គាត់នឹកឃើញដល់ទុក្ខវេទនាដែលគាត់ឆ្លងកាត់ក្នុងរបបខ្មែរក្រហម ។ ចម្លើយមួយពីខេត្តកំពង់ចាម សង្កត់ធ្ងន់ពីអារម្មណ៍ច្របូកច្របល់របស់គាត់ ។ ថ្វីដ្បិតតែគាត់មានកំហឹងចំពោះរបបនោះ ប៉ុន្តែគាត់រីករាយដែលបានមកចូលរួមនិងមើលឃើញទីតាំងប្រវត្តិសាស្ត្រ ។ គាត់បានឲ្យដឹងថា ក្នុងភូមិរបស់គាត់មានសាកសពតែបីបួនប៉ុណ្ណោះក្នុងមួយរណ្តៅ ។ ប៉ុន្តែបន្ទាប់ពីទស្សនាវាលពិឃាតជើងឯក គាត់ភ្ញាក់ផ្អើលយ៉ាងខ្លាំងដែលចំនួនមនុស្សស្លាប់ច្រើនសន្ធឹកសន្ធាប់ស្ទើរតែមិនគួរឲ្យជឿ ។

បញ្ជាក់បន្ថែមលើចម្លើយខាងលើ ចម្លើយមួយទៀតសរសេរថា ដំណើរទស្សនកិច្ចនេះមានផលល្អសម្រាប់គាត់ពីព្រោះគាត់បានដឹងសកម្មភាពមេដឹកនាំខ្មែរក្រហមសម្លាប់ខ្មែរគ្នាឯងក្រោមរូបភាពដ៏សាហាវបំផុត ។ ដំណើរទស្សនកិច្ចនេះជាផ្លូវឆ្ពោះទៅរកការពិតមួយ តាមរយៈការឲ្យផ្តល់ឱកាសឲ្យជនរងគ្រោះមកទស្សនាទីតាំងឧក្រិដ្ឋកម្មនេះផ្ទាល់ បើទោះបីជាអ្នកមកចូលរួមមួយចំនួនមានកំហឹងចំពោះខ្មែរក្រហមក៏ដោយ ។ ជាទូទៅ ការប្រឈមមុខ


សិស្សនិស្សិតជួបសំណេះសំណាលជាមួយមន្ត្រីសាធារណៈ នៅមុខរូបសំណាកអ្នកតាដំបងដែក

នឹងអតីតកាលជាការចាំបាច់និងអាចជួយឲ្យក្មេងជំនាន់ក្រោយចៀសវាងការប្រព្រឹត្តរឿងប្រវត្តិសាស្ត្រនេះម្តងទៀត ។

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** ជាអគារទើបនឹងស្ថាបនាថ្មីសម្រាប់ធ្វើទីបញ្ជាការកងយោធពលខេមរភូមិន្ទ មានទីតាំងនៅជាយរាជធានីភ្នំពេញ ។ អគារនេះត្រូវបានប្រែក្លាយជាការិយាល័យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ជាអគារដែលមានកម្ពស់បួនជាន់និងមានបន្ទប់សវនាការរាងពាក់កណ្តាលរង្វង់មូលនៅក្នុងបរិវេណអង្គជំនុំជម្រះវិសាមញ្ញនេះ ។ អគារទាំងនេះស្វាគមន៍អ្នកមកចូលរួមដំណើរទស្សនកិច្ចនិងសាធារណជនយ៉ាងកក់ក្តៅ ។ ឈានជើងចូលបន្ទប់សវនាការ យើងនឹងឃើញកៅអីពណ៌ខៀវចំនួន៦០០តម្រៀបនៅក្រោមពិដានដែលមានសុទ្ធតែអំពូលភ្លើងពណ៌លឿងជះពន្លឺមកលើវេទិកានិងជណ្តើរឈើធ្វើពីក្តាររលោង និងជញ្ជាំងពណ៌សដែលទើបនឹងលាបថ្នាំថ្មីៗ ។

អគារសវនាការបង្កើតឡើងដើម្បីកាត់ទោស «មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងជនទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មប្រព្រឹត្តពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩» ។ ប្រជាជននៅតាមបណ្តាទីក្រុង និងទីរួមខេត្តនានាសុទ្ធតែបានដឹងពីវត្តមានតុលាការនេះ ប៉ុន្តែប្រជាជននៅតាមទីជនបទដែលគ្មានលទ្ធភាពទទួលការផ្សព្វផ្សាយមិនបានស្វែងយល់ពីការបង្កើតតុលាការនេះទេ ។ ដូច្នេះការចែករំលែកព័ត៌មានអាចជួយឲ្យគាត់យល់ដឹងអំពីដំណើរការនិងសារសំខាន់របស់វា ។ ជាក់ស្តែង ប្រជាជនម្នាក់ឆ្លើយថា ប្រសិនបើគ្មានដំណើរទស្សនកិច្ចនេះទេ គាត់មិនដឹងជាស្វែងយល់ពីតុលាការនេះដូចម្តេចឡើយ ។ គាត់សង្កត់ធ្ងន់ទៀតថា ការមកចូលរួមលើកនេះធ្វើឲ្យគាត់មានអារម្មណ៍ធូរស្រាលនិងយល់ដឹងកាន់តែច្បាស់ពីច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ។

បន្ថែមលើភាពសំខាន់នៃដំណើរទស្សនកិច្ច ប្រជាជនម្នាក់យល់ឃើញថា ដំណើរទស្សនកិច្ចនេះ រំពុកពីអារម្មណ៍ប្រជាជនឲ្យចងកំហឹងរបបខ្មែរក្រហម ។ នេះជាការជំរុញប្រជាជនឲ្យសហការគ្នាយ៉ាងជិតស្និទ្ធជាមួយតុលាការតាមរយៈការផ្តល់ភ័ស្តុតាងនិងសាក្សី ។ ប្រជាជនម្នាក់នេះបញ្ជាក់ថា ញត្តិ និងពាក្យបណ្តឹងដើរតួនាទីសំខាន់ក្នុងការរួមចំណែកជំរុញឲ្យតុលាការស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះគ្រប់រូប ។

ប្រជាជនម្នាក់ទៀតនិយាយថា ការទស្សនាបន្ទប់សវនាការ ការជួបជាមួយមន្ត្រីព័ត៌មាន និងអ្នកជំនាញការច្បាប់ ជាសញ្ញាណជាក់លាក់មួយក្នុងដំណើរស្វែងរកយុត្តិធម៌ដែលទាំងភាគីកម្ពុជានិងសហគមន៍អន្តរជាតិកំពុងធ្វើការទាមទារឲ្យប្រជាជនកម្ពុជា ។ នេះសបង្ហាញឲ្យឃើញថា ទាំងអស់គ្នាមិនបានភ្លេចភ្លេក មិនរវល់ចំពោះវិញ្ញាណក្ខន្ធអ្នកដែលស្លាប់ក្នុងរបប ប៉ុល ពត ទេ ។

នេះបង្ហាញថា ប្រជាជនមកចូលរួមពេញចិត្តនឹងមានសវនាការមួយដែលផ្តល់ឲ្យជនរងគ្រោះនូវពន្លឺនៃក្តីសង្ឃឹម ។ សមាជិកក្រុមប្រឹក្សាភូមិមួយរូបសរសេរថា គាត់ចង់ដឹងថាតើថ្ងៃណាទើបសវនាការកើតមានដើម្បីឲ្យប្រជាជនកម្ពុជាមានដំណោះស្រាយពិតប្រាកដមួយឈានទៅរកការពិត ។ យ៉ាងណាមិញ គាត់សម្តែងការព្រួយបារម្ភ ដោយនិយាយថា «សុំកុំដាក់ទោសជនគ្មានកំហុសដែលជាប់ចោទថា បានសម្លាប់អ្នកនេះ អ្នកនោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សុំលើកលែងទោសដល់អ្នកដែលស្មោះត្រង់នឹងជាតិ» ។

យោងតាមសំណួរស្ទាបស្ទង់ អ្នកមកចូលរួមបានយល់ដឹងច្រើនតាមរយៈការទស្សនាបន្ទប់សវនាការ ។ ប្រជាជនម្នាក់រៀបរាប់ប្រាប់បុគ្គលិកមជ្ឈមណ្ឌលឡើងវិញអំពីរចនាសម្ព័ន្ធនៃអង្គជំនុំជម្រះវិសាមញ្ញថា សវនាការនេះមានពីដំណាក់កាលដោយមានការចូលរួមពីសំណាក់ជាតិនិងសហគមន៍អន្តរជាតិ ។ រៀងរាល់ការសម្រេចចិត្តចាំបាច់ធ្វើឡើងដោយភាគីទាំងពីរ ។ ជាងនេះទៅទៀត គាត់សង្កត់ធ្ងន់ទៅលើចំណុចក្នុងច្បាប់សាលាក្តីនេះថា មានតែមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងជនទទួលខុសត្រូវខ្ពស់បំផុតទេដែលនឹងនាំយកមកកាត់ទោសក្នុងសវនាការ ។ ប្រសិនបើចុងចោទត្រូវបានរកឃើញថា ប្រព្រឹត្តឧក្រិដ្ឋកម្ម ទោសធ្ងន់បំផុតនោះគឺពិរុទ្ធជនមានទោសត្រឹមតែជាប់គុកអស់មួយជីវិតប៉ុណ្ណោះ ។

ការខិតខំប្រឹងប្រែងជួយប្រជាជនឲ្យរកច្រកចេញពីបទពិសោធន៍ដ៏ជូរចត់នេះ និងបែរមកទស្សនាផ្ទាល់នូវទីតាំងប្រវត្តិសាស្ត្រ ជាការសំខាន់អាចជួយឲ្យគាត់រក្សាការចងចាំបានយូរអង្វែង ។ ប្រជាជនទាំងនេះ នឹងក្លាយជាឯកសាររស់ដែលអាចជួយចែករំលែកអ្វីដែលគាត់បានដឹងឮជាមួយសាច់ញាតិ អ្នកជិតខាង និងប្រជាជនឯទៀតដែលរស់នៅក្នុងសហគមន៍ជាមួយគ្នា ។

## ៣) ទស្សនៈអំពីយុត្តិធម៌និងការផ្សះផ្សារបស់បុគ្គល

ប្រជាជនបង្ហាញពីចំណាប់អារម្មណ៍ផ្សេងៗទាក់ទិននឹងសំណួរត្រង់ចំណុចយុត្តិធម៌និងការផ្សះផ្សា ។ ប្រជាជនមួយចំនួនធំមានការគាំទ្រយ៉ាងមុតមាំដើម្បីស្វែងរកយុត្តិធម៌និងការផ្សះផ្សា ។ អ្នកចូលរួមមួយចំនួនបានភ្ជាប់គោលគំនិតផ្សះផ្សាជាមួយនឹងការអភិវឌ្ឍន៍សង្គម ។ ប្រជាជនម្នាក់មានអារម្មណ៍ធូរស្រាលក្រោយពីបានឃើញសាលាក្តីនេះដំណើរការស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះ ។ ប្រជាជនម្នាក់ទៀតយល់ថា ប្រជាជនកម្ពុជាទាំងអស់គួរតែឈប់ចងគំនុំគ្នា ហើយងាកមករកការផ្សះផ្សាជាតិវិញ ។ គាត់គិតថាប្រទេសកម្ពុជាបានឆ្លងកាត់ជម្លោះគ្រប់គ្រាន់ហើយ ។ អ្នកទាំងពីរនាក់បានដកស្រង់ពាក្យទូន្មានរបស់ព្រះពុទ្ធថា «ពៀររំងាប់ដោយការមិនចងពៀរ» ។ នេះមានន័យថា យើងគួរបញ្ចប់វដ្តនៃការសងសឹក ។ ប្រសិនបើគ្មានការផ្សះផ្សាទេនោះ ប្រទេសនឹងជួបប្រទះសង្គ្រាម គ្មានសន្តិភាព គ្មានស្ថិរភាព ហើយប្រទេសនឹងគ្មានការអភិវឌ្ឍន៍ ។

អ្នកខ្លះយល់ឃើញថា ដំណើរទស្សនកិច្ចនេះនឹងនាំមកនូវការផ្សះផ្សារវាងអតីតកម្មាភិបាលថ្នាក់ក្រោមដែលសម្លាប់ប្រជាជនសាមញ្ញដោយសារតែមានបញ្ជាពីថ្នាក់លើ ដោយសារអវិជ្ជានិងដោយសារខ្លួនវ័យក្មេងគ្មានការពិចារណា ។ ទោះជាយ៉ាងណា គាត់នៅតែមានកំហឹងចំពោះមេដឹកនាំជាន់ខ្ពស់ដែលមានចំណេះដឹងពេញខ្លួន ហើយបែរជាមកប្រព្រឹត្តអំពើព្រៃផ្សៃបែបនេះ ។ គាត់ឆ្ងល់ថាហេតុអ្វីបានជាមេដឹកនាំជាន់ខ្ពស់ទាំងនោះក្លាយជាមនុស្សឆ្កួតលេលាដូច្នេះ ។ គាត់គិតថា ការផ្លាស់ប្តូររបបច្រើនលើកច្រើនសាឆ្លុះបញ្ចាំងពីសង្គមមួយដែលបែកខ្ញែកដោយសារសង្គ្រាមផ្ទៃក្នុងឥតឈប់ឈរ ។ កត្តាចម្បងដែលបណ្តាលឲ្យគ្មានឯកភាពនៅកម្ពុជាគឺអយុត្តិធម៌សង្គម ។ ដូច្នេះ តម្រូវការចាំបាច់បច្ចុប្បន្នគឺ ការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះពីសម័យខ្មែរក្រហម ។ ប្រសិនបើយុត្តិធម៌ទទួលបានការផ្សះផ្សាជាតិអាចគង់វង្សស្ថិតស្ថេរយូរអង្វែង ។

យ៉ាងណាមិញ អ្នកខ្លះពិបាកចិត្តពេលដែលបានឃើញសារជាតិពិតនៃរបបកម្ពុជាប្រជាធិបតេយ្យដែលបង្ហាញក្រោមរូបភាពជាមន្ទីរឃុំឃាំងនានា ។ ក្នុងចំណោមប្រជាជនទាំងនោះមានម្នាក់សរសេរថា «ដំណើរទស្សនកិច្ចនេះធ្វើឲ្យខ្ញុំកាន់តែចងកំហឹងខ្លាំងឡើង ។ ខ្ញុំសំណូមពរឲ្យសាលាក្តីនេះ ចាប់ផ្តើមបើកសវនាការឲ្យឆាប់មុនពេលដែលមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមស្លាប់ ព្រោះមនុស្សស្លាប់មិនអាចមានវត្តមានរកខុសត្រូវក្នុងសវនាការឡើយ ។ ប្រសិនបើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមស្លាប់មុនពេលបើកសវនាការប្រាកដជាគួរឲ្យសោកស្តាយណាស់ ហើយអំពើដែលអ្នកទាំងនោះធ្វើមិនត្រូវបានកត់ត្រាក្នុងប្រវត្តិសាស្ត្រឡើយ ។ ខ្ញុំយល់ថាការផ្សះផ្សាជាតិជារឿងធម្មតាទេ ពីព្រោះយើងបានទទួលរួចហើយ រីឯយុត្តិធម៌តាមផ្លូវច្បាប់នឹងក្លាយជាឧទាហរណ៍ល្អសម្រាប់ប្រទេស



សិស្សវិទ្យាល័យកំពុងកត់ត្រាវិន័យសន្តិបាលនៅបរិវេណមន្ទីរឧក្រិដ្ឋកម្មប្រល័យ

កម្ពុជានិងសហគមន៍អន្តរជាតិ» ។

ពិចារណាលើគំនិតផ្សះផ្សាជាតិនិងយុត្តិធម៌ ប្រជាជនម្នាក់និយាយថា មេដឹកនាំប្រទេសកម្ពុជាសុទ្ធតែបានដឹងថា គ្មានបរទេសណាគិតគូរប្រទេសកម្ពុជាជាងជនជាតិកម្ពុជាឡើយ ។ ប្រជាជនកម្ពុជាត្រូវចេះស្រឡាញ់នឹងជួយជនជាតិដូចគ្នា ។ មានតែមធ្យោបាយនេះទេដែលអាចឲ្យប្រទេសកម្ពុជាចុះសម្រុងគ្នា និងប្រកបដោយភាពរុងរឿង ។ គាត់បន្ថែមទៀតថា «ខ្ញុំសុំឲ្យប្រជាជនកម្ពុជាទាំងឡាយកុំវាយប្រហារគ្នា» ។

ប្រជាជនម្នាក់ទៀតបង្ហាញគោលជំហរយ៉ាងមុតមាំ

តាមរយៈសំណេររបស់គាត់៖ «តាមរយៈដំណើរទស្សនកិច្ច ខ្ញុំបានទទួលការផ្សះផ្សាជាបុគ្គលហើយ ពីព្រោះខ្ញុំជឿជាក់ថា សាលាក្តីនេះនឹងផ្តល់យុត្តិធម៌ដល់ក្រុមគ្រួសារជនរងគ្រោះ» ។ ផ្ទុយទៅវិញ ទោះបីជាដឹងថា ដំណើរការស្វែងរកយុត្តិធម៌របស់អង្គជំនុំជម្រះវិសាមញ្ញមានគោលបំណងឈានទៅរកការផ្សះផ្សា និងយុត្តិធម៌ក៏ដោយ ប្រជាជនម្នាក់បែរជាយល់ថា ដំណើរទស្សនកិច្ចនេះមិនបានផ្តល់ការផ្សះផ្សាជូនគាត់ទាល់តែសោះ ពីព្រោះគាត់មិនអាចបំភ្លេចរឿងរ៉ាវទាំងនេះបាន ។ ដើម្បីទទួលបានការផ្សះផ្សា យើងចាំបាច់ត្រូវកំណត់កម្រិតមួយ ។ គាត់សង្កត់ធ្ងន់ថា «យុត្តិធម៌ជាបុគ្គលអាចកើតមានឡើង ដរាបណាតុលាការអាចសម្រេចបានយុត្តិធម៌យ៉ាងហោចណាស់៨០ភាគរយ» ។


ពូជសាសន៍ទួលស្លែង

ប្រជាជនម្នាក់ទៀតលើកចំណុចមួយថា តុលាការនេះមិនត្រឹមតែមានគោលបំណងសម្រេចឲ្យបាននូវការផ្សះផ្សា និងយុត្តិធម៌ប៉ុណ្ណោះទេ ថែមទាំងបញ្ចៀសការកើតឡើងវិញនូវអំពើដ៏ឃោរឃៅផង ។

ឆ្លងតាមបទសម្ភាសន៍និងសំណួរស្ទាបស្ទង់មតិ ប្រជាជនសុទ្ធតែយល់ឃើញថា សវនាការនឹងធ្វើឲ្យជនរងគ្រោះទទួលបានយុត្តិធម៌សម្រាប់កំណត់ត្រាប្រវត្តិសាស្ត្រកម្ពុជាក៏ដូចជាពិភពលោកទាំងមូល និងសម្រាប់ជាឧទាហរណ៍ដល់ក្មេងជំនាន់ក្រោយ ។ អ្នកមកចូលរួមដំណើរទស្សនកិច្ចនឹងទទួលបានចំណេះដឹងពីរបបខ្មែរក្រហមតាមរយៈការទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង វាលពិឃាតជើងឯក ការសិក្សាអំពីបញ្ហាផ្លូវច្បាប់និងព័ត៌មានទាក់ទិននឹងអង្គជំនុំជម្រះវិសាមញ្ញ ។ សកម្មភាពទាំងនេះជំរុញឲ្យប្រជាជនក៏ដូចជាអ្នកភូមិរបស់គាត់ទាំងអស់ផ្តោតការយកចិត្តទុកដាក់ទៅលើការស្វែងរកយុត្តិធម៌របស់អង្គជំនុំជម្រះវិសាមញ្ញ ។

## ៤) សន្និដ្ឋាន

ការជួយឲ្យសាធារណជនយល់ដឹងពីបញ្ហាយុត្តិធម៌ដែលនឹងស្តែងចេញតាមរយៈសាលាក្តីខ្មែរក្រហមគឺជាផ្នែកចម្បងនៃគម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ កិច្ចការទាំងនេះកើតចេញពីជំនឿចិត្តរបស់យើងថា ប្រជាជនទទួលព័ត៌មានល្អកម្រិតណា គាត់អាចមានលទ្ធភាពចូលរួមដំណើរការស្វែងរកយុត្តិធម៌កម្រិតនោះដែរឬទេ ។ គម្រោងនេះជំរុញឲ្យអ្នករស់រានមានជីវិតសម្តែងចេញនូវរឿងរ៉ាវផ្ទាល់ខ្លួន ដើរតួនាទីជាសាក្សីក្នុងករណីតុលាការត្រូវការចម្លើយបំភ្លឺនិងជាអ្នកសង្កេតសវនាការ ។ ការតាមដានយ៉ាងជិតដល់របស់គាត់ចំពោះដំណើរការស្វែងរកយុត្តិធម៌ប្រាកដជាអាចធានាឲ្យអង្គជំនុំជម្រះវិសាមញ្ញ រកយុត្តិធម៌ជូនជនរងគ្រោះពីរបបប្រល័យពូជសាសន៍ប្រកបដោយឯករាជ្យភាព អព្យាក្រឹត និងភាពមិនលម្អៀង ។

យ៉ាងណាក៏ដោយ តម្រូវការនាំប្រជាជនមកទស្សនាទីតាំងប្រវត្តិសាស្ត្រនៅតែមាន ។ ជាក់ស្តែងតាមរយៈការចុះសាកសួរតាមខេត្តក្រចេះ អ៊ីង ដែត បង្ហាញពីការសោកស្តាយដែលប្តីរបស់គាត់បាត់បង់ជីវិតក្នុងគុកទួលស្លែង ។ គាត់ចង់រករូបថតប្តីរបស់គាត់ដើម្បីយកមកធ្វើបុណ្យ ។ គាត់កំពុងរង់ចាំយ៉ាងអត់ធ្មត់ដើម្បីទទួលលិខិតអញ្ជើញពីមជ្ឈមណ្ឌលដើម្បីបានចូលរួមដំណើរទស្សនកិច្ចនេះ ។ ទោះបីជាយ៉ាងណា គាត់នឹងមានឱកាសមកទស្សនាទីតាំងប្រវត្តិសាស្ត្រទាំងនេះនៅពេលក្រោយ ។

អារម្មណ៍របស់ប្រជាជនមកចូលរួមបង្ហាញថា ប្រជាជនចង់ដឹងចង់ឮពីយុត្តិធម៌ផ្លូវតុលាការដែលរៀបចំឡើងដោយអង្គជំនុំជម្រះវិសាមញ្ញ ។ តាមរយៈដំណើរការនេះ ប្រជាជនខ្លះអាចមានការធូរស្រាល បន្ទាប់ពីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងអ្នកទទួលខុសត្រូវខ្ពស់បំផុតត្រូវបានដាក់ទោសតាមផ្លូវច្បាប់ ។ ដូច្នេះ ក្រោយពីវប្បធម៌រួចទោសរលាយបាត់ ប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតរបស់កម្ពុជានឹងត្រូវបញ្ចប់ជាផ្លូវការ ។ នេះជាការបើកផ្លូវមួយសម្រាប់ឲ្យប្រជាជនកម្ពុជាបោះជំហានទៅមុខប្រកបដោយជំនឿចិត្តនិងភាពរុងរឿង ។ ជាមួយនឹងការចូលរួមពីសំណាក់សាធារណជនជាច្រើន ការខំប្រឹងប្រែងនៅជំហានបន្ទាប់នឹងជួយឲ្យជនរងគ្រោះផ្សះផ្សាខ្លួនឯង ជាមួយសហគមន៍ដែលខ្លួនរស់នៅនិងជាមួយសង្គមជាតិទាំងមូល ។

**លី សុខឃាង**

# ការផ្តល់យុត្តិធម៌ចំពោះឧក្រិដ្ឋកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

***(តចប់)***

### ***ការកាត់ក្តីដោយត្រឹមត្រូវគឺជាកត្តាសំខាន់មួយនៃយុត្តិធម៌***

ចំនួននិងឋានៈជាមេដឹកនាំជាន់ខ្ពស់ដែលនឹងត្រូវយកមកកាត់ទោសដោយតុលាការខ្មែរក្រហម មិនមែនជាបញ្ហាចោទនោះទេ ជោគជ័យនៃតុលាការនេះនឹងត្រូវបានកំណត់ដោយសមត្ថភាពក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ។ ដំណើរការកាត់សេចក្តីនិងសេចក្តីសម្រេចចិត្តរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងត្រូវទទួលស្គាល់ថាត្រឹមត្រូវតាមច្បាប់ដោយប្រជាជនកម្ពុជានិងអ្នកសង្កេតការណ៍បរទេសបាន លុះត្រាតែតុលាការនេះគោរពតាមស្តង់ដារយុត្តិធម៌ ដែលទទួលស្គាល់ជាអន្តរជាតិ ។

### ***ទស្សនវិស័យនៃការកាត់សេចក្តីដោយយុត្តិធម៌***

ឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មក្នុងកំឡុងសង្គ្រាមលោកលើកទី២ និងការកើនឡើងនូវការស្រុះស្រួលគ្នាក្នុងចំណោមសមាជិកនៃសហគមន៍អន្តរជាតិ អង្គការសហប្រជាជាតិនិងអង្គការនយោ-បាយក្នុងតំបន់បានបង្កើតឡើងនូវបទបញ្ញត្តិជាច្រើន ដើម្បីការពារសិទ្ធិនិងសេរីភាពជាមូលដ្ឋានរបស់មនុស្ស ។ បទបញ្ញត្តិទាំងអស់នោះបានបង្កើតឲ្យមាននូវសន្ធិសញ្ញា ឬអនុសញ្ញាតាមតំបន់និងអន្តរជាតិផ្សេងៗជាច្រើនទៀតដូចជាអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស និងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ។ ដោយធ្វើការផ្តល់សច្ចាប័នលើឧបករណ៍ច្បាប់ទាំងនេះ ប្រទេសជាច្រើនបានទទួលយកនូវកាតព្វកិច្ចផ្លូវច្បាប់ ដើម្បីធានាសិទ្ធិប្រជាជនទាំងអស់នៅក្នុងប្រទេសរបស់ខ្លួន ។

សិទ្ធិសំខាន់ៗមួយចំនួនដែលមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនិងឧបករណ៍ច្បាប់ប្រហាក់ប្រហែលគ្នាដទៃទៀត បានការពារចុងចោទនៅក្នុងការកាត់សេចក្តីផ្នែកព្រហ្មទណ្ឌ ។ ច្បាប់អន្តរជាតិបានចែងថា ជនជាប់ចោទនឹងត្រូវបានចាត់ទុកថាជាជនគ្មានទោស រហូតដល់ពេលតុលាការបង្ហាញភ័ស្តុតាងថាជននោះមានទោសកាត់ក្តីដោយយុត្តិធម៌និងក្នុងពេលវេលាសមស្របនិងទទួលបាននូវសិទ្ធិតាមច្បាប់នីតិវិធីមួយចំនួន ។ ឧទាហរណ៍ ចុងចោទទទួលបាននូវសិទ្ធិមានអ្នកតំណាងតាមផ្លូវច្បាប់ និងសិទ្ធិទទួលបាននូវពេលវេលានិងមធ្យោបាយគ្រប់គ្រាន់ ដើម្បីរៀបចំការការពាររបស់ខ្លួន ។ ការបដិសេធចោលនូវសិទ្ធិទាំងនេះ គឺជាសញ្ញានៃប្រព័ន្ធតុលាការមិនយុត្តិធម៌និងភាពខ្សោយនៃនីតិរដ្ឋ ។ ផ្ទុយមកវិញ ការការពារបាននូវសិទ្ធិរបស់ចុងចោទជាសញ្ញាបង្ហាញថា ប្រទេសនេះបានតាំងចិត្តសម្រេចឲ្យបាននូវយុត្តិធម៌ជាជាងការសងសឹក ។

ការគោរពសិទ្ធិរបស់ចុងចោទក៏បានផ្តល់នូវភាពស្របច្បាប់និងភាពគួរទុកចិត្តបានសម្រាប់ដំណើរការផ្លូវច្បាប់មួយនេះផងដែរ ។ គោលការណ៍នេះមានសារសំខាន់ខ្លាំងណាស់ នៅពេលតុលាការធ្វើការកាត់ក្តីបទឧក្រិដ្ឋដែលមានទំហំធំធេងនិងដែលមនុស្សគ្រប់រូបបានដឹងឮ ដូចជាឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។ ប្រសិនបើការកាត់សេចក្តីមានភាពលម្អៀងនិងមិនយុត្តិធម៌សហគមន៍អន្តរជាតិក៏ដូចជាអ្នកសង្កេតការណ៍ក្នុងស្រុកនឹងបដិសេធការរកឃើញរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ការកាត់សេចក្តី ប៉ុល ពត និង អៀង សារី ដោយកំបាំងមុខនៅឆ្នាំ១៩៧៩ គឺជាឧទាហរណ៍មួយក្នុងចំណោមនោះ ។ ផ្ទុយទៅវិញ ការកាត់សេចក្តីដោយយុត្តិធម៌នឹងត្រូវបានមើលឃើញថាស្របច្បាប់ពីគ្រប់ភាគីទាំងអស់ក៏ដូចជាសង្គមជាតិទាំងមូលដែរ ។ ជនជាប់ចោទទំនងជានឹងទទួលយកសេចក្តីសម្រេចចិត្តរបស់តុលាការ និងទទួលស្គាល់ពីកំហុសរបស់ខ្លួន ប្រសិនបើជនទាំងនោះទទួលស្គាល់ថា ដំណើរការកាត់សេចក្តីនេះប្រព្រឹត្តទៅដោយយុត្តិធម៌ ។ ប្រហែលជាសំខាន់ជាងនេះទៀត ជនរងគ្រោះនឹងមានជំនឿកាន់តែខ្លាំង នៅពេលដែលឧក្រិដ្ឋជនពិតប្រាកដត្រូវបានកាត់ទោស បន្ទាប់ពីពិនិត្យពិច័យទៅលើភ័ស្តុតាងឲ្យបានត្រឹមត្រូវរួចមក ។ ប្រតិបត្តិការកាត់សេចក្តីដោយយុត្តិធម៌របស់អង្គការលើកលែងទោសអន្តរជាតិ បានលើកឡើងដ៏គួរឲ្យជឿជាក់ថា ៖

*រដ្ឋាភិបាលទាំងអស់មានកាតព្វកិច្ច ត្រូវតែនាំយកឧក្រិដ្ឋជនមកទទួលខុសត្រូវនៅចំពោះមុខច្បាប់ ។ ទោះជាយ៉ាងណាក៏ដោយ*

ប្រសិនបើប្រជាជនទទួលបាននូវការកាត់សេចក្តីដោយអយុត្តិធម៌នោះ យុត្តិធម៌នឹងមិនអាចទទួលបានទេ ។ នៅពេលប្រជាជនទទួលរងនូវទារុណកម្មឬការប្រព្រឹត្តមកលើមិនត្រឹមត្រូវពីសំណាក់មន្ត្រីអនុវត្តច្បាប់ នៅពេលជនគ្មានកំហុសត្រូវបានកាត់ទោស ឬនៅពេលការកាត់សេចក្តីត្រូវបានធ្វើឡើងដោយអយុត្តិធម៌ ឬត្រូវបានប្រជាជនយល់ឃើញថាមិនយុត្តិធម៌ ប្រព័ន្ធយុត្តិធម៌នោះនឹងបាត់បង់នូវភាពអាចគួរទុកចិត្តបាន ។ ប្រសិនបើសិទ្ធិមនុស្សមិនត្រូវបានគោរពនៅក្នុងប៉ុស្តិ៍ប៉ូលិស បន្ទប់សួរចម្លើយ មន្ទីរឃុំឃាំង តុលាការ និងគុកទេនោះ មានន័យថា រដ្ឋាភិបាលបរាជ័យក្នុងការបំពេញកាតព្វកិច្ចនិងបោកប្រាស់ការទទួលខុសត្រូវរបស់ខ្លួន ។

អង្គការសហប្រជាជាតិបានសង្កត់ធ្ងន់ទៅលើសារសំខាន់នៃការកាត់សេចក្តីដោយយុត្តិធម៌ នៅពេលរៀបចំបង្កើតសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិ និងតុលាការចម្រុះ ដោយយល់ឃើញថា ភាពស្របច្បាប់និងភាពគួរទុកចិត្តបានសម្រាប់សាលាក្តីទាំងនេះ អាស្រ័យលើគោលគំនិតដែលថា សាលាក្តីទាំងនេះប្រព្រឹត្តទៅលើភាគីទាំងអស់ស្មើៗគ្នា ។ លក្ខន្តិកៈសម្រាប់សាលាក្តីទាំងនេះរួមមានទាំងបទបញ្ញត្តិដែលធានាសិទ្ធិរបស់ចុងចោទ ដែលមានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ។

ក្រុមអ្នករិះគន់មួយចំនួនបានរិះគន់តុលាការដែលគាំទ្រដោយអង្គការសហប្រជាជាតិថា បានធ្វើតាមការទាមទាររបស់ចុងចោទខ្លាំងពេក ដែលបានធ្វើឲ្យខូចប្រយោជន៍ដល់ដំណើរការកាត់សេចក្តី ។ ឧទាហរណ៍ អ្នកខ្លះបានរកឃើញកំហុសអំពីរយៈពេលយូរនៃការកាត់សេចក្តីមេដឹកនាំ ស៊ែបប៊ី ស្លូបូដាន់ មីឡូសើវិក ដែលជាកំហុសមួយផ្នែកនៃការសង្កត់ធ្ងន់របស់តុលាការទៅលើសិទ្ធិរបស់ជនជាប់ចោទម្នាក់នេះ ។ សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូ-ហ្គោស្លាវីមានកំហុសដោយតុលាការនេះបានផ្តល់ឲ្យ មីឡូសើវិកនូវសិទ្ធិនិងការនិយាយដែលផ្សាយផ្ទាល់តាមទូរទស្សន៍យូរពេកដែលបានធ្វើឲ្យខូចប្រយោជន៍ ដល់ការប្រើប្រាស់ក្នុងស្រុកនៅក្នុងប្រទេសស៊ែបប៊ី ។ ជាងនេះទៅទៀត សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានចំណាយថវិកាយ៉ាងច្រើនទៅលើការពន្យារការកាត់ក្តី និងខកខានមិនបានចេញសាលក្រមមុនពេលមេដឹកនាំរូបនេះស្លាប់ ។

តុលាការខ្មែរក្រហមនឹងមានកាតព្វកិច្ចមួយដ៏លំបាក ក្នុងការធានានូវតុល្យភាពរវាងសិទ្ធិរបស់ចុងចោទនិងការធានាការកាត់សេចក្តីឲ្យបានឆាប់រហ័ស ។ ប្រសិនបើដំណើរការកាត់ក្តីនៃអង្គជំនុំជម្រះវិសាមញ្ញត្រូវបានពន្យារពេលយូរ ចុងចោទដែលជាមេដឹកនាំខ្មែរក្រហមមួយចំនួនអាចស្លាប់ ឬមិនអាចឡើងតុលាការបានមុនពេលការជំនុំជម្រះក្តី ។ សម្រាប់មនុស្សមួយចំនួនប្រការនេះមានន័យថាជាការបាត់បង់ឱកាសក្នុងការស្វែងរកយុត្តិធម៌ ។

## ការធានាការកាត់ក្តីដោយយុត្តិធម៌ក្នុងតុលាការខ្មែរក្រហម

នីតិវិធីយុត្តិធម៌មានសារសំខាន់ខ្លាំងណាស់ ដើម្បីឲ្យអ្នកសង្កេតការណ៍មើលឃើញថា តុលាការខ្មែរក្រហមប្រព្រឹត្តទៅដោយស្របច្បាប់ ។ វាក៏ជាកត្តាជំរុញឲ្យច្បាប់យុត្តិធម៌អន្តរជាតិអាចជ្រាបចូលមកក្នុងប្រព័ន្ធតុលាការកម្ពុជាផងដែរ ។ ក្រុមសិទ្ធិមនុស្សមានបំណងស្វែងរកវិធីដើម្បីធានាឲ្យបានថាការកាត់ទោសទាំងឡាយនាពេលអនាគតនឹងប្រព្រឹត្តទៅដោយយុត្តិធម៌តាមតែអាចធ្វើទៅបាន ។

## តម្រូវការយុត្តិធម៌នៅក្នុងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ និងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ការរួមបញ្ចូលគ្នានៃបទបញ្ញត្តិដើម្បីធានាសិទ្ធិរបស់ចុងចោទនៅក្នុងឯកសារនៃការបង្កើតតុលាការខ្មែរក្រហម គឺជាតម្រូវការជាបឋមមួយសម្រាប់ការចូលរួមរបស់អង្គការសហប្រជាជាតិនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ ទោះបីជាអង្គសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានជជែកគ្នាអំពីបញ្ហានៃការដាក់បញ្ចូលបទបញ្ញត្តិមួយចំនួននៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយក៏ដោយ ក៏ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ជាចុងក្រោយបានរួមបញ្ចូលសិទ្ធិស្ទើរតែទាំងអស់របស់ចុងចោទ ដែលធានាដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ។ ឯកសារទាំងពីរនេះក៏បានបញ្ជាក់ផងដែរថា អង្គជំនុំជម្រះវិសាមញ្ញ

"គួរអនុវត្តដែនយុត្តាធិការរបស់ខ្លួនដោយអនុលោមទៅតាមស្តង់ដារយុត្តិធម៌អន្តរជាតិនិងប្រព័ន្ធច្បាប់តុលាការអន្តរជាតិ ដូចដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ។

ដោយកម្ពុជាបានផ្តល់សច្ចាប័នរួចហើយ ទៅលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ មនុស្សមួយចំនួនបានអះអាងថា វាមិនចាំបាច់ទេក្នុងការបញ្ជាក់អំពីចំណុចនេះនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ប៉ុន្តែ ការប្រុងប្រយ័ត្ននេះបានបង្ហាញពីការតាំងចិត្តរបស់អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា យ៉ាងហោចណាស់ក៏នៅក្នុងទ្រឹស្តីដែរ ក្នុងការការពារសិទ្ធិរបស់ចុងចោទ ។ នៅក្នុងន័យនេះ អ្នកស្រាវជ្រាវជាន់ខ្ពស់ ស៊ីវ ហេឌ័រ បាននិយាយថា "ទោះបីជាស៊ើរតែមានការបាត់បង់សក្តានុពលក្នុងការពង្រឹងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាក៏ដោយ ក៏ជាគោលការណ៍មិនមានអ្វីខុសជាមួយនឹងបញ្ហាសិទ្ធិមនុស្ស ឬបញ្ហាស្វែងរកការពិតដែរ" ។

## ការជ្រើសរើសបុគ្គលិកតុលាការ

ទោះជាយ៉ាងនេះក្តី ក្រុមសិទ្ធិមនុស្សនិងរដ្ឋាភិបាលលោកខាងលិចមួយចំនួនបានបង្ហាញពីកង្វល់ ចំពោះសមត្ថភាពរបស់អង្គជំនុំជម្រះវិសាមញ្ញ ក្នុងការធានាឲ្យបាននូវសិទ្ធិទាំងនេះនៅក្នុងការអនុវត្ត ។ ការសង្ស័យភាគច្រើនកើតចេញពីកង្វល់ អំពីឯករាជ្យភាពនិងភាពឥតលម្អៀងរបស់មន្ត្រីកម្ពុជា ។ ក្រុមអ្នករិះគន់មានកង្វល់ថា វានឹងមានព្រះរាជអាជ្ញានិងចៅក្រមខ្មែរភាគច្រើននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនេះ ។ នៅក្នុងអំឡុងពេលនៃការចរចាបង្កើតតុលាការខ្មែរក្រហម សកម្មជនសិទ្ធិមនុស្សបានទាមទារឲ្យមានការបង្កើតតុលាការមួយ ដែលរួមមានចៅក្រមនិងព្រះរាជអាជ្ញាអន្តរជាតិភាគច្រើនឬទាំងអស់ ដើម្បីកម្រិតគ្រោះថ្នាក់នៃការកាត់ក្តីមិនយុត្តិធម៌ ឬការត្រួតត្រាគ្មានប្រសិទ្ធភាព ។ ក្រុមឃ្លាំមើលសិទ្ធិមនុស្សបានតវ៉ានៅក្នុងរបាយការណ៍ឆ្នាំ២០០៥ថា "របាយការណ៍ស្តីពីការជ្រៀតជ្រែករបស់រដ្ឋាភិបាលកម្ពុជា ទៅលើតុលាការនិងការដាក់សម្ពាធទៅលើចៅក្រម ក៏ដូចជាកង្វះខាតនៃការបង្ហាត់បង្រៀនមន្ត្រីតុលាការជាច្រើននៅទូទាំងប្រទេស បានផ្តល់ហេតុផលគ្រប់គ្រាន់ចំពោះកង្វល់ដែលថា ការកាត់សេចក្តីអាចទទួលឥទ្ធិពលនយោបាយ" ។

ទោះជាយ៉ាងនេះក្តី មន្ត្រីអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា មិនបានអនុវត្តតាមសេចក្តីណែនាំនេះទេ ។ អនុលោមតាមច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីបម្រើការក្នុងតុលាការត្រូវបានតែងតាំងនៅក្នុងខែឧសភា ឆ្នាំ២០០៦ ។ ក្រុមអ្នករិះគន់ជាតិនិងអន្តរជាតិបានតវ៉ាថា ដំណើរការជ្រើសរើសបុគ្គលិករបស់រាជរដ្ឋាភិបាលកម្ពុជាមិនមានតម្លាភាពនិងមានលក្ខណៈជាការលើកទឹកចិត្តបែបនយោបាយ ។ ក្រុមអ្នករិះគន់ទាំងនេះក៏បានលើកឡើងពីបញ្ហាឯករាជ្យភាព និងសមត្ថភាពរបស់មន្ត្រីកម្ពុជាដែលត្រូវបានតែងតាំងផងដែរ ។ ក្រុមអ្នករិះគន់បានអះអាងថា ដោយមានមន្ត្រីទាំងនោះធ្វើការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តុលាការនេះនឹងមិនអាចផ្តល់យុត្តិធម៌ដែលមានកម្រិតស្តង់ដារខ្ពស់បានទេ ។

បញ្ហានេះមានសារសំខាន់ណាស់ ។ ជោគជ័យរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺ ពិតជាអាស្រ័យមួយផ្នែកធំទៅលើគុណភាពរបស់មន្ត្រីដែលបម្រើការនៅទីនោះ ។ ប្រសិនបើអ្នកសង្កេតការណ៍ជឿជាក់ថា អង្គជំនុំជម្រះវិសាមញ្ញមានជាប់ពាក់ព័ន្ធនឹងអំពើពុករលួយ ភាពលម្អៀង និងបុគ្គលអសមត្ថភាពនោះ កេរ្តិ៍ឈ្មោះរបស់ប្រព័ន្ធតុលាការកម្ពុជាកាន់តែមានឈ្មោះអាក្រក់ថែមទៀត ។ ជាងនេះទៅទៀត ជំនឿទៅលើប្រព័ន្ធយុត្តិធម៌ផ្នែកព្រហ្មទណ្ឌក្នុងស្រុកនឹងកាន់តែដុនដាប ហើយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងបរាជ័យក្នុងការនាំយកយុត្តិធម៌ដែលគួរទុកចិត្តបានសម្រាប់ជនរងគ្រោះពីការរំលោភបំពានក្នុងរបបខ្មែរក្រហម ។

កង្វល់សំខាន់មួយទៀត ដែលកើតមានឡើងនៅគ្រប់តុលាការព្រហ្មទណ្ឌអន្តរជាតិកម្រិតខ្ពស់ ពាក់ព័ន្ធទៅនឹងការសន្និដ្ឋានអំពីកំហុសដែលចុងចោទត្រូវបានចោទប្រកាន់អំពីឧក្រិដ្ឋកម្មធ្ងន់ធ្ងរត្រូវតែពុះពារ ។ អត្រានៃការផ្តន្ទាទោសបានល្អគឺជាសញ្ញាចង្អុលបង្ហាញអំពីជោគជ័យនៃសាលាក្តីចម្រុះនិងសាលាក្តីអន្តរជាតិ ។ សាលាក្តី

ទាំងនេះបានធានាអះអាងជាមួយម្ចាស់ជំនួយថា ថវិកាដែលបានផ្តល់ឲ្យត្រូវបានប្រើប្រាស់ត្រឹមត្រូវនិងបានបំពេញតាមការទាមទាររបស់ជនរងគ្រោះ ។ ផ្ទុយមកវិញ ការសម្រេចឲ្យរួចទោសអាចត្រូវបានចាត់ទុកថាជាបរាជ័យនិងជាការខ្ជះខ្ជាយធនធាន ហើយថែមទាំងមានការពិបាកក្នុងការនិយាយដោះសាជាមួយជនរងគ្រោះទៀតផង ។ តុលាការខ្មែរក្រហមស្ទើរតែប្រឈមមុខទាំងស្រុងទៅនឹងសម្ពាធធ្ងន់ធ្ងរពីសាធារណជនក្នុងការកាត់ក្តីជនជាប់ចោទដែលនេះប្រឆាំងទៅនឹងតម្រូវការនៃការធានាឲ្យបាននូវនីតិវិធីយុត្តិធម៌ ។

យុត្តិធម៌មិនគួរត្រូវបានវាស់វែងត្រឹមតែភាគរយនៃការផ្តន្ទាទោសនោះទេ ។ ជាការពិត វាពាក់ព័ន្ធទៅនឹងសមត្ថភាពរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងការស្វែងរកការពិតនិងផ្នែកការផ្តន្ទាទោសទៅលើការកាត់សេចក្តីដោយយុត្តិធម៌និងតាមនីតិវិធីច្បាប់ ។ ធ្វើរបៀបនេះជនជាប់ចោទត្រូវតែទទួលបាននូវឱកាសក្នុងការការពារខ្លួនឯងឲ្យបានគ្រប់គ្រាន់ និងស្មើគ្នាទៅនឹងភាគីខាងកាត់សេចក្តី ដែលប្រការនេះបានបើកឱកាសឲ្យករណីមួយចំនួនមានលទ្ធភាពនឹងរួចផុតពីការលើកលែង ការចោទប្រកាន់បាន ។ ហេតុដូច្នេះ ចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏ដូចជាចៅក្រមនៃតុលាការចម្រុះ ឬតុលាការឧក្រិដ្ឋកម្មអន្តរជាតិដទៃទៀត ត្រូវតែមានកម្រិតស្តង់ដារខ្ពស់ ។ ចៅក្រមទាំងអស់នេះ ត្រូវតែមានអភ័យឯកសិទ្ធិមួយកម្រិតខ្ពស់ផុតពីសាធារណជននិងសម្ពាធនយោបាយ អនុវត្តការសន្មតថា គ្មានកំហុសក្នុងអំឡុងពេលនៃការកាត់សេចក្តី និងគោរពនីតិវិធីច្បាប់យុត្តិធម៌ ។

## យុត្តិធម៌ជាមធ្យោបាយក្នុងការទទួលបានគោលបំណងទូលំទូលាយ

ប្រជាជនកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍អន្តរជាតិមានការរំពឹងទុកផ្សេងៗគ្នាចំពោះអ្វីដែលអង្គជំនុំជម្រះវិសាមញ្ញអាចសម្រេចបាន ។ ការស្វែងរកការពិត ការបង្ហាញពីការផ្តន្ទាទោសផ្នែកសីលធម៌ និងធ្វើឲ្យមានការញញើតចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មរបៀបនេះនាពេលអនាគត គឺជាស្តង់ដារនៃការរំពឹងទុកចំពោះការកាត់សេចក្តីផ្នែកព្រហ្មទណ្ឌ ។ ទោះជាយ៉ាងនេះក្តី អ្នកគាំទ្រតុលាការខ្មែរក្រហមមានមហិច្ឆតាចង់បានគោលដៅច្រើនជាងនេះទៅទៀត ដូចជាការបង្កើតនីតិរដ្ឋ ឬការពង្រឹងដំណើរការនៃការប្រព្រឹត្តរបស់រដ្ឋាភិបាល ដែលប្រការនេះនឹងធ្វើឲ្យអង្គជំនុំជម្រះវិសាមញ្ញមានកិត្តិនាមខ្ពស់ក្នុងចំណោមសាធារណជន និងអាចប្រើប្រាស់អស់នូវធនធានដែលខ្លួនមាន ។

## ការលាតត្រដាងការពិត

ប្រសិនបើប្រជាជនកម្ពុជាត្រូវដោះស្រាយបញ្ហាពីអតីតកាល វាមានសារសំខាន់ខ្លាំងណាស់ ដែលពួកគាត់ត្រូវយល់ដឹងអំពីរបៀប និងមូលហេតុដែលការរំលោភបំពានរបៀបនេះអាចកើតមានឡើងបានក្នុងរបបខ្មែរក្រហម ។ នៅក្នុងរបាយការណ៍ស្ទាបស្ទង់មតិមួយក្នុងឆ្នាំ២០០២ ដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ៧៣ភាគរយនៃអ្នកដែលទទួលការសម្ភាសន៍បានបង្ហាញថាខ្លួនចង់ដឹងបន្ថែមទៀតអំពីប្រវត្តិរបស់អង្គការខ្មែរក្រហម និងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដោយបង្កើតឡើងនូវវេទិកាសាធារណៈដើម្បីស្វែងរកការពិត អង្គជំនុំជម្រះវិសាមញ្ញមានលទ្ធភាពរួមវិភាគទានយ៉ាងច្រើនដើម្បីទទួលបាននូវគោលដៅនេះ និងបំពេញសេចក្តីស្រេកឃ្លានក្នុងការយល់ដឹងពីអតីតកាលរបស់ប្រជាជនកម្ពុជា ។

វាមិនមែនជារឿងមួយដែលត្រូវជជែកតវ៉ានោះទេ ដែលថាសង្គមមួយដែលទទួលរងរបួសផ្លូវចិត្តពីការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ ត្រូវតែយល់ច្បាស់អំពីការពិតប្រឈមមុខ និងសិក្សារៀនសូត្រពីការពិតទាំងនេះ ។ តុលាការអាចត្រូវបានចាត់ទុកថាទទួលបានជ័យជម្នះ លុះត្រាតែតុលាការនេះ អាចនាំសង្គមកម្ពុជាទៅកាន់ការពិតនៃប្រវត្តិសាស្ត្ររបស់ខ្លួន និងនាំឲ្យសាធារណជនមានការយល់ដឹងកាន់តែប្រសើរឡើងអំពីព្រឹត្តិការណ៍ដែលកើតមានឡើងក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ។ ដំណើរការជាផ្លូវការច្បាស់លាស់របស់តុលាការរួមនឹងការចូលរួមរបស់អន្តរជាតិ ធ្វើឲ្យការតាំងចិត្តរបស់តុលាការក្នុងពេលបំពេញការងារតាមផ្លូវច្បាប់កាន់តែជ្រួតជ្រាបថែមទៀត ។ ការរកឃើញរបស់អង្គជំនុំជម្រះវិសាមញ្ញអាចជួយបង្កើតឡើងនូវប្រវត្តិសាស្ត្រអាចទទួលយកបានមួយដែលអាចយកទៅផ្សព្វផ្សាយដល់ប្រជាជនកម្ពុជាជំនាន់បច្ចុប្បន្ននិងជំនាន់អនាគត ។ ឧទាហរណ៍មួយនៃសង្គមដែលបានដោះស្រាយបញ្ហាពីអតីតកាល គឺប្រទេសអាល្លឺម៉ង់ ដែលការបង្ហាត់បង្រៀនអំពីរបបណាស៊ីនិងអំពើប្រល័យពូជសាសន៍ គឺជាផ្នែកមួយដ៏សំខាន់និងជាមូលដ្ឋានក្នុងការអប់រំកូន

ក្មេងអស់រយៈពេលជាយូរមកហើយ ។ ប្រទេសកម្ពុជាមិនទាន់មានកម្មវិធីសិក្សាប្រហាក់ប្រហែលនេះនៅឡើយទេ ប៉ុន្តែតុលាការនេះអាចជួយផ្លាស់ប្តូរបញ្ហានេះបាន ។

ទោះជាយ៉ាងនេះក្តី យើងមិនគួររំពឹងថា ការរកឃើញរបស់តុលាការខ្មែរក្រហមនឹងជា«ការពិតពេញលេញ»អំពីរបបកម្ពុជាប្រជាធិបតេយ្យ ។ ការកាត់សេចក្តីផ្តោតតែទៅលើការស្វែងរកការពិតពីទស្សនវិស័យកម្រិតណាមួយប៉ុណ្ណោះ ។ អ្នកច្បាប់និងចៅក្រមពិនិត្យពិច័យទៅលើការពិតទាំងឡាយ ដែលពោលអះអាងទាក់ទងនឹងចុងចោទជាក់លាក់ណាមួយ ដោយផ្តោតជាសំខាន់ទៅលើការជាប់ពាក់ព័ន្ធរបស់ជនសង្ស័យទាំងនោះជាមួយនឹងព្រឹត្តិការណ៍ជាក់លាក់ណាមួយ ។ សូម្បីតែការកាត់ទោសមេដឹកនាំជាន់ខ្ពស់ក៏នឹងផ្តោតទៅលើការពិតជាសាកលកម្រិតណាមួយ ដែលត្រូវបានយល់ឃើញថា មានទំនាក់ទំនងក្នុងការបង្ហាញពីភាពគ្មានទោសពៃរ៍ឬពិរុទ្ធភាពរបស់ចុងចោទ ។ ជាងនេះទៅទៀត "ការពិត" ដែលរកឃើញដោយអង្គជំនុំជម្រះវិសាមញ្ញនឹងអាចទទួលយកបានលុះត្រាតែដំណើរការរបស់អង្គជំនុំជម្រះនេះត្រូវបានមើលឃើញថា ត្រឹមត្រូវតាមផ្លូវច្បាប់ ។ តុលាការព្រហ្មទណ្ឌកំណត់ការពិតតាមរយៈដំណើរការផ្លូវច្បាប់ ដែលរួមមានការដាក់បញ្ចូលបទដ្ឋាននៃការបង្ហាញការពិតដែលអាចទទួលយកបានទៅជាភ័ស្តុតាង ។ នៅពេលតុលាការបរាជ័យក្នុងការអនុវត្តបទដ្ឋានទាំងនោះឲ្យបានត្រឹមត្រូវ អ្នកសង្កេតការណ៍ប្រហែលជានឹងមិនអាចទទួលយកការរកឃើញរបស់តុលាការថា ជាការពិតបានទេ ។ ដូចដែលអ្នកស្រាវជ្រាវជាន់ខ្ពស់ ស៊ីវ ហេឌ័រ បានអះអាងថា "ប្រសិនបើការកាត់សេចក្តីក្នុងអង្គជំនុំជម្រះវិសាមញ្ញមិនយុត្តិធម៌ ហើយការកាត់សេចក្តីត្រូវបានកំណត់ដោយកត្តានយោបាយជាជាងអត្ថបទនៃច្បាប់នោះ ការកាត់សេចក្តីនោះនឹងមិនអាចជួយអ្វីបានច្រើនចំពោះចំណេះដឹងនិងការយល់ដឹងអំពីអ្វីដែលបានកើតឡើងនៅក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជានិងដោយមូលហេតុអ្វី" ។ នេះគឺជាហេតុផលមួយទៀតចំពោះមូលហេតុដែលថាវាមានសារសំខាន់ខ្លាំងណាស់ដែលតុលាការខ្មែរក្រហមត្រូវអនុវត្តតាមច្បាប់នីតិវិធីឲ្យបានខ្ជាប់ខ្ជួន ។

ដោយពិចារណាទៅលើកត្តាខាងលើ អ្នកដែលរំពឹងថានឹងអាចស្វែងរក"ការពិតទាំងស្រុង"តាមរយៈតុលាការខ្មែរក្រហមប្រហែលជានឹងខកចិត្ត ។ ទោះជាយ៉ាងនេះក្តី ការកាត់សេចក្តីអតីតមេដឹកនាំខ្មែរក្រហមជាសាធារណៈ អាចបញ្ជាក់បង្ហាញនូវព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗមួយចំនួន ពាំនាំព័ត៌មានទៅកាន់ប្រជាជនទូទៅកាន់តែច្រើនឡើង ជួយប្រជាជនកម្ពុជាឲ្យសិក្សាស្វែងយល់ពីអតីតកាលនិងទទួលយកនូវការពិតនៃអតីតកាលដ៏សោកសៅនោះ ។ ទិដ្ឋភាពជាច្រើនក្នុងរបបខ្មែរក្រហមនឹងស្ថិតនៅជាអាថ៌កំបាំង បើគ្មានការសិក្សាអំពីប្រវត្តិសាស្ត្របន្តទៀត ។ ក៏ប៉ុន្តែ តុលាការនេះអាចទាញអារម្មណ៍មនុស្សឲ្យមកផ្តោតទៅលើប្រធានបទដ៏សំខាន់នេះ នឹងជាការដាស់តឿនមួយដ៏ខ្លាំងក្លាអំពីតម្រូវការក្នុងការសិក្សាបន្ថែមលើបញ្ហានេះក្រៅសៀនតុលាការ ។

## ការការពារឧក្រិដ្ឋកម្មនាពេលអនាគត

លទ្ធផលដែលត្រូវបានរំពឹងទុកជាទូទៅមួយទៀតពីយុត្តិធម៌គឺថាតុលាការនេះនឹងដើរតួនាទីជាឧបករណ៍កម្លាំមួយ ដើម្បីការពារការប្រព្រឹត្តអំពើឧក្រិដ្ឋប្រហាក់ប្រហែលគ្នានេះនាពេលអនាគត ។ ដោយអនុវត្តនូវច្បាប់ព្រហ្មទណ្ឌនិងដាក់ទណ្ឌកម្មជាសាធារណៈដល់អ្នករំលោភច្បាប់ តុលាការអាចផ្ញើសារគំរាមកំហែងមួយទៅជនទាំងឡាយណា ដែលប្រហែលជាប៉ុនប៉ងប្រព្រឹត្តបទល្មើសប្រហាក់ប្រហែលគ្នានេះ ។ យោងតាមការស្ទាបស្ទង់មតិមួយដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រជាជនកម្ពុជាជាច្រើនបានផ្តល់អាទិភាពចំពោះ"ការធ្វើឲ្យរាងចាល"ពីសំណាក់តុលាការខ្មែរក្រហម ដែលការកាត់សេចក្តីនេះជា"មេរៀន"មួយសម្រាប់ផ្សព្វផ្សាយសារនេះ ។ ទាំងក្រុមអ្នកគាំទ្រជាតិនិងអន្តរជាតិរំពឹងនិងសង្ឃឹមថា អង្គជំនុំជម្រះវិសាមញ្ញនឹងមាន"ការធ្វើឲ្យរាងចាលនេះ" ។

នៅក្នុងការវិភាគទៅលើលទ្ធផលនៃការស្ទាបស្ទង់មតិឆ្នាំ២០០២របស់មជ្ឈមណ្ឌលឯកសារកម្ពុជា អ្នកច្បាប់អន្តរជាតិ ស៊ូហ្សាណា លីនតុន បានអះអាងថា ការយកចិត្តទុកដាក់របស់កម្ពុជាទៅលើការធ្វើឲ្យរាងចាល គឺមានទំនាក់ទំនងទៅនឹង "...សារសំខាន់ដ៏ធំមួយដែលថា អ្នកឆ្លើយចង់ទទួលបាននូវការផ្លាស់ប្តូរការប្រព្រឹត្តរបស់ក្មេងជំនាន់ក្រោយ ។ ការកាត់ទោសត្រូវបានមើលឃើញថាមានសក្តានុពលក្នុងការបញ្ចប់ការវិលចុះវិលឡើងនៃអំពើហិង្សានិងនិទ្ទណ្ឌភាព ។ នេះគឺជាការប្រើប្រាស់ដំណើរការ

តាមផ្លូវតុលាការ ជាឧបករណ៍ក្នុងការអប់រំ ។ ការធ្វើឲ្យរាងចាលនេះលេចចេញឡើងជាកត្តាមួយគួរឲ្យភ្ញាក់ផ្អើល ដែលបានដើរតួនាទីជាការព្រមានចំពោះគ្រោះថ្នាក់ដែលបណ្ដាលមកពីការគោរពតាមលទ្ធិមួយដោយគ្មានការពិចារណានិងព្រមានចំពោះគ្រោះថ្នាក់ដ៏ធំនៃការដឹកនាំបែបផ្ដាច់ការ និងការដាក់ទណ្ឌកម្មដល់បុគ្គលទាំងឡាយចំពោះតួនាទីរបស់ខ្លួននៅក្នុងការប្រព្រឹត្តអំពើព្រៃផ្សៃទាំងនោះ» ។

ការទប់ស្កាត់ការប្រព្រឹត្តឧក្រិដ្ឋកម្មសាហាវព្រៃផ្សៃនាពេលអនាគតនៅកម្ពុជានិងនៅលើពិភពលោក គឺពិតជាគោលដៅចម្បងមួយដែលនាំដល់ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនេះឡើង ។ គ្រប់តុលាការព្រហ្មទណ្ឌអន្តរជាតិនិងតុលាការចម្រុះត្រូវបានបង្កើតឡើងក្នុងគោលបំណងធ្វើឲ្យរាងចាលចំពោះការប្រព្រឹត្តបទឧក្រិដ្ឋក្នុងទ្រង់ទ្រាយធំនិងសាហាវយង់ឃ្នងនាពេលអនាគត ។

ទោះជាយ៉ាងនេះក្ដី ការសង្ស័យមួយចំនួនត្រូវបានបង្ហាញជុំវិញប្រសិទ្ធភាពនៃយុត្តិធម៌ក្នុងការធ្វើឲ្យរាងចាលចំពោះបទឧក្រិដ្ឋអន្តរជាតិ ។ សាស្ត្រាចារ្យ Colm Campbell បានអះអាងថា «អ្វីដែលយើងអាចនិយាយបានប្រសើរបំផុតចំពោះសមត្ថភាពនៃទ្រឹស្ដីធ្វើឲ្យមានការរាងចាលក្នុងបរិបទនៃការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិគឺថា វាមិនទាន់បានបង្ហាញចេញឲ្យឃើញនៅឡើយទេ» ។

ផ្អែកលើគោលគំនិតរបស់ប្រជាជនកម្ពុជា ចន្លោះពេលដ៏យូររវាងពេលដែលការរំលោភសិទ្ធិមនុស្សត្រូវបានប្រព្រឹត្តនិងពេលដែលតុលាការត្រូវបានបង្កើតឡើងធ្វើឲ្យប្រសិទ្ធភាពនៃការធ្វើឲ្យរាងចាលមានភាពទន់ជ្រាយ ។ ទោះបីជាតុលាការខ្មែរក្រហមអាចធ្វើឲ្យមានការរាំងចាលកម្រិតមួយក៏ដោយ តុលាការនេះនឹងដើរតួយ៉ាងសំខាន់ក្នុងការជួយឲ្យប្រជាជនកម្ពុជាមានលទ្ធភាពអាចដាក់រឿងរ៉ាវពីអតីតកាលនៅពីក្រោយខ្នងហើយសម្លឹងទៅអនាគត ។

## ការប្រឈមទៅនឹងវប្បធម៌និទ្ទណ្ឌភាព

វប្បធម៌និទ្ទណ្ឌភាពបានក្លាយទៅជាជំងឺគ្មានថ្នាំព្យាបាលមួយនៅកម្ពុជា ដោយសារហេតុផលមួយផ្អែកចំពោះការពិតដែលថាមិនមានការដាក់ឲ្យមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម ។ មនុស្សជាច្រើនរំពឹងថា តុលាការនេះនឹងជួយពង្រឹងការគោរពច្បាប់ ដោយជួយពង្រឹងជំនឿលើយុត្តិធម៌របស់សាធារណជននៅកម្ពុជា និងបង្ហាញឲ្យឃើញច្បាស់ថា មិនមាននរណាម្នាក់រួមទាំងមេដឹកនាំនយោបាយផងនៅពីលើច្បាប់នោះទេ ។

ប្រជាជនកម្ពុជាមានការលំបាកក្នុងការជឿទៅលើប្រព័ន្ធយុត្តិធម៌ នៅពេលចោរលួចតូចតាច ឬប្រជាជនដែលគ្មានកំហុសត្រូវបានចាប់ដាក់គុក ក្នុងខណៈពេលដែលមេដឹកនាំខ្មែរក្រហមដែលទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋធ្ងន់ធ្ងរបន្តរស់នៅដោយមានសេរីភាព ។ អង្គជំនុំជម្រះវិសាមញ្ញអាចជួយព្យាបាលជំងឺវប្បធម៌និទ្ទណ្ឌភាពកម្រិតខ្ពស់នេះបាន ដោយធ្វើការដាក់ទោសអ្នកដែលទទួលខុសត្រូវចំពោះអំពើឃោរឃៅក្នុងរបបខ្មែរក្រហម ។ តាមរយៈការកាត់សេចក្ដីនិងការសម្រេចចិត្ត តុលាការអាចស្ដារឡើងវិញនូវអត្ថន័យនៃយុត្តិធម៌ដល់កម្ពុជាក៏ដូចជាពង្រឹងការគោរពច្បាប់ ។ សហគមន៍អន្តរជាតិ តាមរយៈអង្គការសហប្រជាជាតិបានមើលឃើញលទ្ធភាពនេះនៅពេលខ្លួនផ្ដល់យោបល់ឲ្យបង្កើតអង្គជំនុំជម្រះវិសាមញ្ញនេះឡើង ។ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តសេចក្ដីសម្រេចលេខ៥៧-២២៨ នៅខែធ្នូ ឆ្នាំ២០០២ ដោយសង្កត់ធ្ងន់ថា «ការទទួលខុសត្រូវរបស់បុគ្គលដែលជាជនដៃដល់ចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរគឺជាកត្តាគន្លឹះដើម្បីធានាប្រព័ន្ធយុត្តិធម៌ត្រឹមត្រូវនិងសមធម៌នៅក្នុងរដ្ឋមួយ» ។

ជាងនេះទៅទៀត ដូចតុលាការព្រហ្មទណ្ឌអន្តរជាតិនិងតុលាការចម្រុះដទៃទៀតដែរ អង្គជំនុំជម្រះវិសាមញ្ញត្រូវបានរំពឹងថា នឹងរួមចំណែកជាមួយការខិតខំប្រឹងប្រែងរបស់សហគមន៍អន្តរជាតិក្នុងការប្រយុទ្ធប្រឆាំងនឹងនិទ្ទណ្ឌភាព ដោយបង្កើតឡើងនូវសេចក្ដីសម្រេចដ៏រឹងមាំមួយ ។ គ្មានអ្វីដែលគួឲ្យឆ្ងល់នោះទេ ការកាត់សេចក្ដីរបស់អង្គជំនុំជម្រះវិសាមញ្ញនឹងរួមចំណែកចំពោះគោលដៅនេះ ដោយផ្ដោតការយកចិត្តទុកដាក់របស់សហគមន៍អន្តរជាតិទៅលើបញ្ហាដែលថា និទ្ទណ្ឌភាពចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតគឺកង្វល់របស់កម្ពុជានិងពិភពលោកទាំងមូល ។

## ការស្ដាបនានីតិរដ្ឋ

ការពុះពារក្នុងការដោះស្រាយបញ្ហានិទ្ទណ្ឌភាពនៅកម្ពុជាមិនអាចកាត់ផ្ដាច់បានពីគោលដៅដ៏មានសារសំខាន់លើសលប់មួយទៀតរបស់អង្គជំនុំជម្រះវិសាមញ្ញដែលនឹងមកដល់នោះទេ ។

គោលដៅនោះគឺ ការកសាងនីតិរដ្ឋនៅកម្ពុជា ។ អង្គជំនុំជម្រះវិសាមញ្ញអាចជួយពន្លឿនគោលដៅនេះ ដោយធ្វើជាគំរូយុត្តិធម៌មួយដល់តុលាការក្នុងស្រុកនៅកម្ពុជា ។ វាមានសារសំខាន់ណាស់ដែលអង្គជំនុំជម្រះវិសាមញ្ញបង្កើតឡើងនូវគំរូយុត្តិធម៌មួយ ដែលអនុលោមតាមស្តង់ដារយុត្តិធម៌និងនីតិវិធីច្បាប់អន្តរជាតិ ។ ដោយហេតុថា តុលាការខ្មែរក្រហមជាផ្លូវការស្ថិតនៅក្នុងប្រព័ន្ធតុលាការកម្ពុជា នោះបុគ្គលិកបម្រើការភាគច្រើនជាជនជាតិកម្ពុជា ។ មន្ត្រីតុលាការទាំងនេះអាចផ្ទេរជំនាញដែលខ្លួនទទួលបានពីការអនុវត្តតាមស្តង់ដារយុត្តិធម៌អន្តរជាតិទៅរកការអនុវត្តន៍ប្រព័ន្ធច្បាប់ក្នុងស្រុក ។ ជាងនេះទៅទៀត តុលាការនេះអាចជួយបង្កើតឡើងនូវជំនឿទុកចិត្តទៅលើតុលាការក្នុងស្រុកនៅកម្ពុជាពីសាធារណជនឡើងវិញ ដោយបង្ហាញឲ្យប្រជាជនឃើញថា ប្រព័ន្ធតុលាការនេះអាចកាត់សេចក្តីដោយយុត្តិធម៌បាន ។

ដំណើរការវិវឌ្ឍន៍នេះនឹងជួយពង្រឹងប្រព័ន្ធរដ្ឋាភិបាលកម្ពុជាទាំងមូល និងកសាងមូលដ្ឋានគ្រឹះសម្រាប់លទ្ធិប្រជាធិបតេយ្យដែលអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជានិងក្រុមអ្នកនយោបាយក្នុងស្រុក បានបង្កើតឡើងនៅក្រោយរយៈកាលនៃសង្គ្រាមត្រជាក់ ។ បន្ទាប់ពីការតស៊ូសង្គ្រាមត្រជាក់និងភាពមិនល្អូតលាស់អស់ជាច្រើនទសវត្សរ៍មក រដ្ឋាភិបាលនិងប្រព័ន្ធច្បាប់នៅកម្ពុជាត្រូវការយ៉ាងខ្លាំងក្នុងការទទួលបានមកវិញនូវជំនឿទុកចិត្តពីប្រជាពលរដ្ឋ ។ អ្នកខ្លះឲ្យយោបល់ថាធម្មជាតិនៃការដាក់ទណ្ឌកម្មតាមផ្លូវតុលាការនឹងជួយពង្រឹងរដ្ឋាភិបាលថ្មី ដោយហេតុថា ការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងជាសារបង្ហាញថា រដ្ឋាភិបាលថ្មីមានការប្តេជ្ញាចិត្តក្នុងការនាំយកយុត្តិធម៌មកជូនប្រជាពលរដ្ឋកម្ពុជា ។

***សេចក្តីសន្និដ្ឋាន ៖ តើអ្វីនឹងនាំឲ្យមានការកាត់ទោសដោយយុត្តិធម៌ទេ?***

កង្វល់ទាំងប៉ុន្មានខាងលើនាំឲ្យមានការលើកឡើងជាសំណួរមួយថាតើស្តង់ដារនីតិវិធីនិងការធ្វើសេចក្តីសម្រេចចិត្តបែបណាចាំបាច់សម្រាប់ការកាត់សេចក្តីដែលអាចចាត់ទុកថាយុត្តិធម៌បាន? មានគំនិតជាច្រើនខុសៗគ្នា ។ អង្គការសិទ្ធិមនុស្សអន្តរជាតិ អ្នកស្រាវជ្រាវ ប្រទេសជាសមាជិកអង្គការសហប្រជាជាតិនិងមន្ត្រីមួយចំនួនបានអះអាងថា ការគ្មានតុលាការទាល់តែសោះប្រសើរជាងការមានតុលាការមួយដែលមិនគោរពតាមបទដ្ឋានយុត្តិធម៌និងនីតិវិធីច្បាប់អន្តរជាតិ ។ ដូចដែលបានកត់សម្គាល់ខាងលើ អ្នករិះគន់ជាបឋមខ្វល់ខ្វាយអំពីការពិតដែលថា តុលាការនេះនឹងរួមបុគ្គលិកកម្ពុជាភាគច្រើន ដែលប្រហែលជានឹងទទួលឥទ្ធិពលពីរដ្ឋាភិបាល ។ អ្នកផ្សេងទៀតដែលរួមមានទាំង Cregory Stanton ប្រធានអង្គការឃ្លាំមើលអំពើប្រល័យពូជសាសន៍បានលើកឡើងថា "ភាពត្រឹមត្រូវឥតខ្ចោះគឺជាសត្រូវរបស់យុត្តិធម៌" ហើយ "វិធីសាស្ត្រមាន ឬគ្មានយុត្តិធម៌"គឺជាការបំផ្លាញខ្លួនឯង ។ ជាការគាំទ្រចំពោះគោលការណ៍នេះ អ្នកនាំពាក្យតុលាការបានបញ្ជាក់ថាប្រជាជនកម្ពុជាបានរង់ចាំមើលការឆ្លើយតបទៅនឹងការទាមទាររកយុត្តិធម៌របស់ខ្លួនអស់ជាច្រើនឆ្នាំមកហើយ នៅពេលជនដែលកាន់តែមានវ័យចាស់ជរាណាស់ទៅហើយ ។ អ្នកទាំងនេះបានបន្តថា បរាជ័យក្នុងការកាត់ទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរដោយសារហេតុផលដើម្បីទទួលបាននូវទម្រង់ល្អឥតខ្ចោះនៃយុត្តិធម៌ អាចនឹងរងការខូចខាតច្រើនជាងការមានការកាត់ក្តីមិនពេញបរិបូណ៌ ។

ការស្ទាបស្ទង់មតិបានបង្ហាញដូចគ្នាដែរថា ប្រជាជនកម្ពុជាមានជំនឿតិចតួចណាស់ទៅលើប្រព័ន្ធតុលាការរបស់ខ្លួន ហើយចង់បានតុលាការមួយដែលរួមមានចៅក្រមនិងព្រះរាជអាជ្ញាអន្តរជាតិសុទ្ធជាជាងតុលាការចម្រុះ ។ ទោះជាយ៉ាងនេះក្តី ការស្ទាបស្ទង់មតិមួយធ្វើឡើងដោយវិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យបានបង្ហាញឲ្យឃើញថា នៅពេលត្រូវបានផ្តល់ជម្រើសរវាងការគ្មានការកាត់ក្តី ឬការកាត់ក្តីដែលអនុវត្តតាមបទដ្ឋានយុត្តិធម៌ទាបជាង ភាគច្រើនពេញចិត្តជម្រើសទីពីរ ។ ជាងនេះទៅទៀត ៦១ ភាគរយនៃប្រជាជនដែលទទួលបានការសម្ភាសន៍ជឿថា តុលាការក្នុងទម្រង់ជាតុលាការចម្រុះនឹងអាចនាំមកនូវយុត្តិធម៌បាន ។

បញ្ហាប្រកបដោយជម្លោះមួយទៀត ទាក់ទងនឹងអត្តសញ្ញាណរបស់ជនកម្ពុជាមួយចំនួនដែលត្រូវបានតែងតាំងជាព្រះរាជអាជ្ញានិងចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញ ។ ក្រុមអ្នករិះគន់មួយចំនួនបានឲ្យយោបល់ថា សមាជិកភាពក្នុងគណបក្សនយោបាយរបស់សហព្រះរាជអាជ្ញានិងចៅក្រម គឺជាសញ្ញាចង្អុលបង្ហាញអំពីការខ្វះឯករាជ្យភាពនិងភាពឥតលម្អៀង ។ មនុស្សមួយចំនួនផ្សេងទៀត

មិនយល់ស្របទៅនឹងយោបល់នេះទេ ។ ទោះជាយ៉ាងនេះក្ដី ការពិភាក្សាបែបនេះបានបង្ហាញអំពីសារសំខាន់នៃរបៀបដែលអង្គជំនុំជម្រះវិសាមញ្ញត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួន ដោយឯករាជ្យភាពឥតលម្អៀង និងប្រកបដោយក្រមសីលធម៌ ។ ការពិភាក្សាក៏បានទាញការចាប់អារម្មណ៍ទៅលើបញ្ហាសមត្ថភាពនិងបទពិសោធន៍របស់មន្ត្រីបម្រើការក្នុងតុលាការ និងតម្រូវការដែលថា ភាគីកម្ពុជា និងអន្តរជាតិត្រូវធ្វើការជាមួយគ្នាឲ្យបានល្អ ។

ដូចគ្នាដែរ សារសំខាន់នៃការមានមេធាវីការពារក្ដីដែលមានសមត្ថភាពនិងប្រសិទ្ធភាពនៅចំពោះមុខតុលាការខ្មែរក្រហមមិនអាចលេងសើចបានទេ ។ ប្រៀបបានទៅនឹងអង្គភាពខាងក្រោមមួយ មេធាវីការពារក្ដីគួរដើរតួនាទីក្នុងការជួយធានាបូរណភាព និងយុត្តិធម៌នៃការកាត់សេចក្ដីផ្នែកព្រហ្មទណ្ឌ ។ ហេតុដូច្នេះហើយ អង្គការក្នុងស្រុកនិងអង្គការអន្តរជាតិមួយចំនួនបានផ្ដល់ការហ្វឹកហ្វឺន ដើម្បីពង្រឹងចំណេះដឹងអំពីច្បាប់ព្រហ្មទណ្ឌអន្តរជាតិដល់ស្មាក្ដីក្នុងស្រុក និងដើម្បីពន្យល់សាធារណជនអំពីសារសំខាន់នៃតួនាទីរបស់មេធាវីក្នុងអំឡុងពេលនៃដំណើរការតាមផ្លូវច្បាប់ ។ ជាងនេះទៅទៀត ដោយមើលឃើញពីសារសំខាន់នៃការការពារក្ដីប្រកបដោយប្រសិទ្ធភាពនៅចំពោះមុខតុលាការខ្មែរក្រហម អង្គការសហប្រជាជាតិបានបង្កើតការិយាល័យស្មាក្ដីនៅក្នុងរចនាសម្ព័ន្ធនៃតុលាការខ្មែរក្រហម ។ ការិយាល័យនេះគឺមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងការិយាល័យការពារក្ដីចម្បងដែលត្រូវបានបង្កើតឡើងនៅក្នុងតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ា-ឡេអូន ដើម្បីផ្ដល់ការទ្រទ្រង់ផ្នែកបច្ចេកទេសនិងជំនួយផ្នែកច្បាប់ទៅការិយាល័យស្មាក្ដី ។


មន្ទីរឃុំឃាំងរបស់សាលាក្ដីខ្មែរក្រហមសាងសង់ឡើងតាមកម្រិតស្តង់ដារអន្តរជាតិ ក្រោមការជួយឧបត្ថម្ភពីរដ្ឋាភិបាលឥណ្ឌានិងជប៉ុន ព្រមទាំងមានការពិគ្រោះយោបល់ពីគណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហមទាំងផ្នែកគំនិតនិងការរចនាអគារ ។

អង្គការក្នុងស្រុកនិងអ្នកស្រាវជ្រាវក៏បានសង្កត់ធ្ងន់ទៅលើតម្រូវការក្នុងការធានាថា ការកាត់សេចក្ដីនេះនឹងបើកចំហដល់សាធារណជនដែលរួមមានប្រព័ន្ធផ្សព្វផ្សាយនិងអង្គការក្នុងស្រុកក៏ដូចជាអង្គការអន្តរជាតិដែលបានធានាដោយច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ។ ការកាត់ក្ដីជាសាធារណៈ នឹងជួយធានាឲ្យបានថាចៅក្រមអនុវត្តច្បាប់បានត្រឹមត្រូវ និងមិនបដិសេធសិទ្ធិរបស់ចុងចោទ ។ អង្គការជាច្រើនមានគម្រោងរៀបចំដំណើរការ«ឃ្លាំមើល» ដោយធ្វើការត្រួតពិនិត្យទៅលើការកាត់សេចក្ដីនិងធ្វើសេចក្ដីរាយការណ៍ទៅលើការរកឃើញការរំលោភបំពានទៅលើច្បាប់ឬបទដ្ឋានសិទ្ធិមនុស្ស ។ អង្គការផ្សេងទៀតដែលរួមទាំងមជ្ឈមណ្ឌលឯកសារកម្ពុជាផង មានគម្រោងចូលរួមផ្ដល់ការយល់ដឹងដល់សាធារណជនអំពីដំណើរការកាត់ក្ដីដោយជួយឲ្យសាធារណជនអាចចូលទៅស្ដាប់ការកាត់ក្ដីនៅតុលាការនិងផ្ដល់ព័ត៌មានអំពីការកាត់ក្ដី ។ ជាចុងក្រោយ លទ្ធផលនៃតុលាការខ្មែរក្រហមមានវិសាលភាពធំធេងណាស់ ប្រសិនបើជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យដើរតួនាទីយ៉ាងសកម្មជាអ្នកសង្កេតការណ៍ និងជាអ្នកចូលរួមក្នុងការដំណើរការដាក់ឲ្យមានការទទួលខុសត្រូវនិងការនិយាយការពិតទូលំទូលាយមួយ ។

**ហេងឡេន អ៊ុយណាក និង ស៊ីង លាង**

# សេចក្តីថ្លែងការរបស់លោក រ៉ូភើត ស្គីលបេក ប្រធានផ្នែកគាំទ្រមេធាវីការពារក្តី

ការអនុម័តវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ គឺជាមហាជោគជ័យ និងជាជំហានដ៏សំខាន់មួយដើម្បីធានាដល់ការជំនុំជម្រះដោយយុត្តិធម៌ ។

ចៅក្រមបានរៀបចំបង្កើតក្របខណ្ឌការងារមួយដើម្បីគ្រប់គ្រងសវនាការព្រហ្មទណ្ឌកម្រិតខ្ពស់ហើយសាំញ៉ាំ ។ ពួកគេទទួលជោគជ័យក្នុងការបញ្ចូលច្បាប់ព្រហ្មទណ្ឌអន្តរជាតិជាមួយច្បាប់កម្ពុជា និងសេចក្តីវិធាននីតិវិធីផ្ទៃក្នុងជាបីភាសា ។ ចៅក្រមដែលមានសាវតារច្បាប់ខុសៗគ្នាបានត្រៀមខ្លួនរួចជាស្រេច ដើម្បីបើកសវនាការប្រកបដោយសក្តានុពលក្នុងការនាំមកនូវយុត្តិធម៌ឲ្យជនរងគ្រោះ ហើយស្របពេលជាមួយគ្នា ពួកគេធានានូវការជំនុំជម្រះដោយយុត្តិធម៌ឲ្យជនជាប់ចោទផងដែរ ។

## សិទ្ធិជាមូលដ្ឋាន

វិធានផ្ទៃក្នុងធានាសិទ្ធិជាមូលដ្ឋានមួយចំនួនដែលនឹងជួយដល់ការជំនុំជម្រះដោយយុត្តិធម៌ដល់ជនជាប់ចោទ ។ ឧទាហរណ៍ ៖

- វិធានផ្ទៃក្នុងធានាសិទ្ធិរបស់ជនជាប់ចោទទទួលបាននូវក្រុមការពារប្រកបដោយប្រសិទ្ធភាព ដែលមានសមាសភាពសហមេធាវីក្នុងនោះមានសហមេធាវីកម្ពុជាម្នាក់ និងសហមេធាវីអន្តរជាតិម្នាក់ ស្របគ្នានិងសហព្រះរាជអាជ្ញាដែរ ។
- វិធានផ្ទៃក្នុងធានាសិទ្ធិរបស់ជនជាប់ចោទ ក្នុងការមិនឆ្លើយនិងសំណួរបើគ្មានវត្តមានមេធាវីប្រសិនបើគាត់ជ្រើសរើសធ្វើដូច្នេះ ។
- វិធានផ្ទៃក្នុងចែងយ៉ាងច្បាស់ថា បន្ទុកនៃការបង្ហាញភ័ស្តុតាង ជាការបន្ទុករបស់អយ្យការ ដើម្បីរកភ័ស្តុតាងដាក់បន្ទុកមកលើជនជាប់ចោទ ហើយត្រូវបង្ហាញភ័ស្តុតាងឲ្យហួសពីវិមតិសង្ស័យ ។

## បញ្ហាសំខាន់ៗ

បទបញ្ញត្តិរបស់វិធានផ្ទៃក្នុងទាក់ទងនឹងការការពារជនជាប់ចោទ មិនសូវមានវឌ្ឍនភាព បើប្រៀបធៀបនឹងវឌ្ឍនភាពនៃការការពារជនជាប់ចោទនៅតុលាការដទៃទៀត ។ ជាការពិត មានការព្រួយបារម្ភណ៍មួយចំនួនដែលថា វិធានផ្ទៃក្នុងមិនបានឆ្លើយតបទៅនឹងបទដ្ឋានអន្តរជាតិនៃការជំនុំជម្រះដោយយុត្តិធម៌ ក្រុមការពារក្តីអាចលើកពីការព្រួយបារម្ភណ៍នេះជាមួយតុលាការក្នុងអំឡុងពេលចំណាត់ការរឿងក្តី ។

## ផ្នែកគាំទ្រមេធាវីការពារក្តី

វិធានផ្ទៃក្នុងក៏បានបង្កើតក្របខណ្ឌច្បាប់សម្រាប់ផ្នែកគាំទ្រមេធាវីការពារក្តី និងគូរវាសត្រួសៗអំពីភារកិច្ចដែលផ្នែកនេះត្រូវអនុវត្ត ។

*អំពីបញ្ជី*

ផ្នែកគាំទ្រមេធាវីការពារក្តី តម្រូវឲ្យរៀបចំបញ្ជីមេធាវីដែលអាចការពាររឿងក្តីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ហើយ

ទទួលខុសត្រូវបង្ហាញបញ្ជីនោះទៅជនសង្ស័យ ហើយជួយពួកគេក្នុងការជ្រើសរើសក្រុមអ្នកច្បាប់ ។ ផ្នែកគាំទ្រមេធាវីការពារក្តី នឹងរៀបចំពាក្យសុំចុះឈ្មោះមេធាវីដែលនឹងត្រូវបញ្ជូនទៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បើទោះបីជាមេធាវីខ្លួនឯងត្រូវបង់ប្រាក់៥០០ដុល្លារអាមេរិកជាថ្លៃចុះឈ្មោះដោយផ្ទាល់ក៏ដោយ ។

បញ្ជីមេធាវីនឹងបើកក្នុងពេលឆាប់ៗនេះ បន្ទាប់ពីការចូលជាធរមាននៃវិធានផ្ទៃក្នុង ហើយពាក្យសុំនឹងអាចរកបាននៅលើគេហទំព័ររបស់តុលាការ ឬទំនាក់ទំនងនៅផ្នែកគាំទ្រមេធាវីការពារក្តី ។

យើងទទួលបានការចាប់អារម្មណ៍ពីមេធាវីមកពីប្រទេសអូស្ត្រាលី បារាំង ហុងកុង ជប៉ុន ម៉ាឡេស៊ី ហូឡង់ និងចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិកដែលមានបំណងចុះឈ្មោះក្នុងបញ្ជីមេធាវី ។

## គ្រោងការជំនួយការច្បាប់

ផ្នែកគាំទ្រមេធាវីការពារក្តីនឹងបង់ប្រាក់ឈ្នួលដល់មេធាវីដែលការពារជនជាប់ចោទ ដែលគ្មានមធ្យោបាយបង់ថ្លៃមេធាវី ។ គ្រោងការជំនួយការច្បាប់របស់ផ្នែកគាំទ្រមេធាវីការពារក្តី បង្កើតឡើងតាមការសិក្សាមេរៀននៅតុលាការអន្តរជាតិ និងតុលាការចម្រុះផ្សេងៗក្នុងគោលបំណងបង្កើតប្រព័ន្ធមួយយុត្តិធម៌ និងគ្មានអំពើពុករលួយ និងដើម្បីការពារក្តីប្រកបដោយប្រសិទ្ធភាព ។ មេធាវីកម្ពុជានឹងទទួលបានប្រាក់ឈ្នួលក្នុងអត្រាស្មើគ្នានឹងព្រះរាជាអាណាចក្រកម្ពុជាដែរ ហើយមេធាវីអន្តរជាតិទទួលបានប្រាក់កម្រៃស្មើគ្នានឹងព្រះរាជអាជ្ញាអន្តរជាតិ ។

## ការគាំទ្រផ្នែកច្បាប់និងការបណ្តុះបណ្តាល

ផ្នែកគាំទ្រមេធាវីការពារក្តី តម្រូវផ្តល់ការគាំទ្រផ្នែកច្បាប់តាមរយៈការស្រាវជ្រាវ និងវិភាគទៅក្រុមការពារក្តី ។ បច្ចុប្បន្នយើងមានក្រុមជំនាញការដែលមានមេធាវីនិងនិស្សិតមានបទពិសោធន៍ចំនួន៨នាក់ ដែលមានលទ្ធភាពផ្តល់ការគាំទ្រទៅក្រុមការពារក្តីនៅពេលឆាប់ៗនេះបន្ទាប់ពីការចាប់ខ្លួន ។ វិធានផ្ទៃក្នុងចែងយ៉ាងច្បាស់ថា ផ្នែកគាំទ្រមេធាវីការពារក្តីឯករាជ្យដាច់ចេញពីការិយាល័យរដ្ឋបាលហើយ យើងនឹងបំពេញតួនាទីដើម្បីផលប្រយោជន៍របស់កូនក្តី ។

វិធាន១១នៃវិធានផ្ទៃក្នុង តម្រូវផ្នែកគាំទ្រមេធាវីការពារក្តីរៀបចំវគ្គបណ្តុះបណ្តាល ដោយសហការជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។ ការនេះអនុញ្ញាតឲ្យពួកយើងអភិវឌ្ឍវគ្គបណ្តុះបណ្តាលស្តីពីនីតិព្រហ្មទណ្ឌអន្តរជាតិទទួលបានជ័យជម្នះកាលពីដើមឆ្នាំនេះ ហើយយើងបានចាប់ផ្តើមរៀបចំវគ្គបណ្តុះបណ្តាលផ្សេងទៀត ។

ជាការខកចិត្តដែលអង្គជំនុំជម្រះវិសាមញ្ញ មិនប្រតិបត្តិតាមការអនុវត្តន៍ដែលអនុម័តដោយតុលាការ ពិសេសសៀរ៉ាឡេអូន អង្គជំនុំជម្រះវិសាមញ្ញសង្គ្រាមសៀរ៉ាឡេវ៉ូនៅប៊ូស្នៀ និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងមិនអនុញ្ញាតឲ្យមេធាវីមកពីផ្នែកគាំទ្រមេធាវីការពារក្តីបង្ហាញខ្លួន“ជំនួស” នៅតុលាការ ។ ការប្រើប្រាស់មេធាវីមកពីផ្នែកគាំទ្រ មេធាវីការពារក្តីបង្ហាញខ្លួននៅតុលាការក្នុងរយៈពេលខ្លីជាជាងការរង់ចាំមេធាវីអន្តរជាតិដែលធ្វើដំណើរតាមយន្តហោះ អាចសន្សំពេលវេលា និងថវិកា ។ សេចក្តីសម្រេចនេះនឹងបណ្តាលឲ្យមានការពន្យារពេលនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

អង្គជំនុំជម្រះវិសាមញ្ញអាចនាំមកនូវយុត្តិធម៌ដល់ប្រជាជនកម្ពុជា លុះត្រាតែការជំនុំជម្រះក្តី ដែលធ្វើនៅបន្ទប់សវនាការប្រកបដោយយុត្តិធម៌ ឥតលម្អៀង និងជាសាធារណៈ ។ មេធាវីការពារក្តីនឹងធ្វើឲ្យប្រាកដថា លក្ខខណ្ឌនេះត្រូវតែបានបំពេញ ។

# សេចក្តីថ្លែងការណ៍រួមដោយចៅក្រមជាតិនិងអន្តរជាតិ

## *ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧*

### *សម័យប្រជុំពេញអង្គអនុម័តជាឯកច្ឆ័នលើវិធានផ្ទៃក្នុង*

*កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ កិច្ចប្រជុំពេញអង្គនៃអង្គចៅក្រមជាតិនិងអន្តរជាតិ បានអនុម័តជាឯកច្ឆ័ន្ទលើវិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយបានធ្វើការបញ្ចប់កិច្ចប្រជុំរយៈពេលពីរសប្តាហ៍នៅទីក្រុងភ្នំពេញ ។*

*ដំណើរនៃសេចក្តីព្រាងវិធានផ្ទៃក្នុងនេះគឺជាការងារមួយដ៏លំបាក ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាស្ថាប័នតុលាការដែលមានលក្ខណៈពិសេសដោយឡែកនៅក្នុងឆាកយុត្តិធម៌អន្តរជាតិ ។ នេះជាលើកទីមួយហើយដែលតុលាការកូនកាត់មួយនេះបាន រួមបញ្ចូលការងាររបស់សហចៅក្រមស៊ើបអង្កេតទៅក្នុងកិច្ចដំណើរការនីតិវិធី ដោយយកច្បាប់ជាតិកំពុងអនុវត្តធ្វើជាមូលដ្ឋានគ្រឹះ ។ យើងមិនមានករណីយុត្តិសាស្ត្រឡើយនៅពេលដែលយើងធ្វើការប្រឃាច់បញ្ចូលគ្នារវាងច្បាប់ជាតិនិងនីតិវិធី និងលក្ខណៈពិសេសទាំងឡាយព្រមទាំងរចនាសម្ព័ន្ធរបស់តុលាការនេះ ដោយព្យាយាមធ្វើយ៉ាងណាធានាឲ្យបានបទដ្ឋានអន្តរជាតិ ។*

*ក្នុងរយៈពេល១១ខែក្រោយពីការពិភាក្សាកន្លងមកនេះ ចៅក្រមមកពីប្រទេសផ្សេងៗដែលអនុវត្តប្រព័ន្ធច្បាប់ខុសៗគ្នា រួមទាំងចៅក្រមមកពីប្រទេសដែលអនុវត្តច្បាប់អង់គ្លូសាក់សុងផងនោះ បានស្វែងរកដំណោះស្រាយដែលអាចទទួលយកបាននិងមានការយោគយល់គ្នា ដើម្បីធានាឲ្យមានការជំនុំជម្រះដោយមានភាពយុត្តិធម៌ ។*

*យើងខ្ញុំបានដោះស្រាយរួចរាល់លើបញ្ហានានាដែលយើងខ្ញុំបានចង្អុលបង្ហាញពីតម្រូវការពិភាក្សាបន្ថែមកាលពីខែវិច្ឆិកាកន្លងផុតទៅនេះ ។ បញ្ហាដែលមានលក្ខណៈស្មុគស្មាញជាងគេនោះ គឺធ្វើយ៉ាងណាដើម្បីធានាឲ្យបាននូវសិទ្ធិនិងការចូលរួមទាំងជនរងគ្រោះ ។ ចំណុចនេះមិនមានចែងឲ្យបានច្បាស់លាស់នៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះនិងកិច្ចព្រមព្រៀងទេ តែវាជាសមាសធាតុមួយដែលមានចែងយ៉ាងច្បាស់នៅក្នុងច្បាប់កម្ពុជារបស់យើង ។ យើងខ្ញុំយល់ឃើញថា ជនរងគ្រោះអាចមានសិទ្ធិតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក៏ប៉ុន្តែដោយសារតែពិចារណាលើ លក្ខណៈពិសេសរបស់អង្គជំនុំជម្រះរបស់យើងនោះ យើងខ្ញុំបានធ្វើការសម្រេចថា នឹងបើកឲ្យមានសំណងជាសមូហភាពតែមិនមែនក្នុងលក្ខណៈជាហិរញ្ញវត្ថុនោះឡើយ ។*

*យើងខ្ញុំមានសេចក្តីរីករាយណាស់ដោយបានធ្វើសេចក្តីសម្រេចចុងក្រោយលើវិធានទាំងនេះក្នុងពេលមួយដែលសមស្រប បើពិនិត្យលើភាពស្មុគស្មាញទាំងឡាយ និងបន្ទាប់ពីមានការពិភាក្សាពិគ្រោះយោបល់ និងបំពេញការងារដ៏ច្រើននេះ ។ នេះគឺជាដំណើរការមួយដ៏មានតម្លៃ ហើយមានសារសំខាន់ណាស់ក្នុងការចំណាយពេលរៀបចំចងក្រងនូវសេចក្តីព្រាងនេះឡើង ។ ក្នុងរយៈពេលមិនដល់មួយឆ្នាំផង អង្គជំនុំជម្រះមិនត្រឹមតែបានអនុម័តលើវិធានផ្ទៃក្នុងរបស់ខ្លួនទេ ថែមទាំងបានចាប់ផ្តើមការរៀបចំផ្សេងៗទៀតដើម្បីឲ្យតុលាការនេះដំណើការបានពេញលេញ ។*

*ឥឡូវនេះ វិធានផ្ទៃក្នុងត្រូវបានអនុម័តរួចរាល់ហើយ ហើយយើងអាចដំណើរការទៅមុខបាន ។ យើងខ្ញុំយល់ឃើញថា សហព្រះរាជអាជ្ញា នឹងបញ្ជូនដីកាសន្និដ្ឋានឲ្យស៊ើបសួរលើកដំបូងរបស់ខ្លួនក្នុងពេលដ៏ខ្លីខាងមុខនេះ ។ បន្ទាប់មក សហចៅក្រមស៊ើបអង្កេតអាចចាប់ផ្តើមបំពេញកិច្ចស៊ើបសួររបស់ខ្លួន ហើយនៅក្នុងថ្ងៃនេះផងដែរ អង្គជំនុំជម្រះនឹងបើកការជំនុំជម្រះលើកទីមួយរបស់ខ្លួន នៅពេលចៅក្រមនៃអង្គបុរេជំនុំជម្រះបើកសវនាការដើម្បីអនុញ្ញាតឲ្យអ្នកស៊ើបអង្កេតធ្វើសច្ចាប្រណិធានចូលកាន់តំណែង ។*

*ចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញទាំងអស់ដឹងយ៉ាងច្បាស់ថា ប្រជាជនកម្ពុជាទន្ទឹងរង់ចាំដំណើរការរបស់សាលាក្តីនេះអស់រយៈពេលយ៉ាងយូរមកហើយ ។ យើងខ្ញុំទាំងអស់គ្នាធ្វើការប្តេជ្ញាចិត្តធ្វើការជំនុំជម្រះឲ្យបានរួសរាន់ទាន់ពេល ដោយធានាឲ្យបាននូវបទដ្ឋានយុត្តិធម៌ដ៏ខ្ពស់បំផុត ។ វិធានទាំងនេះអាចផ្តល់ឱកាសឲ្យយើងខ្ញុំអាចដំណើការកាត់ក្តីដ៏មានភាពយុត្តិធម៌ និងតម្លាភាពនៅចំពោះមុខសាលាក្តីឯករាជ្យ និងអព្យាក្រឹតមួយនេះ ។*

# ភាពតក់ស្លុត និងការប៉ះទង្គិចផ្លូវចិត្ត នៅក្នុងអំពើប្រល័យពូជសាសន៍នៅកម្ពុជា

**(តចប់)**

**អត្ថន័យនៃពាក្យកំហឹងនិងឈឺចាប់ផ្អែកលើវប្បធម៌និងសាសនា**

ដូចដែលហេតុការណ៍បានស្តែងឲ្យឃើញការប៉ះទង្គិចផ្លូវចិត្ត នៅក្នុងវប្បធម៌ផ្សេងៗគ្នាមិនអាចទទួលយកទាំងស្រុងដោយស្រួលនោះទេ ចំពោះការយល់ដឹងរបស់មនុស្សទូទៅនិងកត្តាជីវសាស្ត្រដែលស៊ាំជាមួយយើងទាំងអស់គ្នា ។ ប្រសិនបើយើង



ការប៉ះទង្គិចផ្លូវចិត្តដែលបណ្តាលមកពី
ការឃើញហេតុការណ៍រន្ធត់

និយាយថា យ៉ុម ទទួលរងនូវការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរមែននោះ យើងនឹងសម្គាល់បានតាមសញ្ញាណចម្លែកៗជាក់ស្តែងមួយចំនួន (ការជួបប្រទះ ការឃើញផ្ទាល់ភ្នែក ឬការប្រឈមមុខទៅនឹងហេតុការណ៍ប៉ះទង្គិចផ្លូវចិត្តខ្លាំងដែលបង្កឲ្យមាន "ការភ័យខ្លាចអស់សង្ឃឹម ឬរន្ធត់ចិត្ត" ធ្ងន់ធ្ងរ) រោគសញ្ញា ("ឆាប់ខឹង" ឬ "ការផ្ទុះកំហឹង") ការយល់ដឹងពីអារម្មណ៍និងការប៉ះទង្គិចផ្លូវចិត្ត (ស្ថានភាពក្នុងខ្លួនមានលក្ខណៈខុសពីអារម្មណ៍ទាក់ទងទៅនឹងជីវភាពរស់នៅក្នុងសង្គមនិងសីលធម៌) និងការចេញវេជ្ជបញ្ជា (ការព្យាបាលរោគនិងការប្រើថ្នាំពេទ្យ) ដែលបានចាក់ឫសយ៉ាងជ្រៅនៅក្នុងប្រវត្តិសាស្ត្រនិងវប្បធម៌ ដោយមើលរំលងទំហំនៃការជួបប្រទះខាងវប្បធម៌ជាក់ស្តែងដែលមានសារសំខាន់ទាំងការយល់ដឹងនិងរកឲ្យឃើញថាតើប្រជាជនកម្ពុជាទប់ទល់ជំងឺប៉ះទង្គិចផ្លូវចិត្តយ៉ាងដូចម្តេច? ការយល់ដឹងពីភាពស្រួចស្រាល់ខាងវប្បធម៌នឹងនាំឆ្ពោះទៅរកលទ្ធផលជោគជ័យជាមួយប្រជាជនកម្ពុជា ។

ដើម្បីបង្ហាញបន្ថែមលើចំណុចនេះ ខ្ញុំនឹងបកស្រាយចំណុចខ្លះទាក់ទងនឹងការឆ្លើយតបរបស់ យ៉ុម ចំពោះការប៉ះទង្គិចផ្លូវចិត្ត ។ ក៏ដូចជាប្រជាជនកម្ពុជាផ្សេងៗទៀតដែលបានបាត់បង់សមាជិកគ្រួសារនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ យ៉ុម បន្តមានគំនុំគុំគួនយ៉ាងខ្លាំងចំពោះខ្មែរក្រហម ។ ជាទូទៅ គាត់បានពិភាក្សាអំពីសម័យខ្មែរក្រហមនៅក្នុងបរិបទទូលំទូលាយ (ដែលខុសពីចំណុច

ឈើចាប់ជាក់ស្តែង ដូចមាននៅក្នុងបទសម្ភាសន៍) ដោយរាប់ចាប់តាំងពីការបញ្ចេញកំហឹងខ្លាំងរហូតទៅដល់ការយល់ដឹងអំពីកម្មផល និងការចាប់កំណើតថ្មីខាងព្រះពុទ្ធសាសនា ។ ឧទាហរណ៍ មុនពេលធ្វើសម្ភាសន៍ យ៉ុម តែងតែនិយាយពាក្យ "ស្អប់" "ឈឺចាប់" និង "ខឹង" នៅពេលពិភាក្សាអំពីរបបកម្ពុជាប្រជាធិបតេយ្យ ដូចបានបង្ហាញតាមរយៈសម្តីខាងក្រោម ៖ "ខ្ញុំស្អប់ខ្មែរក្រហម ។ ខ្ញុំស្អប់របបនោះ ។ ខ្ញុំមិនចង់ឃើញ មិនចង់ឮរបបនេះម្តងទៀតទេ ។ ខ្ញុំស្អប់របបនោះ ។ ខ្ញុំមានកំហឹងនៅពេលខ្ញុំគិតអំពីរបបនោះ" ។ គាត់បង្ហាញចេញនូវការប្រមាថចំពោះខ្មែរក្រហមដោយពិពណ៌នារបបនោះតាមរយៈសព្វនាមប្រមាថថា "វា" ព្រោះថាពាក្យនេះក៏ត្រូវបានប្រើសម្រាប់ពិពណ៌នាអំពីមនុស្សដែលមានឋានៈសង្គមទាប ដូចជាសត្វ វត្ថុ ឬអ្នកដែលគួរឲ្យមើលងាយ ។ មានពេលមួយនោះ នៅពេលមានការពិភាក្សាពីការភ័យខ្លាចសេចក្តីស្លាប់ យ៉ុម និយាយអំពី ប៉ុល ពត ភ្លាមថា ៖ "អ្នកធ្វើអំពើបាបនឹងចុះទៅឋាននរក អ្នកដែលធ្វើអំពើល្អនឹងបានឡើងទៅឋានសួគ៌ ហើយ ប៉ុល ពត នឹងចាប់កំណើតជាសត្វចង្រៃរស់នៅក្នុងភក់ជ្រាំកន្លែងដីគគ្រិច" ។ ជាមួយគ្នានោះដែរ នៅពេលពិភាក្សាអំពីការស្លាប់របស់ប្តីគាត់ យ៉ុម បង្ហាញចេញនូវឥរិយាបថប្រកបដោយការគោរពដែលឆ្លុះបញ្ចាំងពីភាពខុសប្លែកគ្នា ។

ការឆ្លើយតបរបស់ យ៉ុម ស្របជាមួយនឹងការឆ្លើយតបរបស់ប្រជាជនកម្ពុជាផ្សេងៗទៀត ដែលតស៊ូអត់ធ្មត់ទៅនឹងកេរដំណែលរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ ឧទាហរណ៍ នារីជាស្ត្រីដែលសមាជិកគ្រួសារទាំង១១នាក់របស់គាត់ លើកលែងតែគាត់និងប្អូនស្រីម្នាក់ដែលក្រៅពីនោះត្រូវបានសម្លាប់ដោយពួកខ្មែរ-ក្រហម បានបន្តចងគំនុំយ៉ាងខ្លាំងចំពោះជនដៃដល់ដែលបានសម្លាប់សមាជិកគ្រួសារ ។ នារី បានរៀបរាប់ឡើងវិញអំពីអារម្មណ៍របស់គាត់នៅពេលគាត់ជួប ហ៊ាន ជាអតីតសិស្សរបស់ឪពុកគាត់ដែលចូលរួមក្នុងចលនាខ្មែរក្រហមនិងបន្ទាប់មកបានសម្លាប់ឪពុកគាត់ ព្រោះតែហេតុផលមួយដោយសារឪពុកគាត់ធ្លាប់វាយ ហ៊ាន នៅក្នុងថ្នាក់រៀនៈ នៅពេលខ្ញុំឃើញ ហ៊ាន ខ្ញុំខឹងណាស់ ។ ប៉ុន្តែខ្ញុំមិនដឹងធ្វើយ៉ាងម៉េច ។ ខ្ញុំជាស្ត្រីភេទ ។ ខ្ញុំគិតខ្លួនឯងថា "អាមនុស្សម្នាក់នេះ សម្លាប់ឪពុកខ្ញុំ ប៉ុន្តែវាអត់ងាប់" ។ នៅពេលខ្ញុំឃើញវា ខ្ញុំមានកំហឹងក្នុងចិត្ត ។ ចិត្តមួយចង់សងសឹក... នៅពេលខ្ញុំរំឭកឡើងវិញពីអ្វីដែលវាបានធ្វើខ្ញុំចាប់ផ្តើមក្តៅក្រហាយភ្លាម ។ ខ្ញុំចង់សម្លាប់វា ។ ខ្ញុំចង់សួរវាថា "តើឪពុកខ្ញុំបានធ្វើអ្វីឯងបានជាសម្លាប់គាត់? គាត់វាយឯងដោយសារតែឯងខ្ជិល" ។ នៅពេលខ្ញុំគិតអំពីវា ខ្ញុំខឹងយ៉ាងខ្លាំង ។ ខ្ញុំមានចិត្តឆាប់ខឹង ។ ប៉ុន្តែខ្ញុំមានចិត្តមួយទៀតខ្ជិល ។ ខ្ញុំគិតខ្លួនឯងថា "កុំសងសឹកអាមនុស្ស

ការប៉ះទង្គិចផ្លូវចិត្តដែលបណ្តាលមកពីការរងអំពើទារុណកម្មធ្ងន់ធ្ងរ



អាក្រក់ ។ បណ្តោយវាទៅតាមកម្មផលរបស់វាទៅ ។ "ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់" ។ ចិត្តខ្ញុំចង់ធ្វើបាប និងសម្លាប់វាចោល ។ ប៉ុន្តែចិត្តខ្ញុំមួយផ្នែកទៀតគិតថា មិនបាច់ធ្វើអីចឹងទេ ។ ខ្ញុំសង្ឃឹមថាអ្នកផ្សេងដែលស្អប់វា ដែលចងគំនុំជាមួយវានឹងសម្លាប់វាចោលជាមិនខាន ។ អ្នកទាំងនោះនឹងធ្វើបែបនេះដើម្បីរំងាប់អារម្មណ៍ឆ្លើយតបទៅនឹងអ្វីដែល ហ៊ាន បានប្រព្រឹត្តចំពោះក្រុមគ្រួសារ ។ ដូច្នេះ ប្រសិនបើខ្ញុំមិនសម្លាប់វាទេ អ្នកផ្សេងទៀតនឹងសម្លាប់វាជាមិនខាន ។

ដើម្បីស្វែងយល់អំពីសម្តីនេះ ដែលនឹងនាំឲ្យយល់ពីការឆ្លើយតបរបស់ យ៉ុម និង នារី ចំពោះជំងឺប៉ះទង្គិចផ្លូវចិត្ត មនុស្សម្នាក់ៗត្រូវតែបង្ហាញចេញនូវសំនួនវោហារសព្ទមួយចំនួនដែលរៀបរាប់

ចម្លើយឆ្លើយតបរបស់ខ្លួនជាពិសេសគឺការសម្តែងចេញតាមតថភាពដែលផ្តល់នូវអំណាចនិងកម្លាំង ។ ប្រសិនបើការសម្តែងចេញនេះជាទ្រឹស្តីរបស់មនុស្សមែននោះ ខ្ញុំសូមប្រើពាក្យ "ការសម្តែងចេញតាមតថភាព" ដើម្បីនិយាយសំដៅយករបៀប ដែលសកម្មភាពរបស់មនុស្សនិងការស្វែងយល់របស់មនុស្សទូទៅត្រូវបានជ្រួតជ្រាបដោយសារតែការសម្តែងចេញពីក្នុងខ្លួនតាមតថភាពនិងត្រូវបានបង្ហាញចេញតាមរយៈបទពិសោធន៍ ឬរបៀបរបបរបស់មនុស្សនៅក្នុងពិភពលោកបានប្រឡូកចូលនៅក្នុងសកម្មភាពសង្គម ។

យ៉ុម និង នារី ចិញ្ចឹមចិត្តចងកំហឹងយ៉ាងខ្លាំង ដែលជាអារម្មណ៍មួយភ្ជាប់ជំងឺប៉ះទង្គិចផ្លូវចិត្តទៅនឹងទស្សនៈក្តៅក្រហាយដែលស្តែងចេញពីធម្មជាតិ ។ ឧទាហរណ៍ នៅពេលពិភាក្សាអំពីរបបខ្មែរក្រហម យ៉ុម បានប្រាប់ខ្ញុំថា "នៅពេលខ្ញុំគិតពី ប៉ុល ពត ខ្ញុំក្តៅ... ខ្ញុំខឹងហើយស្អប់ពួកវាដែលធ្វើបាបយើង" ។ ស្រដៀងគ្នានេះដែរ នារី និយាយថា គាត់មាន"អារម្មណ៍ក្តៅក្រហាយ" នៅពេលគាត់ឃើញ ហ៊ាន ហើយរំឭកដល់អ្វីដែល ហ៊ាន បានប្រព្រឹត្តមកលើឪពុករបស់គាត់ ។ នៅក្នុងវចនានុក្រមខ្មែរ ពាក្យដែល យ៉ុម និង នារី និយាយអំពីកំហឹងមានន័យថា "ការទទួលនូវសម្ពាធ" នៅពេលដែល "មានអារម្មណ៍មិនសប្បាយចិត្តនឹងអ្វីមួយ"...ប្រការនេះបង្កឲ្យចិត្តក្តៅក្រហាយ ។ ពាក្យ"កំហឹង" ដែលមានន័យច្រើននៅក្នុងភាសាខ្មែរ ត្រូវបានបកស្រាយតាម រយៈពាក្យប្រដូច "ក្តៅ" : មនុស្សដែលខឹងអាចនិយាយបានថា អ្នកនោះមានចិត្ត "ក្តៅ" ដូចជា "ក្តៅចិត្ត" ឬ "ក្តៅក្រហាយ" ។

បើទោះជាពាក្យ "ក្តៅ" មិនសូវបានកត់សម្គាល់នៅក្នុងផ្នត់គំនិតរបស់អឺរ៉ុប-អាមេរិកាំងនិងកម្ពុជាក៏ដោយ ពាក្យ"កំហឹង"នៅក្នុងភាសាខ្មែរមានការជាប់ទាក់ទិនទៅនឹងនរវិទ្យាដែលទទួលឥទ្ធិពលពីព្រះពុទ្ធសាសនា ជំនឿលើព្រលឹង អេយូវើឌិក (Ayurvedic) និងប្រពៃណីព្យាបាលជំងឺរបស់ចិន ព្រមទាំងផ្តោតសំខាន់ជុំវិញទស្សនៈតុល្យភាពនិងលំហូរសមស្របទាក់ទងនឹង "ខ្យល់" ហើយឈាមដែលហូរតាមសរសៃតូចៗនៅក្នុងខ្លួនមនុស្ស ។

នៅក្នុងប្រព័ន្ធរូបារម្មណ៍នេះ មនុស្សម្នាក់ៗជាប់ពាក់ព័ន្ធជាមួយនឹងតុល្យភាពខាងសរីរាង្គ ជាពិសេសតុល្យភាពរវាងក្តៅនិងត្រជាក់ ។ រូបារម្មណ៍មួយចំនួនមានលក្ខណៈក្តៅនិងត្រជាក់ដូច្នេះ "ភាពនឹងនរ"របស់មនុស្សទាក់ទងទៅនឹងភាពស្មុគស្មាញនៃអារម្មណ៍ក្តៅ ហើយ "ភាពឆាប់ខឹង" ទាក់ទងនឹងភាពត្រជាក់ពេក ។ "ខ្យល់" ដែលជារូបារម្មណ៍សំខាន់នៅក្នុងនរវិទ្យារបស់ខ្មែរមានលក្ខណៈត្រជាក់ ហើយមានផលប៉ះពាល់ដោយផ្ទាល់ទៅនឹងតុល្យ-ភាពនៃភាពក្តៅនិងត្រជាក់តាមរយៈចលនាឈាមរត់ ។ នៅពេលដែលមនុស្សម្នាក់ជួបប្រទះនូវភាពធុញថប់ក្នុងអារម្មណ៍ ចរន្តឈាមនឹងរអាក់រអួលនិងលែងដំណើការដែលនាំទៅដល់រោគសញ្ញាផ្សេងៗចេញពីរាងកាយនិងជំងឺផ្សេងៗ ។ នៅពេលនោះ ប្រជាជនកម្ពុជាគ្រាន់តែនិយាយថា គាត់"ឈឺ" ជាពាក្យដែល យ៉ុម បាននិយាយម្តងហើយម្តងទៀតក្នុងពេលជួបសម្ភាសន៍ ។ ដើម្បីស្តារតុល្យភាពខាងសរីរាង្គកាយ ប្រជាជនកម្ពុជាប្រើប្រាស់វិធីព្យាបាលជំងឺតាមមូលដ្ឋានដើម្បីបំបាត់ភាពរាំងស្ទះនៅខាងក្នុងខ្លួន ឬបន្ទូរខ្យល់ដ៏ច្រើនលើសលប់នៅក្នុងខ្លួនតាមរយៈ"កោសខ្យល់" (កោសលើស្បែកខ្លាំងៗដោយប្រើជាយកាក់) ចាប់ ឬម៉ាស្សាចំណុចសំខាន់ៗនៃដងខ្លួន ជប់ខ្យល់នៅលើស្បែកដោយប្រើពែងក្តៅដើម្បីបឺតខ្យល់ចេញឬលាបប្រេងកូឡា ។ ជំងឺធ្ងន់ធ្ងរផ្សេងៗទៀតអាចនឹងជំរុញឲ្យអ្នកជំងឺទៅរកព្រះសង្ឃ ឬគ្រូបុរាណដែលចេះក្បួនខ្នាតប្រកបដោយអំណាចដើម្បីស្តារសុខភាពផ្លូវកាយ ។

ដូចការអនុវត្តបានបង្ហាញខាងលើ តុល្យភាពមានសារសំខាន់ចំពោះសុខុមាលភាពរបស់ប្រជាជនកម្ពុជា ទាំងផ្នែកទំនាក់ទំនងសង្គម និងសុខភាពរាងកាយ ដែលផ្នែកទាំងពីរនេះមានទំនាក់ទំនងគ្នាយ៉ាងស្អិតល្មួតនៅក្នុងផ្នែកចិត្តវិទ្យារបស់មនុស្ស ។ អារម្មណ៍ខឹងបង្កឲ្យមានភាពរអាក់រអួលដល់តុល្យភាពនេះយ៉ាងខ្លាំង ដោយឲ្យសញ្ញាណនានាចំពោះភាពរអាក់រអួលដល់របៀបរបបសង្គមដែលមនុស្សម្នាក់ៗ មាននិងបង្កើតនូវអារម្មណ៍ធុញថប់ដូចជា ឈឺចាប់មិនសូវស្រួលខ្លួន វិលមុខ ឬក្តៅ ជារោគសញ្ញាដែលប្រជាជនកម្ពុជាមានជាញឹកញាប់ ។ "កំហឹងពេញបន្ទុក" អាចនិយាយបានថាជា"សម្ពាធ"នៃអារម្មណ៍ដែលជាចំណែកមួយដ៏រស់រវើក ក៏ប៉ុន្តែមានលក្ខណៈរអាក់រអួលនិងចិត្តសង្គមយ៉ាងខ្លាំង ហើយដែល "ញាំុងចិត្តរបស់មនុស្ស"ឲ្យមានសកម្មភាព ។ ចិត្តក្តៅនិងកំហឹងរបស់ យ៉ុម ផ្តល់នូវភាពអតុល្យភាពដ៏មានសារសំខាន់ខាងវប្បធម៌

ដែលទាក់ទងទៅនឹងជំងឺប៉ះទង្គិចផ្លូវចិត្តរបស់គាត់ ដែលមិនគ្រាន់តែជា "ការរំខានដល់ស្ថានភាពខាងក្នុងខ្លួន" ប៉ុណ្ណោះទេ ក៏ប៉ុន្តែជាការបន្ថែមផលប៉ះពាល់ដល់សង្គមថែមទៀតដោយភ្ជាប់ជាមួយនឹងនយោបាយនិងសីលធម៌ ។

ម្យ៉ាងទៀត នារី មានជំនឿទៅលើព្រះពុទ្ធសាសនា ដោយនិយាយថា ប្រហែលជាគាត់គួរទុកឲ្យ ហ៊ាន "ទទួលយកកម្មផលរបស់គាត់" ហើយ ។ នារី បានលើកយកពុទ្ធឱវាទមួយឃ្លាថា ៖ *"ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់"* ។ ព្រះពុទ្ធសាសនាជាចំណែកសំខាន់សម្រាប់បទពិសោធន៍និងការយល់ដឹងអំពីជំងឺប៉ះទង្គិចផ្លូវចិត្តរបស់ យ៉ុម ដោយផ្ដល់នូវការពន្យល់ចំពោះអ្វីដែលបានកើតឡើង (ការលើកឡើងជារឿយៗអំពីទស្សនៈរបស់ព្រះពុទ្ធសំខាន់ពីរយ៉ាងគឺ ទុក្ខនិងបាបកម្ម ហើយយុត្តិធម៌ចុងក្រោយ (ការអះអាងរបស់គាត់ថា ប៉ុល ពត នឹងចាប់កំណើតទៅជាសត្វតិរច្ឆាន) ។ ទ្រឹស្ដីរបស់ព្រះពុទ្ធផ្ដល់នូវគតិភាពច្បាស់លាស់ដែលពន្យល់អំពីថាអំពើហិង្សាមានប្រភពចេញពីភាពមិនយល់ និងឆន្ទៈផ្ទាល់ ។

ប្រសិនបើផលប៉ះពាល់នៃអំពើហិង្សាបង្ហាញចេញតាមរយៈសញ្ញាណដ៏ទូលំទូលាយនោះ សកម្មភាពបែបនេះនឹងមានផលប៉ះពាល់យូរអង្វែងជាមិនខាន ។ ម្យ៉ាងទៀត អំពើហិង្សាអាចធ្វើឲ្យអ្នកផ្សេងទៀតសងសឹកជាមួយនឹងអ្នកនោះ ។ ម្យ៉ាងវិញទៀត ការធ្វើឲ្យអ្នកផ្សេងឈឺចាប់ចាត់ទុកថាជាអំពើបាបនៅក្នុងព្រះពុទ្ធសាសនា ដោយនាំទៅរកការបាត់បង់អំពើដែលជាកុសល ហើយទំនងជានឹងចុះថយឋានៈពេលចាប់កំណើតនៅជាតិមុខទៀតផង ។ អ្នកដែលសម្លាប់គេនឹងទៅចាប់កំណើតជាសត្វថោកទាប ឬប្រហែលជាចុះទៅនរកថែមទៀត ដូចជានរកឡហាកុមបា ដែលអ្នកដែលសម្លាប់គេនោះនឹងត្រូវកាត់កនិងស្ងោរ ។

ក្រៅពីផ្ដល់ការសិក្សាស្វែងយល់អំពីមូលហេតុនៃអំពើហិង្សា និងផលវិបាក ព្រះពុទ្ធសាសនាក៏បានផ្ដល់នូវវិធីបង្ការចំពោះស្ថានភាពដ៏អាក្រក់នេះតាមរយៈមាគ៌ាកណ្ដាល ។ នៅតាមមូលដ្ឋាន ប្រជាជនកម្ពុជាត្រូវបានលើកទឹកចិត្តឲ្យអនុវត្តសីលប្រាំ ដែលក្នុងនោះមានការហាមប្រាមមិនឲ្យសម្លាប់ ។ ព្រះសង្ឃប្រៀនប្រដៅថា មនុស្សគ្រប់រូបត្រូវចេះគ្រប់គ្រង និងពន្លត់កំហឹងដែលកើតចេញពីអចេតនា និងចេតនា ព្រមទាំងនាំទៅរកអំពើហិង្សា និងផលប៉ះពាល់ ។ នៅក្នុងសាសនាព្រះពុទ្ធ វិធីសាស្ត្រប្រកបដោយភាពប្រយ័ត្នប្រយែងដើម្បីទប់ទល់នឹងអំពើហិង្សានិងអារម្មណ៍ផ្សេងៗ គឺត្រូវរកឲ្យឃើញពីប្រភពនិងទុកឲ្យកំហឹងនិងអារម្មណ៍ទាំងអស់នោះរលត់ទៅវិញ ដោយសារតែអារម្មណ៍បែបនោះ ក៏ដូចជាអ្វីៗផ្សេងទៀតនៅក្នុងលោកយើងនេះមិនមានលក្ខណៈអចិន្ត្រៃយ៍ ។ អ្នកដែលបន្តការប្រព្រឹត្តអំពើអ្វីមួយដោយអចេតនានឹងទទួលផលវិបាកចំពោះសកម្មភាពរបស់ខ្លួន ដោយអំពើទាំងនោះប្រៀបបាននឹងស្រមោលអន្ទោលតាមប្រាណ ដោយអ្នកនោះនឹងពើបប្រទះនៅក្នុងជាតិនេះ ឬជាតិខាងមុខ ។

ប្រសិនបើព្រះពុទ្ធសាសនាផ្ដល់យុត្តិធម៌ដល់ជនរងគ្រោះដ៏សមស្រប នោះបង្ហាញថាផលប៉ះពាល់របស់សត្វលោកជាលទ្ធផលនៃអំពើបាបពីអតីតជាតិ ។ អ្នកខ្លះចាត់ទុកអ្វីៗដែលបានកំពុងកើតឡើងនោះ ថាជាការត្រាស់ដឹងរបស់ព្រះពុទ្ធអស់រយៈពេលច្រើនពាន់ឆ្នាំមកហើយ ដូចជាពុទ្ធទំនាយជាដើម ។ ពុទ្ធទំនាយជាច្រើនកើតមាននៅពេលដែលមនុស្សអាក្រក់ ឬសមាជិកនៃអ្នកដែលមានឋានៈទាបបំផុតនៅក្នុងសង្គមខ្មែរបានឡើងគ្រប់គ្រងហើយធ្វើឲ្យសណ្ដាប់ធ្នាប់សង្គមមានលក្ខណៈបញ្ច្រាសទិស ដែលនាំឲ្យមានការវាយប្រហារទៅលើព្រះពុទ្ធសាសនា គ្រោះទុរភិក្ស និងសេចក្ដីស្លាប់គ្រប់ទីកន្លែង ។ តាមពិតនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនកម្ពុជាតែងតែក្រើនរំឭកខ្លួនឯងនូវពាក្យមួយឃ្លាថា "ដាំដើមគ" ដែលហាក់ដូចជាពាក្យកម្ចីអំពីពុទ្ធទំនាយនោះឯង ។

នៅក្នុងភាសាខ្មែរ ពាក្យ "ដាំដើមគ" គឺមានពាក្យដើម "គ" ដែលអាចមានន័យថា "និយាយមិនរួច គ្មានសំឡេង និងសំឡេងខ្សាវស្ដាប់មិនបាន" ។ អាស្រ័យហេតុនេះ ឃ្លា "ដាំដើមគ" បង្ហាញឲ្យឃើញថាមនុស្សម្នាក់ៗត្រូវតែកសាងជញ្ជាំងស្ងប់ស្ងាត់ដើម្បីរស់រានពីអំពើឃោរឃៅនៃរបបប្រល័យពូជសាសន៍ ។ ឪពុករបស់លោក ហាំង ង៉ោ បានប្រដៅកូនគាត់ថា ៖ *"ចាប់ពីឥឡូវនេះទៅត្រូវបិទមាត់ (ដាំដើមគ) ទោះជាមានអ្វីកើតឡើងក៏ដោយ កុំឲ្យគេមានលេសយកឯងទៅឲ្យសោះ... ដូច្នេះកូនត្រូវដាំដើមគ ។ អត់ធ្មត់ ស្ងៀមស្ងាត់ និងកុំនិយាយ ។ មិនយូរមិនឆាប់ថ្ងៃណាមួយបដិវត្តន៍នេះនឹងក្រឡាប់ចាក់ជាមិនខាន"* ។

ពិន យ៉ាថៃ បានពន្យល់ប្រភពដើមនៃពុទ្ធទំនាយរបស់ព្រះពុទ្ធថា ៖ "ពុទ្ធ"ជារឿងរ៉ាវកាលពីសតវត្សរ៍ទី១៩ដែលព្យាករណ៍ថា ប្រទេសនេះនឹងជួបប្រទះនូវការផ្លាស់ប្តូរទាំងស្រុងនូវគោលការណ៍សីលធម៌ជាប្រពៃណី គេហដ្ឋាននិងផ្លូវថ្នល់គ្មានមនុស្សរស់នៅ និងដើរ អ្នកល្ងង់ខ្លៅនឹងធ្វើទុក្ខទោសអ្នកចេះដឹង ពួកទមិឡនឹងកាន់អំណាចពេញបន្ទុកនិងសម្លាប់អ្នកធម៌អាថ៌ ។ ក៏ប៉ុន្តែមនុស្សទាំងឡាយអាចរស់រានមានជីវិតបើសិនជាអ្នកនោះដាំដើមគ ។ "គ" មានន័យថា "និយាយមិនរួច" ។ ការបកស្រាយដ៏លំបាកនូវខ្លឹមសារនេះគឺថាមានតែអ្នកគថ្លង់ប៉ុណ្ណោះនឹងអាចរស់រានមានជីវិតក្នុងអំឡុងពេលមានគ្រោះមហន្តរាយនោះ ។ ធ្វើថ្លង់ធ្វើគ ។ ឥឡូវនេះខ្ញុំចាប់ផ្តើមយល់អំពីវិធីដែលធ្វើឲ្យអាចរស់បាន ។ ធ្វើពុតជាថ្លង់ល្ងីល្ងើ ។ កុំនិយាយអ្វីទាំងអស់ មិនស្តាប់ឮអ្វីទាំងអស់ និងមិនយល់អ្វីទាំងអស់ ។

ការព្យាករណ៍បែបនេះធ្វើឲ្យប្រជាជនខ្មែរយល់អំពីភាពស្អាតស្អំនិងភាពបំពុលដែលជាផ្នែកមួយផ្ទុយគ្នារវាងសាសនាព្រះពុទ្ធនិងទមិឡ ធម្មានិងគ្មានធម្មា សណ្តាប់ធ្នាប់និងភាពគ្មានសណ្តាប់ធ្នាប់ ភាពស៊ីសង្វាក់និងភាពបែកខ្ញែកគ្នា ។ ប្រជាជនកម្ពុជាខ្លះ ចាប់ផ្តើមចាត់ទុកខ្មែរក្រហមថាជាទមិឡភ្នែកក្រហម ដែលស៊ីសាច់ជនរងគ្រោះដូចមាននៅក្នុងរឿងព្រេងខ្មែរដែលត្រូវបានអះអាង (តាមពាក្យចចាមអារ៉ាមនិងការអង្កេតផ្ទាល់) តាមរយៈការអនុវត្តន៍របស់ពួកខ្មែរក្រហមស៊ីថ្លើមជនរងគ្រោះ ។

## សន្និដ្ឋាន

ក្នុងលក្ខខណ្ឌបែបនេះ ប្រជាជនកម្ពុជាបានឆ្លើយតបចំពោះជំងឺប៉ះទង្គិចផ្លូវចិត្តតាមរយៈការយល់ដឹងនៅតាមមូលដ្ឋាន តាមរយៈការសម្តែងចេញនូវតថភាពជាក់ស្តែង ។ ខ្ញុំសូមធ្វើសេចក្តីសន្និដ្ឋានដោយគូសបញ្ជាក់លើប្រាំចំណុច ៖

ទីមួយ យើងត្រូវពិនិត្យពិចារណាពីភាពខុសគ្នាខាងផ្នែកវប្បធម៌នៅពេលពិនិត្យមើល និងព្យាបាលជំងឺប៉ះទង្គិចផ្លូវចិត្ត ។ ដូចមាននៅក្នុងការពិភាក្សារបស់ខ្ញុំស្តីពីព្រះពុទ្ធសាសនា សរីរវិទ្យារបស់ខ្មែរ និង"ដាំដើមគ" បានបង្ហាញថា ការយល់ដឹងរបស់ប្រជាជននៅតាមមូលដ្ឋានស្តីពីការសម្តែងចេញប្រកបដោយតថភាពអាចធ្វើឲ្យបទពិសោធន៍និងការឆ្លើយតបរបស់មនុស្សម្នាក់ចំពោះការប៉ះទង្គិចផ្លូវចិត្តប្រកបដោយឥទ្ធិពល ។ ជាងនេះទៀត យើងត្រូវមានការប្រយ័ត្នប្រយែងចំពោះទំនាក់ទំនងរវាងវប្បធម៌ និងការព្យាបាល ដោយសារតែការព្យាបាលជំងឺថប់បារម្ភមានលក្ខណៈខុសៗគ្នាទៅតាមវប្បធម៌ ទាមទារឲ្យមានការយល់ដឹងអំពីវប្បធម៌ផ្សេងៗនោះឲ្យបានស៊ីជម្រៅដើម្បីធ្វើការព្យាបាល ។

ទីពីរ តាមរយៈការយល់ដឹងអំពីភាពខុសគ្នាខាងវប្បធម៌បែបនេះ យើងនឹងទទួលបានចក្ខុវិស័យថ្មីៗថែមទៀតស្តីពីការសន្មតទុកជាមុននិងភាពលម្អៀងចំពោះការយល់ដឹង ។ ឧទាហរណ៍ នៅក្នុងភាសាខ្មែរ គ្មានពាក្យ "ប៉ះទង្គិចផ្លូវចិត្ត" ។ ដើម្បីនិយាយអំពីអ្វីៗទាក់ទងនឹងការប៉ះទង្គិចផ្លូវចិត្ត អ្នកនោះត្រូវនិយាយអំពីការរងទុក្ខ (ដែលនិយាយជាទូទៅនៅក្នុងសាសនាព្រះពុទ្ធ) ឬការឈឺចាប់ ។ ទស្សនៈទាំងអស់នេះផ្សារភ្ជាប់នឹងរោគសញ្ញាខាងផ្នែកសរីរាង្គកាយ ដែលប្រជាជនកម្ពុជាជួបប្រទះតាមរយៈភាពអតុល្យ-ភាពនៃអារម្មណ៍ដូចជាឈឺក្បាល បែក



ការប៉ះទង្គិចផ្លូវចិត្តដែលបណ្តាលមកពីសង្គ្រាម

ញើស ឈឺក្នុងខ្លួន ឬវិលមុខ ។ ដើម្បីឲ្យមានតុល្យភាពគ្នាវិញ អ្នកនោះមិនគ្រាន់តែស្វែងរកការព្យាបាលតាមវេជ្ជសាស្ត្រប៉ុណ្ណោះទេ ពីព្រោះតុល្យភាពនេះជាប់ទាក់ទិននឹងបរិស្ថាន សីលធម៌ សាសនា និងអន្តរបុគ្គលដែលបរិស្ថាននេះជះឥទ្ធិពលផ្ទាល់ដល់តុល្យភាពខាងរាងកាយ ។ យើងត្រូវពិចារណាឡើងវិញអំពីសារសំខាន់ដើម្បីព្យាបាលតាមក្បួនវេជ្ជសាស្ត្រ និងកំណត់រោគសញ្ញាភ្លាមៗ ដោយសារតែការព្យាបាលតាមក្បួនផ្នែកវេជ្ជសាស្ត្រអាចធ្វើបាត់បង់វិសាលភាពវប្បធម៌ សង្គម សីលធម៌ និងនយោបាយនៃជំងឺប៉ះទង្គិចផ្លូវចិត្ត ។

ទីបី យើងត្រូវប្រយ័ត្នប្រយែងមិនត្រូវវិនិច្ឆ័យអ្នកប៉ះទង្គិចផ្លូវចិត្តតែទៅលើភាពអកម្មទាំងស្រុងនោះទេ ។ ដូចដែល អាឡាន យ៉ាំង បានបង្ហាញយ៉ាងសមរម្យថា គំនិតស្តីពីការប៉ះទង្គិចផ្លូវចិត្តគឺជាពាក្យថ្មីដែលស្តែងចេញតាមរយៈភាពអកម្មដែលជាជំងឺចិត្តសាស្ត្រយូរអង្វែងដល់អ្នកជំងឺ ដោយរោគសញ្ញាថប់បារម្ភរបស់អ្នកជំងឺត្រូវទទួលការការព្យាបាល ។ ក្នុងន័យទូលំទូលាយជាងនេះទៀត ការសង្កត់ធ្ងន់ទៅលើជំងឺប៉ះទង្គិចផ្លូវចិត្តថាជាការថប់បារម្ភដែលបុគ្គលម្នាក់ៗទ្រាំអត់ធ្មត់យ៉ាងលំបាក ក៏ដូចជាជំងឺលើរាងកាយដែរ គឺភ្ជាប់ជាមួយភាពទំនើប ដែលកាត់ផ្តាច់ភាពស្មុគស្មាញរបស់មនុស្ស ហើយបង្កើតគំនិតបុគ្គលដែលមានកត្តាជីវសាស្ត្រពីធម្មជាតិ ។ ការប៉ះទង្គិចផ្លូវចិត្តនាំឲ្យលេចឡើងជំងឺចិត្តសាស្ត្រ ដែលធ្វើឲ្យអ្នកជំងឺថប់បារម្ភ ។ ចក្ខុវិស័យនេះ ខកខានមិនបានទទួលស្គាល់ទាំងស្រុងនូវអ្វីដែលផលប៉ះពាល់នេះ បង្កដោយសង្គមសីលធម៌និងនយោបាយ ។ ទោះជាមានជំងឺប៉ះទង្គិចផ្លូវចិត្ត អ្នកជំងឺនៅតែជាមនុស្សដ៏មានតម្លៃនិងពោរពេញដោយការស្ថាបនា ដោយឆ្លើយតបនិងមានសកម្មភាពក្នុងលក្ខខណ្ឌជីវិតដ៏លំបាកនេះ ។

ជាងនេះទៀត ទស្សនៈស្តីពី «របួស» បឋមអាចបង្វែរការចាប់អារម្មណ៍របស់យើងចេញពីអ្វីដែលការប៉ះទង្គិចផ្លូវចិត្តពីមុនអាចកើនឡើងដោយសារតែមានហេតុការណ៍បន្តបន្ទាប់ ។ ឧទាហរណ៍ ថាតើប្រជាជនកម្ពុជាឬប្រជាជនវៀតណាមបានទទួលផលប៉ះពាល់យ៉ាងដូចម្តេចខ្លះនៅពេលដែលអ្នកទាំងនោះត្រូវបានដាក់បង្ខំឲ្យរស់នៅក្បែរជនដៃដល់? ឬថាតើជំងឺរបស់ជនភៀសខ្លួនកម្ពុជាមានផលប៉ះពាល់ដែរឬទេ ចំពោះការធ្វើអន្តោប្រវេសន៍ទៅកាន់ពិភពវប្បធម៌ខុសគ្នាស្រឡះដូចជានៅសហរដ្ឋអាមេរិក ជនភៀសខ្លួនទាំងនោះត្រូវរស់នៅឆ្លងកាត់យ៉ាងលំបាកលំបិន ដូចជាការបាត់បង់តួនាទីសេវាសង្គមរអាក់រអួល ការរស់នៅក្បែរអ្នកជិតខាងប្រកបដោយគ្រោះថ្នាក់ និងការចិញ្ចឹមបីបាច់ថែក្សាកូនដែលកំពុងរៀនអំពីតម្លៃវប្បធម៌របស់ប្រទេសនេះ ហើយដែលអាចធ្វើជាអ្នកនាំផ្លូវរបស់ខ្លួនដោយសារតែការប្រើប្រាស់ភាសារបស់កូនបានល្អជាងនិងភាពស៊ាំទៅនឹងរបៀបរបបរស់នៅក្នុងប្រទេសអាមេរិក?

ទីបួន ក្រៅពីការព្យាយាមព្យាបាលនិងពិនិត្យទៅលើការឆ្លើយតបនិងឥទ្ធិពលរបស់ជំងឺប៉ះទង្គិចផ្លូវចិត្ត យើងក៏ត្រូវបង្វែរការចាប់អារម្មណ៍របស់យើងទៅរកប្រភពដើមព្រមទាំងការទប់ស្កាត់អំពើហិង្សាដែលបង្កឲ្យមានជំងឺប៉ះទង្គិចផ្លូវចិត្តពីដំបូងដែរ ។ ការស្រាវជ្រាវរបស់ខ្ញុំនៅក្នុងដំណើរការនេះ ដែលពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍ ជួយឲ្យខ្ញុំយល់អំពីសារសំខាន់ដើម្បីប្រែក្លាយការយល់បែបនេះទៅជាគោលដៅសុខភាពសាធារណៈ ។ នៅទីបញ្ចប់ យើងគិតអំពីជំងឺប៉ះទង្គិចផ្លូវចិត្ត ដែលអាចទុកឲ្យយើងគោរពការវិភាគខុសៗគ្នា និងសម្លឹងជ្រៅទៅក្នុងការវិភាគនីមួយៗ ដោយសារតែយើងព្យាយាមរកវិធីសាស្ត្រស្វែងយល់បញ្ចូលគ្នាស្តីពីការប៉ះទង្គិចផ្លូវចិត្តដែលស្ថិតនៅចន្លោះកម្រិតនៃការវិភាគខាងវប្បធម៌ ចិត្តសាស្ត្រ និងជីវសាស្ត្រ ។

ខ្ញុំសូមបញ្ចប់ដោយលើកយកពាក្យសម្តីរបស់ រ៉ូនី យីមស៊ុត ។ ខ្មែរក្រហមនាំយកមនុស្សទាំងគ្រួសារៗទៅកាន់វាលពិឃាតនិងសម្លាប់ចោល ។ ទោះបីជាត្រូវបានវាយចំកញ្ចឹងក និងដងខ្លួនជាច្រើនដង រ៉ូនី បានភ្ញាក់ដឹងខ្លួនវង្វេងវង្វាន់នៅក្នុងរណ្តៅសាកសពរួមពោរពេញដោយឈាម សាកសពអ្នកជាទីស្រលាញ់ និងជនរងគ្រោះជាច្រើននាក់ទៀត ។ គាត់បានសរសេរថា "ខ្ញុំនៅតែសុបិនឃើញការសម្លាប់រង្គាលនោះនារាត្រីដ៏ងងឹតស្ងួនស្ងៀសុងក្នុងខែធ្នូ ។ សុបិននេះមិនដែលចេញឆ្ងាយពីដួងចិត្តខ្ញុំឡើយ ហើយខ្ញុំនៅតែភ័យខ្លាចនៅពេលគិតអំពីរឿងនោះ ។ ពេលវេលាមិនអាចព្យាបាលការប៉ះទង្គិចផ្លូវអារម្មណ៍បានទេ ជាពិសេស គឺខ្ញុំតែម្តង ។ ខ្ញុំរស់នៅយ៉ាងយូរជាមួយនឹងការប៉ះទង្គិចផ្លូវអារម្មណ៍នេះ ។ តែជីវិតខ្ញុំចេះតែបន្តទៅមុខ ។ **អាឡិចសេនដឺ ហ៊ីនតុន**

# អ្វីៗដែលខ្ញុំនៅចងចាំពីរបបខ្មែរក្រហម

ខ្ញុំបាទឈ្មោះ នូ ប៊ុនធី មានកំណើតនៅភូមិកណ្តាល ឃុំវាល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ និងជាអតីតសិស្សថ្នាក់ទីបញ្ចប់នៃវិទ្យាល័យកំពង់ស្ពឺក្នុងឆ្នាំ១៩៧៤-៧៥ ហើយសព្វថ្ងៃ ខ្ញុំរស់នៅទីក្រុងអូតាវ៉ានៃប្រទេសកាណាដា ។

ក្នុងវ័យជាយុវជនដែលធ្លាប់ឆ្លងកាត់នូវអ្វីៗក្នុងសម័យនោះ ខ្ញុំបានចងក្រងអត្ថបទនេះឡើងដែលជាប្រវត្តិពិតនៅក្នុងគ្រួសារផ្ទាល់និងអ្វីៗដែលខ្ញុំនៅចងចាំ ។ ខ្ញុំនៅតែមានអារម្មណ៍ភ័យខ្លាចតក់ស្លុត និងឈឺចាប់ ទោះបីជាព្រឹត្តិការណ៍នោះបានកន្លងហួសជាច្រើនឆ្នាំមកហើយ ។ ដូច្នេះ ប្រសិនបើខ្ញុំបាននិយាយប្រាប់អ្នកណាម្នាក់ ឬប្រជាជនទូទាំងប្រទេស ជាពិសេសប្រាប់ទៅពិភពលោកឲ្យបានដឹងពីប្រវត្តិសាស្ត្រនោះ ប្រហែលជាអាចធ្វើឲ្យការភ័យខ្លាចនិងការឈឺចាប់នៅក្នុងអារម្មណ៍ខ្ញុំបានរំសាយខ្លះ ។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រសួងឃោសនាការស្ថានីយវិទ្យុផ្សាយសំឡេងបានចាក់ផ្សាយសេចក្តីថ្លែងការណ៍ខ្លីមួយរបស់ឧត្តមសេនីយ៍ ម៉ី ស៊ីចន ថា *«សូមឲ្យគ្រប់កងពលខាងផ្នែកជើងគោក ជើងទឹក ជើងអាកាស កុំធ្វើសកម្មភាពអ្វីទាំងអស់ ហើយលើកទង់ជ័យសជាសញ្ញាបញ្ចប់សង្គ្រាម»* ។ ប្រជាពលរដ្ឋនៅទីក្រុងភ្នំពេញក៏ដូចជានៅក្នុងក្រុងកំពង់ស្ពឺសប្បាយរីករាយណាស់ក្រោយពីទទួលដំណឹងនេះ ។ ប៉ុន្តែការសប្បាយបានក្លាយទៅជាទុក្ខទៅវិញ ពីព្រោះថាក្នុងរយៈពេលពីរម៉ោងក្រោយមកកងទ័ពខ្មែរក្រហមបានចូលពេញទីក្រុង ហើយប្រកាសប្រាប់ប្រជាជនដែលរស់នៅក្នុងទីក្រុងទាំងអស់ឲ្យចាកចេញ រួមទាំងអ្នកជំងឺនៅក្នុងមន្ទីរពេទ្យផងដែរ ។ កងទ័ពខ្មែរក្រហមបានបញ្ជាក់បន្ថែមថា ចេញឲ្យអស់ក្នុងរយៈពេលតែពីរ-បីថ្ងៃប៉ុណ្ណោះ ដើម្បីសម្រួលក្នុងការរៀបចំបោសសម្អាតទីក្រុង ។

ប្រជាជនរាប់លាននាក់ត្រូវបានជម្លៀសចេញពីទីក្រុងទាំងគក់ក្រហល់ ។ តាមច្រកព្រំប្រទល់ត្រូវបិទខ្ទប់ជាប់ ហើយទំនាក់ទំនងក្រៅប្រទេសត្រូវកាត់ផ្តាច់ ។ ទីក្រុងភ្នំពេញទាំងមូលបានក្លាយទៅជាទីក្រុងខ្មោច ។ ក្នុងស្ថានការណ៍ដែលកំពុងច្របូកច្របល់នោះ ខ្មែរក្រហមបានប្រើប្រាស់នយោបាយបោកបញ្ឆោតមួយឲ្យពួកអ្នកធ្លាប់ធ្វើទាហានរៀបចំខ្លួនដើម្បីទៅទទួលសម្តេចឪ ។ គេ[ខ្មែរក្រហម] បាននាំទាហានទាំងឡាយៗសំដៅទៅកន្លែងមួយដែលគ្មាននរណាដឹង ហើយអ្នកទាំងនោះក៏គ្មានថ្ងៃត្រឡប់មកវិញដែរ ។

ក្រោយមកគេបានរំសាយប្រជាពលរដ្ឋទៅរស់នៅតាមភូមិដែលមានប្រជាជនមូលដ្ឋានគឺ ពួកខ្មែរក្រហមនោះឯងកាន់ក្តាប់យ៉ាងតឹងរ៉ឹងបំផុត ។ ខ្មែរក្រហមបានប្រើនយោបាយត្រជាក់មួយទៀត គឺប្រមូលផ្តុំប្រជាជននៅតាមកន្លែងមករួមប្រជុំ ហើយប្រកាសនិងអំពាវនាវរកអ្នកធ្លាប់ធ្វើការឲ្យរដ្ឋាភិបាល ទាហាន ស៊ីវិល និស្សិត បញ្ញវន្ត ព្រោះអង្គការត្រូវការអ្នកចេះដឹងទាំងនោះ ដើម្បីរៀបចំប្រទេសជាតិឡើងវិញ ។ ដោយមិនបានយល់ពីនយោបាយបោកបញ្ឆោតទាំងនោះ អ្នកខ្លះក៏បានសារភាពថែមទាំងបានយកសញ្ញាប័ត្រដែលធ្លាប់រៀននៅប្រទេសវៀតណាមមកបង្ហាញទៀត ដែលអ្នកទាំងនោះក្រោយមកត្រូវអង្គការដម្រិតសួរ ស៊ើបអង្កេត និងតាមដានគ្រប់បែបយ៉ាង ហើយប្រសិនបើខ្មែរក្រហមសង្ស័យថាធ្វើទាហាន ឬធ្វើអ្វីមួយនៅក្នុងជួររដ្ឋាភិបាល អ្នកនោះនឹងត្រូវបាត់ខ្លួន ។ អ្នកដែលនៅសល់ជីវិត ហើយបានដឹងខ្លះៗពីអំពើកាប់សម្លាប់មនុស្សយ៉ាងព្រៃផ្សៃ រស់នៅទាំងភ័យរន្ធត់គ្រប់ជំហាននិងគ្រប់ដង្ហើមចេញចូល ។ អ្នកទាំងនោះទៀតសោតត្រូវបង្ខំឲ្យធ្វើការជាទម្ងន់ដូចជាលើកទំនប់ ជីកប្រឡាយ កាប់គាស់ព្រៃឈើ ។ ជីវភាពប្រជាជនកាន់តែខ្សត់ទៅៗ ។ អ្នកខ្លះទំស្តាយលុយយកទៅជាមួយដើម្បីចាយវាយ ប៉ុន្តែជាអកុសលទីផ្សារនិងការចាយលុយត្រូវបានបំបាត់ចោល សាលារៀន និងវត្តអារាមត្រូវបានបិទទ្វារ ចំណែកឯវត្តអារាមត្រូវប្រើប្រាស់ធ្វើជាមន្ទីរពេទ្យជាដើម ។ អង្គការប្រមូលផ្តុំប្រជាជនធ្វើការប្រជុំរៀនសូត្រញឹកញាប់ដើម្បីបំពាក់បំប៉នគោលនយោបាយ បង្រៀនកុមារឲ្យប្រឆាំងនឹងឪពុកម្តាយខ្លួន ហ៊ានសម្លាប់ឪពុកម្តាយឯង ។

ភាពអត់បាយក្រហាយទឹកកាន់តែធ្ងន់ធ្ងរឡើងៗជំរុញឲ្យប្រជាជនយកគល់ល្ហុង គល់ចេក មើមក្តួច មើមប្រងមកលាយជាមួយបាយ ។ ប្រជាជនត្រូវជួបប្រទះនឹងជំងឺរាតត្បាតជាច្រើនដូចជា ៈ ជំងឺគ្រុនចាញ់ ស្គមស្លេកស្លាំងអស់ពីស្គមទៅជាហើម ។

បើអ្នកណាម្នាក់មានរបួសនៅលើដៃឬជើង របួសនោះនឹងក្លាយទៅជាដំបៅដ៏ធំមួយដែលពិបាកនឹងព្យាបាល ហើយប្រសិនបើសំអាងទៅលើពេទ្យ គឺមិនឃើញមានថ្នាំអ្វីប្លែក ក្រៅពីថ្នាំដាក់នៅក្នុងដបទឹកក្រូចនិងថ្នាំគ្រាប់ដែលប្រជាជននាំគ្នាហៅថាថ្នាំអាចម៍ទន្សាយ ។ ថ្នាំទាំងនោះគឺការផ្នែប្រឌិតដោយខ្លួនឯង ហើយក៏គ្មានប្រសិទ្ធភាពអ្វីដែរ ។ ដូច្នេះអ្នកជំងឺដែលដេកនៅក្នុងមន្ទីរពេទ្យគឺរង់ចាំតែដល់ថ្ងៃស្លាប់ប៉ុណ្ណោះ ។

ចុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានដកប្រជាជនរាប់ពាន់គ្រួសារពីខេត្តកំពង់ស្ពឺ ទៅដាក់នៅតាមបណ្តោយទន្លេក្នុងខេត្តកំពង់ឆ្នាំង ពីព្រោះនៅទីនោះនៅមានសល់ដីទំនេរច្រើន ។ តំបន់នោះឲ្យឈ្មោះថា "ស្រុក១៨" ដែលចំណុះដោយឃុំជាច្រើនទៀតដូចជា ឃុំអម្ពិលទឹក ឃុំកោះថ្កូវ ឃុំកំពង់ត្រឡាចលើ និងឃុំកំពង់ត្រឡាចក្រោម ។ អង្គការបានបំបែកគ្រួសារនីមួយៗទៅតាមក្រុមទៅតាមកងយុវជន រស់នៅក្នុងកងយុវជន នារីរស់នៅក្នុងកងនារី កុមារអាយុចាប់ពី៦ឆ្នាំឡើងទៅនៅតាមកងកុមារ ។ បុរសជាប្តីក៏ត្រូវដកឲ្យទៅធ្វើការនៅកន្លែងផ្សេង ឯការតាមដានស៊ើបអង្កេតស្រាវជ្រាវរកអ្នកដែលជាប់និន្នាការក្នុងជួររដ្ឋាភិបាលរឹតតែតឹងឡើង មិនថាឡើយទាហាន សូម្បីតែគ្រប់ក្រសួងឲ្យតែអ្នកនោះជាប់និន្នាការក្នុងជួររដ្ឋាភិបាលត្រូវដកចេញឲ្យអស់ ។ ក្នុងរយៈពេលតែ៤-៥ខែ ស្ថិតិប្រជាជនថ្មីនៅក្នុងឃុំអម្ពិលទឹកមានចំនួន២៥០០នាក់នៅសល់តែ២៥០នាក់ ហើយប្រជាជនចំនួន៣០០០នាក់នៅឃុំកោះថ្កូវនៅសល់តែ៣០០នាក់ប៉ុណ្ណោះនេះ នោះបើតាមការអះអាងរបស់តំណាងអង្គការម្នាក់ដែលធ្លោយមាត់និយាយដោយមិនបានគិតពីទ្រឹស្តីអង្គការឲ្យចេះលាក់ការណ៍សម្ងាត់ ។ ស្ត្រីម្នាក់រស់នៅ ភូមិក្អែកពងឃុំអម្ពិលទឹក កំពុងតែព្រួយបារម្ភ ពេលដែលឈ្លបឆែកឃើញរូបថតប្តីរបស់ខ្លួនស្លៀកពាក់ជាឯកសណ្ឋានទាហាន ។ មួយសប្តាហ៍ក្រោយមក មួយគ្រួសារដែលមានកូនតូចបីនាក់ ម្តាយ ឪពុក ព្រមទាំងប្អូនប្រុសម្នាក់ផង ត្រូវយកទៅសម្លាប់ចោលទាំងអស់ ។ តាមតែអ្នកធ្លាប់បានឃើញនិយាយថា ការសម្លាប់ប្រជាជនទាំងខ្សែៗនោះជាអំពើដ៏សាហាវបំផុត ។ ជនដៃដល់សម្លាប់ដោយប្រើដំបង ឬត្បូងចប វាយចំកញ្ចឹងក ដោយអនុវត្តទៅតាមទ្រឹស្តីរបស់អង្គការឲ្យចេះមានការសន្សំសំចៃ ដូច្នេះជនដៃដល់មិនប្រើគ្រាប់រំសេវក្នុងការសម្លាប់មនុស្សទេ ។ គួរកត់សម្គាល់ផងដែរថា អ្នកដែលសម្លាប់មនុស្សនោះភាគច្រើនជាក្មេងអាយុប្រហែល១៨ឬ១៩ឆ្នាំប៉ុណ្ណោះ ។ ស្របពេលនោះសម្តីរបស់ស្ត្រីម្នាក់កំពុងតែដើរផងរត់ផងទៅតាមល្បឿនដែលឈ្លបគេទាញអូសពីមុខ និងម្នាក់ទៀតដេញតាមពីខាងក្រោយ គាត់បាននិយាយទាំងឈឺចុកចាប់ថា "អីក៏ពិបាកម្ល៉េះកូន ម្តេចក៏មិនសម្លាប់ឲ្យហើយទៅ" ។ មួយខ្សែដែលគេចងជាប់គ្នានោះមានមនុស្សប្រមាណ២០នាក់ ក្នុងនោះមានស្ត្រីពីរនាក់ ស្ត្រីម្នាក់មានកូនតូចនៅចង្កេះនិងកូនក្មេងអាយុប្រាំឬប្រាំមួយឆ្នាំបីនាក់ទៀត ។ នៅមិនឆ្ងាយប៉ុន្មានចុះពីផ្លូវជាតិលេខ៥ ទៅខាងជើងតាមផ្លូវលំមួយដែលមានរបងលួសព័ទ្ធជុំវិញ បុរសម្នាក់ឈ្មោះ យឹម សំបូរ ស្រុកកំណើតនៅភូមិកណ្តាល ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ជាអតីតគ្រូបង្រៀននៅសាលាបឋមសិក្សាខេត្តកំពង់ស្ពឺ ត្រូវជាប់នៅទីឃុំឃាំងនោះបានរយៈពេលតែប៉ុន្មានសប្តាហ៍ គាត់ក៏ត្រូវស្លាប់នៅទីនោះ ។ មានមន្ទីរមួយទៀតនៅតំបន់នោះដែរ សម្រាប់ដាក់អ្នកទោសធ្ងន់ដែលត្រូវបានសង្ស័យថា ធ្លាប់ធ្វើជាទាហាន ។ បុរសម្នាក់ឈ្មោះ សៀម ជាកូនលោកអ៊ំ យឹម ស្រុកកំណើតនៅភូមិកណ្តាលក៏ជាប់ឃុំឃាំងនៅទីនោះដែរ ។ ពេលយប់គាត់ត្រូវដាក់ខ្នោះដៃជើងឆ្កាងជាប់ទៅនឹងជញ្ជាំង ពេលថ្ងៃត្រូវបញ្ចេញឲ្យទៅធ្វើការ ។ គាត់ប្រហែលជាមិនបានឆ្លងផុតពីទីនោះទេ ។

ដើមឆ្នាំ១៩៧៦ អង្គការបានបង្កើតឲ្យមានជាសហករណ៍ គឺអ្វីៗត្រូវដាក់រួមទាំងអស់ តាំងពីការហូបចុកត្រូវមានចង្ក្រានរួមតែមួយ ។ គ្រប់ពេលប្រជុំរៀនសូត្រ អង្គការបានយកពាក្យសមូហភាពអ្វីៗត្រូវឲ្យស្មើភាពគ្នា ធ្វើការឲ្យត្រូវស្មើភាពគ្នា មិនជិះជាន់ពលកម្មអ្នកណា ប៉ុន្តែពាក្យទាំងនេះមាននៅតែក្នុងទ្រឹស្តីប៉ុណ្ណោះ តាមការពិតមានការបែងចែកដាច់ស្រឡះរវាងប្រជាជនមូលដ្ឋាន និងប្រជាជនជម្លៀសឬប្រជាជន១៧មេសា ។ ប្រជាជនមូលដ្ឋានមិនត្រឹមតែមានសិទ្ធិបញ្ជាឲ្យប្រជាជនជម្លៀសធ្វើការទាំងថ្ងៃទាំងយប់ប៉ុណ្ណោះទេ ថែមទាំងបានទទួលការហូបចុកគ្រប់គ្រាន់ទៀតផង បើទោះបីជាកម្រិតជីវភាពប្រជាជនជម្លៀសបានកំណត់ឲ្យហូបអង្ករមួយកំប៉ុងសម្រាប់គ្នា៤នាក់ឬ៥នាក់ក៏ដោយ ។

ចេញពីទីរួមខេត្តកំពង់ឆ្នាំង ទៅកាន់ខេត្តពោធិសាត់នៅចន្លោះ

ម្តុំផ្សារពន្លៃ ដែលក្នុងសម័យនោះឲ្យឈ្មោះថា "ស្រុក១០" មានសហករណ៍មួយចំនួនដូចជា សហករណ៍បន្ទាយដើមសំរោងធំ និងទេពប្រណមជាដើម ភាគច្រើននៅសល់តែស្ត្រីនៅតាមសហករណ៍ ចំណែកបុរសជាប្តីត្រូវបានដកយកទៅអស់ ហើយបាត់រហូតមិនដែលឃើញវិលត្រឡប់មកជួបប្រពន្ធកូនវិញទេ ។ សហករណ៍បន្ទាយដើមស្ថិតនៅខាងជើងថ្នល់ជាតិប្រហែលជា៤គីឡូម៉ែត្រ ។ សហករណ៍នោះមានទារកតូចៗចំនួន៦០នាក់ ហើយមានមេដោះជាអ្នកមូលដ្ឋាននៅមើលថែរក្សា ព្រោះម្តាយត្រូវចេញទៅធ្វើការតាំងពីព្រឹកព្រលឹមរហូតដល់ល្ងាចជារៀងរាល់ថ្ងៃ ។ មានថ្ងៃខ្លះពេលម្តាយត្រឡប់មកពីធ្វើការឃើញកូនដេកស្លាប់នៅក្នុងអង្រឹងដោយគ្មានការទទួលខុសត្រូវពីមេដោះអ្វីឡើយ ។ ក្នុងរយៈពេលតែមួយខែ ទារកទាំងអស់ត្រូវស្លាប់បាត់បង់ជីវិតគ្មានសល់ដោយគ្មានទឹកដោះនិងគ្មានទឹកបបរគ្រប់គ្រាន់ ។ ទណ្ឌកម្មផ្សេងទៀតដែលកើតមាននៅក្នុងសហករណ៍នោះដែរ គឺការបង្អត់អាហារចំពោះអ្នកដែលឈឺសុំសម្រាកនៅកន្លែង ។ ដោយក្តីស្រេកឃ្លានខ្លាំងពេកអ្នកជំងឺដែលមិនបានទទួលអាហារនោះបានទៅបន្ទំខ្លួនទទួលយកអាហារជាមួយនឹងគេ ហើយក៏ត្រូវបានវាយដួលសន្លប់នៅនឹងកន្លែង ដោយត្រូវបានចោទថា ឈឺសតិអារម្មណ៍ ឈឺពុត ជិះជាន់កម្លាំងពលកម្មគេ ។

ប្រជាជនដែលបានរស់រហូតដល់ឆ្នាំ១៩៧៨ ក៏មិនមានន័យថាមានចំណីអាហារគ្រប់គ្រាន់ ហើយរួចផុតពីការកាប់សម្លាប់នោះដែរ ព្រោះថាខ្មែរក្រហមនៅតែធ្វើការតាមដានគ្រប់សកម្មភាពជាប់ជានិច្ច ។ មកដល់ចុងឆ្នាំ១៩៧៨ មិនត្រឹមតែប្រជាជន ជម្លៀសទេ សូម្បីកម្មាភិបាលដែលធ្វើការជាមួយគ្នាក៏មិនមានទុកចិត្តគ្នាដែរ កម្មាភិបាលមួយចំនួនដែលត្រូវបានចោទថា ក្បត់អង្គការ អ្នកនោះក៏ត្រូវយកសម្លាប់ចោលដែរ ។ នៅម្តុំស្រុក១០ ដដែលនោះ ចុះពីផ្លូវជាតិប្រហែលជាពីរ-បីគីឡូទៅខាងត្បូង មានយុវជនមួយក្រុមប្រហែលជា៣០នាក់ ឯកសណ្ឋានជាកងទ័ព ភូមិភាគបូព៌ាបានធ្វើស្តុកស្តោតនៅទីនោះ ។ យុវជនទាំងនោះហាក់ដូចជាមានចិត្តមនុស្សធម៌ច្រើន បានចុះទៅជួបនិងសួរនាំប្រជាជនពីជីវភាពរស់នៅពីរបបស៊ីចុក ហើយដូចជាមានចិត្តអាណិតអាសូរជាខ្លាំងដល់ប្រជាជន ។ ប៉ុន្តែអ្នកទាំងនេះមិនបញ្ចេញសកម្មភាពអ្វីជាដុំកំភួនទេ ។ ដើមឆ្នាំ១៩៧៩ យុវជនទាំងនេះត្រូវកងទ័ពខ្មែរក្រហមនៅតំបន់នោះចោទថាជាអ្នកនាំបះបោរ ហើយត្រូវបានចាប់ខ្លួនយកទៅសម្លាប់ចោល ប៉ុន្តែអ្នកខ្លះក៏បានគេចខ្លួនរត់រួច ។ ក្រោយមកអង្គការបានប្រកាសឲ្យប្រជាជនទៅមើលខ្មោច១២នាក់ដើម្បីជាការព្រមានកុំឲ្យប្រជាជនទាំងអស់យកតម្រាប់តាម ។ សាកសពត្រូវបានវាយចោលនៅកណ្តាលវាលស្រែ ស្លាប់យ៉ាងអាណោចអាធ័ម ស្លាប់ទាំងឈឺចាប់បំផុត ស្លាប់ទាំងចំណងនៅជាប់ដៃនៅឡើយ ។ ទិដ្ឋភាពនេះបានធ្វើឲ្យប្រជាជនតក់ស្លុត ខ្លបខ្លាចនូវអំណាចផ្តាច់ការរបស់អង្គការ ប៉ុល ពត មហាអំណាចផ្តាច់ការ អង្គការអាចបង្កុលឲ្យអ្នកណាត្រូវរស់អ្នកណាត្រូវស្លាប់ ។

បើតាមការស្មាន អត្រាភាគរយអ្នកស្លាប់នៅខេត្តកំពង់ឆ្នាំងមានច្រើនជាងបើប្រៀបធៀបទៅនឹងភូមិភាគខាងជើងខេត្តកំពង់ស្ពឺ ប៉ុន្តែក៏គ្មានអ្នកណាម្នាក់អាចកំណត់ឲ្យបានច្បាស់លាស់ពីចំនួនប្រជាជនដែលបានស្លាប់ក្នុងរបបនោះដែរ គ្រាន់តែសន្និដ្ឋានថា ប្រហែលជាងពីរលាននាក់ ហើយការសន្និដ្ឋាននេះគឺអាចយកជាការពិតបាន ។ ឧទាហរណ៍គ្រួសារម្នាក់ឈ្មោះ នូ ជុន និងភរិយា ស្រុកកំណើតនៅភូមិកណ្តាល ឃុំវល្លិស ស្រុកសំរោង ខេត្តកំពង់ស្ពឺ មានកូន៤នាក់ កូនប្រសាប្រុសម្នាក់និងចៅបីនាក់ ត្រូវបានសម្លាប់ចោលនៅខេត្តកំពង់ឆ្នាំង ក្រោយពេលដែលឈ្លបឆែកឃើញរូបថតកូនប្រសាស្លៀកពាក់ជាឯកសណ្ឋានទាហាន ។ ចំណែកកូនទី៣ បានចេញទៅធ្វើការឆ្ងាយតាមកងចល័ត ឯកូនទី១ឈ្មោះ នូ ប៊ុនម៉ា ដឹងខ្លួនហើយក៏គេចខ្លួនរត់ទៅខេត្តកំពង់ស្ពឺវិញ ប៉ុន្តែក៏ត្រូវបានសម្លាប់ចោលនៅទីនោះ ។ សរុបទៅសមាជិកគ្រួសារនោះមានគ្នា១០នាក់ នៅសល់តែកូនទី៣ឈ្មោះ នូ ប៊ុនធី ដែលនៅរស់រានមានជីវិតរហូតដល់សព្វថ្ងៃ ។

ទោះបីជាប្រជាជនខ្មែរជំនាន់ក្រោយមិនបានឆ្លងកាត់ក្នុងដំណាក់កាលនោះ ក៏អាចសន្និដ្ឋានបានដែរថា អត្រាស្លាប់គឺពិតជាមានដល់កម្រិតនោះមែន ព្រោះស្លាកស្នាមដ៏ឈឺចុកចាប់ដិតជាប់នៅគុកទួលស្លែងដែលភស្តុតាងទាំងអស់នេះជាសាក្សីមិនអាចប្រកែកបាន ។

ប្រជាជនដែលរស់នៅតាមជនបទដាច់ស្រយាលមានការយល់ដឹងតិចតួច អ្នកខ្លះមិនទាំងចេះសរសេរនិងអានអក្សរផងអ្នកទាំងនោះត្រូវបានបំពាក់បំប៉នបង្រៀនឲ្យមានជំនឿជឿស្លុង

ទៅតាមទ្រឹស្តីរបស់អង្គការ ហើយអ្នកទាំងនោះត្រូវបានលើកបន្តុបឲ្យកាន់តំណែងជាប្រធានកងឬជាប្រធានក្រុម ។ ក៏ប៉ុន្តែគេក៏មិនអាចដាក់កំហុសទាំងស្រុងទៅលើអ្នកទាំងនោះដែរ ។ បើយើងយកមកវិភាគ អ្នកដែលបង្កើតទ្រឹស្តីគឺជាអ្នកដឹកនាំទាំងមូល ហើយអ្នកទាំងនោះគឺសុទ្ធតែមានកម្រិតវិជ្ជាខ្ពង់ខ្ពស់ដូចជា អៀង សារី, ខៀវ សំផន, នួន ជា ពិសេសគឺ ប៉ុល ពត ។ អ្នកទាំងនេះអាចយល់ដឹងថាអ្វីជាអ្វី ។ ជាង៣ឆ្នាំដែលអង្គការរៀបចំប្រទេស តើមានការជឿនលឿនដល់កម្រិតណា? ឬមួយក៏គេចង់បំបាត់ចោលឲ្យអស់មនុស្សមួយជំនាន់នោះតែម្តង?

សរុបទៅអ្វីដែលបន្សល់ទុកមកទល់សព្វថ្ងៃគឺ អ្នកពិការដៃ ពិការជើង ដើរសុំទានតាមថ្នល់តាមផ្សារដើម្បីរស់ទាំងលំបាកវេទនា ហើយជនរងគ្រោះដែលបានរស់រានមានជីវិតក៏ទទួលនូវការប៉ះទង្គិចផ្លូវអារម្មណ៍យ៉ាងធ្ងន់ធ្ងរនិងរស់នៅសោកសៅអស់មួយជីវិត ។

**នូ ប៊ុនធី**

# ដំណឹងសួររកបងប្អូន

នាងខ្ញុំឈ្មោះ យូ សៀមអេង អាយុ៥៨ឆ្នាំ (ឪពុកឈ្មោះ យូ ប៉េងស៊ា និងម្តាយឈ្មោះ វ៉ាន់ សារ៉ុន) និងស្វាមីឈ្មោះ ប៉ាន់ ជឿន អាយុ៦១ឆ្នាំ ដែលពីមុនរស់នៅភូមិខ្សា ឃុំដា ស្រុកក្រចេះ ខេត្តក្រចេះ ហើយបច្ចុប្បន្នរស់នៅភូមិជើងស្ពឹង ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប សូមសួររក បងស្រីឈ្មោះ យូ សៀមចេង និងស្វាមីឈ្មោះ ជឹង ហាំងវេង មុនឆ្នាំ១៩៧៥ គាត់ទាំងពីររស់នៅទីក្រុងភ្នំពេញហើយត្រូវអង្គការជម្លៀសទៅខេត្តបាត់ដំបង ក្នុងឆ្នាំ១៩៧៥ ក្រោយមកទើបឮដំណឹងថាប្តីគាត់ស្លាប់ នៅសល់តែកូននិងបងស្រីខ្ញុំប៉ុណ្ណោះ ។ នៅឆ្នាំ១៩៧៩ ឮដំណឹងថាគាត់នៅទឹកថ្លាទីក្រុងភ្នំពេញ តែក្រោយមកបាត់ដំណឹងសូន្យឈឹងតែម្តង ។ បើបងប្អូនញាតិមិត្តណាបានទទួលដំណឹងពីបងទាំងពីរ សូមមេត្តាផ្តល់ដំណឹងមកនាងខ្ញុំតាមអាសយដ្ឋានខាងលើ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# ដំណឹងសួររកកូនប្រុសឈ្មោះ ហ៊ី អុល

នាងខ្ញុំឈ្មោះ ពេជ យ៉ាន់ អាយុ៦៦ឆ្នាំ មានកូន៤នាក់ (ស្លាប់ម្នាក់) កាលពីមុនឆ្នាំ១៩៧៥និងបច្ចុប្បន្ន រស់នៅភូមិត្រពាំងឈូក ឃុំជ្រលង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ សូមសួររកកូនប្រុសឈ្មោះ ហ៊ី អុល ដែលបានបាត់ខ្លួនមុនថ្ងៃរំដោះ ១៧មេសា ឆ្នាំ១៩៧៥ ដោយសារទៅតាមទ័ពខ្មែរក្រហម ។ ហ៊ី អុល ក្នុងអាយុ១៦ឆ្នាំ ហើយបានទៅតាមទ័ពខ្មែរក្រហមនៅវត្តគុកក្នុង ឃុំជ្រលង ជាមួយមិត្តឡូន (បាត់ខ្លួន) ក្រោយមកមិនដែលឮដំណឹងអ្វីទាំងអស់ ។ បើបងប្អូនញាតិមិត្តណាបានទទួលដំណឹងពីបងទាំងពីរ សូមមេត្តាផ្តល់ដំណឹងមកនាងខ្ញុំតាមអាសយដ្ឋានខាងលើ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# ដំណឹងសួររកកូនប្រុសពីរនាក់

នាងខ្ញុំឈ្មោះ ស អ៊ួច អាយុ៧៣ឆ្នាំ មានកូន៩នាក់ សព្វថ្ងៃនៅរស់៥នាក់ មុននិងក្រោយឆ្នាំ១៩៧៩ រស់នៅភូមិត្រពាំងឈូក ឃុំជ្រលង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ សូមសួររកកូនប្រុសពីរនាក់ដែលមានឈ្មោះ ដួន ចេន និង ដួន សៀ បានបាត់ខ្លួនក្នុងរបបខ្មែរក្រហម (ឆ្នាំ១៩៧៥-១៩៧៩) ដោយសារគេចាប់យកទៅធ្វើជាកងទ័ព ។ ដួន ចេន បានចូលបដិវត្តន៍មុនឆ្នាំ១៩៧៥ ហើយធ្លាប់មកលេងផ្ទះម្តងបានជួបម្តាយ (បានតែមួយភ្លែត) ក្រោយមកបាត់ដំណឹងឈឹងមិនដឹងជានៅទីណា ។ ដួន សៀ ទៅធ្វើបដិវត្តន៍ក្រោយឆ្នាំ១៩៧៥ ហើយបាត់ខ្លួនតាំងពីពេលចេញទៅបដិវត្តមិនដែលឃើញត្រឡប់មកផ្ទះឡើយ ។ បើបងប្អូនញាតិមិត្តណាបានទទួលដំណឹងពីបងទាំងពីរ សូមមេត្តាផ្តល់ដំណឹងមកនាងខ្ញុំតាមអាសយដ្ឋានខាងលើ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកប្អូនប្រុសឈ្មោះ ជីន ឡុញ

ខ្ញុំបាទឈ្មោះ ជីន បូរាណ អាយុ៥៨ឆ្នាំ បច្ចុប្បន្នរស់នៅភូមិពងពស់ ឃុំរោងដំរី ស្រុកបាភ្នំ ខេត្តព្រៃវែង។ ខ្ញុំបាទសូមសួររកប្អូនប្រុសឈ្មោះ ជីន ឡុញ ដែលបានបែកគ្នាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ មុនឆ្នាំ១៩៧៥ ប្អូនបួសជាសង្ឃនៅវត្តពងពស់។ នៅឆ្នាំ១៩៧៥ ពួកខ្មែរក្រហមបានចាប់ផ្សឹកប្អូនឲ្យចូលបម្រើកងទ័ព។ នៅឆ្នាំ១៩៧៩ បងបានជួបប្អូនដោយចៃដន្យនៅទន្លេបាសាក់ ពេលនោះបងបានបបួលប្អូនមកផ្ទះវិញតែប្អូនមិនព្រមមក ចាប់តាំងពីពេលនោះមកក៏បាត់ដំណឹងប្អូនរហូត។ បើបងប្អូនញាតិមិត្តណាបានដឹងដំណឹងពី ជីន ឡុញ សូមមេត្តាផ្តល់ដំណឹងមកខ្ញុំបាទតាមអាសយដ្ឋានខាងលើ ឬតាមទូរស័ព្ទលេខ (៨៥៥) ១២ ៣៧២ ៥៤១ និង (៨៥៥) ៩២ ២៥៣ ៧៧០ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ។

# ដំណឹងសួររកកូនប្រុសឈ្មោះ ដួង ធុយ


ឈឿន អ៊ុយ

នាងខ្ញុំឈ្មោះ ឈឿន អ៊ុយ អាយុ៨៣ឆ្នាំ មានកូន៧នាក់ ពីមុនរស់នៅភូមិស្វាយចេក ឃុំតាត្រាវ ស្រុកពួក ខេត្តសៀមរាប បច្ចុប្បន្នរស់នៅស្វាយចេក ឃុំស្វាយចេក ស្រុកអង្គធំ ខេត្តសៀមរាប សូមសួររកកូនឈ្មោះ ដួង ធុយ ភេទប្រុស ដែលបាត់ខ្លួនកាលពីឆ្នាំ១៩៧៣ ដោយមូលហេតុចូលក្រុមសិល្បៈរបស់ខ្មែរក្រហម។ ធុយ ជាកូនទី៣ ហើយធ្លាប់រៀនដល់ថ្នាក់ទី១១ពីសង្គម។ ក្នុងឆ្នាំ១៩៧០ ធុយ ចូលធ្វើមិត្តខ្មែរក្រហមដើរយាមល្បាតក្នុងភូមិ។ បន្ទាប់មក អង្គការជ្រើសរើសក្រុមសិល្បៈ ធុយ ក៏ចូលរួមក្នុងក្រុមសិល្បៈនោះទៅ។ នៅឆ្នាំ១៩៧៣ ឪពុកម្តាយរបស់ ធុយ ត្រូវជម្លៀសទៅស្រុកស្វាយលើ រួចក៏បានដាច់ការទាក់ទងជាមួយ ធុយ តាំងពីពេលនោះរហូតមក។ បន្ទាប់ពីរំដោះឆ្នាំ១៩៧៩ឪពុកម្តាយរបស់ ធុយ បានចូលក្នុងស្រុកកំណើតវិញ និងឮដំណឹងតាមអ្នកភូមិ ថា ធុយ បានចូលក្នុងក្រុមសិល្បៈ និងមានតួនាទីជាប្រធានក្រុមសិល្បៈដើរសម្តែងសិល្បៈចល័តរួចក៏បាត់ដំណឹងឈឹង។ បើបងប្អូនញាតិមិត្តណាបានទទួលដឹងដំណឹងអំពី ដួង ធុយ សូមមេត្តាផ្តល់ដំណឹងមកនាងខ្ញុំតាមអាសយដ្ឋានខាងលើ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ។

# ដំណឹងសួររកបងស្រីឈ្មោះ ឈុន រ៉ន និងបងប្រុសឈ្មោះ ឈុន រៀន


ឈុន រ៉ុម

នាងខ្ញុំឈ្មោះ ឈុន រ៉ុម អាយុ៥៣ឆ្នាំ មានបងប្អូន៥នាក់ រស់នៅភូមិមមាញ ឃុំរលួស ស្រុកបាគង ខេត្តសៀមរាប (ឪពុកឈ្មោះ ឈុន ជម និងម្តាយឈ្មោះ យុន រឿន អ្នកទាំងពីរស្លាប់មុនរដ្ឋប្រហារដោយសារជំងឺ) សូមសួររកបងស្រីឈ្មោះ ឈុន រ៉ន ជា គ្រូបង្រៀន និងបងប្រុសឈ្មោះ ឈុន រៀន។

ឈុន រ៉ន មុនឆ្នាំ១៩៧៥រស់នៅភ្នំពេញ ក្រោយថ្ងៃរំដោះ១៧មេសាឆ្នាំ១៩៧៥ ក៏បាត់ខ្លួនរហូតមកទល់សព្វថ្ងៃ។ ឯ ឈុន រៀន ចូលបម្រើកងទ័ពនៅឆ្នាំ១៩៧២ ហើយបានផ្ញើសំបុត្រប្រាប់ក្រុមគ្រួសារថា ខ្លួនទៅយកកងពីកន្លែងហ៊ឹកហាត់។ តាំងពីពេលនោះមកក៏បាត់ដំណឹងរហូត។ បើបងប្អូនញាតិមិត្តណាបានទទួលដឹងដំណឹងពី ឈុន រ៉ន និង ឈុន រៀន សូមមេត្តាផ្តល់ដំណឹងមកនាងខ្ញុំតាមអាសយដ្ឋានខាងលើ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ។



# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃនេះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រារព្ធពិធីផ្ទេរប្រគល់កូនសោរជានិមិត្តរូបនៃមន្ទីរឃុំឃាំងរបស់សាលាក្តីខ្មែរក្រហមជូនទៅឯកឧត្តម គុយ ប៊ុនសន អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធនាគាររបស់ក្រសួងមហាផ្ទៃ ។ ពិធីនេះគឺជាដំណាក់កាលដ៏សំខាន់មួយក្នុងការរៀបចំឲ្យមានការកាត់ក្តីនាពេលខាងមុខនេះ ។ ពិធីផ្ទេរប្រគល់នេះបានប្រព្រឹត្តឡើងក្រោមអធិបតីភាពរបស់ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

យោងទៅតាមមាត្រាទី២៨ នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ និងមាត្រាទី៩ នៃកិច្ចព្រមព្រៀងបន្ថែមលើសុវត្ថិភាព និងការរៀបចំសន្តិសុខចុះហត្ថលេខាកាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៦ ការគ្រប់គ្រងលើអ្នកជាប់ឃុំរបស់សាលាក្តីខ្មែរក្រហម គឺជាភារកិច្ចទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា ។

យើងសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាលឥណ្ឌានិងជប៉ុន ដែលបានផ្តល់ជំនួយក្នុងការសាងសង់មន្ទីរឃុំឃាំងឲ្យមានកម្រិតស្តង់ដារអន្តរជាតិ ។ ការសាងសង់បានប្រព្រឹត្តធ្វើឡើងដោយមានការពិគ្រោះយោបល់ជាមួយនឹងគណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហមលើផ្នែកគំនិតនិងការរចនាអគារ ។ មន្ទីរឃុំឃាំងនេះមានលោក គិម ដួន ជាប្រធានដោយមានការគាំទ្រពីសំណាក់អនុប្រធានមួយរូប រួមទាំងអ្នកយាមមួយក្រុម ។ ការរៀបចំផ្សេងៗកំពុងដំណើរការដើម្បីធានាឲ្យមានសុវត្ថិភាព ការគាំទ្រផ្នែកសុខភាព និងអាហារសម្រាប់បុគ្គលណាដែលត្រូវឃុំខ្លួនតាមការបង្គាប់របស់ដីការឃុំខ្លួនបណ្តោះអាសន្នចេញដោយសហចៅក្រមស៊ើបអង្កេត ។

ពិធីប្រគល់មន្ទីរឃុំឃាំងនេះ គឺជាជំហានដ៏មានសារសំខាន់មួយក្នុងការត្រៀមខ្លួនសម្រាប់ដំណើរការរកយុត្តិធម៌ដែលនឹងកើតមានក្នុងពេលឆាប់ៗខាងមុខនេះ ។

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុីតដែន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨